# គោលការណ៍ណែនាំស្តីពីការតាមដានផ្នែកសេដ្ឋកិច្ចសង្គម
# សំរាប់អ្នកគ្រប់គ្រងតំបន់ឆ្នេរនៅអាស៊ីអាគ្នេយ៍
# SOCMON SEA

*(រូបភាព)*

ខែ មីនា ឆ្នាំ ២០០៣


Leah Bunce និង Bob Pomeroy

ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មការផ្តល់ប្រឹក្សា SocMon អាស៊ីអាគ្នេយ៍ៈ

Kuperan Viswanathan ( ប្រធាន)

Elmer Ferrer

Gregor Hodgson

Susan Siar

Becky Pestano-Smith

Johnnes Tulungen


*(រូបសញ្ញា)* *(រូបសញ្ញា)* *(រូបសញ្ញា)* *(រូបសញ្ញា)* *(រូបសញ្ញា)*

គោលការណ៍ណែនាំទាំងនេះ ត្រូវបានរៀបចំឡើងសំរាប់ភាគីដែលបានស្នើសុំប្រើប្រាស់ឯកសារនេះប៉ុណ្ណោះ។ ភាគីដែលទទួលឯកសារនេះ គឺជាភាគីតែមួយគត់ដែលទទួលខុសត្រូវចំពោះការអនុវត្តន៏ ឬប្រើប្រាស់ឯកសារនេះ ព្រមទាំងទិន្នន័យ ឬព័តិមានផ្សេងទៀតដែលមាននៅក្នុងនេះ ។ WCPA-Marine និង GCRMN/AIMS ពុំផ្តល់ការធានា ឬការអះអាងណាមួយថា ផ្នែកណាមួយ ឬ ផ្នែកទាំងមូលនៃឯកសារនេះ មានភាពត្រឹមត្រូវ ឬសមស្រប សំរាប់ប្រើប្រាស់ក្នុងគោលបំណង ឬសំរាប់អនុវត្តន៏ជាក់លាក់ណាមួយនោះទេ។ លើកលែងតែមានការកំណត់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចែងផ្ទុយពីនេះ មិនដូច្នោះទេ ទាំង WCPA-Marine ទាំង GCRMN/AIMS និង បុគ្គលិកផ្ទាល់របស់ពួកគេនឹងមិនទទួលខុសត្រូវ (មិនថាទាំងស្រុង ឬដោយផ្នែកនោះទេ) ចំពោះភាគីដែលបានស្នើសុំរបាយការណ៍ ឬបុគ្គលណាមួយដែលទាមទារតាមរយៈភាគីនោះ លើរាល់លទ្ធផលនៃការប្រើប្រាស់ ឬអនុវត្តន៏ឯកសារនេះឡើយ។

© គណៈកម្មាធិការពិភពលោកទទួលបន្ទុកតំបន់ការពារ និង វិទ្យាស្ថានសាគរវិទ្យារបស់អូស្ត្រាលី ឆ្នាំ ២០០៣

របាយការណ៏នេះអាចត្រូវបានអនុញ្ញាតឱ្យបោះពុម្ពបាន សំរាប់គោលបំណងសិក្សា ឬមិនមែនជាលក្ខណៈធ្វើអាជីវកម្ម ដោយពុំចាំបាច់មានការអនុញ្ញាតជាលាយលក្ខណ៏អក្សរជាមុនពីម្ចាស់កម្មសិទ្ធិដើមឡើយ ក្នុងករណីដែលមានការទទួលស្គាល់ទាំងស្រុងនូវប្រភពនោះ ។

ឯកសារ SocMon SEA និង សៀវភៅណែនាំស្តីពីសេដ្ឋកិច្ចសង្គម GCRMN (២000) អាចដោនឡូតពីវ៉ិបសាយសេដ្ឋកិច្ចសង្គម WCPA-Marine:
http://iucn.org/themes/wcpa/biome/marine/socioeconmanual.htm

និងវ៉ិបសាយវិទ្យាសាស្ត្រសាគរវិទ្យារបស់អូស្ត្រាលី :
http://www.aims.gov.au/pages/reflib/smcrm/mcrm-000.html

**សំរាប់ការស្នើសុំផ្តល់ឯកសារជាលាយលក្ខណ៏អក្សរ សូមទំនាក់ទំនងមកកាន់ :**

Kuperan Viswanathan
WorldFish Center
Jalan Batu Maung
11960 Bayan Lepas, Penang, ម៉ាឡេស៊ី
ប្រអប់សំបុត្រ 500 GPO, 10670 Penang, ម៉ាឡេស៊ី
អ៊ីម៉ែល : k.viswanathan@cgiar.org
វ៉ិបសាយ : www.worldfishcenter.org

Leah Bunce
International Program Officer/NOS
1315 East-West Hwy#5369
Silver Spring, MD 20910 សហរដ្ឋអាមេរិក
(301) 713-3078x222; ទូរសារ: fax-4263
Leah.Bunce@noaa.gov
www.noaa.gov

យើងខ្ញុំរង់ចាំទទួលនូវយោបល់ស្តីពី SocMon និងមតិត្រឡប់ស្តីពីរបៀបប្រើប្រាស់វាជានិច្ច។ សូមផ្ញើមកកាន់ Kuperan និង Leah ។

*រូបថតនៅក្របមុខតាមទិសដៅបញ្ច្រាសទ្រនិចនាឡិកាពីលើចុះក្រោម :*

បទសម្ភាសន៍ក្នុងភូមិ Cilicap, Java ប្រទេសឥណ្ឌូនេស៊ី - Leah Bunce

ភូមិ Pere, Manus, Papua New Guinea – Joshua Cinner

Airbanua, North Sulawesi – Joshua Cinner

បទសម្ភាសន៍ក្នុងភូមិ Cilicap, Java, ប្រទេសឥណ្ឌូនេស៊ី - Leah Bunce

ផែនទីអាស៊ីអាគ្នេយ៍

ពិធីបុណ្យនេសាទនៅកោះ Ahus, Papua New Guinea – Joshua Cinner

*រូបថតក្របក្រោយតាមទិសដៅបញ្ច្រាសទ្រនិចនាឡិកាពីលើចុះក្រោម :*

បទសម្ភាសន៍នៅក្នុងភូមិ Cilicap, Java, ប្រទេសឥណ្ឌូនេស៊ី - Leah Bunce

Kecamatan, Tejakula, Bali, ប្រទេសឥណ្ឌូនេស៊ី - Aiko Serrabno

Bangka'tbuhayWorkshop – Susana Siar

ភូមិ Tubuseria ខេត្តកណ្តាល, Papua New Guinea – Joshua Cinner

Rai Lei Beach, Krabi, ប្រទេសថៃ - Steve Morrison

S O C M O N   S E A

## តារាងមាតិកា


**អារម្ភកថា** **១**

**១. តើឯកសារនេះស្តីអំពីអ្វី ?** **៣**

១.១ ហេតុអ្វីត្រូវបង្កើត SocMon? ៣

១.២ តើ SocMon ជាអ្វី ? ៥

១.៣ តើ SocMon ដំណើរការដោយរបៀបណាទៅ? ៦

១.៤ តើ SocMon សំរាប់នរណា? ៧

១.៥ តើ SocMon មានដែនកំរិតត្រឹមណា? ៧

**២. ហេតុអ្វីខ្ញុំគួរធ្វើការងារនេះ?** **៨**

២.១ ការកំណត់ការគំរាមកំហែង បញ្ហា ដំណោះស្រាយ និងឱកាស ៨

២.២ ការកំណត់សារប្រយោជន៍ តំលៃ និងសារៈសំខាន់ផ្នែកវប្បធម៌នៃធនធាន និងការប្រើប្រាស់ធនធាន ៨

២.៣ ការវាយតំលៃផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃវិធានការគ្រប់គ្រង ៩

២.៤ ការវាយតំលៃរបៀបដែលស្ថាប័នគ្រប់គ្រងកំពុងធ្វើការ ( ប្រសិទ្ធភាពក្នុងការគ្រប់គ្រង) ៩

២.៥ ការទាក់ទាញការចូលរួមពីអ្នកពាក់ព័ន្ធ និងការបង្កើតកម្មវិធីអប់រំ និងលើកកំពស់ការយល់ដឹងដែលសមស្រប ១០

២.៦ ការផ្ទៀងផ្ទាត់ និងការចងក្រងជាឯកសារនូវការសន្ទតលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ កំលាំងសហគមន៍ និងទស្សនៈយល់ឃើញរបស់អ្នកពាក់ព័ន្ធ ១០

២.៧ ការបង្កើតព័ត៌មានគោលអំពីគ្រួសារ និងសហគមន៍ ១១

**៣. តើមានអ្វីពាក់ព័ន្ធខ្លះ?** **១២**

៣.១ តើនរណាគួរធ្វើការតាមដាន? ១២

៣.២ តើអ្វីទៅជាដំណើរការសំរាប់ការធ្វើការតាមដាន? ១៣

៣.៣ តើខ្ញុំប្រមូលទិន្នន័យតាមរបៀបណា? ១៤

៣.៤ តើត្រូវសម្ភាសនរណា? ១៧

៣.៥ តើការតាមដាននេះគួរមានរយៈពេលយូរប៉ុណ្ណា? ២៣

៣.៦ តើការតាមដាននេះនឹងប្រើប្រាស់ថវិកចំនួនប៉ុន្មាន? ២៣

៣.៧ តើគួរធ្វើការតាមដានញឹកញាប់ប៉ុណ្ណា? ២៤

៣.៨ តើគួរធ្វើការតាមដាននេះនៅទីកន្លែងណា? ២៤

៣.៩ តើអ្នកណាគួរទទួលបានលទ្ធផលនៃការតាមដាននេះ? ២៥

៣.១០ តើមានអ្វីផ្សេងទៀតដែលខ្ញុំគួរតែដឹងដែរឬទេ? ២៥

**៤. តើទិន្នន័យអ្វីដែលខ្ញុំត្រូវប្រមូល? ២៧**

៤.១ តើអ្វីទៅគឺជាសូចនាករ? ២៧

៤.២ តើសូចនាករមួយណាដែលខ្ញុំត្រូវប្រើ? ៤១

**៥. តើខ្ញុំត្រូវធ្វើអ្វីជាមួយនឹងទិន្នន័យទាំងនេះ? ៤៣**

៥.១ ការវិភាគ ៤៣

៥.២ ការផ្សព្វផ្សាយ ៤៤

**ឧបសម្ព័ន្ធ "ក" : សូចនាករ ៤៨**

**ឧបសម្ព័ន្ធ "ខ" : គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ ១២៦**

**ឧបសម្ព័ន្ធ "គ" : គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍តាមគ្រួសារ ១៣៣**

**ឧបសម្ព័ន្ធ "ឃ" : សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ ១៣៨**

**ឧបសម្ព័ន្ធ "ង" : សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ ១៤៥**

# អារម្ភកថា

*SocMon SEA* និងឯកសារភ្ជាប់ផ្សេងទៀត *សៀវភៅណែនាំស្តីពីសេដ្ឋកិច្ចសង្គម GCRMN សំរាប់ការគ្រប់គ្រងផ្កាថ្ម (សៀវភៅណែនាំ GCRMN)* ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងតំរូវការនូវការយល់ដឹងកាន់តែប្រសើរឡើងអំពីវិស័យមនុស្សក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរ និងសមុទ្រ។ *សៀវភៅណែនាំ GCRMN* ត្រូវបានចេញផ្សាយនៅឆ្នាំ ២០០០ នៅក្នុងសន្និសិទអន្តរជាតិស្តីពីផ្កាថ្ម នៅក្នុងបាលី។ *SocMon SEA*និង *SocMon Caribbean* ដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗនេះ ត្រូវបានរៀបចំឡើងដើម្បីបំពេញបន្ថែមលើ *សៀវភៅណែនាំ GCRMN* ដោយផ្តល់នូវកម្រងគោលការណ៍ណែនាំដែលបានរៀបចំកាន់តែមានរចនាសម្ព័ន្ធត្រូវត្រឹម និងមានភាពងាយយល់ជាង អាចកែសំរួលទៅតាមតំរូវការរបស់តំបន់។ ឯកសារទាំងពីរនេះយកល្អត្រូវប្រើប្រាស់រួមគ្នា — *SocMon* ស្តីពីសូនាករវាយជាអាទិភាពសំរាប់ការវាយតំលៃ សំណួរដែលត្រូវសាកសួរ និងតារាងសំរាប់វិភាគទិន្នន័យ ហើយ *សៀវភៅណែនាំGCRMN* គឺស្តីពីព័ត៌មានលំអិតអំពីរបៀបអនុវត្តវា។

*SocMon SEA* គឺជាសមិទ្ធិផលប្រសូតចេញពីកិច្ចប្រឹងប្រែងរួមគ្នាយ៉ាងរឹងមាំរបស់ក្រុមអ្នកវិទ្យាសាស្ត្រ សង្គម និងអ្នកគ្រប់គ្រងតំបន់ឆ្នេរ នៅក្នុងតំបន់។ ជាពិសេស គណៈកម្មការផ្តល់ប្រឹក្សាអាស៊ីអាគ្នេយ៍ SocMon ដែលមានតុល្យភាពរវាងអ្នកវិទ្យាសាស្ត្រសង្គម និងអ្នកគ្រប់គ្រងតំបន់ឆ្នេរ បានផ្តល់នូវទិសដៅគំរោង និងធនធានបច្ចេកទេសយ៉ាងសំខាន់។ គោលបំណង *SocMon* ទាក់ទិនទៅនឹងព័ត៌មានសេដ្ឋកិច្ចសង្គម សូចនាករ និងរចនាសម្ព័ន្ធទាំងមូលត្រូវបានបំផុសដោយគណៈកម្មការ ក្នុងសិក្ខាសាលាតូចមួយធ្វើឡើងនៅក្នុងខែ សីហា ឆ្នាំ ២០០២ នៅក្នុងទីក្រុង Iloilo ប្រទេសហ្វីលីពីន។ បន្ទាប់មក Leah Bunce (NOAA/WCPA-marine) និង Bob Pomeroy (សកលវិទ្យាល័យ Connecticut) បានរៀបចំគំនិតទាំងនេះទៅជាឯកសារនេះ។ គណៈកម្មការរួមមាន : Kuperan Viswanathan (ប្រធាន, WorldFish Center), Elmer Ferrer (សកលវិទ្យាល័យហ្វីលីពីន/មជ្ឈមណ្ឌលគ្រប់គ្រងធនធានតំបន់ឆ្នេរតាមសហគមន៍), Gregor Hodgson (ReefCheck), Becky Pestano-Smith (គំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរ, ហ្វីលីពីន), Johnnes Tulungen (Proyek Pesisir, ឥណ្ឌូនេស៊ី) និង Susan Siar (មជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យនេសាទអាស៊ី អាគ្នេយ៍/ផ្នែកជលវប្បកម្ម)។

សេចក្តីព្រាងនៃ *SocMon SEA* ត្រូវបានទទួលការរិះគន់ស្ថាបនាពីបណ្តាញអ្នកពិនិត្យជាច្រើន។ សូមថ្លែងអំណរគុណជាពិសេសចំពោះបុគ្គលតទៅនេះ សំរាប់មតិល្អៗរបស់ពួកគេ : Renato Agbayani – ប្រធានមជ្ឈមណ្ឌលប្រចាំតំបន់របស់អង្គការអប់រំអាស៊ីអាគ្នេយសំរាប់ការសិក្សា និងស្រាវជ្រាវថ្នាក់បរិញ្ញាប័ត្រផ្នែកកសិកម្ម, Didi Baticados – មជ្ឈមណ្ឌលអភិវឌ្ឍន៍វិស័យនេសាទអាស៊ីអាគ្នេយ៍/ផ្នែកជលវប្បកម្ម, Ratana Chuenpagdee វិទ្យាស្ថានសាគរវិទ្យា Virginia, Josh Cinner សង្គមអភិរក្សសត្វព្រៃ, Gregor Hodgson, Reff Check; Danny Israel, វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ហ្វីលីពីន, Rezal Kusumaatmadja ក្រុមប្រឹក្សាជលវប្បដ្ឋានសាគរ,

Kusairi Mohd Noh, Univeriti Putra Malaysia; Richard Pollnac សកលវិទ្យាល័យ Rhode Island; Sarah Preisler, Reef Check; Becky Smith, គំរោងគ្រប់គ្រងធនធានតំបន់ឆ្នេរ (ហ្វីលីពីន) នៃក្រសួងបរិស្ថាន និងធនធានធម្មជាតិ និងទីភ្នាក់ អភិវឌ្ឍន៍អន្តរជាតិរបស់អង្គការសហប្រជាជាតិ. Jan Steffen អង្គការ UNESCO; Vo Si Tuan, វិទ្យាស្ថានសាគរសាស្ត្រ, ប្រទេសវៀតណាម; Sheila Vergara, WorldFish Center; និង Tai Shzee Yew មហាវិទ្យាល័យសេដ្ឋកិច្ច និងគ្រប់គ្រង នៃសកលវិទ្យាល័យ Putra ប្រទេសម៉ាឡេស៊ី។ លើសពីនេះទៀត សូមអរគុណជាពន្លឹកដល់ Steve Morrison និង Elizabeth Ban នៃ NOAA ព្រមទាំង Michael James និង Sheri Beauregard នៃ DesignPond ដែលបានសំរបសំរួល និងធ្វើការកែសំរួល រៀបចំទំរង់ និង បោះពុម្ព។ មូលនិធិសំរាប់ *SocMon SEA* គឺទទួលបានពីផ្នែករដ្ឋបាលជាតិសហរដ្ឋអាមេរិកសំរាប់បរិយាកាស និង មហាសមុទ្រ និងការិយាល័យមហាសមុទ្រ និងបរិស្ថានអន្តរជាតិ និងកិច្ចការវិទ្យាសាស្ត្ររបស់ក្រសួងការបរទេសអាមេរិក។

*SocMon Southeast Asia* គឺជាកម្មវិធិប្រចាំតំបន់ដែលបន្តពង្រឹងការយល់ដឹងរបស់សហគមន៍ និងទំនាក់ទំនងរបស់ពួកគេទៅនឹងធនធានតំបន់ឆ្នេរ និងសមុទ្រ។

# ផ្នែកទី ១ : តើឯកសារនេះស្តីអំពីអ្វី ?

## ១.១ ហេតុអ្វីត្រូវបង្កើត SOCMON ?

អ្នកគ្រប់គ្រងធនធានឆ្នេរសមុទ្រយល់ឃើញថា ពួកគេមិនអាចគ្រប់គ្រងធនធានឆ្នេរបានដោយផ្តោតការយកចិត្តទុកដាក់តែលើជីវរូបតែមួយមុខនោះទៀតទេ។ ឥរិយាបថ ចំពោះធនធានឆ្នេរ និងការប្រើប្រាស់ធនធានឆ្នេររបស់សហគមន៍មានភាពសាំញ៉ាំច្រើនទៅលើលក្ខណៈជីវរូបនៃប្រព័ន្ធឆ្នេរសមុទ្រ។ ការគ្រប់គ្រប់ធនធានតំបន់ឆ្នេរក៏មានភាពសាំញ៉ាំច្រើនស្មើគ្នា សំរាប់លក្ខណៈសេដ្ឋកិច្ចសង្គមរបស់សហគមន៍ផងដែរ។ ព័ត៌មានស្តីពីសេដ្ឋកិច្ចសង្គមមានសារៈសំខាន់សំរាប់ការគ្រប់គ្រងឆ្នេរប្រកបដោយប្រសិទ្ធភាព។ ជាឧទាហរណ៍ :

SocMon *គឺជាមាគ៌ាដឹកនាំមួយឈុត សំរាប់បង្កើតកម្មវិធីតាមដានសេដ្ឋកិច្ចសង្គមនៅកន្លែងគ្រប់គ្រងឆ្នេរមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។*

- តំបន់ហាមនេសាទមួយត្រូវបានគេស្នើឱ្យបង្កើតឡើងនៅក្នុងផ្នែកមួយនៃតំបន់នេសាទដ៏ធំមួយ ដើម្បីការពារកន្លែងភ្ញាស់កូនត្រី និងជំរកសត្វដែលរងការគំរាមកំហែង។ សហគមន៍នេសាទធ្វើការតវ៉ាប្រឆាំងនឹងការដាក់តំបន់ហាមឃាត់នេះ ដោយភ័យខ្លាចដល់ការបាត់បង់មុខរបរទទួលទានរបស់ពួកគេ។ ព័ត៌មានដែលប្រមូលបានជាលក្ខណៈប្រព័ន្ធស្តីពីគំរូនេសាទ ចំនួនអ្នកនេសាទ និងទស្សនៈយល់ឃើញរបស់អ្នកនេសាទអាចជួយឱ្យអ្នកគ្រប់គ្រងកំណត់បានយ៉ាងជាក់ច្បាស់ថា តើនរណាខ្លះនឹងរងផលប៉ះពាល់ និងកំណត់បាននូវប្រភេទរបរទទួលទានផ្សេងទៀតដែល អាចទទួលយកបាន។
- អ្នករៀបចំគោលនយោបាយ និងសាធារណជនចង់ដឹងថា "តើតំបន់ការពារសមុទ្រនោះមានប្រសិទ្ធភាពដែរឬទេ?" ព័ត៌មានស្តីពីការផ្លាស់ប្តូរទស្សនៈយល់ឃើញរបស់ប្រជាជនអំពីការគោរព និងអនុវត្តតាមគោលការណ៍ និងបទបញ្ញត្តិអាចបង្ហាញអំពីភាពជោគជ័យ ឬការបរាជ័យនៃសកម្មភាពគ្រប់គ្រង ព្រមទាំងលទ្ធភាពអាចទទួលយកតំបន់ការពារសមុទ្រនោះ។
- កម្មវិធីអប់រំថ្មីដ៏ធំមួយត្រូវបានគេស្នើរៀបចំឡើងសំរាប់សហគមន៍ឆ្នេរ។ តាមរយៈការសិក្សាយល់ដឹងអំពីមធ្យោបាយផ្សព្វផ្សាយនៅក្នុងសហគមន៍ (ដូចជា ផ្ទាំងប៉ាណូ ទូរទស្សន៍ កាសែត) អក្ខរកម្ម និងកិរិតវប្បធម៌របស់ក្រុមអ្នកប្រើប្រាស់ផ្សេងៗ និងទស្សនៈយល់ឃើញរបស់ពួកគេអំពីការគំរាមកំហែងនានានោះ អ្នកគ្រប់គ្រងមានលទ្ធភាពអាចរៀបចំកម្មវិធីនេះដើម្បីប្រើប្រាស់នូវមធ្យោបាយផ្សព្វផ្សាយសមស្របបំផុត និងធានាថាសាររបស់ពួកគេស័ក្តិសមសំរាប់ទស្សនិកជនរបស់ពួកគេ។

ការយល់ដឹងអំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងវិធីដែលសហគមន៍មួយប្រើប្រាស់ធនធានឆ្នេរ និងលក្ខណៈសេដ្ឋកិច្ចសង្គមរបស់សហគមន៍នោះគឺពិតជាមានសារៈសំខាន់។ ព័ត៌មានស្តីពីសេដ្ឋកិច្ចសង្គមផ្តល់នូវការយល់ដឹងអំពីលក្ខណៈ និងស្ថានភាព

សង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយរបស់បុគ្គល គ្រួសារ ក្រុម អង្គការ និងសហគមន៍នីមួយៗ។ វាអាចជួយឱ្យអ្នកគ្រប់គ្រងឆ្លើយតបការកំណត់បាននូវបញ្ហាដែលអាចកើតមាន និងផ្តោតការយកចិត្តទុកដាក់សំខាន់លើអាទិភាពគ្រប់គ្រងទៅតាមលក្ខណៈ និងស្ថានភាពនោះ។

## ១.២ តើ SOCMON ជាអ្វី ?

*SocMon* គឺជាមាគ៌ាដឹកនាំមួយឈុត សំរាប់បង្កើតកម្មវិធីតាមដានសូចនាករសេដ្ឋកិច្ចសង្គមនៅកន្លែងគ្រប់គ្រងឆ្នេរមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ មាគ៌ាដឹកនាំនេះផ្តល់ជូននូវបញ្ជីអាទិភាពនៃសូចនាករសេដ្ឋកិច្ចសង្គមដែលមានសារប្រយោជន៍សំរាប់អ្នកគ្រប់គ្រងឆ្នេរ ព្រមទាំងសំណួរសំរាប់ការប្រមូលទិន្នន័យ និងតារាងសំរាប់ការវិភាគទិន្នន័យផងដែរ ។ គេរំពឹងថា មាគ៌ាដឹកនាំទាំង នេះនឹងត្រូវយកទៅសំរបសំរួលឱ្យស្របទៅតាមតំរូវការរបស់កន្លែងនីមួយៗ ។ *SocMon* គឺជាមាគ៌ាដឹកនាំដែលត្រូវប្រើប្រាស់រួមគ្នាជាមួយ *សៀវភៅណែនាំសេដ្ឋកិច្ចសង្គម GCRMN ស្តីពីការគ្រប់គ្រងថ្មប៉ប្រះទឹក (GCRMN Manual)* ។

*កម្មវិធីតាមដានសេដ្ឋកិច្ចសង្គមគឺជាវិធីមួយសំរាប់ធ្វើការកំណត់ ប្រមូល និងវិភាគទិន្នន័យសង្គម វប្បធម៌ សេដ្ឋកិច្ច និង នយោបាយរបស់ប្រជាជន ក្រុមសហគមន៍ និងអង្គការ ។*

*SocMon* ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បី :

- ផ្តល់នូវវិធីសាស្ត្រមួយសំរាប់ការប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមមូលដ្ឋានជាទៀងទាត់ ដែលមានសារប្រយោជន៍សំរាប់ការគ្រប់គ្រងតំបន់ឆ្នេរនៅកំរិតមូលដ្ឋាន ។
- ផ្តល់ជាមូលដ្ឋានមួយសំរាប់ប្រព័ន្ធថ្នាក់តំបន់មួយ ដែលទិន្នន័យថ្នាក់មូលដ្ឋានបានមកពីប្រព័ន្ធនេះ អាចយកទៅបញ្ចូលក្នុងបញ្ជីទិន្នន័យថ្នាក់ជាតិ តំបន់ និងអន្តរជាតិសំរាប់ធ្វើការប្រៀបធៀប ។

គោលបំណងនៃការបង្កើត *SocMon* ក៏ដើម្បីផ្តល់ឱ្យអ្នកគ្រប់គ្រង ដែលភាគច្រើននៃពួកគាត់មានប្រវត្តិសិក្សា និងបទពិសោធន៍ការងារផ្នែកជីវវិទ្យានូវទស្សនវិស័យអំពីអត្ថន័យនៃ "ការសិក្សាផ្នែកសេដ្ឋកិច្ចសង្គម" សារប្រយោជន៍នៃព័ត៌មានសេដ្ឋកិច្ចសង្គមចំពោះការគ្រប់គ្រងរបស់ពួកគេ និងអំពីប្រភេទទិន្នន័យសេដ្ឋកិច្ចសង្គមដែលមានសារប្រយោជន៍សំរាប់ការគ្រប់គ្រងនៅកំរិតមូលដ្ឋានរបស់ពួកគេ ។

បច្ចុប្បន្ននេះមានកម្មវិធីសេដ្ឋកិច្ចសង្គមជាច្រើនផ្សេងទៀតផងដែរនៅក្នុងតំបន់នេះ ដែលមានទំនោរធ្វើឡើងជាក់ស្តែងនៅនឹងមូលដ្ឋាន ។ អ្នកប្រើប្រាស់ *SocMon* នៅពេលនេះក៏ប្រហែលជាមានកម្មវិធីតាមដានសេដ្ឋកិច្ចសង្គមមួយសំរាប់ប្រើប្រាស់ផងដែរ ។ អស់រយៈកាលជាច្រើនទសវត្សរ៍មកហើយដែលអ្នកវិទ្យាសាស្ត្រសង្គមបាន និងកំពុងបន្តធ្វើការសិក្សាស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គមនៅពាសពេញតំបន់អាស៊ីអាគ្នេយ៍នេះ ។ *SocMon* មានបំណងបំពេញបន្ថែមកម្មវិធីទាំងនេះដោយផ្តល់ជូននូវមាគ៌ាដឹកនាំមួយឈុតដែលមានលក្ខណៈសាមញ្ញ និងត្រឹមត្រូវតាមបទដ្ឋានសំរាប់តំបន់នេះ ។

## ១.៣ តើ *SocMon* ដំណើរការដោយរបៀបណាទៅ?

ដូចដែលបានពន្យល់រួចទៅក្នុងឯកសារនេះ វាគឺជាកម្មវិធីតាមដានសេដ្ឋកិច្ចសង្គមមួយ ដែលមានដំណាក់កាលសំខាន់ៗ ចំនួនប្រាំមួយ : ១) ការរៀបចំទុកជាមុន រួមមាន ការកំណត់គោលបំណងនៃការតាមដានសេដ្ឋកិច្ចសង្គម ការជ្រើសរើសសូចនាករដែលពាក់ព័ន្ធ ការកំណត់នូវដំណើរការសំរាប់ធ្វើការតាមដានសេដ្ឋកិច្ចសង្គម ការកំណត់ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការកំណត់ក្រុមធ្វើការតាមដាន, ២) ការប្រមូលទិន្នន័យតាមរយៈប្រភពបន្ទាប់បន្សំ, ៣) ការប្រមូលទិន្នន័យ តាមរយៈអ្នកផ្តល់ព័ត៌មានសំខាន់ៗ, ៤) ការប្រមូលទិន្នន័យតាមរយៈការធ្វើបទសម្ភាសន៍តាមគ្រួសារ ៥) ការប្រមូលទិន្នន័យតាមរយៈការអង្កេត, និង ៦) ការវិភាគទិន្នន័យ និងការផ្សព្វផ្សាយ។ នេះគឺជាដំណើរការមួយដែលមានលក្ខណៈដដែលៗ ដូច្នេះលទ្ធផលនៃដំណាក់កាលទាំងនេះអាចនឹងប៉ះពាល់ដល់ការសំរេចចិត្តដំបូងៗ ហើយអាចនឹងតំរូវឱ្យមានការអនុវត្តន៏ជំហានកន្លងមកសាជាថ្មីម្តងហើយម្តងទៀតផងដែរ។ កត្តានេះតំរូវឱ្យមានភាពបត់បែន និងការសំរបសំរួល។

សូចនាករ SocMon (សូមមើល *ផ្នែកទី ៤* និង*ឧបសម្ព័ន្ធ ក*) ត្រូវបានផ្តល់ជូនដោយផ្អែកលើមធ្យោបាយនៃការប្រមូលទិន្នន័យដែលរួមមាន : ប្រភពបន្ទាប់បន្សំ អ្នកផ្តល់ព័ត៌មានសំខាន់ និងបទសម្ភាសន៍តាមគ្រួសារ។ សូចនាករទាំងនេះត្រូវបានបែងចែកតាមវិធីនេះ ដើម្បីឱ្យមានលក្ខណៈពាក់ព័ន្ធទៅនឹងមាគ៌ាដឹកនាំសំរាប់ការធ្វើសម្ភាសន៍ចំនួនពីរប្រភេទ ទីមួយ គឺប្រភពបន្ទាប់បន្សំ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងទីពីរ គឺការធ្វើសម្ភាសន៍តាមគ្រួសារ។ សូចនាករទាំងនេះក៏ត្រូវបានបែងចែកជាប្រភេទស្របទៅតាមសារៈសំខាន់របស់ពួកវាផងដែរ គឺថា តើពួកវាជាសូចនាករសំខាន់ជាចំបងដែលត្រូវប្រមូល ឬក៏ជាសូចនាករសំខាន់បន្ទាប់បន្សំដែលត្រូវប្រមូល (សូមមើល *ផ្នែកទី ៤.២.២*)។

វាមានសារៈសំខាន់ដែលត្រូវកត់សំគាល់ថា *SocMon* មិនមែនគឺជាមាគ៌ាដឹកនាំមួយឈុតដែលមានភាពតឹងតែងមិនអាចបត់បែនទៅតាមកាលៈទេសៈនោះទេ។ អ្នកប្រើប្រាស់ *SocMon* (ក្រុមតាមដានសេដ្ឋកិច្ចសង្គម) ត្រូវជ្រើសរើសយកសូចនាករ និងវិធីសាស្ត្រណាដែលសមស្របជាមួយតំរូវការតាមមូលដ្ឋានរបស់ខ្លួន ដូចដែលមានពណ៌នានៅក្នុង *ផ្នែកទី ៤.២*។



## ១.៤ តើ *SOCMON* សំរាប់នរណា?

អ្នកប្រើប្រាស់ *SocMon* ជាគោលដៅ គឺក្រុមអ្នកគ្រប់គ្រងឆ្នេរសមុទ្រ រួមមាន បុគ្គលិកគ្រប់គ្រងតំបន់ឆ្នេរ អាជ្ញាធរនៅក្នុងមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងប្រជាជននៅក្នុងមូលដ្ឋាន (ដូចជា អង្គការនៅតាមសហគមន៍ សមាគមនេសាទ) ។ អ្នកប្រើប្រាស់បន្ទាប់បន្សំផ្សេងទៀតរួមមានដូចជា ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការអន្តរជាតិ និង អង្គការនៅក្នុងតំបន់ ។

## ១.៥ តើ *SOCMON* មានដែនកំរិតត្រឹមណា ?

*SocMon* គឺជាមាគ៌ាដឹកនាំជាមូលដ្ឋានមួយឈុត ។ វាមិនគ្របដណ្តប់លើសូចនាករទាំងអស់ដែលអាចមានសំរាប់ការតាមដានសេដ្ឋកិច្ចសង្គម (ឧទាហរណ៍ វាមិនបានពិភាក្សាអំពីយ៉េនឌ័រជាក់លាក់នោះទេ) ។ វាត្រូវបានរៀបចំឡើងជាសូចនាករអាទិភាពមួយឈុត ដែលមានចំនួនតិចបំផុតសំរាប់ធ្វើការ ហើយវាត្រូវបានរចនាឡើងសំរាប់ការប្រើប្រាស់រួមគ្នាជាមួយសៀវភៅ *GCRMN Manual* ដែលជាសៀវភៅពណ៌នាលំអិតអំពីសូចនាករផ្សេងៗដែលអាចមានសំរាប់ធ្វើការវាយតំលៃផ្នែកសេដ្ឋកិច្ចសង្គម ។ ដូច្នេះ គេរំពឹងថា ក្រុមប្រើប្រាស់នឹងអានសៀវភៅ *GCRMN Manual* (ជាពិសេសគឺ *ឧបសម្ព័ន្ធ ក : កត្តាវាស់វែងផ្នែកសេដ្ឋកិច្ចសង្គម*) ប្រសិនបើក្រុមខ្លួនសំរេចចិត្តជ្រើសរើសយកសូចនាករដែលមិនមែនជាសូចនាករអាទិភាព នៅក្នុង *SocMon* ទេនោះ ។

*SocMon* ក៏មិនផ្តល់នូវព័ត៌មានលំអិតអំពីវិធីក្នុងការប្រមូលទិន្នន័យ (ដូចជា របៀបធ្វើសម្ភាសន៍) នោះដែរ ។ ព័ត៌មាននេះ ត្រូវបានផ្តល់ជូននៅក្នុងសៀវភៅ *GCRMN Manual* ដែលមានរួមបញ្ចូលនូវការពន្យល់យ៉ាងពិស្តារអំពីរបៀបក្នុងការប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គម ដូចជាការធ្វើបទសម្ភាសន៍ ការអង្កេត និងការប្រមូលទិន្នន័យបន្ទាប់បន្សំ (សូមអាន *ជំពូក ៣ : ការចុះប្រមូលទិន្នន័យ*) ។ ដូច្នេះ យើងសូមផ្តល់ជាអនុសាសន៍ថា អ្នកអានគួរតែប្រើប្រាស់ឯកសារទាំងពីរនេះគឺអាន *SocMon* ដើម្បីជ្រាបអំពីសូចនាករអាទិភាពដែលត្រូវធ្វើការវាយតំលៃសំណួរដែលត្រូវសួរ និងតារាងដែលត្រូវវិភាគទិន្នន័យ និងអាន សៀវភៅ *GCRMN Manual* ដើម្បីជ្រាបអំពីរបៀបធ្វើការងារទាំងនេះ ។

# ផ្នែកទី ២ : ហេតុអ្វីខ្ញុំគួរធ្វើការងារនេះ?

អ្នកគ្រប់គ្រងឆ្នេរអាចប្រើប្រាស់ព័ត៌មានសេដ្ឋកិច្ចសង្គម ដើម្បីបំរើដល់គោលបំណងមួយចំនួន។ ជាការសំខាន់ដែលអ្នកគ្រប់គ្រងឆ្នេរ និងក្រុមតាមដានសេដ្ឋកិច្ចសង្គមធ្វើការកំណត់នូវគោលបំណងពាក់ព័ន្ធសំរាប់ការតាមដានរបស់ពួកគេ ធ្វើដូច្នេះពួកគេអាចជ្រើសរើសបាននូវសូចនាករសមស្របសំរាប់ធ្វើការប្រមូលទិន្នន័យ។ *ផ្នែកទី ៤* ដែលមានបញ្ជាក់អំពីសូចនាករ និងដំណើរការនៃការជ្រើសរើសសូចនាករនោះក៏មានបញ្ចូលនូវតារាងមួយដែលបង្ហាញអំពីថា តើសូចនាករណាខ្លះដែលមានសារៈសំខាន់ត្រូវប្រមូលសំរាប់បំរើដល់គោលបំណងនីមួយៗ។

*គោលបំណងទាំងនេះគឺសំរាប់អនុវត្តនៅក្នុងតំបន់នេះ។ អ្នកគ្រប់គ្រងឆ្នេរ និងក្រុមតាមដានត្រូវសំរបគោលបំណងទាំងនេះឱ្យត្រូវនឹងតំរូវការនៅមូលដ្ឋានរបស់ពួកគេ។*

## ២.១ ការកំណត់ការគំរាមកំហែង បញ្ហា ដំណោះស្រាយ និងឱកាស



នៅពេលដែលត្រូវបានប្រមូលជាផ្នែកមួយនៃកម្មវិធីតាមដានជាបន្តបន្ទាប់ ដែលមិនមែនជាការវាយតំលៃម្តងជាការស្រេចនោះ ព័ត៌មានសេដ្ឋកិច្ចសង្គមអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់នូវនិន្នាការ និងការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច និងប្រជាសាស្ត្រតាមគ្រួសារ និងសហគមន៍ទាំងមូល ក៏ដូចជាសកម្មភាពតាមឆ្នេរសមុទ្រ ទស្សនៈយល់ឃើញរបស់ប្រជាជនអំពីបញ្ហាឆ្នេរ និងបញ្ហាសហគមន៍ផងដែរ។ និន្នាការ និងការផ្លាស់ប្តូរទាំងនេះ អាចយកមកប្រើប្រាស់ដើម្បីកំណត់នូវការគំរាមកំហែង បញ្ហា ដំណោះស្រាយ និងឱកាសសំរាប់ការគ្រប់គ្រងធនធានឆ្នេរសមុទ្រ។ ឧទាហរណ៍ ក្នុងករណីមានការកើនឡើងនៃប្រជាជនចំណូលស្រុកទៅក្នុងតំបន់នោះ អាចបង្ហាញអំពីការគំរាមកំហែងដែលអាចកើតមានពីការកើនឡើងនៃសកម្មភាពនេសាទ និងការអភិវឌ្ឍន៍ការប្រើប្រាស់ដីដូចជាការកាប់ព្រៃកោងកាងជាដើម។

## ២.២ ការកំណត់សារប្រយោជន៍ តំលៃ និងសារៈសំខាន់ផ្នែកវប្បធម៌នៃធនធាន និងការប្រើប្រាស់ធនធាន

ព័ត៌មានសេដ្ឋកិច្ចសង្គមអាចយកទៅប្រើប្រាស់ដើម្បីបង្ហាញអំពីសារប្រយោជន៍ និងតំលៃនៃធនធាន និងសេវាកម្មនៅតំបន់ឆ្នេរ ដូចជា ថ្មប៉ប្រះទឹក និងប្រពៃណីវប្បធម៌ទៅដល់សាធារណជនទូទៅ ក្រុមអ្នកពាក់ព័ន្ធ និងអ្នកធ្វើការសំរេចចិត្ត ដែលអាចជួយ

*"អ្នកពាក់ព័ន្ធ" សំដៅទៅលើអ្នកដែលប្រើប្រាស់ធនធានឆ្នេរដោយផ្ទាល់ ព្រមទាំងអ្នកដែលធ្វើសកម្មភាពប៉ះពាល់ដល់ធនធានឆ្នេរសមុទ្រ។*

ប្រមូលបាននូវការគាំទ្រកាន់តែធំចំពោះកម្មវិធីគ្រប់គ្រងធនធានឆ្នេរសមុទ្រ។ ជាឧទាហរណ៍ ការយល់ដឹងអំពីតំលៃនៃថ្មប៉ប្រះទឹកអាចយកទៅប្រើប្រាស់ដើម្បីធ្វើការវាយតំលៃនូវអត្ថប្រយោជន៍ និងថ្លៃដើមនៃគំរោងអភិវឌ្ឍន៍ គ្រប់គ្រង និងអភិរក្សតាមរបៀបផ្សេងវិញ (ឧទាហរណ៍ ការសំរេចចិត្តអនុញ្ញាតឱ្យមានការមុជទឹកកំសាន្តបាតសមុទ្រ នៅក្នុងតំបន់មួយអាចធ្វើឡើងដោយផ្អែកទៅលើការរំពឹងទុកអំពីភាពអាចបង្កើតការងារ និងចំណូលជូនដល់សហគមន៍ ពីសកម្មភាពទេសចរណ៍ជាដើម)។

## ២.៣ ការវាយតំលៃផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃវិធានការគ្រប់គ្រង

ព័ត៌មានសេដ្ឋកិច្ចសង្គម អាចយកទៅប្រើប្រាស់ដើម្បីកំណត់នូវផលប៉ះពាល់នៃការសំរេចចិត្តផ្នែកគ្រប់គ្រងទៅលើអ្នកពាក់ព័ន្ធ ដែលអាចជួយលើកកំពស់ដល់ការសំរេចចិត្តលើគោលនយោបាយកាត់បន្ថយឱ្យបានជាអប្បបរិមានៃផលប៉ះពាល់អវិជ្ជមាន និងបង្កើនឱ្យបានជាអតិបរិមានៃផលប៉ះពាល់វិជ្ជមានទៅលើអ្នកពាក់ព័ន្ធ។ ជាឧទាហរណ៍ គោលនយោបាយហាមប្រាមមិនឱ្យប្រើប្រាស់ស្ពឺនេសាទមួយប្រភេទណាមួយអាចប៉ះពាល់ដល់រចនាសម្ព័ន្ធមុខរបរនៅក្នុងសហគមន៍ និងតំលៃត្រីនៅក្នុងទីផ្សារ។ តាមរយៈការចងក្រងជាឯកសារនូវការផ្លាស់ប្តូររចនាសម្ព័ន្ធមុខរបរ និងតំលៃទីផ្សារនៅមុន និងនៅក្រោយពេលដែលគំរោងត្រូវបានអនុវត្តនោះ អ្នកគ្រប់គ្រងអាចកំណត់បានកាន់តែប្រសើរនូវឥទ្ធិពលនៃគោលនយោបាយប្រភេទនេះ។ ស្រដៀងគ្នានេះដែរ អ្នកគ្រប់គ្រងក៏អាចប្រើប្រាស់ព័ត៌មានសេដ្ឋកិច្ចសង្គមដើម្បីធ្វើការព្យាករណ៍អំពីឥទ្ធិពលនៃគំរោងផ្សេងៗទៀតទៅលើសហគមន៍ផងដែរ។ ជាឧទាហរណ៍ អ្នកគ្រប់គ្រងអាចព្យាករណ៍បានពីចំនួនអ្នកនេសាទដែលត្រូវជំលៀសខ្លួនដោយសារតែគំរោងហាមនេសាទមួយនៅពេលអនាគត ប្រសិនបើអ្នកគ្រប់គ្រងបានដឹងអំពីចំនួនប្រជាជនដែលនេសាទនៅតាមតំបន់នីមួយៗ។

## ២.៤ ការវាយតំលៃរបៀបដែលស្ថាប័នគ្រប់គ្រងកំពុងធ្វើការ (ប្រសិទ្ធភាពនៃការគ្រប់គ្រង)

ព័ត៌មានសេដ្ឋកិច្ចសង្គមអាចយកទៅប្រើប្រាស់ ដើម្បីវាស់ស្ទង់នូវប្រសិទ្ធភាពរបស់កម្មវិធីគ្រប់គ្រងធនធានឆ្នេរសមុទ្រក្នុងការសំរេចបាននូវគោលដៅ និងវត្ថុបំណងរបស់ខ្លួន។ ជាឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងធនធានឆ្នេរសមុទ្រមានគោលដៅមួយគឺធ្វើការលើកកំពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងមូលដ្ឋានទៅក្នុងដំណើរការគ្រប់គ្រង នោះដើម្បីអាចវាយតំលៃបានថាស្ថាប័នគ្រប់គ្រងនោះធ្វើការមានប្រសិទ្ធភាព គប្បីគួរមានការលើកកំពស់ការយល់ដឹងរបស់ប្រជាជនអំពីការចូលរួមនៅក្នុងការធ្វើសេចក្តីសំរេចចិត្តអំពីការគ្រប់គ្រងធនធានតំបន់ឆ្នេរ។

ការតាមដានសេដ្ឋកិច្ចសង្គមអាចអនុញ្ញាតឱ្យមានការលើកកំពស់ដល់ការគ្រប់គ្រងធនធានឆ្នេរសមុទ្រ តាមរយៈការរៀនសូត្រ និងការសំរបសំរួល និងការកំណត់នូវបញ្ហាជាក់លាក់ដែលជះឥទ្ធិពលទៅលើភាពជោគជ័យនៃកម្មវិធីគ្រប់គ្រងធន

ធានឆ្នេរក្នុងការសំរេចនូវគោលដៅ និងកម្មវត្ថុរបស់កម្មវិធីនេះ។ ជាឧទាហរណ៍ ការផ្លាស់ប្តូរនៃទស្សនៈយល់ឃើញរបស់ប្រជាជនអំពីការគោរព និងការអនុវត្តន៏តាមច្បាប់ និងបទបញ្ញត្តិនានា អាចបង្ហាញបានពីភាពជោគជ័យ ឬភាពបរាជ័យនៃសកម្មភាពគ្រប់គ្រង និងតំរូវការដែលអាចទាមទារឱ្យមានការផ្លាស់ប្តូរនៃសកម្មភាពអនុវត្តន៏ផងដែរ។

## ២.៥ ការទាក់ទាញការចូលរួមពីអ្នកពាក់ព័ន្ធ និងការបង្កើតកម្មវិធីអប់រំ និងលើកកំពស់ការយល់ដឹងដែលសមស្រប

ព័តិមានសេដ្ឋកិច្ចសង្គមអាចយកទៅប្រើប្រាស់ដើម្បីណែនាំអំពីការបញ្ចូលនូវការចូលរួម កង្វល់ និងចំណាប់អារម្មណ៏របស់ក្រុមអ្នកពាក់ព័ន្ធទៅក្នុងដំណើរការនៃការគ្រប់គ្រង។ គេក៏អាចយកវាទៅប្រើប្រាស់សំរាប់រៀបចំផែនការបង្កើត និងដឹកនាំ កម្មវិធីអប់រំ និងលើកកំពស់ការយល់ដឹង សំរាប់ការគ្រប់គ្រងធនធានឆ្នេរសមុទ្រ។ ជាឧទាហរណ៍ អត្តសញ្ញាណរបស់សហគមន៏ និងអង្គការអ្នកពាក់ព័ន្ធនៅក្នុងតំបន់នេះអាចជួយអ្នកគ្រប់គ្រងឆ្នេរសមុទ្រធ្វើការធានាបានថា អ្នកពាក់ព័ន្ធសំខាន់ៗ មានឱកាសចូលរួមនៅក្នុងដំណើរការនៃការគ្រប់គ្រងធនធានឆ្នេរសមុទ្រ។

## ២.៦ ការផ្ទៀងផ្ទាត់ និងការចងក្រងជាឯកសារនូវការសន្មតលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ កំលាំងសហគមន៏ និងទស្សនៈយល់ឃើញរបស់អ្នកពាក់ព័ន្ធ

ការប្រមូល និងការវាយតំលៃទិន្នន័យសេដ្ឋកិច្ចសង្គមមានសារៈសំខាន់សំរាប់ការផ្ទៀងផ្ទាត់ និងចងក្រងជាឯកសារជាក់លាក់នូវលក្ខខណ្ឌរបស់សហគមន៏។ រាល់កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ ជាញឹកញាប់មានទស្សនៈយល់ឃើញជាទូទៅអំពីលក្ខខណ្ឌនៅក្នុងមូលដ្ឋាន។ ជាឧទាហរណ៍ វាអាចមានការយល់ស្របជាទស្សនៈទូទៅថា លក្ខខណ្ឌនៃព្រៃកោងកាងកំពុងធ្លាក់ចុះ។ អ្នកគ្រប់គ្រងត្រូវការទិន្នន័យជាក់លាក់ដើម្បីបញ្ជាក់ថាពិត និងចងក្រងនូវទស្សនៈនេះជាឯកាសារ។ ប្រសិនបើគ្មានភស្តុតាង ជាក់ស្តែងទេនោះ ការពោលដូចនេះគ្រាន់តែជាទ្រឹស្តីមួយប៉ុណ្ណោះ។ ការផ្ទៀងផ្ទាត់ និង ការចងក្រងជាឯកសារនូវទស្សនៈយល់ឃើញរបស់ប្រជាជនមានសារៈសំខាន់ស្មើគ្នាទៅនឹងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមផងដែរ ដោយហេតុថាពួកវាងាយស្រួលនឹងលំអៀងដោយសារកង្វល់ និងតំលៃរបស់ប្រជាជន។ តាមរយៈការធ្វើការសិក្សាជាលក្ខណៈប្រព័ន្ធដែលមិនមានភាពលំអៀងមួយនោះ អ្នកគ្រប់គ្រងអាចកំណត់បាននូវលក្ខខណ្ឌសេដ្ឋកិច្ចសង្គមក្នុងមូលដ្ឋាន ដែលមានលក្ខណៈពិតប្រាកដ ដូចជា ការប្រើប្រាស់ធនធាន កំលាំងសហគមន៏ និងទស្សនៈយល់ឃើញរបស់អ្នកពាក់ព័ន្ធ។

## ២.៧ ការបង្កើតព័ត៌មានគោលអំពីគ្រួសារ និងសហគមន៍

ព័ត៌មានសេដ្ឋកិច្ចសង្គមដែលប្រមូលបាននៅពេលចាប់ផ្តើមកម្មវិធីគ្រប់គ្រងធនធានឆ្នេរសមុទ្រ អាចជួយអ្នកគ្រប់គ្រងឱ្យយល់អំពីសហគមន៍ និងគ្រួសារ និងបង្កើតលក្ខណៈគោលសំរាប់ធ្វើការប្រៀបធៀបនាពេលអនាគត។ ព័ត៌មានគោលនេះមានសារប្រយោជន៍យ៉ាងពិសេសសំរាប់ការគ្រប់គ្រងបែបសំរបសំរួល។ ខណៈពេលដែលគោលដៅ និងសកម្មភាពរបស់កម្មវិធីមានការផ្លាស់ប្តូរនោះ អ្នកគ្រប់គ្រងអាចធ្វើការប្រៀបធៀបរវាងលក្ខខណ្ឌពេលបច្ចុប្បន្នជាមួយនឹងលក្ខខណ្ឌគោលនោះ ដើម្បីធ្វើការកំណត់អំពីមូលហេតុនៃការផ្លាស់ប្តូរ ក៏ដូចជាឥទ្ធិពលនៃការផ្លាស់ប្តូរ។ ជាឧទាហរណ៍ ប្រសិនបើ "គាំទ្រប្រពៃណីប្រជាជនក្នុងមូលដ្ឋាន" មិនមែនជាគោលដៅមួយក្នុងចំណោមគោលដៅដំបូងនៃកម្មវិធីគ្រប់គ្រងឆ្នេរទេនោះ ដូច្នេះលក្ខណៈប្រពៃណីរបស់ប្រជាជនក្នុងមូលដ្ឋានអាចមិនត្រូវបានតាមដានទេនាពេលកន្លងមក។ ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងមានព័ត៌មានគោលអំពីប្រពៃណីប្រជាជនក្នុងមូលដ្ឋាននោះ អ្នកគ្រប់គ្រងអាចយកព័តមានគោលនេះទៅធ្វើការវាយតំលៃថាតើលក្ខខណ្ឌទាំងនោះបានផ្លាស់ប្តូរយ៉ាងណានាពេលកន្លងមកនោះ។

# ផ្នែកទី ៣ ៖ តើមានអ្វីពាក់ព័ន្ធខ្លះ?

## ៣.១ តើនរណាគួរធ្វើការតាមដាន?

ការតាមដានសេដ្ឋកិច្ចសង្គមអាចធ្វើឡើងដោយបុគ្គលម្នាក់ ប៉ុន្តែដើម្បីភាពឥតខ្ចោះ ការតាមដានសេដ្ឋកិច្ចសង្គមនឹងត្រូវធ្វើឡើងដោយក្រុមតាមដានមួយដែលដឹកនាំដោយបុគ្គលម្នាក់មកពីបុគ្គលិកគ្រប់គ្រងឆ្នេរ (ដូចជា អ្នកសំរបសំរួលការតាមដានមកពីអាជ្ញាធរតំបន់ការពារសមុទ្រ មន្ត្រីអប់រំមកពីអង្គការបរិស្ថាន) ដែលមានប្រវត្តិសិក្សា ឬបទពិសោធន៍ផ្នែកវិទ្យាសាស្ត្រសង្គម (ដូចជា ជំនាញសង្គមវិទ្យា នរវិទ្យា សេដ្ឋកិច្ច វិទ្យាសាស្ត្រនយោបាយ ចិត្តសាស្ត្រ ឬភូមិសាស្ត្រ)។ ការចូលរួមពាក់ព័ន្ធរបស់ បុគ្គលិកជាសមាជិកមួយរូបនៅក្នុងការតាមដានសេដ្ឋកិច្ចសង្គមមានសារៈសំខាន់សំរាប់ការបង្កើតបាននូវចិរភាពយូរអង្វែង និងធានាបានថា បុគ្គលិកគ្រប់គ្រងឆ្នេរសមុទ្ររូបនោះបានប្រើប្រាស់ទិន្នន័យនេះដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងឆ្នេរ។

ប្រធានក្រុមជាអ្នកទទួលខុសត្រូវលើការរៀបចំផែនការ និងការតាមដាន ការប្រមូល ការវិភាគ និងការធ្វើបទបង្ហាញអំពីទិន្នន័យ និងធានាថា កម្មវិធីនឹងបន្តទៅមុខបានរយៈពេលយូរអង្វែង។ សមាជិកក្រុមតាមដានដទៃទៀតមានភារកិច្ចជួយក្នុងការប្រមូលទិន្នន័យ ជាពិសេសការធ្វើបទសម្ភាសន៍ ការវិភាគ ការសរសេររបាយការណ៍ និងការធ្វើបទបង្ហាញ។

ជាការល្អ សមាជិកក្រុមនឹងត្រូវមានប្រវត្តិសិក្សា ឬបទពិសោធន៍ខាងជំនាញណាមួយក្នុងចំណោមជំនាញវិទ្យាសាស្ត្រសង្គម។ វាក៏ជាការល្អដែរ ប្រសិនបើសមាជិកក្រុមបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍ខាងធ្វើបទសម្ភាសន៍នៅក្នុងតំបន់នោះ។ ទោះបីជាពួកគេមានប្រវត្តិសិក្សា ឬបទពិសោធន៍ខាងជំនាញវិទ្យាសាស្ត្រសង្គមដែរឬយ៉ាងណានោះ ការសំខាន់ គឺថាសមាជិកក្រុមមានជំនាញទំនាក់ទំនងល្អ មានទឹកចិត្តធ្វើការ និងចេះវិភាគ ព្រមទាំងមានចំណាប់អារម្មណ៍ជាមួយនឹងគំរោងនេះ។ ដោយសារតែបុគ្គលិកកម្មវិធីគ្រប់គ្រងឆ្នេរសមុទ្រភាគច្រើនមានសញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រធម្មជាតិនោះ *SocMon* ត្រូវបានតាក់តែងឡើងដោយសន្មតជាមុនថា សមាជិកក្រុម មានចំណេះដឹងផ្នែកសេដ្ឋកិច្ចសង្គមនៅមានកំរិត ប៉ុន្តែយ៉ាងហោចណាស់ក៏មានកំរិតវប្បធម៌បញ្ចប់ថ្នាក់ទុតិយភូមិផងដែរ។

ប្រសិនបើប្រធានក្រុម និង/ឬសមាជិកក្រុមមានឯកទេសផ្នែកសេដ្ឋកិច្ចសង្គមមានកំរិតនោះ វាពិតជាសំខាន់ថែមទៀតដែលពួកគេត្រូវអានសៀវភៅ *GCRMN Manual* ដែលមានរៀបរាប់ពិស្តារអំពីរបៀបធ្វើការវាយតំលៃផ្នែកសេដ្ឋកិច្ចសង្គមនោះ។ សៀវភៅ *GCRMN Manual ជំពូកទី ១ ៖ សកម្មភាពត្រៀម កំណត់ក្រុមវាយតំលៃ* ក៏ផ្តល់នូវគន្លឹះសំខាន់ៗអំពីការបង្កើតក្រុមនេះផងដែរ។

ក្នុងករណីបើគ្មានអ្នកវិទ្យាសាស្ត្រសង្គមដែលទទួលបានការបណ្តុះបណ្តាលអំពីក្រុមទេនោះ គេក៏នៅតែអាចធ្វើការតាមដានសេដ្ឋកិច្ចសង្គមបានផងដែរ ។ មានធនធានជាច្រើន រាប់ទាំងសៀវភៅ *GCRMN Manual* ផង ដែលអាចប្រើប្រាស់សំរាប់ធ្វើការអភិវឌ្ឍន៍ជំនាញ (សូមអានសៀវភៅ *GCRMN Manual ចំណុចឯកសារយោង* សំរាប់ជាប្រភពបន្ថែម) ។ គេអាចពិគ្រោះយោបល់ជាមួយអ្នកជំនាញការមកពីស្ថាប័នសិក្សា ឬស្រាវជ្រាវដើម្បីស្នើសុំការណែនាំ។ ដូចបានបញ្ជាក់ខាងលើរួចមកហើយថា ការលើកទឹកចិត្តក្នុងការងារ និងចំណាប់អារម្មណ៍គឺជាកត្តាដែល សំខាន់បំផុត ។

## ៣.២ តើអ្វីទៅជាដំណើរការសំរាប់ការធ្វើការតាមដាន?

ដូចបានបញ្ជាក់នៅក្នុង *ផ្នែកទី ១.៣* រួចមកហើយថា ជាទូទៅមានជំហានចំនួនប្រាំមួយសំរាប់ធ្វើការតាមដានសេដ្ឋកិច្ចសង្គមដែលរួមមាន :

១. ការរៀបចំទុកជាមុន រួមមាន ការកំណត់គោលបំណងនៃការតាមដានសេដ្ឋកិច្ចសង្គម ការជ្រើសរើសសូចនាករដែលពាក់ព័ន្ធ ការកំណត់នូវដំណើរការសំរាប់ធ្វើការតាមដានសេដ្ឋកិច្ចសង្គម ការកំណត់ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងកំណត់ក្រុមធ្វើការតាមដាន (សូមអានសៀវភៅ *GCRMN Manual ជំពូកទី ១ : សកម្មភាពត្រៀម* និង *ជំពូកទី ២ : ការអង្កេតតាមដាន និងការរៀបចំផែនការ*)

២. ការប្រមូលទិន្នន័យតាមរយៈប្រភពបន្ទាប់បន្សំ

៣. ការប្រមូលទិន្នន័យតាមរយៈអ្នកផ្តល់ព័ត៌មានសំខាន់ៗ

៤. ការប្រមូលទិន្នន័យតាមរយៈបទសម្ភាសន៍តាមគ្រួសារ

៥. ការប្រមូលទិន្នន័យតាមរយៈការអង្កេត

៦. ការវិភាគទិន្នន័យ និងការផ្សព្វផ្សាយ ។



នេះគឺជាដំណើរការមួយដែលមានលក្ខណៈដដែល១ដែលចាំបាច់ត្រូវធ្វើឡើងម្តងហើយម្តងទៀត ដើម្បីការកែសំរួល និង បូកបន្ថែមនូវទិន្នន័យ និងព័ត៌មានថ្មី១។ វាក៏ជាដំណើរការមួយដែលទាមទារឱ្យមានភាពបត់បែនច្រើន ព្រោះថា ជំហាន ដែលពាក់ព័ន្ធនៅក្នុងការតាមដានសេដ្ឋកិច្ចសង្គមជាក់ស្តែង ជានិច្ចកាលមិនអនុវត្តទៅតាមដំណើរការនេះដោយផ្ទាល់ នោះទេ ហើយជាញឹកញាប់វាទាមទារឱ្យមានការអនុវត្តន៍ម្តងហើយម្តងទៀតសាជាថ្មី។ ព័ត៌មានថ្មីអាចបង្កើតឡើងនូវ លក្ខខណ្ឌតំរូវថ្មី១ផងដែរ ដូច្នេះក្រុមតាមដានគប្បីធ្វើការពិនិត្យមើលលើការរីកចំរើន ហើយធ្វើការផ្លាស់ប្តូរផែនការ ឱ្យស្របទៅតាមលក្ខខណ្ឌថ្មី១ទាំងនោះ។

## ៣.៣ តើខ្ញុំត្រូវប្រមូលទិន្នន័យដោយរបៀបណា?

សូចនាករដែលផ្តល់ជូននៅក្នុង *SocMon* នេះ ត្រូវបានបែងចែកទៅជាវិធីប្រមូលទិន្នន័យសំខាន់១ចំនួនបួនដូចតទៅ :

១. ប្រភពបន្ទាប់បន្សំ
២. បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់១
៣. បទសម្ភាសន៍តាមគ្រួសារ
៤. ការអង្កេត

ជាទូទៅ គេគួរប្រមូលទិន្នន័យពីប្រភពបន្ទាប់បន្សំជាមុនសិន ហើយទើបឈានទៅធ្វើការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់១។ បន្ទាប់មក គេគួរធ្វើបទសម្ភាសន៍តាមគ្រួសារ ដើម្បីប្រមូលយកទិន្នន័យកាន់តែជាក់លាក់អំពីបុគ្គល ឬគ្រួសារនៅក្នុងសហគមន៍។ ការអង្កេតគួរធ្វើជាប្រចាំ ខណៈពេលដែលស្ថិតនៅក្នុងសហគមន៍។ វិធីទាំងនេះមានបង្ហាញ យ៉ាងពិស្តារនៅក្នុងសៀវភៅ GCRMN Manual *ជំពូកទី ៣ : ការចុះប្រមូលទិន្នន័យ*។

*ក្រុមតាមដានគួរតែអនុវត្តស្របទៅតាមគោលការណ៍ណែនាំនៅក្នុងអំឡុងពេលធ្វើការប្រមូលទិន្នន័យ :*

- *គោរពអ្នកពាក់ព័ន្ធ និងសហគមន៍ ដូចជា ពេលវេលាធ្វើការទំនាមទំលាប់ក្នុងមូលដ្ឋាន និង សាសនា*
- *ទទួលស្គាល់ភាពលំអៀងរបស់អ្នកផ្តល់ព័ត៌មាន*
- *ដោះស្រាយបញ្ហាស្ត្រី (ដូចជា ឱ្យស្ត្រីធ្វើការសម្ភាសន៍ស្ត្រី)*
- *ទៅកាន់តំបន់អាចចូលទៅបានតិចតួច*
- *ដោះស្រាយបញ្ហាភាសា (ដូចជា មានអ្នកបកប្រែភាសា)*
- *ធ្វើការកត់សំគាល់យ៉ាងពិស្តារ*

*គោលការណ៍ទាំងនេះ និងគោលការណ៍ណែនាំដទៃទៀតសំរាប់ការចុះប្រមូលទិន្នន័យក៏មានបរិយាយយ៉ាងពិស្តារនៅក្នុងសៀវភៅ* អដំព្រែំានុាល ជំពូកទី ៣ : ការចុះប្រមូលទិន្នន័យ *ផងដែរ។*

### ៣.៣.១ ទិន្នន័យបន្ទាប់បន្សំ

ក្រុមតាមដានគួរតែចាប់ផ្តើមដោយធ្វើការវាយតំលៃល្អិតល្អន់មួយលើទិន្នន័យបន្ទាប់បន្សំទាំងអស់ដែលពាក់ព័ន្ធនឹងសូចនាករដែលត្រូវបានកំណត់រួច។ ទិន្នន័យបន្ទាប់បន្សំគឺជាទិន្នន័យដែលត្រូវបានគេប្រមូល វិភាគ និងបោះពុម្ពរួចហើយនៅក្នុងទំរង់ផ្សេង១ដូចជា :

- ឯកសារផ្លូវការ និងមិនផ្លូវការ
- របាយការណ៍ស្ថិតិ
- របាយការណ៍វាយតំលៃ និងអង្កេតមុនៗ
- របាយការណ៍ស្រាវជ្រាវ
- ឯកសារគំរោងមុន និងគំរោងបច្ចុប្បន្ន រួមទាំងរបាយការណ៍តាមដាន និងវាយតំលៃផង
- ផែនទី
- រូបថតពីលើអាកាស និងរូបភាពពីផ្កាយរណប
- ឯកសារ និងរឿងរ៉ាវប្រវត្តិសាស្ត្រ
- គេហទំព័រលើប្រព័ន្ធអ៊ីនធើណេត

ការវាយតំលៃលើទិន្នន័យបន្ទាប់បន្សំរួមបញ្ចូលទាំងការចងក្រង ការវាយតំលៃ និងការត្រួតពិនិត្យលើទិន្នន័យដែលពាក់ព័ន្ធទៅនឹងសូចនាករទាំងនោះផងដែរ ។



## ៣.៣.២ បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ

អ្នកផ្តល់ព័ត៌មានសំខាន់ៗគឺជាបុគ្គលដែលអាចផ្តល់នូវទស្សនវិស័យ និងព័ត៌មានអំពីប្រជាជន និង/ឬក្រុមជាក់លាក់មួយតាមរយៈតួនាទី បទពិសោធន៍ និង/ឬចំណេះដឹងរបស់ខ្លួន។ ជាឧទាហរណ៍ មេភូមិអាចផ្តល់នូវទស្សនៈអំពីសហគមន៍ទាំងមូល ប្រធានសមាគមអ្នកនេសាទអាចផ្តល់ទស្សនៈអំពីសកម្មភាពរបស់អ្នកនេសាទ និងសង្ឃសាសនាគ្រិស្តក្នុងមូលដ្ឋានអាចផ្តល់ទស្សនៈអំពីទស្សនៈយល់ឃើញរបស់គ្រិស្តសាសនិកនៅក្នុងសហគមន៍ជាដើម។ ដូច្នេះ អ្នកផ្តល់ព័ត៌មានសំខាន់អាចផ្តល់នូវចំណេះដឹងទូទៅ ចំណេះដឹងជារួម និងចំណេះដឹងឯកទេស។ ដោយមូលហេតុថា ជាញឹកញាប់គេមិនអាចនិយាយជាមួយមនុស្សគ្រប់រូបនៅក្នុងតំបន់សិក្សាបាននោះ ជាញឹកញាប់គេតែងស្វះស្វែងរកបុគ្គលដែលមានបទពិសោធន៍ និងចំណេះដឹងទាំងនេះ។ ការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ជាញឹកញាប់ត្រូវបានប្រើប្រាស់នៅពេលដែលក្រុមតាមដានមិនចាំបាច់ត្រូវដឹងនូវទស្សនៈយល់ដឹងរបស់ប្រជាជនជាលក្ខណៈបុគ្គលមួយរូបៗ។ ជាឧទាហរណ៍ ក្រុមតាមដានមិនចាំបាច់ទៅសម្ភាសន៍ សមាជិកមួយរូបៗនៅក្នុងសហគមន៍ ដើម្បីកំណត់ថា តើនៅក្នុងសហគមន៍មានផែនការគ្រប់គ្រងការនេសាទដែរឬយ៉ាងណានោះ ដោយគេគ្រាន់តែទៅសាកសួរប្រធានការិយាល័យជលផលអំពីព័ត៌មាននេះទៅជាការស្រេច។ ភាគច្រើននៃសូចនាករ ដែលត្រូវបានប្រមូលតាមរយៈការប្រើប្រាស់បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ គឺដើម្បីស្វែងយល់នូវព័ត៌មានទូទៅ ជាមូលដ្ឋាន (ដូចជា ទិន្នន័យប្រជាសាស្ត្រនៅក្នុងសហគមន៍ វត្តមាននៃស្ថាប័នគ្រប់គ្រងជាផ្លូវការ -ល-)។ វាគឺជាការសំខាន់ ដែលត្រូវសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ ដើម្បីទទួលបាននូវទស្សនៈយល់ឃើញយ៉ាងទូលំទូលាយ។ គោលការណ៍ទូទៅក្នុង ការកំណត់នៅពេលដែលមានអ្នកផ្តល់ព័ត៌មានសំខាន់គ្រប់គ្រាន់ត្រូវបានធ្វើសម្ភាសន៍ទាក់ទិននឹងសូចនាករជាក់លាក់មួយនោះគឺ នៅពេល

ដែលចំលើយជាច្រើនចំពោះសំណួរដដែលនោះមានលក្ខណៈដដែលៗនោះផងដែរ។ ឧទាហរណ៍ ប្រសិនបើក្រុមតាមដានសាកសួរអំពីប្រភេទសកម្មភាពនៅក្នុងតំបន់សិក្សាស្រាវជ្រាវ ហើយនៅពេលនោះអ្នកផ្តល់ព័ត៌មានទាំងអស់សុទ្ធតែបានឆ្លើយនូវសកម្មភាពដូចៗគ្នានោះ នៅពេលនោះក្រុមតាមដានអាចឈប់សម្ភាសន៍អំពីសូចនាករនេះបានហើយ។

## ៣.៣.៣ បទសម្ភាសន៍តាមគ្រួសារ

ការធ្វើបទសម្ភាសន៍តាមគ្រួសាររបស់ *SocMon* មានតារាងសំណួរជាច្រើនដែលមានសំណួរប្រកបទៅរចនាសម្ព័ន្ធខ្ពស់ និងជា សំណួរបិទ។ តារាងសំណួរនោះមានសំណួរជាក់លាក់ជាច្រើន តែមានចំលើយមានកំរិត (ឧទាហរណ៍ ចំលើយពហុជំរើសចំលើយមែន/មិនមែន) ដែលលទ្ធផលរបស់វាផ្តល់នូវទិន្នន័យជាច្រើនដែលគេអាចយកវាទៅធ្វើការវិភាគជាស្ថិតិ។ ការធ្វើបទសម្ភាសន៍តាមគ្រួសារផ្តល់នូវសារៈសំខាន់ដើម្បីយល់ដឹងអំពីទស្សនៈយល់ឃើញរបស់បុគ្គលមួយរូបៗ។ ជាឧទាហរណ៍ ប្រសិនបើក្រុមតាមដានដឹងថា តើប្រជាជនមានគំនិតយ៉ាងដូចម្តេចចំពោះការអនុវត្តន៍ការគ្រប់គ្រងឆ្នេរសមុទ្រនោះ ក្រុមនេះត្រូវសម្ភាសន៍ប្រជាជនជាច្រើននាក់។ ភាគច្រើននៃសូចនាករដែលត្រូវបានសិក្សាតាមរយៈការធ្វើបទសម្ភាសន៍តាមគ្រួសារនោះ គឺដើម្បីស្វែងយល់អំពីទស្សនៈយល់ដឹង (ដូចជា តំលៃមិនមែនទីផ្សារ និងតំលៃមិនមែនប្រើប្រាស់បញ្ហារបស់សហគមន៍ ដែលប្រជាជនយល់ថាមាន)។ ការធ្វើបទសម្ភាសន៍តាមគ្រួសារមានគុណប្រយោជន៍ពីព្រោះថា វាមិនតំរូវឱ្យមានអ្នកដែលទទួលបានការបណ្តុះបណ្តាលខ្ពស់ដើម្បីគ្រប់គ្រងតារាងសំណួរនោះទេ វាមានលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ហើយត្រូវការពេលវេលាតិចតួច បើប្រៀបធៀបទៅនឹងការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ។ ទោះជាយ៉ាងណាក្តី ការធ្វើបទសម្ភាសន៍តាមគ្រួសារមានគុណវិបត្តិត្រង់ថា វាមានការលំបាកក្នុងការកំណត់ថា តើអ្នកផ្តល់ព័ត៌មានបានផ្តល់ ព័ត៌មានដែលពួកគេគិតថា អ្នកធ្វើសម្ភាសន៍ចង់បានដែរឬយ៉ាងណាទេ ហើយវាពិបាកក្នុងការសាកសួរសំណួររសើប ដូចជា អំពីប្រាក់ចំណូលជាដើម។ អ្នកធ្វើសម្ភាសន៍មានចំនួនសំណួរមានកំរិតប៉ុណ្ណោះដែលពួកគេអាចធ្វើការសាកសួរប្រជាជនបាន។

## ៣.៣.៤ ការអង្កេត

នៅក្នុងករណីខ្លះ គេអាចប្រមូលទិន្នន័យបានតាមរយៈការអង្កេត។ ការអង្កេតគឺជាការពណ៌នាប្រកបដោយគុណភាពអំពីអ្វីដែលសមាជិកក្រុមតាមដានមើលឃើញ និងទទួលបានតាមរយៈការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ និងការកត់ត្រាបរិស្ថានជុំវិញ។ ឧទាហរណ៍ សមាជិកក្រុមមួយអាចប្រមូលព័ត៌មានអំពីសម្ភារៈ និងជីវភាពរស់នៅ ដោយអង្កេតមើលផ្ទះសម្បែងរបស់អ្នកឆ្លើយសំណួរក្នុងពេលធ្វើបទសម្ភាសន៍ និងកត់សំគាល់លើគ្រឿងបរិក្ខារសំណង់ដំបូល ជញ្ជាំងឥដ្ឋ និងបង្អួចផ្ទះ។ ការអង្កេត គឺជាវិធីដ៏មានសារប្រយោជន៍មួយ ដោយហេតុថា ក្រុមតាមដានអាចសិក្សាលើព័ត៌មានមានស្រាប់អំពីសកម្មភាពសាំញ៉ាំផ្សេងៗ ដូចជាទំរង់នៃការនេសាទជាដើម។

## ៣.៤ តើគួរសម្ភាសន៍នរណាសំរាប់បទសម្ភាសន៍តាមគ្រួសារ?

ក្រុមតាមដានគួរតែបង្កើតនូវវិធីកំណត់អ្នកចូលរួមដោយខ្លួនឯងដើម្បីកំណត់ថា តើពួកគេគួរសម្ភាសន៍នរណាសំរាប់បទសម្ភាសន៍តាមគ្រួសារ។ សៀវភៅ GCRMN Manual *ឧបសម្ព័ន្ធ ខ : វិធីកំណត់អ្នកចូលរួម* មានបរិយាយនូវការពន្យល់យ៉ាងពិស្តារអំពីរបៀបជ្រើសរើសចំនួនមនុស្សសមរម្យសំរាប់ធ្វើការសម្ភាសន៍ និងរបៀបកំណត់អត្តសញ្ញាណប្រជាជនដែលត្រូវសម្ភាសន៍ (ទាំងព្រៀវ និងទាំងមិនព្រៀវ)។ ក្រុមតាមដានក៏អាចពិភាក្សាអំពីផែនការកំណត់អ្នកចូលរួម និងចំនួនអ្នកចូលរួម ជាមួយអ្នកជំនាញផ្នែកស្ថិតិនៅឯការិយាល័យស្ថិតិ ឬនៅសាកលវិទ្យាល័យក្បែរៗតំបន់សិក្សានោះ។

ការសំរេចចិត្តដ៏សំខាន់មួយគឺនៅត្រង់ថា តើត្រូវធ្វើសម្ភាសន៍ក្រុមអ្នកចូលរួមតាមលក្ខណៈព្រៀវ ឬមិនព្រៀវ។ ការសំរេចចិត្ត នេះអាស្រ័យលើថា តើលទ្ធផលនោះចាំបាច់ជាលទ្ធផលតំណាងឱ្យសហគមន៍ទាំងមូលតាមបែបស្ថិតិដែរ ឬយ៉ាងណា។ ប្រសិនបើមែននោះ អញ្ចឹងវាមានសារៈសំខាន់ដែលត្រូវប្រមូលសំណាកដែលតំណាងតាមបែបស្ថិតិតាមរយៈការកំណត់អ្នកចូលរួមតាមបែបព្រៀវ (សូមអានសៀវភៅ GCRMN Manual *ឧបសម្ព័ន្ធ ខ : វិធីកំណត់អ្នកចូលរួម ទំព័រទី២៣* ដែលមានបង្ហាញអំពីតារាងកំណត់អ្នកចូលរួមមួយ)។ ក្នុងករណីដែលក្រុមតាមដានមិនត្រូវការនូវអ្នកចូលរួមដែលតំណាងតាមបែបស្ថិតិទេនោះ គេអាចប្រើប្រាស់នូវចំនួនអ្នកចូលរួមតូចជាងនេះ។ ថ្វីបើចំនួនអ្នកចូលរួមនេះមិនតំណាងឱ្យប្រជាជនទាំងមូលតាមបែបស្ថិតិក៏ដោយ ប៉ុន្តែលទ្ធផលរបស់វានឹងផ្តល់ឱ្យនូវការយល់ដឹងដែលមានសារប្រយោជន៍អំពីប្រជាជនទាំងនោះផងដែរ។ នៅក្នុងករណីបែបនេះ គប្បីជ្រើសរើសនូវចំនួនអ្នកចូលរួមដូចខាងក្រោម :

| ចំនួនប្រជាជន | ចំនួនអ្នកចូលរួម |
|---|---|
| ១០០ | ២៥ |
| ២០០ | ៤០ |
| ៣០០ | ៦០ |
| ៤០០ | ៦០ |
| ៥០០ | ៨០ |
| ១០០០ | ១០០ |

មិនថាជាការកំណត់អ្នកចូលរួមតាមបែបព្រៀវ ឬមិនព្រៀវនោះទេ ជាការសំខាន់ដែលត្រូវកំណត់អ្នកចូលរួមពីក្រុមអ្នកពាក់ព័ន្ធមកពីប្រភេទផ្សេងៗដើម្បីធានាបានថា ទស្សនាទានទូលំទូលាយត្រូវបានវាយតំលៃ។ ព័តិមានដែលប្រមូលបានពីប្រភពបន្ទាប់បន្សំ និងបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័តិមានសំខាន់អាចផ្តល់នូវសារប្រយោជន៍សំរាប់ការធានាបានថា មានប្រជាជនជាច្រើននៅក្នុងសហគមន៍ត្រូវបានសម្ភាសន៍។ ទិន្នន័យបន្ទាប់បន្សំ និងទិន្នន័យបានមកពីអ្នកផ្តល់ព័តិមានសំខាន់ៗនឹងរួមបញ្ចូលនូវព័តិមានទាក់ទិនទៅនឹងអ្នកពាក់ព័ន្ធមកពីប្រភេទផ្សេង ព្រមទាំងរបាយប្រជាសាស្ត្រជាមូលដ្ឋាន ដូចជា អាយុ ភេទ ការអប់រំ ជនជាតិ និងសាសនា ជាដើម។ ក្រុមតាមដាន ចាំបាច់ត្រូវសម្ភាសន៍ប្រជាជនទាំងនេះឱ្យសមស្របទៅនឹងអត្រាភាគរយរបស់ក្រុមពួកគេផងដែរ។ ឧទាហរណ៍ ប្រសិនបើសហគមន៍មួយមានហិណ្ឌូសាសនិក ៣០% អ៊ិស្លាមសាសនិក ៤០% និងគ្រិស្តសាសនិក ៣០% នោះ ក្រុមតាមដានចាំបាច់ត្រូវធ្វើសម្ភាសន៍ជាមួយសាសនិកជនទាំងនោះទៅតាមអត្រាភាគរយរបស់ពួកគេផងដែរ។

## ៣.៥ តើការតាមដាននេះគួរមានរយៈពេលយូរប៉ុណ្ណា?

ពេលវេលាសំរាប់ធ្វើការតាមដានសេដ្ឋកិច្ចសង្គមនឹងមានរយៈពេលខុសៗគ្នា អាស្រ័យទៅតាមស្ថានភាព ដូចជា ទំហំរបស់សហគមន៍ ជំនាញ និងធនធានរបស់ក្រុមតាមដាន ទំហំក្រុមតាមដាន និងចំនួនសូចនាករដែលត្រូវបានជ្រើសរើស។ ជាទូទៅ ពេលវេលាដំបូងនឹងមានរយៈពេលយូរបំផុត ពីព្រោះថា ដំណើរការនេះមានលក្ខណៈថ្មី ហើយបញ្ជីរាយនាមសូចនាករអាចនឹងមានទំហំធំជាងបញ្ជីរាយនាមសូចនាករ ដែលត្រូវបានជ្រើសរើសសំរាប់ការតាមដាននៅក្នុងពេលអនាគតខាងមុខទៀតផងដែរ។ ជារួម គេប៉ាន់ស្មានជាទូទៅថា វានឹងប្រើប្រាស់ពេលវេលាពី ៣ ទៅ ៦ សប្តាហ៍ (ពី ១៧ ទៅ ៣០ ថ្ងៃធ្វើការជាក់ស្តែង) ដើម្បីធ្វើការតាមដានដូចខាងក្រោមនេះ ៖

*សកម្មភាពត្រៀម ៖* ៣-៥ ថ្ងៃ

*ការប្រមូលទិន្នន័យតាមរយៈប្រភពបន្ទាប់បន្សំ ៖* ៣-៥ ថ្ងៃ

*ការប្រមូលទិន្នន័យតាមរយៈអ្នកផ្តល់ព័ត៌មានសំខាន់ៗ ៖* ៣-៥ ថ្ងៃ

*ការប្រមូលទិន្នន័យតាមរយៈបទសម្ភាសន៍តាមគ្រួសារ ៖* ៣-៥ ថ្ងៃ

*ការវិភាគទិន្នន័យ ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញ និងការពិគ្រោះយោបល់ ៖* ៣-៥ ថ្ងៃ

ចំនួនថ្ងៃធ្វើការជាក់ស្តែងទាំងនេះអាចនឹងអូសបន្លាយវែងជាងនេះ ដោយហេតុថា សកម្មភាពនីមួយៗអាចនឹងមិនដំណើរការតាមលំដាប់លំដោយដោយផ្ទាល់នោះទេ។

## ៣.៦ តើការតាមដាននេះនឹងប្រើប្រាស់ថវិកាចំនួនប៉ុន្មាន?

ថវិកាក៏នឹងត្រូវចំណាយខុសៗគ្នាដែរ ដោយអាស្រ័យទៅលើតំរូវការនៅនឹងកន្លែង ធនធានដែលមានស្រាប់ និងការចំណាយក្នុងមូលដ្ឋាន។ ជាទូទៅ គេរំពឹងថា ថវិកានឹងត្រូវប្រើប្រាស់លើមុខចំណាយដូចខាងក្រោម ប៉ុន្តែក៏អាចត្រូវប្រើប្រាស់លើមុខចំណាយផ្សេងៗទៀតផងដែរ ៖

- ការធ្វើដំណើរទៅកាន់ការិយាល័យរដ្ឋាភិបាលដើម្បីប្រមូលយកនូវទិន្នន័យបន្ទាប់បន្សំ
- ប្រាក់បៀវត្សរ៍សំរាប់អ្នកសម្ភាសន៍ ៣-៤ នាក់
- ប៊ិច ក្រដាស សៀវភៅសរសេរ និងសំភារៈផ្សេងទៀត
- ផែនទី ក្រាបបង្ហាញផ្លូវ
- ការធ្វើដំណើរទៅកាន់តំបន់សិក្សាស្រាវជ្រាវ (រថយន្ត ទូក)
- ថតចំលងឯកសារ
- កុំព្យូទ័រដែលមានកម្មវិធីមូលដ្ឋានទីរ្វដ ភរ្សែចសេសិនង្ស្សែថតីារ

- ផ្សេងៗ : កាមេរ៉ា កែវយឺត ឧបករណ៍ថតសំលេង វីដេអូកាមេរ៉ា ឧបករណ៍ អភ្យ

## ៣.៧ តើគួរធ្វើការតាមដានញឹកញាប់ប៉ុណ្ណា?

ជាទូទៅ កម្មវិធីតាមដានសេដ្ឋកិច្ចសង្គមចាប់ផ្តើមជាមួយនឹងការវាយតំលៃសេដ្ឋកិច្ចសង្គមគោល ដោយប្រើប្រាស់នូវសូចនាករជាច្រើន ដែលផ្តល់នូវមូលដ្ឋានទិន្នន័យមួយសំរាប់ប្រើប្រាស់នៅថ្ងៃអនាគតជាទិន្នន័យយោង។ ការខិតខំតាមដានជាបន្តបន្ទាប់ អាចប្រើប្រាស់នូវបញ្ជីរាយនាមសូចនាករដែលមានតិចជាងការតាមដានគោលនោះ ដោយហេតុថាសូចនាករ មួយចំនួនគួរត្រូវបានប្រមូលច្រើនដងជាងសូចនាករផ្សេងទៀត។ *តារាង ៤.១* និង*តារាង ៤.២* នៅក្នុង*ផ្នែកទី ៤* ដែលមានបង្ហាញអំពីសូចនាករទាំងនោះ ផ្តល់នូវចំនួននៃការប្រមូលទិន្នន័យសំរាប់សូចនាករនីមួយៗ ដែលមានចាប់ពីចំនួនយ៉ាងតិចបំផុតមួយដងក្នុងរៀងរាល់រយៈពេលពី ២ ទៅ ៥ ឆ្នាំម្តង។ ក្រុមតាមដានចាំបាច់ត្រូវកំណត់នូវចំនួនសមស្របបំផុតសំរាប់ការប្រមូលទិន្នន័យ ដោយអាស្រ័យទៅលើស្ថានភាព និងតំរូវការទិន្នន័យសំរាប់តំបន់របស់ខ្លួន។ ជាឧទាហរណ៍ នៅក្នុងតំបន់ដែលមានអត្រានៃការផ្លាស់ប្តូរសេដ្ឋកិច្ច និងប្រជាសាស្ត្រខ្ពស់ ក្រុមតាមដានអាចនឹងត្រូវប្រមូលទិន្នន័យឱ្យបានញឹកញាប់ ដើម្បីធ្វើការវាយតំលៃលើនិន្នាការនេះ ចំណែកឯនៅក្នុងសហគមន៍ដែលមានស្ថេរភាពច្រើនវិញ ក្រុមតាមដាន អាចនឹងមិនត្រូវធ្វើការប្រមូលទិន្នន័យញឹកញាប់ពេកនោះទេ។

## ៣.៨ តើគួរធ្វើការតាមដាននេះនៅទីកន្លែងណា?

ការប្រមូលទិន្នន័យជាទូទៅកើតឡើងនៅកន្លែងចំនួនពីរគឺ :

- នៅខាងក្រៅសហគមន៍ - ជាការពិត ទិន្នន័យបន្ទាប់បន្សំមាននៅក្នុងស្ថាប័នរដ្ឋាភិបាល ស្ថាប័នសិក្សា ស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និងការិយាល័យផ្សេងៗទៀត ដែលជាធម្មតាស្ថិតនៅខាងក្រៅសហគមន៍។
- នៅខាងក្នុងសហគមន៍ - បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ បទសម្ភាសន៍តាមគ្រួសារ និងការអង្កេតនឹងត្រូវធ្វើឡើងនៅក្នុងសហគមន៍ផ្ទាល់តែម្តង។

## ៣.៩ តើអ្នកណាគួរទទួលបានលទ្ធផលនៃការតាមដាននេះ?

នៅមុនពេលធ្វើការតាមដានសេដ្ឋកិច្ចសង្គម ជាការសំខាន់ដែលត្រូវកំណត់នូវអ្នកដែលគួរទទួលបានលទ្ធផលនៃការតាមដាននេះ។ ការដែលបានដឹងអំពីអ្នកគួរទទួលបានព័ត៌មានអំពីសេដ្ឋកិច្ចសង្គមនោះ វាអាចជួយឱ្យយើងផ្តោតការយកចិត្តទុកដាក់លើដំណើរការ និងលទ្ធផលតាមវិធីមួយដែលអាចបង្កើត និងផ្សព្វផ្សាយលទ្ធផលបានយ៉ាងមានប្រសិទ្ធភាព។

នៅក្នុងការកំណត់អ្នកគួរទទួលបានលទ្ធផលនោះ ជាការសំខាន់ដែលត្រូវពិចារណាថា តើអ្នកណាខ្លះនឹងរងផលប៉ះពាល់ពីលទ្ធផលនេះ ទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន។ អ្នកដែលរងផលប៉ះពាល់អាចអាស្រ័យលើគោលបំណងនៃព័ត៌មានសេដ្ឋកិច្ចសង្គមនោះ ដូចដែលបានបរិយាយរួចនៅក្នុង*ផ្នែកទី ២* ។ ឧទាហរណ៍ ប្រសិនបើគោលបំណងនៃការតាមដានគឺដើម្បីវាយតំលៃលើដំណើរការការងាររបស់ស្ថាប័នគ្រប់គ្រង នោះស្ថាប័នគ្រប់គ្រងនោះនឹងក្លាយជាអ្នកគួរទទួលបានលទ្ធផល ព្រមទាំងអ្នកដទៃទៀតដែលមានចំណាប់អារម្មណ៍ទៅលើប្រសិទ្ធភាពរបស់ស្ថាប័នគ្រប់គ្រងនេះ ដូចជាទីភ្នាក់ងារតាមដានស្ថាប័ន គ្រប់គ្រង (ឧទាហរណ៍ដូចជា អង្គការ National Parks Trust) សាធារណជនទូទៅ និងក្រុមអ្នកពាក់ព័ន្ធជាក់ស្តែង (ដូចជា អ្នកនេសាទ ប្រតិបត្តិករទេសចរណ៍ ជាដើម)។

វាក៏មានសារៈសំខាន់ផងដែរដែលត្រូវពិចារណាដល់អ្នកដែលអាចចាត់វិធានការពាក់ព័ន្ធនឹងលទ្ធផលនេះ។ ឧទាហរណ៍ ប្រសិន បើគោលបំណងនៃការតាមដានគឺដើម្បីទាក់ទាញការចូលរួមពីអ្នកពាក់ព័ន្ធ នោះអ្នកពាក់ព័ន្ធក៏ជាផ្នែកដ៏សំខាន់មួយនៃអ្នកគួរទទួលបានលទ្ធផលនេះផងដែរ។

ជាទីបញ្ចប់ វាពិតជាមានសារៈសំខាន់ដែលត្រូវពិចារណាដល់អ្នកដែលចាំបាច់ត្រូវជ្រាបអំពីសកម្មភាពគ្រប់គ្រងឆ្នេរសមុទ្រ និងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមពាក់ព័ន្ធផ្សេងៗ។ នៅក្នុងករណីខ្លះ នេះអាចជាសហគមន៍ទាំងមូល ហើយនៅក្នុងករណីខ្លះទៀត វាអាចជាស្ថាប័នរដ្ឋាភិបាលមួយចំនួន ឬគណៈកម្មាធិការប្រឹក្សាយោបល់ជាដើម។

## ៣.១០ តើមានអ្វីផ្សេងទៀតដែលខ្ញុំគួរតែដឹងដែរឬទេ?

វាផ្តល់នូវសារៈសំខាន់ដែលអាចកំណត់បាននូវគំរោងអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវផ្សេងៗដែលត្រូវបានធ្វើឡើងកាលពីពេលថ្មីៗកន្លងមក ដែលក្នុងនោះអាចរួមមានការវាយតំលៃអំពីសេដ្ឋកិច្ចសង្គមផងដែរ។ ដំណើរការនេះ ព្រមទាំងព័ត៌មានស្តីពីលទ្ធផលទាំងនោះគួរត្រូវបានយកមកធ្វើការពិនិត្យជាទិន្នន័យសំរាប់ធ្វើការប្រៀបធៀប និងនៅមុនពេលចាប់ផ្តើមធ្វើការប្រមូលទិន្នន័យ *SocMon* ដើម្បីបញ្ចៀសនូវការចំលងទិន្នន័យដូចគ្នា។ ប្រសិនបើមានសកម្មភាព

បន្តណាមួយកំពុងធ្វើការវិភាគសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់នោះ វាគឺជាការសំខាន់ដែលត្រូវកំណត់ថា តើការវិភាគនោះមានជាប់ពាក់ព័ន្ធទៅនឹងការតាមដាន *SocMon* ដែរឬយ៉ាងណា ហើយព្យាយាមធ្វើសមាហរណកម្ម ឬបញ្ចូលសកម្មភាពទាំងនោះជាមួយគ្នា។ ការនេះគឺមាន លក្ខណៈសំខាន់យ៉ាងពិសេសសំរាប់ការកាត់បន្ថយបានជាអប្បបរិមានៃការបំពានលើសហគមន៍។ វាមិនមែនមិនប្រក្រតីទេ ដែលសមាជិកក្នុងសហគមន៍មានការធុញទ្រាន់នឿយណាយជាមួយនឹងបទសម្ភាសន៍ នៅពេលដែលពួកគេត្រូវបានសម្ភាសន៍ ច្រើនដងពេកនោះ។

ដូចដែលបានធ្វើការកត់សំគាល់នៅក្នុង*ផ្នែកទី ១* រួចមកហើយ ឯកសារនេះត្រូវបានរចនាឡើងដើម្បីប្រើប្រាស់ជាមួយនឹងសៀវភៅ *អជព្រៃរនាំនុាល* ។ វាពិតជាមានសារៈសំខាន់ណាស់ដែលត្រូវអាន*ជំពូកទី ១ : សកម្មភាពត្រៀម* និង*ជំពូកទី ២ : ការអង្កេតតាមដាន និងការរៀបចំផែនការ* មុននឹងចាប់ផ្តើមធ្វើការប្រមូលទិន្នន័យ។ *ជំពូកទី ៣ : ការចុះប្រមូលទិន្នន័យ* ក៏មានសារៈសំខាន់ផងដែរដើម្បីយល់ច្បាស់អំពីរបៀបធ្វើបទសម្ភាសន៍។

# ផ្នែកទី ៤ : តើទិន្នន័យអ្វីដែលខ្ញុំត្រូវប្រមូល?

## ៤.១ តើអ្វីទៅគឺជាសូចនាករ?

*ដើម្បីកំណត់បរិបទនៃការចុះប្រមូលទិន្នន័យ ដំបូងក្រុមតាមដានចាំបាច់ត្រូវយល់អំពីតំបន់សិក្សាស្រាវជ្រាវ* (KS1) ប្រជាជន (KS2) ចំនួនគ្រួសារ (KS3) សកម្មភាព (KS14) *និងអ្នកពាក់ព័ន្ធ* (KS24)។ សូចនាករទាំងនេះអាចត្រូវបានវាយតំលៃកាន់តែពេញលេញជាងនេះនៅក្នុងអំឡុងពេលធ្វើបទសម្ភាសន៍ ប៉ុន្តែដើម្បីកំណត់បាននូវទីកន្លែងធ្វើសម្ភាសន៍ និងចំនួនប្រជាជន ដែលត្រូវសម្ភាសនោះ យ៉ាងហោចណាស់ក៏គេចាំបាច់ត្រូវកំណត់ឱ្យបាននូវសូចនាករទាំងបួននេះជាមុនផងដែរ។

*SocMon* ផ្តោតការយកចិត្តទុកដាក់លើសូចនាករសេដ្ឋកិច្ចសង្គមចំនួន ៦០ ដែលត្រូវបាន ផ្តល់ជូន ផ្អែកទៅតាមមធ្យោបាយនៃការចុះប្រមូលទិន្នន័យ : ប្រភពបន្ទាប់បន្សំ/បទ សម្ភាសន៍ ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (*តារាង ៤.១*) ឬបទសម្ភាសន៍តាមគ្រួសារ (*តារាង ៤.២*)។ *ឧបសម្ព័ន្ធ ក* ផ្តល់នូវព័ត៌មានពិស្តារអំពីសូចនាករនីមួយៗ រួមមាន តើមានសូចនាករអ្វីខ្លះ វិធីសាស្ត្រប្រមូលវា វិធីសាស្ត្រវិភាគវា ហើយតើព័ត៌មានជាលទ្ធផលអាច មានសារប្រយោជន៍សំរាប់អ្នកគ្រប់គ្រងដោយរបៀបណា។ ដើម្បីបានជ្រាបអំពីសេចក្តី បរិយាយពីសូចនាករទាំងនេះបែបពិស្តារជាងនេះ និងរបៀបធ្វើបទសម្ភាសន៍នោះ សូមអានសៀវភៅ *GCRMN Manual ឧបសម្ព័ន្ធ ក : កត្តាវាស់វែងផ្នែកសេដ្ឋកិច្ចសង្គម* និង*ជំពូកទី ៣ : ការចុះប្រមូលទិន្នន័យ* បទសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ។

មួយចំនួននៃសូចនាករទាំងនោះ ដូចជា អាយុ ភេទ និងការអប់រំ ត្រូវបានប្រមូលតាមរយៈអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ និងតាមរយៈបទសម្ភាសន៍តាមគ្រួសារផងដែរ។ នេះត្រូវបានធ្វើឡើងដើម្បីពិនិត្យប្រៀបធៀបលទ្ធផលទាំងនោះ ហើយក៏ដោយសារតែទិន្នន័យទាំងពីរប្រភេទនេះបំពេញឱ្យគ្នាទៅវិញទៅមកផងដែរ។ ទិន្នន័យបានមកពីប្រភព អ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំផ្តល់នូវព័ត៌មានជារួមក៏រិតសហគមន៍ ដែលមានសារប្រយោជន៍សំរាប់ការវាយតំលៃលើបំលាស់ប្តូរ និងនិន្នាការនាពេលកន្លងមក ចំណែកឯ ទិន្នន័យ បានមកពីបទសម្ភាសន៍តាមគ្រួសារផ្តល់នូវព័ត៌មានកាន់តែជាក់លាក់អំពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ។ ឧទាហរណ៍ ព័ត៌មានក៏រិតសហគមន៍អំពីមុខរបរ និងប្រជាសាស្ត្រផ្តល់ ឱ្យនូវការយល់ដឹងជារួមមួយអំពីអត្រាភាគរយនៃប្រជាជនក្នុងសហគមន៍ដែលប្រកបរបរនីមួយៗ និងអត្រាភាគរយនៃក្រុម អាយុ ក៏រិតវប្បធម៌ របស់ប្រជាជននៅក្នុងសហគមន៍ -ល-។ ផ្ទុយមកវិញ ព័ត៌មានអំពីមុខរបរ និងប្រជាសាស្ត្រ ដែលទទួលបានមកពីការធ្វើបទសម្ភាសន៍តាមគ្រួសារអាចយកទៅប្រើប្រាស់ ដើម្បីកំណត់ជនជាតិរបស់អ្នកពាក់ព័ន្ធទាំងឡាយ ដូចជា អ្នកនេសាទ និង មគ្គុទ្ទេសក៍ទេសចរណ៍ជាដើម។

*សំរាប់ការវាយតំលៃលើកទីមួយ ក្រុមតាមដានអាចនឹងត្រូវប្រមូលទិន្នន័យស្តីពីសូចនាករច្រើនជាងសំរាប់ការតាមដាន នាពេលបន្ទាប់ ។ តួយ៉ាង ការវាយតំលៃគោលត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវសូចនាករជាច្រើនដែលផ្តល់នូវមូលដ្ឋានគ្រឹះនៃទិន្នន័យសំរាប់ប្រើប្រាស់ជាទិន្នន័យយោងនៅថ្ងៃអនាគត ។ ការតាមដាននាពេលបន្ទាប់អាចរួមបញ្ចូលនូវបញ្ជីរាយនាមសូចនាករដែលមានទំហំតូចជាង ដោយហេតុថាសូចនាករមួយចំនួនអាចត្រូវបានប្រមូលញឹកញាប់ជាងសូចនាករផ្សេងទៀត ។ សូមអាន* តារាង ៤.១ និង ៤.២ *ខាងក្រោមដើម្បីជាព័ត៌មានយោងនៅពេលដែលត្រូវប្រមូលទិន្នន័យអំពីសូចនាករនីមួយៗ ។*

*តារាង ៤.១* និង*៤.២* បង្ហាញអំពីសូចនាករជាច្រើនដែលអាស្រ័យទៅតាមប្រភេទ និងមធ្យោបាយនៃការប្រមូលទិន្នន័យ ។ តារាងទាំងនេះកត់សំគាល់យ៉ាងពិសេសនូវលក្ខណៈមានប្រយោជន៍នៃសូចនាករនីមួយៗ រួមមានដូចជា មធ្យោបាយសំខាន់ៗនៃការប្រមូលទិន្នន័យ ចំនួនអប្បបរិមានៃការប្រមូលទិន្នន័យ និងសារៈសំខាន់ជាទូទៅនៃការប្រមូលទិន្នន័យ ។ ការអង្កេតមិនត្រូវបានកត់សំគាល់យ៉ាងជាក់លាក់សំរាប់សូចនាករណាមួយនៃសូចនាករទាំងនោះទេ ដោយហេតុថា ការអង្កេតមានសារៈសំខាន់សំរាប់សូចនាករទាំងអស់នោះ។ គេរំពឹងថា ក្រុមតាមដាននឹងប្រើប្រាស់ការអង្កេតសំរាប់ធ្វើការពិនិត្យប្រៀបធៀបលើទិន្នន័យដែលប្រមូលបានតាមរយៈប្រភពបន្ទាប់បន្សំ បទសម្ភាសន៍ជាមួយអ្នកផ្តល់ ព័ត៌មានសំខាន់ និងបទសម្ភាសន៍តាមគ្រួសារ ។

## តារាង ៤.១ សូចនាករប្រមូលពីអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ

| បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ (KS) | | មធ្យោបាយសំខាន់ៗក្នុងការប្រមូលទិន្នន័យ ( ប្រភពបន្ទាប់បន្សំ អ្នកផ្តល់ព័ត៌មានសំខាន់ ឬទាំងពីរ ) | ចំនួនអប្បបរិមានៃការប្រមូលទិន្នន័យ (គិតជាឆ្នាំ) | សារៈសំខាន់ជាទូទៅនៃការប្រមូលទិន្នន័យ (ខ្ពស់ ឬមធ្យម) |
|---|---|---|---|---|
| *ប្រជាសាស្ត្រក៏រិតសហគមន៍* | | | | |
| KS1. | តំបន់សិក្សា | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS2. | ចំនួនប្រជាជន | ប្រភពបន្ទាប់បន្សំ | ៥ | ខ្ពស់ |
| KS3. | ចំនួនគ្រួសារ | ប្រភពបន្ទាប់បន្សំ | ៥ | ខ្ពស់ |
| KS4. | អត្រាចំណាកស្រុក | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS5. | អាយុ | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS6. | ភេទ | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS7. | ការអប់រំ | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS8. | អក្ខរកម្ម | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS9. | ជនជាតិ | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS10. | សាសនា | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS11. | ភាសា | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| KS12. | មុខរបរ | ប្រភពបន្ទាប់បន្សំ | ៣ | ខ្ពស់ |
| *ហេដ្ឋារចនាសម្ព័ន្ធសហគមន៍* | | | | |
| KS13. | ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| *សកម្មភាពតាមតំបន់ឆ្នេរ និងសមុទ្រ* | | | | |
| KS14. | សកម្មភាព | ទាំងពីរ | ២ | ខ្ពស់ |
| KS15. | ទំនិញ និងសេវាកម្ម | ទាំងពីរ | ២ | ខ្ពស់ |
| KS16. | ប្រភេទនៃការប្រើប្រាស់ | ទាំងពីរ | ២ | ខ្ពស់ |
| KS17. | តំលៃទំនិញ និងសេវាកម្ម | ទាំងពីរ | ២ | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| KS18. | គោលដៅទីផ្សារទំនិញ និងសេវាកម្ម | ទាំងពីរ | ២ | ខ្ពស់ |
| KS19. | លំនាំនៃការប្រើប្រាស់ | ទាំងពីរ | ២ | ខ្ពស់ |
| KS20. | កំរិតនៃផលប៉ះពាល់ | ទាំងពីរ | ២ | ខ្ពស់ |
| KS21. | ប្រភេទនៃផលប៉ះពាល់ | ទាំងពីរ | ២ | ខ្ពស់ |
| KS22. | កំរិតការប្រើប្រាស់របស់អ្នកពីខាងក្រៅ | ទាំងពីរ | ២ | ខ្ពស់ |
| KS23. | ការប្រើប្រាស់របស់គ្រួសារ | ទាំងពីរ | ២ | ខ្ពស់ |
| KS24. | អ្នកពាក់ព័ន្ធ | ប្រភពបន្ទាប់បន្សំ | ៥ | មធ្យម |
| ***អភិបាលកិច្ច*** | | | | |
| KS25. | ស្ថាប័នគ្រប់គ្រង | ទាំងពីរ | ៣ | មធ្យម |
| KS26. | ផែនការគ្រប់គ្រង | ទាំងពីរ | ៣ | មធ្យម |
| KS27. | ច្បាប់អនុវត្តន៍ | ទាំងពីរ | ៣ | មធ្យម |
| KS28. | ការបែងចែកធនធាន | ទាំងពីរ | ៣ | មធ្យម |
| KS29. | សិទ្ធិប្រើប្រាស់ និងគោលការណ៍ផ្លូវការ | ទាំងពីរ | ៣ | មធ្យម |
| KS30. | សិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការ ទំនៀមទំលាប់ និងប្រពៃណី | ទាំងពីរ | ៣ | មធ្យម |
| KS31. | ការចូលរួមពីអ្នកពាក់ព័ន្ធ | ទាំងពីរ | ៣ | មធ្យម |
| KS32. | អង្គការរបស់សហគមន៍ និងអ្នកពាក់ព័ន្ធ | ទាំងពីរ | ៣ | មធ្យម |

តារាង ៤.២ សូចនាករសំរាប់សម្ភាសន៍តាមគ្រួសារ

| បទសម្ភាសន៍តាមគ្រួសារ (H) | | ចំនួនអប្បបរិមានៃការប្រមូលទិន្នន័យគិតជាឆ្នាំ | សារៈសំខាន់ជាទូទៅនៃការប្រមូលទិន្នន័យ (ខ្ពស់ ឬមធ្យម) |
|---|---|---|---|
| *ប្រជាសាស្ត្រតាមគ្រួសារ* | | | |
| H1. | អាយុ | ៥ | មធ្យម |
| H2. | ភេទ | ៥ | មធ្យម |
| H3. | ជនជាតិ | ៥ | មធ្យម |
| H4. | ការអប់រំ | ៥ | មធ្យម |
| H5. | សាសនា | ៥ | មធ្យម |
| H6. | ភាសា | ៥ | មធ្យម |
| H7. | មុខរបរ | ៥ | មធ្យម |
| H8. | ទំហំគ្រួសារ | ៥ | មធ្យម |
| H9. | ចំណូលក្នុងគ្រួសារ | ៣ | មធ្យម |
| *សកម្មភាពតាមតំបន់ឆ្នេរឆ្នេរសមុទ្រ និងសមុទ្រ* | | | |
| H10. | សកម្មភាពគ្រួសារ | ២ | មធ្យម |
| H11. | ទំនិញ និងសេវាកម្មរបស់គ្រួសារ | ២ | មធ្យម |
| H12. | ប្រភេទនៃការប្រើប្រាស់របស់គ្រួសារ | ២ | មធ្យម |
| H13. | ការកំណត់ទីផ្សាររបស់គ្រួសារ | ២ | មធ្យម |
| H14. | ការប្រើប្រាស់របស់គ្រួសារ | ២ | មធ្យម |
| *ឥរិយាបថ និងការយល់ឃើញ* | | | |
| H15. | តំលៃមិនមែនទីផ្សារ និងតំលៃមិនមែនប្រើប្រាស់ | ៣ | មធ្យម |
| H16. | ការយល់ឃើញអំពីស្ថានភាពធនធាន | ៣ | មធ្យម |
| H17. | ការយល់ឃើញអំពីការគំរាមកំហែង | ៣ | មធ្យម |
| H18. | ការយល់ដឹងអំពីច្បាប់ និងបទបញ្ញត្តិ | ៣ | មធ្យម |
| H19. | ការគោរពតាម | ៣ | មធ្យម |
| H20. | ការអនុវត្តន៍ | ៣ | មធ្យម |

| | | | |
|---|---|---|---|
| H21. | ការចូលរួមក្នុងការធ្វើសេចក្តីសំរេច | ៣ | មធ្យម |
| H22. | សមាជិកភាពនៅក្នុងស្ថាប័នពាក់ព័ន្ធ | ៣ | មធ្យម |
| H23. | ការយល់ឃើញអំពីបញ្ហានៃការគ្រប់គ្រងតំបន់ឆ្នេរ | ៣ | មធ្យម |
| H24. | ដំណោះស្រាយចំពោះការគ្រប់គ្រងតំបន់ឆ្នេរ ដែលកើតមាន | ៣ | មធ្យម |
| H25. | បញ្ហាដែលយល់ថាកើតមានចំពោះសហគមន៍ | ៣ | មធ្យម |
| H26. | ជោគជ័យក្នុងការគ្រប់គ្រងតំបន់ឆ្នេរ | ៣ | មធ្យម |
| H27. | បញ្ហាប្រឈមក្នុងការគ្រប់គ្រងតំបន់ឆ្នេរ | ៣ | មធ្យម |
| *សម្ភារៈ និងជីវភាពរស់នៅ* | | | |
| H28. | សម្ភារៈ និងជីវភាពរស់នៅ | ៣ | មធ្យម |

## តារាងទី ៤.៣ គោលបំណងនៃសូចនាករតាមដានសេដ្ឋកិច្ចសង្គម និងសូចនាករពាក់ព័ន្ធនានា

| ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ចំនួនប្រជាជន | សូចនាករការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | *ប្រជាសាស្ត្រថ្នាក់សហគមន៍* | | | | | | | | | | | | *ហេដ្ឋារចនាសម្ព័ន្ធសហគមន៍* |
| | តំបន់សិក្សា អាយុ ភេទ ការអប់រំ ចំនួនគ្រួសារ អត្រាចំណាកស្រុក អក្ខរកម្ម ជនជាតិ ភាសា មុខរបរ សាសនា | | | | | | | | | | | | |
| **គោលបំណង** | **KS1** | **KS2** | **KS3** | **KS4** | **KS5** | **KS6** | **KS7** | **KS8** | **KS9** | **KS10** | **KS11** | **KS12** | **KS13** |
| **ការកំណត់ការគំរាមកំហែង បញ្ហា ដំណោះស្រាយ និងឱកាស** | | | | | | | | | | | | | |
| ការគំរាមកំហែង | ● | ● | ● | ● | | | | | | | | ● | ● |
| បញ្ហា | | | | | | | | | | | | | ● |
| ដំណោះស្រាយ និងឱកាស | | | | | | | | | | | | | |
| **ការកំណត់សារៈសំខាន់តំលៃ និងសារៈសំខាន់ផ្នែកវប្បធម៌នៃធនធាន និងការប្រើប្រាស់របស់វា** | | | | | | | | | | | | | |
| សារៈសំខាន់/តំលៃ | | | | | | | | | | | | ● | |
| សារៈសំខាន់ផ្នែកវប្បធម៌ | | | | | | | | | | | | | |
| **ការវាយតំលៃផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃវិធានការគ្រប់គ្រង** | | | | | | | | | | | | | |
| មធ្យោបាយចិញ្ចឹមជីវិត | | ● | | | | | ● | ● | ● | ● | | ● | ● |
| ទីផ្សារ និងផលិតកម្ម | | | | | | | | | | | | | |
| សន្តិសុខស្បៀងអាហារ | | | | | | | | | | | | | |
| ឥរិយាបថ និងការយល់ឃើញ | | | | | | | | | | | | | |
| សកម្មភាពនៅតាមតំបន់ឆ្នេរ | | | | | | | | | | | | ● | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អភិបាលកិច្ច | | | | | | | | | | | | | |
| **ការវាយតំលៃអំពីរបៀបដែលស្ថាប័នគ្រប់គ្រង កំពុងអនុវត្ត** | | | | | | | | | | | | | |
| ប្រសិទ្ធភាពនៃការគ្រប់គ្រង | | | | | | | | | | | | | |
| **ការកសាងការចូលរួមរបស់អ្នកពាក់ព័ន្ធ និងកម្មវិធីអប់រំ និងលើកកំពស់ការយល់ដឹងត្រឹមត្រូវ** | | | | | | | | | | | | | |
| ការចូលរួមរបស់អ្នកពាក់ព័ន្ធ | | ● | | | ● | ● | ● | ● | ● | ● | ● | ● | |
| កម្មវិធីលើកកំពស់ការយល់ដឹង | | | | ● | | | | | | | | | ● |
| **ការផ្ទៀងផ្ទាត់ និងការរៀបចំឯកសារស្តីពីសេចក្តីសន្និដ្ឋានលក្ខខណ្ឌសេដ្ឋកិច្ចសង្គមក្នុងតំបន់ កំលាំងសហគមន៍ និងការយល់ឃើញរបស់ក្រុមអ្នកចូលរួម** | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |
| **ការបង្កើតប្រវត្តិគោលរបស់សហគមន៍ និងគ្រួសារ** | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |

## តារាងទី ៤.៣ គោលបំណងនៃសូចនាករតាមដានសេដ្ឋកិច្ចសង្គម និងសូចនាករពាក់ព័ន្ធនានា (ត)

| សូចនាករសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| *សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ* | | | | | | | | | | | *អភិបាលកិច្ច* | | | | | | | |
| សកម្មភាព | ទំនិញ និងសេវាកម្ម | ប្រភេទនៃការប្រើប្រាស់ | តំលៃទំនិញ និង[illegible] | [illegible] | [illegible] | កំរិតនៃផលប៉ះពាល់ | ប្រភេទនៃផលប៉ះពាល់ | កំរិតនៃការប្រើប្រាស់របស់អ្នកពីខាងក្រៅ | ការប្រើប្រាស់របស់គ្រួសារ | អ្នកពាក់ព័ន្ធ | ស្ថាប័នគ្រប់គ្រង | ផែនការគ្រប់គ្រង | ច្បាប់អនុវត្តន៍ | [illegible] | | | | |
| KS14 | KS15 | KS16 | KS17 | KS18 | KS19 | KS20 | KS21 | KS22 | KS23 | KS24 | KS25 | KS26 | KS27 | KS28 | KS29 | KS30 | KS31 | KS32 |
| | | | | | | | | | | | | | | | | | | |
| ● | ● | ● | | | ● | ● | ● | | | | | | | | | | | |
| | | | | | ● | | | ● | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | ● | ● | | | ● | ● | | | | | | | | ● | |
| | | | | | | | | | | | | | | | | ● | | |
| | | | | | | | | | | | | | | | | | | |
| ● | ● | ● | ● | | | | | | ● | | | | | | | | | |
| | ● | ● | ● | ● | | | | | | | | | | | | | | |
| | ● | ● | ● | ● | | | | | ● | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| ● | ● | ● | | | ● | | | | | | | | | | | | | |
| | | | | | | | | | | | ● | ● | ● | ● | ● | ● | | |
| | | | | | | | | | | | | | | | | | | |
| ● | ● | ● | | | ● | ● | ● | | | | | | | | | | ● | ● |
| | | | | | | | | | | | | | | | | | | |
| | | ● | | | | | | ● | | ● | | | | | | | ● | ● |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ● | ● | ● | | | | ● | ● | ● | | | | | | | | | | |
| ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | | | ● | ● |
| ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | | | ● | ● |

**តារាងទី ៤.៣ គោលបំណងនៃសូចនាករតាមដានសេដ្ឋកិច្ចសង្គម និងសូចនាករពាក់ព័ន្ធនានា (ត)**

| អាយុ ភេទ ជនជាតិ ការអប់រំ សាសនា ភាសា សកម្មភាពគ្រួសារ ទំនិញ និងសេវាកម្មរបស់គ្រួសារ ប្រភេទនៃការប្រើប្រាស់របស់គ្រួសារ ការកំណត់ទីផ្សាររបស់គ្រួសារ ការប្រើប្រាស់របស់គ្រួសារ | សូចនាករនៃបទសម្ភាសន៍តាមគ្រួសារ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | *ប្រជាសាស្ត្រគ្រួសារ* | | | | | | | | | *សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ* | | | | |
| | មុខរបរ | ទំហំគ្រួសារ | ចំណូលក្នុងគ្រួសារ | | | | | | | | | | | |
| **គោលបំណង** | H1 | H2 | H3 | H4 | H5 | H6 | H7 | H8 | H9 | H10 | H11 | H12 | H13 | H14 |
| **ការកំណត់ការគំរាមកំហែង បញ្ហា ដំណោះស្រាយ និង ឱកាស** | | | | | | | | | | | | | | |
| ការគំរាមកំហែង | | | | | | | | | | ● | ● | ● | | |
| បញ្ហា | | | | | | | ● | | | | | | | |
| ដំណោះស្រាយ និងឱកាស | | | | | | | | ● | | | | | | |
| **ការកំណត់សារៈសំខាន់ តំលៃ និង សារៈសំខាន់ផ្នែកវប្បធម៌នៃធនធាន និងការប្រើប្រាស់របស់វា** | | | | | | | | | | | | | | |
| សារៈសំខាន់/តំលៃ | | | | | | | ● | | ● | | | | ● | |
| សារៈសំខាន់ផ្នែកវប្បធម៌ | | | | | | | | | | | | | | |
| **ការវាយតំលៃផលប៉ះពាល់ ជាវិជ្ជមាន និងអវិជ្ជមាននៃ វិធានការគ្រប់គ្រង** | | | | | | | | | | | | | | |
| មធ្យោបាយចិញ្ចឹមជីវិត | | | ● | ● | ● | | ● | | | ● | ● | ● | ● | ● |
| ទីផ្សារ និងផលិតកម្ម | | | | | | | | | | | ● | ● | ● | ● |
| សន្តិសុខស្បៀងអាហារ | | | | | | | | | | | ● | ● | ● | ● |
| ឥរិយាបថ និងការយល់ឃើញ | | | | | | | | | | | | | | |
| សកម្មភាពនៅតាមតំបន់ឆ្នេរ | | | | | | | ● | | | ● | ● | ● | | |
| អភិបាលកិច្ច | | | | | | | | | | | | | | |
| **ការវាយតំលៃអំពីរបៀបគប់គ្រងរបស់ស្ថាប័ន** | | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រសិទ្ធភាពនៃការគ្រប់គ្រង | | | | | | | | | | ● | ● | ● | | |
| **ការកសាងការចូលរួមរបស់អ្នកពាក់ព័ន្ធ និង កម្មវិធីអប់រំ និងលើកកំពស់ការយល់ដឹង ត្រឹមត្រូវ** | | | | | | | | | | | | | | |
| ការចូលរួមរបស់អ្នកពាក់ព័ន្ធ | ● | ● | ● | ● | ● | ● | ● | | | | | ● | | |
| កម្មវិធីលើកកំពស់ការយល់ដឹង | | | | | | | | | | ● | ● | ● | | |
| **ការផ្ទៀងផ្ទាត់ និងការរៀបចំឯកសារស្ដីពីសេចក្ដីសន្និដ្ឋាន លក្ខខណ្ឌសេដ្ឋកិច្ចសង្គមក្នុងតំបន់ កំលាំងសហគមន៍ និងការយល់ឃើញរបស់ក្រុមអ្នកចូលរួម** | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |
| **ការបង្កើតប្រវត្តិគោលរបស់សហគមន៍ និងគ្រួសារ** | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |

**តារាងទី ៤.៣ គោលបំណងនៃសូចនាករតាមជាន់ផ្នែកសេដ្ឋកិច្ចសង្គម និងសូចនាករពាក់ព័ន្ធ (ត)**

កំណើនមនុស្សទទួលផ្សារ និងកំណើនមនុស្សប្រើប្រាស់

ការយល់ឃើញអំពីស្ថានភាពធនធាន

សម្ភារៈ និងជីវភាពរស់នៅ

ការយល់ឃើញអំពីការកំណត់ទីតាំង

ការអនុវត្តវិធានច្បាប់ និងបទបញ្ញត្តិ

ការគោរពតាម

ការអនុវត្តន៍

ការចូលរួមនៅក្នុងការធ្វើសេចក្តីសំរេច

សមាជិកភាពនៅក្នុងស្ថាប័នពាក់ព័ន្ធ

ការយល់ឃើញអំពីបញ្ហានៃការគ្រប់គ្រងតំបន់ឆ្នេរ

ដំណោះស្រាយក្នុងការគ្រប់គ្រងតំបន់ឆ្នេរកើតមាន

បញ្ហាដែលយល់ថាកើតមានចំពោះសហគមន៍

ដំណើរការក្នុងការគ្រប់គ្រងតំបន់ឆ្នេរ

បញ្ហាប្រឈមក្នុងការគ្រប់គ្រងតំបន់ឆ្នេរ

| សូចនាករបទសម្ភាសន៍តាមគ្រួសារ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| *ឥរិយាបថ និងការយល់ឃើញ* | | | | | | | | | | | | | សម្ភារៈ និងជីវភាពរស់នៅ |
| H15 | H16 | H17 | H18 | H19 | H20 | H21 | H22 | H23 | H24 | H25 | H26 | H27 | H28 |
| | | | | | | | | | | | | | |
| | ● | ● | | | | | | | | | | | |
| | | | | ● | ● | | | ● | ● | ● | | | |
| | | | | | | | | | ● | | ● | ● | |
| | | | | | | | | | | | | | |
| ● | | | | | | ● | ● | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | ● |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ● | ● | ● | ● | ● | ● | | | ● | ● | ● | ● | ● | |
| | | ● | | | | | | | | | | | |
| | | | | | ● | | | | | | | | |
| | | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | ● | ● | |
| | | | | | | | | | | | | | |
| | | ● | ● | ● | | ● | ● | | | | ● | ● | |
| ● | ● | ● | ● | | | | | | | | | | |
| ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |
| ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● | ● |

## ៤.២ តើសូចនាករមួយណាដែលខ្ញុំត្រូវប្រើ?

ប្រសិនបើមិនអាចសូចនាករទាំងអស់នៅក្នុង *SocMon* នោះមានការណែនាំថា ក្រុមតាមដានគួរកំណត់អាទិភាពរបស់សូចនាករដោយ ផ្អែកទៅតាមលក្ខខណ្ឌដូចតទៅ :

### ៤.២.១ គោលបំណងនៃព័ត៌មានសេដ្ឋកិច្ចសង្គម

សំខាន់បំផុត ក្រុមតាមដានត្រូវបញ្ជាក់យ៉ាងច្បាស់ថា ហេតុអ្វីត្រូវប្រមូលទិន្នន័យ និងជាពិសេសថាតើវានឹងត្រូវ ប្រើប្រាស់របៀបណានៅពេលប្រមូលបាន។ ឧទាហរណ៍ ប្រសិនបើក្រុមតាមដានមានការព្រួយបារម្ភខ្លាំងបំផុតអំពីការកំណត់អត្តសញ្ញាណនៃការគំរាមកំហែង នោះក្រុមអាចផ្តោតទៅលើសូចនាករដែលមានរាយសំរាប់ការកំណត់អត្តសញ្ញាណនៃការគំរាមកំហែង។ *ផ្នែកទី ២* ពិភាក្សាអំពីគោលបំណងផ្សេងៗនៃការប្រមូលព័ត៌មានផ្នែកសេដ្ឋកិច្ចសង្គម។ សូចនាករដែលត្រូវបានកំណត់អាទិភាពសំរាប់ការប្រមូលទិន្នន័យក្នុង *SocMon* ត្រូវបានជ្រើសរើស ពីព្រោះពួកវាឆ្លើយតបទៅនឹងគោលបំណងទាំងនេះ។ *តារាងទី ៤.៣* ត្រូវបានបញ្ជាក់ជូនថាតើសូចនាករមួយណា ទាក់ទិននឹងគោលបំណងមួយណា ដូច្នេះក្រុមតាមដានអាចកំណត់អត្តសញ្ញាណយ៉ាងងាយស្រួលថាតើសូចនាករមួយណា ទាក់ទិននឹងគំរូវការរបស់ខ្លួន។ ការពិភាក្សាអំពីរបៀបដែលអាចប្រើប្រាស់សូចនាករ ដើម្បីស្វែងយល់គោលបំណងទាំងនេះនីមួយៗ ត្រូវបានបង្ហាញនៅក្នុងផ្នែក*របៀបដែលអ្នកគ្រប់គ្រងអាចប្រើប្រាស់ព័ត៌មាននេះ* នៃសូចនាករនីមួយៗនៅក្នុង*ឧបសម្ព័ន្ធ "ក"*។

### ៤.២.២ សារៈសំខាន់ជាទូទៅក្នុងការប្រមូលទិន្នន័យ

ក្នុងករណីខ្លះ គោលបំណងនៃ ការតាមដានផ្នែកសេដ្ឋកិច្ចសង្គម អាចមិនមានលក្ខណៈច្បាស់លាស់ ហើយពេលវេលា និងធនធានដែលមានមិនអាចផ្តល់លទ្ធភាពឱ្យក្រុមតាមដានធ្វើការវាយតំលៃលើសូចនាករទាំងអស់បាន។ ក្នុងស្ថានភាពទាំងនេះ សូចនាករត្រូវបានចាត់ប្រភេទ អនុលោមទៅតាមអ្វីដែលត្រូវបានពិចារណាជាទូទៅថាជាសូចនាករសំខាន់បំផុតដែលត្រូវប្រមូល (សារៈសំខាន់ខ្ពស់) និងសំខាន់បំផុតទីពីរដែលត្រូវប្រមូល (សារៈសំខាន់ជាមធ្យម) (សូមអាន *តារាងទី ៤.១ និង ៤.២*)។ សូចនាករដែលមានសារៈសំខាន់ខ្ពស់ត្រូវបានជ្រើសរើស ផ្អែកទៅតាម ១) ភាពមានប្រយោជន៍ចំពោះការគ្រប់គ្រង (ភាពញឹកញាប់ក្នុង *តារាងទី ៤.៣*) ២) ភាពងាយស្រួលក្នុងការប្រមូលទិន្នន័យ និង ៣) ឱកាសក្នុងការផ្តល់ព័ត៌មានថ្មីៗ។ ដោយសារការសម្ភាសន៍តាមគ្រួសារ ត្រូវចំណាយពេលច្រើនជាងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំ មានតែសូចនាករទាក់ទិននឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំប៉ុណ្ណោះ ត្រូវបានពិចារណាសំរាប់កំរិតនៃសារៈសំខាន់ខ្ពស់ក្នុងការការប្រមូលទិន្នន័យ។

### ៤.២.៣ ទីតាំង - ស្ថានភាពជាក់លាក់

ប្រហែលជាសំខាន់បំផុត ក្រុមតាមដានត្រូវជ្រើសរើសសូចនាករ ដោយផ្អែកទៅតាមបញ្ហាសំខាន់ក្នុងមូលដ្ឋាននៃតំបន់សិក្សា។ ឧទាហរណ៍ ប្រសិនបើការគ្រប់គ្រងកាកសំណល់គឺជាបញ្ហាសំខាន់ៗ នោះក្រុមតាមដានអាចត្រូវកំណត់អាទិភាពនៃហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងបន្ថែមសំណួរកាន់តែច្រើន ដែលមានលក្ខណៈជាក់លាក់ទាក់ទិនទៅនឹងទំលាប់បោះចោលកាកសំណល់។

ក្រុមតាមដានក៏ចាំបាច់ត្រូវពិចារណាអំពីបំរែបំរួលនាពេលអនាគតដែលបានរំពឹងទុកក្នុងការគ្រប់គ្រង និងក្នុងសហគមន៍ផងដែរ។ ឧទាហរណ៍ ប្រសិនបើវិស័យទេសចរណ៍កំពុងកើនឡើង នោះក្រុមតាមដានអាចត្រូវបន្ថែមសំណួរកាន់តែច្រើនទាក់ទិន ទៅនឹងវិស័យទេសចរណ៍ និងផលប៉ះពាល់របស់វិស័យនោះ។

## ផ្នែកទី ៥ : តើខ្ញុំត្រូវធ្វើអ្វីជាមួយនឹងទិន្នន័យទាំងនេះ

### ៥.១ ការវិភាគ

*ចំណេះដឹងជាគន្លឹះសំដៅលើបញ្ហាដែលបានកំណត់ ឬមេរៀនដែលបានសិក្សា ដោយក្រុមតាមដាន ដែលមានសារៈសំខាន់ចំពោះគោលបំណងនៃការតាមដាន ឬដែលចាំបាច់សំរាប់ការស្វែងយល់អំពីបរិបទសេដ្ឋកិច្ចសង្គមរបស់អ្នកពាក់ព័ន្ធ។* សូមអានសៀវភៅណែនាំ GCRMN ជំពូកទី ៤ : ការវិភាគទិន្នន័យចុងក្រោយ *សំរាប់ព័ត៌មានបន្ថែមស្តីពីចំណេះដឹងជាគន្លឹះ និងគោលការណ៍មូលដ្ឋានសំរាប់ការវិភាគ។*

ការវិភាគទិន្នន័យ ជាធម្មតា ត្រូវបានអនុវត្តជាក្រុម។ នៅក្នុងការប្រមូលទិន្នន័យទាំងមូល ក្រុមតាមដានត្រូវជួបប្រជុំគ្នាជាច្រើនដងដើម្បីពិនិត្យ និងធ្វើសុពលកម្មលើទិន្នន័យ ពិភាក្សា និងកែសំរួលចំណេះដឹងសំខាន់ៗ បកស្រាយលទ្ធផល ធ្វើសុពលកម្មចំណេះដឹងសំខាន់ៗ និងរៀបចំផែនការផ្សព្វផ្សាយលទ្ធផល។ ជាលទ្ធផល ការវិភាគទិន្នន័យភាគច្រើន ជាពិសេស ចំពោះទិន្នន័យបែបគុណភាព ត្រូវបានបញ្ចប់ក្នុងពេលប្រមូលទិន្នន័យដល់កន្លែង។ ការវិភាគចុងក្រោយ នៅពេលបញ្ចប់ការប្រមូលទិន្នន័យ គឺត្រូវពិនិត្យ និងសំរេចបញ្ចប់ការវិភាគដល់កន្លែង។

មានជំហានសំខាន់ៗជាច្រើនដែលក្រុមតាមដានត្រូវអនុវត្តរួមគ្នា សំរាប់ការវិភាគទិន្នន័យ :

**១. រៀបចំចងក្រងទិន្នន័យទាំងអស់** ដោយប្រមូលផ្តុំប្រភពបន្ទាប់បន្សំពេញលេញទាំងអស់ និងមគ្គុទេសក៏ស្តីពីកិច្ចសម្ភាសន៏អ្នកផ្តល់ព័តិមានសំខាន់ៗ និងមគ្គុទេសក៏ស្តីពីបទសម្ភាសន៏តាមគ្រួសារ ( *ឧបសម្ព័ន្ធ "ខ" និង "គ"* ) ។

**២. រៀបចំទិន្នន័យ** ដោយបញ្ចូនប្រភពបន្ទាប់បន្សំដែលបានប្រមូលពីបទសម្ភាសន៏អ្នកផ្តល់ព័តិមានសំខាន់ៗ និងទិន្នន័យបទសម្ភាសន៏តាមគ្រួសារទៅក្នុងសន្លឹកវិភាគព័តិមាន *( ឧបសម្ព័ន្ធ "ឃ" និង "ង" )* ។

**៣. បកស្រាយទិន្នន័យ** ដោយពិនិត្យលទ្ធផលដែលទទួលបានពីសន្លឹកវិភាគព័តិមាន ដើម្បីកំណត់ និងរៀបចំព័តិមាន ដែលទាក់ទិនទៅនឹងគោលបំណងដែលបានកំណត់ពីដំបូងនៃការតាមដានផ្នែកសេដ្ឋកិច្ចសង្គម ( សូមអានផ្នែកទី *២*)។ ក្រុមតាមដានត្រូវជ្រើសរើសទិន្នន័យទាក់ទិនទៅនឹងគោលបំណងនៃការពិនិត្យតាមដាន ( សូមអានតារាងទី *៤.៣* ក្នុងផ្នែកទី*៤* ដើម្បីកំណត់ថាតើទិន្នន័យសូចនាករមានប្រយោជន៏សំរាប់ការវិភាគគោលបំណងមួយណា) ។ បន្ទាប់មក ទិន្នន័យទាំងនេះចាំបាច់ត្រូវមានការពិនិត្យឡើងវិញ ភ្ជាប់ទំនាក់ទំនង និងប្រៀបធៀបដើម្បីកំណត់លំនាំ និងនិន្នាការដែលលេចឡើង។ លំនាំ និងនិន្នាការទាំងនេះក្លាយទៅជាចំណេះដឹងជាគន្លឹះ។ បន្ទាប់មក លទ្ធផលត្រូវបានរៀបចំចងក្រង ដើម្បីកំណត់នូវទិន្នន័យដែលគាំទ្រដល់ចំណេះដឹងជាគន្លឹះ។ ឧទាហរណ៏ ប្រសិនបើគោលបំណងនៃ ការពិនិត្យតាមដាន គឺដើម្បីកំណត់អំពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនៃបទបញ្ញត្តិមិនមែនផ្នែកនេសាទនោះ សូចនាករពីរក្នុងចំណោមសូចនាករស្តីពីផលប្រយោជន៏ គឺ*មុខរបរ (k12) និងសកម្មភាព (k14)* ។ សំរាប់ការវិភាគ អាចមាននិន្នាការនៃបំរែបំរួលក្នុងមុខរបរ និងសកម្មភាពដោយប្រជាជនធ្វើការផ្លាស់ប្តូរពីមុខរបរនេសាទទៅមុខរបរ និងសកម្មភាពផ្សេងទៀត។ ប្រសិនបើមានការផ្លាស់ប្តូរពីមុខរបរ

នៃសាទនោះ ចំណេះដឹងជាគន្លឹះអាចថា បទបញ្ញត្តិមានផលប៉ះពាល់លើសកម្មភាពនេសាទ ដូចបានបង្ហាញដោយការផ្លាស់ប្តូរពីមុខរបរនេសាទរបស់ប្រជាជន។ លទ្ធផលស្តីពីមុខរបរ និងសកម្មភាព នឹងគាំទ្រដល់ចំណេះដឹងជាគន្លឹះនេះ។ តាមរយៈការពិនិត្យឡើងវិញ ភ្ជាប់ទំនាក់ទំនង និងប្រៀបធៀបផ្នែកទិន្នន័យផ្សេងៗគ្នាទាំងនេះ យើងអាចកំណត់អំពីការប្រែប្រួលនៅក្នុងសូចនាករនីមួយៗបាន។ សំរាប់សូចនាករនីមួយៗ មានការពិភាក្សាអំពីរបៀបវិភាគ និងប្រើប្រាស់ព័ត៌មាននៅក្នុង*ផ្នែកស្តីពីរបៀបវិភាគទិន្នន័យ* និង *សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង* ក្នុង*ឧបសម្ព័ន្ធ "ក"*។

**៤. យល់ព្រមចំពោះចំណេះដឹងជាគន្លឹះ** តាមរយៈការឯកភាពទៅលើចំណេះដឹងជាគន្លឹះមានសារៈសំខាន់បំផុតដែលត្រូវបានបញ្ជាក់ជូន និងតាមរយៈការជ្រើសរើសនូវព័ត៌មានដែលគាំទ្រ ដល់ចំណេះដឹងជាគន្លឹះទាំងនេះ។

**៥. ធ្វើសុពលកម្មលើលទ្ធផល** តាមរយៈការពិភាក្សាអំពីចំណេះដឹងជាគន្លឹះជាមួយនឹងអ្នកពាក់ព័ន្ធ ដើម្បីជាផ្នែកមួយនៃការផ្សព្វផ្សាយ ដូចមានពិភាក្សាខាងក្រោម។ រាល់ភាពខុសគ្នាដែលគួរឱ្យកត់សំគាល់គួរត្រូវបានពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងប្រភពព័ត៌មានដើម។

## ៥.២ ការផ្សព្វផ្សាយ

ចំណុចដែលមានសារៈសំខាន់បំផុតក្នុងដំណើរតាមដានទាំងមូលគឺ ត្រូវផ្សព្វផ្សាយអំពីលទ្ធផលដែលទាក់ទិនទៅនឹងគោលបំណងត្រឡប់ជូនទៅក្រុមគោលដៅវិញ។ ទាំងនេះរួមមានការពិភាក្សាអំពីលទ្ធផលជាមួយនឹងក្រុមគោលដៅ ការស្វែងរកមតិត្រឡប់ និងការធ្វើសុពលកម្ម ព្រមទាំងការស្វែងរកសេចក្តីសំរេច និងសកម្មភាពត្រឹមត្រូវ ដើម្បីប្រើប្រាស់លទ្ធផលទាំងនេះ។ ដំណើរការផ្សព្វផ្សាយនេះមានសារៈសំខាន់ខ្លាំងណាស់ចំពោះការសំរបសំរួលដល់ផ្នែកគ្រប់គ្រងតំបន់ឆ្នេរ ដែលត្រូវប្រើប្រាស់ពតិមានទាំងនេះ ដើម្បីកែលំអរបៀបគ្រប់គ្រងដែលត្រូវអនុវត្តនាពេលអនាគត។ ឧទាហរណ៍ ប្រសិនបើគោលបំណងនៃការតាមដានផ្នែកសេដ្ឋកិច្ចសង្គមគឺធ្វើឡើង ដើម្បីយល់អំពីតំលៃ និងសារៈសំខាន់របស់ផ្កាថ្ម នោះលទ្ធផលទាក់ទិននឹងការយល់ឃើញរបស់ប្រជាជនស្តីពីតំលៃមិនមែនទីផ្សារ និងតំលៃមិនមែនប្រើប្រាស់អាចត្រូវបានប្រើប្រាស់ដើម្បីយល់អំពីតំលៃ និងសារៈសំខាន់។ ប្រសិនបើលទ្ធផលបង្ហាញថាប្រជាជនកាន់តែច្រើនឡើងៗមានការយល់ឃើញជាវិជ្ជមានអំពីតំលៃនៃការការពារផ្កាថ្ម នោះនេះជាការបង្ហាញឱ្យឃើញអំពីតំលៃខ្ពស់របស់ផ្កាថ្ម។ ដូច្នេះ ព័ត៌មាននេះអាចត្រូវបានប្រើប្រាស់ដោយអ្នកគ្រប់គ្រង ដើម្បីបង្ហាញដល់សាធារណជន និងដល់អ្នករៀបចំគោលនយោបាយអំពីសារៈសំខាន់ក្នុងការចូលរួមធនធានដើម្បីការពារផ្កាថ្ម។

ដូចបានពិភាក្សានៅក្នុង*ផ្នែកទី ៣.៩* ក្រុមគោលដៅអាចមានចាប់ពីអ្នកពាក់ព័ន្ធ ទៅសមាជិកសហគមន៍ និងទៅដល់អ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រងធនធានតាមតំបន់ឆ្នេរ។ ផ្អែកតាមគោលគំនិតផ្នែកសីលធម៌ មានការណែនាំយ៉ាងខ្លាំងថា ត្រូវមានការរាយការត្រឡប់អំពីលទ្ធផលនៃការតាមដានផ្នែកសេដ្ឋកិច្ចសង្គមទៅកាន់សហគមន៍វិញ សូម្បីតែពួកគេមិនមែនជាក្រុមគោលដៅក៏ដោយ។ ការនេះត្រូវបានអនុវត្ត ដើម្បីជាការគួរសមដល់សមាជិកសហគមន៍ដែលបាន

ចំណាយពេលវេលារបស់ពួកគេសំរាប់កិច្ចសម្ភាសន៍។ ការធ្វើបែបនេះក៏ជួយធានានូវទំនាក់ទំនងល្អសំរាប់ការងារនាពេលអនាគតជាមួយនឹងសហគមន៍ផងដែរ។ ការខ្ជើយណាយក្នុងការចូលរួមក្នុងកិច្ចសម្ភាសន៍គឺជាបញ្ហាធ្ងន់ធ្ងរមួយនៅក្នុងកិច្ចប្រឹងប្រែងតាមដានផ្នែកសេដ្ឋកិច្ចសង្គមនានា ហើយកាលណាមានប្រជាជនកាន់តែច្រើនឡើងបានចូលរួមក្នុងដំណើរការនេះ និងបានទទួលលទ្ធផល នោះពួកគេកាន់តែពេញចិត្តចូលរួមនៅក្នុងសកម្មភាពពិនិត្យតាមដាននៅពេលក្រោយៗទៀត។ ដូច្នេះ វាមានសារៈសំខាន់ ណាស់ដែលត្រូវពិភាក្សាជាមួយនឹងសមាជិកសហគមន៍អំពីរបៀបប្រើប្រាស់លទ្ធផល និងរបៀបដែលវានឹងប៉ះពាល់ដល់ការគ្រប់គ្រង។

នៅពេលធ្វើការកំណត់លទ្ធផលមួយណាត្រូវសង្កត់ធ្ងន់ និងចែករំលែកជាមួយនឹងក្រុមគោលដៅនោះ ក្រុមតាមដានចាំបាច់ត្រូវពិចារណាអំពីអ្វីដែលខ្លួនរំពឹងថាក្រុមគោលដៅនីមួយៗ នឹងអនុវត្តជាមួយនឹងលទ្ធផលដែលបានបង្ហាញដល់ពួកគេដោយរាប់បញ្ចូលសកម្មភាពដែលខ្លួនរំពឹងថាពួកគេនឹងអនុវត្តផងដែរ។ វាក៏ជាការចាំបាច់ផងដែរ ដែលត្រូវពិចារណាអំពីផ្នែកសំខាន់ៗនៃព័ត៌មានដែលក្រុមគោលដៅនីមួយៗនឹងស្វែងរកចេញពីលទ្ធផលទាំងនេះ។

លទ្ធផលនៃការតាមដានផ្នែកសេដ្ឋកិច្ចសង្គម អាចត្រូវបានផ្សព្វផ្សាយដល់ក្រុមគោលដៅផ្សេងៗ តាមរយៈយន្តការទំនាក់ទំនងឯកទិស និងទ្វេទិស។ យន្តការទំនាក់ទំនងឯកទិសរួមមាន :

- ឯកសារជាលាយលក្ខណ៍អក្សរ (របាយការណ៍ ឯកសារ)
- សំភារៈទស្សនា (បដារ រូបភាព)
- បទបង្ហាញដោយផ្ទាល់មាត់
- ប្រព័ន្ធផ្សព្វផ្សាយមហាជន (សារព័ត៌មាន ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍)
- វិបសាយ

យន្តការទំនាក់ទំនងទ្វេទិសរួមមាន :

- កិច្ចពិភាក្សាជាក្រុម
- កិច្ចពិភាក្សាមួយនឹងមួយ
- ក្តារផ្សព្វផ្សាយជារូបសាស្ត្រ និងអេឡិចត្រូនិច
- ការផ្សព្វផ្សាយទៅទីឆ្ងាយ (ទូរស័ព្ទ ទូរស័ព្ទវីដេអូ កាម៉ារ៉ាអ៊ីនធើណិត)
- អ៊ីម៉ែល

យន្តការទំនាក់ទំនងទ្វេទិសមានផលប្រយោជន៍ក្នុងការអូសទាញក្រុមគោលដៅទៅក្នុងដំណើរការពិនិត្យតាមដាន ដោយអនុញ្ញាតឱ្យពួកគេផ្តល់មតិត្រឡប់ស្តីពីលទ្ធផល។ ប្រសិនបើពួកគេមានយន្តការសំរាប់ការចូលរួម នោះពួកគេកាន់តែពេញចិត្តក្នុងការគាំទ្រ និងអនុវត្តសកម្មភាពទាក់ទិនទៅនឹងលទ្ធផល។

នៅពេលសំរេចថាតើត្រូវប្រើយន្តការមួយណានោះ ក្រុមតាមដានគួរពិចារណានូវសំណួរដូចខាងក្រោម :

- តើវិធីសាស្ត្រអ្វីដែលពួកគេពេញចិត្តសំរាប់ការទទួលព័តិមាន? នេះអាចទាក់ទងយ៉ាងជិតស្និតទៅនឹងកំរិតវប្បធម៌ និងសមត្ថភាពបច្ចេកវិទ្យារបស់ពួកគេ។ អត្រាអក្ខរកម្មគឺ មានសារៈសំខាន់ក្នុងការពិចារណាក៏ដូចជា ថាតើពួកគេចូលចិត្តអាចព័តិមាន ស្តាប់វិទ្យុ ឬទស្សនាទូរទស្សន៍។ តើពួកគេចេះកុំព្យូទ័រដែរឬទេ? តើពួកគេ ប្រើប្រាស់អ៊ីនធើណិតទៀងទាត់ដែរឬទេ? តើពួកគេមានការបើកអង្គប្រជុំ ឬសន្និសីទទៀងទាត់ឬទេ? ប្រសិនបើដូច្នេះ តើនៅពេលណា?
- តើពួកគេចូលចិត្តការផ្សព្វផ្សាយជាលក្ខណៈបច្ចេកទេស និងសិក្សាស្រាវជ្រាវ ជាងប្រភេទសាមញ្ញធម្មតាឬយ៉ាងណា? តើទំនាក់ទំនងផ្ទាល់មាត់ ជាធម្មតា ធ្វើឡើងនៅកន្លែងណា និងតាមរបៀបណា? តើត្រូវថប្រើប្រាស់ ភាសាអ្វី?

ប្រសិនបើលទ្ធផលនឹងត្រូវបានផ្សព្វផ្សាយក្នុងទំរង់ជាលាយលក្ខណ៍អក្សរនោះ របាយការណ៍ត្រូវបានផ្តល់ជូនសំរាប់ក្រុមគោលដៅ។ របាយការណអាចមានទំរង់ជាច្រើនបែប អាស្រ័យទៅតាមក្រុមគោលដៅនៃរបាយការណ៍។ អ្នកប្រើប្រាស់ចុងក្រោយមួយចំនួន ដូចជា អ្នករៀបចំគោលនយោបាយ ឬអ្នកធ្វើសេចក្តីសំរេចជាន់ខ្ពស់អាចមានចំណាប់អារម្មណ៍តិចតួចទៅលើការអធិប្បាយទូទៅស្តីពីតំបន់ និងសហគមន៍បានសិក្សា ប៉ុន្តែអាចចាប់អារម្មណ៍លើបញ្ហា ការលំបាក និងដំណោះស្រាយដែលអាចមាន។ អ្នកប្រើប្រាស់ចុងក្រោយផ្សេងទៀត ដូចជា អ្នកស្រាវជ្រាវ ទីភ្នាក់ងារអភិវឌ្ឍន៍ដែលមានផែនការអនុវត្តការងារនៅក្នុងតំបន់ និងអ្នកគ្រប់គ្រងធនធានតាមតំបន់ឆ្នេរ អាចត្រូវការនូវសេចក្តីអធិប្បាយលំអិតអំពីស្ថានភាពសេដ្ឋកិច្ចសង្គម និងកត្តាគ្រប់យ៉ាងដែលទាក់ទិនទៅនឹងអ្នកពាក់ព័ន្ធនឹងធនធានតាមតំបន់ឆ្នេរ។

ជាធម្មតា របាយការណ៍ត្រូវមាន :

**សេចក្តីសង្ខេបប្រតិបត្តិ** - ការពិភាក្សាសង្ខេបអំពីបញ្ហា ការលំបាក ឱកាស និងដំណោះស្រាយដែលបានកំណត់នៅក្នុងដំណើរការតាមដាន។

**សេចក្តីផ្តើម** - ការពិភាក្សាអំពីគោលបំណងសំខាន់ៗ និងជាក់លាក់នៃការតាមដានផ្នែកសេដ្ឋកិច្ចសង្គម (ដែលទាក់ទិនទៅនឹងការប្រើប្រាស់ផ្សេងៗគ្នានូវព័តិមានផ្នែកសេដ្ឋកិច្ចសង្គមដែលបានបង្ហាញខាងលើ) ព្រមទាំងប្រវត្តិមួយចំនួនស្តីពីលក្ខណៈជីវសាស្ត្រ រូបសាស្ត្រ សង្គម សេដ្ឋកិច្ច និងនយោបាយនៃតំបន់។

**វិធីសាស្ត្រ** - ការពិភាក្សាស្តីពីវិធីសាស្ត្រប្រមូលគំរូ វិធីសាស្ត្រប្រមូលទិន្នន័យ និងវិធីសាស្ត្រវិភាគទិន្នន័យបែបគុណភាព និងបរិមាណដែលបានប្រើប្រាស់។

**លទ្ធផល** - បទបង្ហាញអំពីលទ្ធផលសំខាន់ៗដែលទទួលបានពីកិច្ចប្រឹងប្រែងតាមដាន ដោយរាប់បញ្ចូលតារាងដ្យាក្រាម ការទាក់ទងទៅវិញទៅមករវាងសូចនាករ និងការពិភាក្សាលំអិត។ លទ្ធផលជាក់លាក់ដែលអាចត្រូវបានបង្ហាញ សំរាប់ធាតុនីមួយៗត្រូវបានកត់ចំណាំក្នុងផ្នែកវិភាគសំរាប់ធាតុនីមួយៗនៅក្នុង *ឧបសម្ព័ន្ធ "ក"* និងក្នុង *សន្លឹកវិភាគព័តិមាន* ក្នុង *ឧបសម្ព័ន្ធ "ឃ" និង "ង"* ។

**ការពិភាក្សា** - ការពិភាក្សាស្តីពីចំណេះដឹងជាគន្លឹះ និងទំនាក់ទំនងដែលទទួលបានពីលទ្ធផលដែលបានរៀបចំជុំវិញ គោលបំណងនៃការតាមដានដែលបានកំណត់ពីដំបូង។

**អនុសាសន៍** - សកម្មភាពគ្រប់គ្រង និងដំណោះស្រាយជាសក្តានុពលដែលបានណែនាំសំរាប់អនុវត្ត ដែលជាលទ្ធផលនៃការតាមដាន។

# ឧបសម្ព័ន្ធ "ក" : សូចនាករ

*ផ្នែកទី ៤* បានផ្តល់នូវបញ្ជីសង្ខេបស្តីពីសូចនាករ SocMon។ ឧបសម្ព័ន្ធនេះពិពណ៌នាអំពីសូចនាករនីមួយៗ ដែលរួមមាន :

*ឧបសម្ព័ន្ធនេះពិពណ៌នាអំពីកំរងពេញលេញនៃសូចនាករដែលអាចត្រូវបានតាមដាន។* ចេញពីកំរងនេះ *ក្រុមតាមដានចាំបាច់ត្រូវជ្រើសរើសសូចនាករត្រឹមត្រូវសំរាប់គោលបំណង និងស្ថានភាពទីតាំងរបស់វា ដូចបានពិភាក្សានៅក្នុង* ផ្នែក ទី ៤។

**ការកំណត់និយមន័យ** – ការអធិប្បាយអំពីសូចនាករ។

**វិធីសាស្ត្រប្រមូលទិន្នន័យ** – ការអធិប្បាយអំពី វិធីសាស្ត្រប្រមូលទិន្នន័យ (ឧ. ប្រភេទអ្នកផ្តល់ព័ត៌មានសំខាន់ៗ ប្រភពនៃទិន្នន័យបន្ទាប់បន្សំ) និងសំណួរសំរាប់ប្រើក្នុងបទសម្ភាសន៍ពាក់ព័ន្ធ ដែលទាំងអស់នេះត្រូវបានរៀបចំចងក្រងនៅក្នុង*ឧបសម្ព័ន្ធ "ខ"* និង*ឧបសម្ព័ន្ធ "គ"*។ ក្នុងករណីខ្លះផ្នែកស្តីពី*ការប្រមូលទិន្នន័យបន្ថែម* ត្រូវបានផ្តល់ដោយណែនាំនូវព័ត៌មានបន្ថែមដែលអាចមានប្រយោជន៍ត្រូវប្រមូល។

**វិធីសាស្ត្រវិភាគទិន្នន័យ** – ការពន្យល់អំពីអ្វីដែលត្រូវអនុវត្តជាមួយនឹងទិន្នន័យ ដោយរាប់បញ្ចូលទាំងការប្រៀបធៀប ដែលត្រូវធ្វើឡើងជាមួយនឹងទិន្នន័យផ្សេងទៀត និងតារាង ឬអត្ថបទអធិប្បាយត្រូវរៀបចំ ដែលត្រូវបានរៀបចំចងក្រងក្នុង*ឧបសម្ព័ន្ធ "ឃ"* និង*ឧបសម្ព័ន្ធ "ង"*។ នៅក្នុងសូចនាករភាគច្រើន ផ្នែកស្តីពី*ការវិភាគបន្ថែម* ត្រូវបានផ្តល់ជូនដោយធ្វើការបញ្ជាក់ជូននូវការវិភាគដែលអាចត្រូវធ្វើឡើង លើសពីអ្វីដែលត្រូវបានបញ្ចូលក្នុង*ឧបសម្ព័ន្ធ "ឃ" និង "ង"*នៃសន្លឹកវិភាគព័ត៌មាន។

ឧបសម្ព័ន្ធ "ខ" *និង* ឧបសម្ព័ន្ធ "គ" *បញ្ចូលនូវសំណួរដែលបាន*បញ្ជាក់ជូន*សំរាប់សូចនាករនីមួយៗនៅក្នុងផ្នែកខាងក្រោម។* ឧបសម្ព័ន្ធ "ឃ" *និង* ឧបសម្ព័ន្ធ "ង" *បញ្ចូលនូវតារាងវិភាគទិន្នន័យសំរាប់ការគណនាដែលបានពិពណ៌នាក្នុងផ្នែកខាងក្រោម។*

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង** – ការពិភាក្សាអំពីរបៀបដែលព័ត៌មានអាចមានប្រយោជន៍ ទាក់ទិនត្រឡប់ទៅគោលបំណងដែលបានបញ្ជាក់ជូននៅក្នុងផ្នែកមុនគឺ*ផ្នែកទី ២*។

សូចនាករត្រូវបានបង្ហាញនៅក្នុងផ្នែកចំនួនពីរដោយអនុលោមទៅតាមមធ្យោបាយក្នុងការប្រមូលទិន្នន័យរបស់វា : ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងបទសម្ភាសន៍តាមគ្រួសារ។ នៅក្នុងផ្នែកនីមួយៗ សូចនាករ (ឧ. អាយុ ភេទ ការអប់រំ អក្ខរកម្ម សាសនា ជនជាតិ) ត្រូវបានបង្ហាញជាក្រុម ពីព្រោះពួកវាមានអត្ថន័យ មធ្យោបាយប្រមូល វិភាគ និង/ឬការប្រើប្រាស់ទិន្នន័យ ជាប់ទាក់ទងគ្នាជិតស្និទ។ សូមយោងទៅ*តារាងទី ៤.១* និង *៤.២* ក្នុង*ផ្នែកទី ៤* សំរាប់បញ្ជីស្តីពីសូចនាករទាំងអស់។

## ប្រជាសាស្ត្រនៅថ្នាក់សហគមន៍

### *KS1. តំបន់សិក្សា*

**ការកំណត់និយមន័យ**

តំបន់សិក្សាសំដៅលើទីតាំងនៃធនធានតាមតំបន់ឆ្នេរ និងសមុទ្រ និងអ្នកពាក់ព័ន្ធ ដែលកំពុងអនុវត្តការសិក្សា។ ព្រំប្រទល់នៃតំបន់សិក្សាត្រូវបានកំណត់ដោយទីតាំងជារូបសាស្ត្រនៃធនធាន និងដោយទីកន្លែងដែលអ្នកពាក់ព័ន្ធរស់នៅ និងធ្វើការ។ ដូច្នេះហើយ ជារឿយៗ តំបន់សិក្សាត្រូវក្តោបទាំងតំបន់ឆ្នេរ និងតំបន់ស្តុកទឹកនៅក្បែរនោះ។ អ្នកពាក់ព័ន្ធ អាចមានភាពចល័តខ្លាំង និងសាយភាយទូលំទូលាយជាងត្រឹមតំបន់ ដែលត្រូវបានគ្រប់គ្រងទៅទៀត។ អាចមានសហគមន៍មួយ ឬច្រើន នៅក្នុងតំបន់សិក្សាដែលបានកំណត់ ដែលរួមបញ្ចូលនូវអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។ សូមអាន*សៀវភៅណែនាំ GCRMN ជំពូកទី ១ : សកម្មភាពរកស៊ី កំណត់តំបន់សិក្សា និងទីតាំងសិក្សា* សំរាប់ការពិភាក្សាបន្ថែម។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ព័ត៌មានស្តីពីតំបន់សិក្សា ជាធម្មតា ទទួលពីផែនទីស្តីពីតំបន់ និងពីកិច្ចពិភាក្សាជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជាប្រធានភូមិ ឬចៅហ្វាយក្រុង។ ដូចបានបញ្ជាក់ជូននៅក្នុង*មគ្គុទេសក៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (ឧបសម្ព័ន្ធ "ខ")* វាមានសារៈសំខាន់ណាស់ចំពោះការឆ្លើយទៅនឹងសំណួរថា : តើអ្វីជាព្រំប្រទល់តំបន់សិក្សា? តំបន់ចាំបាច់ត្រូវបានបញ្ជាក់ជូននៅលើផែនទី។

*ការប្រមូលទិន្នន័យបន្ថែម :* វាក៏អាចមានប្រយោជន៍ផងដែរក្នុងការប្រើប្រាស់និមិត្តសញ្ញា និងពណ៌ ដើម្បីកំណត់ទីតាំង និងធនធានតាមតំបន់ឆ្នេរ និងសមុទ្រដែលមានសារៈសំខាន់ ជាពិសេសនៅក្នុងសហគមន៍ (ឧ. ទីផ្សារត្រី មជ្ឈមណ្ឌលភូមិ)។

**វិធីសាស្ត្រវិភាគទិន្នន័យ**

ធ្វើសំយោគព័ត៌មានដែលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងពីផែនទីនានា ដាក់លើផែនទីតែមួយ ដែលត្រូវបាន ប្រើប្រាស់នៅក្នុងដំណើរការតាមដានទាំងមូល និងដែលត្រូវបានបង្ហាញរួមជាមួយនឹងលទ្ធផល។ ព្រំប្រទល់តំបន់សិក្សា ដោយផ្អែកទៅតាមធនធានតាមតំបន់ឆ្នេរ និងសមុទ្រ ព្រមទាំងទីតាំងអ្នកពាក់ព័ន្ធគួរត្រូវបានកំណត់នៅលើផែនទី។ ទីតាំងសំខាន់ៗក៏អាចត្រូវបានបញ្ជាក់ជូនផងដែរ។ ផែនទីចាំបាច់ត្រូវបានបញ្ចូលជាមួយនឹង*សន្លឹកវិភាគទិន្នន័យបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ (ឧបសម្ព័ន្ធ "ឃ")*។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ការកំណត់យ៉ាងច្បាស់នូវតំបន់សិក្សាគឺមានសារៈសំខាន់ចំពោះការកំណត់លំនាំនៃការប្រើប្រាស់ និងការគំរាមកំហែងដែលអាចកើតមានចំពោះធនធាន។ តាមរយៈការបញ្ជាក់អំពីតំបន់នៅលើផែនទី អ្នកគ្រប់គ្រងអាចមើលឃើញអំពីលក្ខណៈភូមិសាស្ត្រដែលបានបញ្ចូននៅក្នុងតំបន់ ដូចជាព្រំប្រទល់ដែនទឹក តំបន់កសិកម្ម និងតំបន់អភិវឌ្ឍន៍លំនៅដ្ឋាន ដែលមានដង់ស៊ីតេខ្ពស់។

ចេញពីគោលគំនិតនៃកម្មវិធីតាមដានផ្នែកសេដ្ឋកិច្ចសង្គម វាមានសារៈសំខាន់ណាស់ដែលត្រូវកំណត់តំបន់សហគមន៍ ដោយហេតុថាតំបន់សិក្សានេះគឺជាចំណុចផ្តោតលើតាមដានក្នុងរយៈពេលមួយ។ ដើម្បីអាចធ្វើការប្រៀបធៀបក្នុងរយៈពេលមួយ ក្រុមតាមដានត្រូវតែច្បាស់អំពីសហគមន៍នៅក្នុងព្រំប្រទល់នៃការសិក្សា។

## *KS2 និង KS3. ចំនួនប្រជាជន និងចំនួនគ្រួសារ*

**ការកំណត់និយមន័យ**

ចំនួនប្រជាជនគឺជាចំនួនប្រជាជនសរុប ដែលរស់នៅក្នុងតំបន់សិក្សា។ ចំនួនគ្រួសារគឺជាចំនួនលំនៅដ្ឋានមានអ្នកកាន់កាប់នៅក្នុងតំបន់សិក្សា ដោយយមិនគិតពីចំនួនគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋាននោះឡើយ។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ទិន្នន័យស្តីពីចំនួនប្រជាជន និងចំនួនគ្រួសារ ជាទូទៅ ទទួលពីស្ថិតិជំរឿនថ្នាក់ជាតិ តំបន់ និង/ឬមូលដ្ឋាន ដែលទទួលបានពីការិយាល័យជំរឿន ក្រុមប្រឹក្សាក្រុង និង/ឬបណ្ណាល័យសហគមន៍។ វាជាការសំខាន់មួយដែលត្រូវការផ្ទៀងផ្ទាត់ទិន្នន័យទាំងនេះជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា ប្រធានភូមិ ឬចៅហ្វាយក្រុង។ ដូចបានបញ្ជាក់ជូននៅក្នុង *មគ្គុទេសក៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ*

សំណួរដែលត្រូវលើកឡើងគឺ :

តើមានប្រជាជនចំនួនប៉ុន្មានរស់នៅក្នុងតំបន់សិក្សា?____________

តើមានគ្រួសារចំនួនប៉ុន្មាននៅក្នុងតំបន់សិក្សា? __________

**វិធីសាស្ត្រវិភាគទិន្នន័យ**

ធ្វើសំយោគទិន្នន័យដែលទទួលបានពីប្រភពបន្ទាប់បន្សំ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់ចំនួនប្រជាជន និងចំនួនគ្រួសារ ព្រមទាំងបញ្ជាក់អំពីពួកវានៅលើ*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ*។

*ការវិភាគបន្ថែម :* ទាញលទ្ធផលដែលទទួលបានពីឆ្នាំមុនៗ ដើម្បីគណនាបំរែបំរួលក្នុងរយៈពេលមួយ។ ប្រៀបធៀប បំរែបំរួលចំនួនប្រជាជន និងគ្រួសារ ព្រមទាំងចំនួនគ្រួសារ ក្នុងរយៈពេលមួយ ជាមួយនឹងបំរែបំរួល

ស្ថានភាពធនធាន និងទិន្នន័យដែលទទួលបានពីផ្នែកស្តីពី*កំរិត និងប្រភេទនៃផលប៉ះពាល់* (KS20 និង KS21) ដើម្បីពិនិត្យថាតើបំរែបំរួលចំនួនប្រជាជនមានទាក់ទិននឹងស្ថានភាព និងផលប៉ះពាល់ដែរឬទេ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ការយល់ដឹងអំពីកំរិតប្រជាជនក្នុងតំបន់សិក្សា និងចំនួនគ្រួសារគឺមានសារៈសំខាន់ចំពោះការស្វែងយល់អំពីការគំរាមកំហែង។ កំរិតប្រជាជនផ្តល់នូវការយល់ដឹងជាទូទៅអំពីកំរិតនៃសម្ពាធដែលមានលើធនធានធម្មជាតិ។ ចំនួនប្រជាជនកាន់តែច្រើន ជាទូទៅ បង្កើតនូវសម្ពាធកាន់តែខ្លាំងលើធនធាន។ ព័ត៌មានស្តីពីបំរែបំរួលក្នុងរយៈពេលមួយក៏អាចមានប្រយោជន៍ក្នុងការកំណត់ថាតើសម្ពាធទាំងនេះកំពុងកើនឡើង ធ្លាក់ចុះ ឬនៅដដែលផងដែរ។ ការប្រៀបធៀបជាមួយនឹងស្ថានភាពធនធាន និងកំរិតនៃការប្រើប្រាស់ជួយកំណត់ថាតើការកើនឡើងនៃចំនួនប្រជាជនកំពុងជះឥទ្ធិពលដល់ស្ថានភាពធនធានក្នុងទំហំប៉ុណ្ណាដែរ។

ទាក់ទិនទៅនឹងគោលគំនិតស្តីពីកម្មវិធីតាមដានផ្នែកសេដ្ឋកិច្ចសង្គម ចំនួនប្រជាជន និងចំនួនគ្រួសារគឺមានសារៈសំខាន់ក្នុងការការកំណត់គំរូគ្រួសារដែលត្រូវសម្ភាសន៍។ ដូច្នេះវាសារៈសំខាន់ណាស់ ដែលត្រូវប្រមូលនូវព័ត៌មាននេះចេញពីការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ មុននឹងចាប់ផ្តើមធ្វើបទសម្ភាសន៍តាមគ្រួសារ។

## KS4. *អត្រាចំណាកស្រុក*

**ការកំណត់និយមន័យ**

អត្រាចំណាកស្រុកសំដៅដល់ការផ្លាស់ប្តូរជាភាគរយនៃចំនួនប្រជាជន ដោយសារប្រជាជនផ្លាស់ចូលមកក្នុង ឬចាក ចេញក្រៅតំបន់សិក្សាក្នុងឆ្នាំមុនៗ។ ឧទាហរណ៍ ប្រសិនបើមានប្រជាជនចំនួន ១០០០ នាក់ នៅក្នុងភូមិនៅឆ្នាំ ១៩៩៩ ហើយមាន ៥០០ នាក់ ផ្លាស់ចូលមកក្នុងតំបន់សិក្សានៅឆ្នាំ ២០០០ នោះអត្រាចំណាកស្រុកត្រូវស្មើនឹង ៥០០/១០០០ = ៥០%។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ទិន្នន័យស្តីពីចំណាកស្រុក ទទួលបានជាទូទៅពីស្ថិតិជំរឿនថ្នាក់ ជាតិ តំបន់ និង/ឬមូលដ្ឋាន ដែលអាចទទួលបានពីការិយាល័យជំរឿន ក្រុមប្រឹក្សាក្រុង និង/ឬបណ្ណាល័យសហគមន៍។ វាជាការសំខាន់ណាស់ដែលត្រូវផ្ទៀងផ្ទាត់ទិន្នន័យទាំងនេះជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា ប្រធានភូមិ ឬចៅហ្វាយក្រុង។ ដូចបានបញ្ជាក់ជូនក្នុង *មគ្គុទេសក៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់*

សំណួរសំខាន់ៗដែលត្រូវលើកឡើងគឺ : តើការកើនឡើង ឬធ្លាក់ចុះ សុទ្ធនៃចំនួនផ្លាស់មកក្នុង និងចាកចេញពីតំបន់សិក្សានៅក្នុងឆ្នាំមុន មានចំនួនប៉ុន្មាន?_______________

(កត់សំគាល់ + ឬ – ឆ្លុះបញ្ចាំងអំពីការផ្លាស់មកក្នុង ឬការចាកចេញ)

**វិធីសាស្ត្រវិភាគទិន្នន័យ**

ធ្វើសំយោគទិន្នន័យដែលទទួលបានពីប្រភពបន្ទាប់បន្សំ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់អត្រាចំណាកស្រុក និងត្រូវបានបញ្ចូលជូននៅលើ*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ*។

*ការវិភាគបន្ថែម :* ទាញលទ្ធផលពីឆ្នាំមុនៗ ដើម្បីគណនាបំរែបំរួល ក្នុងរយៈពេលមួយ។ ប្រៀបធៀបបំរែបំរួលនៃអត្រាចំណាកស្រុកក្នុងរយៈពេលមួយ ជាមួយនឹងបំរែបំរួលនៃស្ថានភាពធនធាន និង*កំរិត និងប្រភេទនៃផលប៉ះពាល់ (KS20 និង KS21)* ដើម្បីពិនិត្យមើលថាតើអត្រាចំណាកស្រុកមានទាក់ទិននឹងស្ថានភាព និងផលប៉ះពាល់ដែរឬទេ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

អត្រាចំណាកស្រុកក៏មានប្រយោជន៍សំរាប់ការស្វែងយល់អំពីការគំរាមកំហែងផងដែរ។ នៅពេលដែលមានប្រជាជនផ្លាស់ចូលមកក្នុងតំបន់ នោះសម្ពាធលើធនធានក៏កើនឡើងដែរ។ ការប្រៀបធៀបជាមួយនឹងស្ថានភាពធនធាន និងកំរិតនៃផលប៉ះពាល់គឺមានប្រយោជន៍ជាពិសេស ក្នុងការពិនិត្យថាតើអ្នកចំណូលថ្មី មានជាប់ទាក់ទិនជាមួយនឹងការប្រែប្រួលស្ថានភាព និងផលប៉ះពាល់ដែរឬទេ។

អត្រាចំណាកស្រុកក៏មានសារៈសំខាន់ផងដែរ សំរាប់ការទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ ជាពិសេសសំរាប់ការរៀបចំកម្មវិធីលើកកំពស់ការយល់ដឹង។ ជនចំណាកស្រុកអាចត្រូវបានគិតថាមានការយល់ដឹងតិចអំពីធនធានតាមតំបន់ឆ្នេរ និងកម្មវិធីគ្រប់គ្រងជាងអ្នកដែលរស់នៅរយៈពេលយូរមកហើយ។ កម្មវិធីគ្រប់គ្រងតំបន់ឆ្នេរដែលមានអត្រាចំណាកស្រុកចូលក្នុងសហគមន៍ខ្ពស់ អាចត្រូវរៀបចំកម្មវិធីតំរូវទៅតាមកំណើតនៃចំនួនប្រជាជនដែលមានការយល់ដឹង និងការសាទរជាគោលតិចតួចចំពោះបរិស្ថានរបស់ពួកគេ។ ឧទាហរណ៍ អ្នកគ្រប់គ្រងអាចត្រូវការមានកិច្ចប្រជុំសហគមន៍ជាមួយនឹងអ្នកប្រើប្រាស់ធនធានជាប្រពៃណី និងជនចំណាកស្រុក ដើម្បីណែនាំដល់អ្នកចំណូលថ្មីអំពីប្រព័ន្ធបែងចែកសិទ្ធិប្រើប្រាស់ដែលមានស្រាប់។ លើសពីនេះទៅទៀត ប្រសិនបើអ្នកគ្រប់គ្រងដឹងអំពីសកម្មភាពអ្វីដែលជនចំណាកស្រុកបានចូលរួមក្នុងនោះ គាត់ ឬនាងអាចកំណត់គោលដៅសកម្មភាពទាំងនោះបាន។ ឧទាហរណ៍ ប្រសិនបើមានប្រតិបត្តិករសណ្ឋាគារថ្មីច្រើននោះចូលមកក្នុង និងឆ្ការដើមកោងកាងដោយមានការយល់ដឹងតិចតួចអំពីអេកូសាស្ត្រតំបន់ឆ្នេរ នោះអ្នកគ្រប់គ្រងអាចត្រូវរៀបចំខ្សែវីដេអូអប់រំអំពីសារៈសំខាន់នៃធនធានសមុទ្រ ដូចជាការទាក់ទាញភ្ញៀវទេសចរ និងផលប៉ះពាល់នៃការអនុវត្តន៍ផ្នែកសណ្ឋាគារលើធនធានដ៏មានតំលៃទាំងនេះ។

## KS5-11. *អាយុ ភេទ ការអប់រំ អក្ខរកម្ម ជនជាតិ សាសនា និងភាសា*

### ការកំណត់និយមន័យ

អាយុ ភេទ ការអប់រំ អក្ខរកម្ម ជនជាតិ និងសាសនាគឺជាសូចនាករប្រជាសាស្ត្រមូលដ្ឋាន។ ការអប់រំត្រូវបានវាស់វែងដោយចំនួនឆ្នាំជាមធ្យមនៃការសិក្សាជាផ្លូវការ ដែលបញ្ចប់ដោយសមាជិកក្នុងតំបន់សិក្សាដែលមានអាយុលើសពី ១៦ ឆ្នាំ។ អក្ខរកម្មត្រូវបានវាស់វែងដោយភាគរយនៃសមាជិកក្នុងតំបន់សិក្សា ដែលអាចអាន និងសរសេរ។ អាយុត្រូវបានវាស់វែងដោយភាគរយនៃសមាជិកក្នុងតំបន់សិក្សាដែលមានចំណាត់ថ្នាក់អាយុខុសៗគ្នា។ ភេទត្រូវបានវាស់វែងដោយភាគរយនៃចំនួនប្រជាជនដែលជាបុរស និងស្ត្រី។ ជនជាតិ និងសាសនាត្រូវបានវាស់វែងដោយភាគរយនៃសមាជិកក្នុងតំបន់សិក្សាដែលមានទំនាក់ទំនងជនជាតិ និងសាសនាផ្សេងៗ ទៅតាមនោះ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

ព័ត៌មានប្រជាសាស្ត្រជាមូលដ្ឋានស្តីពីតំបន់សិក្សា ជាធម្មតា ទទួលបានពីប្រភពបន្ទាប់បន្សំ ដូចជានាយកដ្ឋានជំរឿនរបស់រដ្ឋាភិបាល សាលាក្រុង និងមជ្ឈមណ្ឌលសហគមន៍។ វាជាការសំខាន់ ដែលត្រូវផ្ទៀងផ្ទាត់ទិន្នន័យទាំងនេះជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា ប្រធានភូមិ ឬចៅហ្វាយក្រុង។

ការប្រមូលទិន្នន័យគួរផ្តោតជុំវិញការកំណត់ភាគរយនៃចំនួនប្រជាជនក្នុងតំបន់សិក្សា ដែលស្ថិតក្នុងចំណាត់ថ្នាក់អាយុ ភេទ ការអប់រំ ទំនាក់ទំនងសាសនា និងជនជាតិផ្សេងៗ។ ដូចបានបញ្ជាក់ជូនក្នុង *មគ្គុទេសក៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់* សំណួរសំខាន់ៗដែលត្រូវលើកឡើងគឺ ៖ តើប្រជាជនប៉ុន្មានភាគរយនៅក្នុងតំបន់សិក្សាបច្ចុប្បន្នមានអាយុ ៖ ០-១៨ ឆ្នាំ _____ ១៩-៣០ ឆ្នាំ_____ ៣១-៥០ ឆ្នាំ _____ លើសពី ៥០ ឆ្នាំ_____

តើមានប្រជាជនប៉ុន្មានភាគរយជាបុរស? ______ ជាស្ត្រី?______

តើប្រជាជនអាយុលើសពី ១៦ ឆ្នាំ នៅក្នុងតំបន់សិក្សាទទួលការអប់រំជាមធ្យមប៉ុន្មានឆ្នាំ?____________

តើភាគរយនៃប្រជាជនដែលចេះអក្សរ (អាចអាន និងសរសេរ) មានចំនួនប៉ុន្មាន?____________

តើនៅក្នុងតំបន់សិក្សាមានជនជាតិអ្វីខ្លះ (ភាគរយនៃក្រុមជនជាតិសំខាន់នីមួយៗក្នុងតំបន់សិក្សា) ៖

(សរសេរក្នុង) _______ (សរសេរក្នុង)_______ (សរសេរក្នុង)_______

តើក្នុងតំបន់សិក្សាមានក្រុមសាសនាអ្វីខ្លះ? (ភាគរយនៃក្រុមសាសនាសំខាន់នីមួយៗ ក្នុងតំបន់សិក្សា) ៖

(សរសេរក្នុង) _______ (សរសេរក្នុង)_______ (សរសេរក្នុង)_______

តើនៅក្នុងតំបន់សិក្សាមានភាសានិយាយសំខាន់ៗប៉ុន្មាន? (ភាគរយនៃភាសាសំខាន់នីមួយៗ ក្នុងតំបន់សិក្សា) ៖

(សរសេរក្នុង) _______ (សរសេរក្នុង)_______ (សរសេរក្នុង)_______

**វិធីសាស្ត្រវិភាគទិន្នន័យ :** ធ្វើសំយោគទិន្នន័យដែលទទួលបានពីប្រភពបន្ទាប់បន្សំ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់ភាគរយនៃប្រជាជនក្នុងប្រភេទនីមួយៗ និងបញ្ចូលជូននៅលើ *សន្លឹកវិភាគទិន្នន័យបានពី បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ។

ឧទាហរណ៍សំរាប់អាយុមានដូចតទៅ :

ភាគរយនៃអាយុក្នុងសហគមន៍ : ០-១៨ ឆ្នាំ *២៣%* ១៩-៣០ ឆ្នាំ *៤១%* ៣១-៥០ ឆ្នាំ *១៦%* លើសពី ៥១ ឆ្នាំ *២០%*

*ការវិភាគបន្ថែម :* តារាងក្រាហ្វិករង្វង់ចំនួនបីអាចត្រូវបានរៀបចំឡើង ដើម្បីបង្ហាញជារូបភាពអំពីអាយុ និងសាសនា ព្រមទាំងរបាយជនជាតិក្នុងតំបន់សិក្សា។ ទាញលទ្ធផលចេញពីឆ្នាំមុនៗ ដើម្បីគណនាបំរែបំរួលក្នុងរយៈពេលមួយ ។ ប្រធានបទខ្លីមួយអាចត្រូវបានរៀបចំឡើង ដើម្បីបរិយាយអំពីលក្ខណៈភូមិសាស្ត្រក្នុងតំបន់សិក្សា និងទំហំនៃការប្រែប្រួលរបស់វាក្នុងរយៈពេលមួយ ។

ទិន្នន័យស្រដៀងគ្នាត្រូវបានប្រមូល ដើម្បីជាផ្នែកមួយនៃបទសម្ភាសន៍តាមគ្រួសារ ។ ការប្រៀបធៀបរវាងលទ្ធផលនានា សំរួលដល់ការពិនិត្យលើភាពត្រឹមត្រូវរបស់ទិន្នន័យ ។ ប្រសិនបើមានភាពខុសគ្នារវាងលទ្ធផលណាមួយនោះ វាអាចជាការចាំបាច់មួយ ដែលត្រូវប្រឹក្សាយោបល់ជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់អំពីមូលហេតុនៃភាពមិនស្របគ្នានោះ។ បើមិនដូច្នេះទេ ការអង្កេតជំរឿនពេញលេញមួយ (ធ្វើសម្ភាសន៍តាមគ្រួសារទាំងអស់ មិនមែនគ្រាន់តែគ្រួសារគំរូនោះទេ) គួរត្រូវធ្វើឡើងដើម្បីអាចយល់បានយ៉ាងត្រឹមត្រូវអំពីលក្ខណៈប្រជាសាស្ត្រក្នុងតំបន់សិក្សា ។

## សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

សូចនាករទាំងអស់នេះមានសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍ការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងដំណើរការគ្រប់គ្រង ។ ការអប់រំ អក្ខរកម្ម និងអាយុអាចជាកត្តាសំរាប់ការព្យាករណ៍អំពីភាពងាយទទួលយកនូវគំនិតថ្មីៗ ។ ជាទូទៅ នៅពេលអាយុកាន់តែច្រើន នោះភាពបើកចំហរចំពោះគំនិតថ្មី (ឧ. ការបង្កើតតំបន់គ្មានការនេសាទ) កាន់តែទាបដែរ ។ ហើយនៅពេលដែលការអប់រំកាន់តែខ្ពស់ នោះការបើកចិត្តទូលាយក៏កាន់តែមានច្រើនឡើងដែរ ។ ឧទាហរណ៍ អ្នកនេសាទចំណាស់ៗអាចមិនពេញចិត្តចំពោះការផ្លាស់ប្តូរមុខរបរ ប៉ុន្តែអ្នកនេសាទក្មេងៗអាចពេញចិត្តចូលរួមការបណ្តុះបណ្តាលទូលំទូលាយដើម្បីអាជីពថ្មីរបស់ពួកគេ ។ តាមរយៈការយល់ដឹងអំពីសូចនាករទាំងនេះ អ្នកគ្រប់គ្រងទទួលគំនិតស្តីពីការយល់ដឹង គាំទ្រ និងការគោរពអនុវត្តនូវវិធានការគ្រប់គ្រង ។

ជនជាតិ និងសាសនាក៏មានសារៈសំខាន់ក្នុងការទទួលបានការចូលរួមរបស់អ្នកពាក់ព័ន្ធផងដែរ ។ សូចនាករទាំងពីរនេះគឺជាចំណុចសារៈសំខាន់រចនាសម្ព័ន្ធសង្គម ហើយជាញឹកញាប់ ទាក់ទិនទៅនឹងសមាជិកភាពរបស់ក្រុម ភាពស្មោះត្រង់ និងចំណុចផ្សេងទៀតនៃឥរិយាបថសង្គម ។ ជាធម្មតា ភាពស្រដៀងគ្នានាំឆ្ពោះទៅរកការពេញចិត្តក្នុង

ការសហការគ្នាកាន់តែខ្លាំងឡើង។ តាមរយៈការយល់ដឹងអំពីសម្ព័ន្ធជនជាតិ និងសាសនា អ្នកគ្រប់គ្រងអាច យល់កាន់តែច្បាស់អំពីរបៀបដែលអ្នកពាក់ព័ន្ធប្រព្រឹត្ត ហើយដូច្នេះក៏អាចយល់អំពីរបៀបទាក់ទងជាមួយនឹង ពួកគេផងដែរ។ ការដែលមានជនជាតិតែមួយ ឬស្រដៀងគ្នា នោះសហគមន៍នឹងអាចមានលទ្ធភាពកាន់តែច្រើន ឡើងក្នុងការសហការជាមួយគ្នា ជាងតំបន់ដែលមានគំលាតផលប្រយោជន៍ផ្នែកជនជាតិ និងសាសនា។

ព័ត៌មាននេះក៏អាចមានប្រយោជន៍ក្នុងការកំណត់ចំណុចចូលទៅទាក់ទងក្រុមនានាផងដែរ។ ឧទាហរណ៍ ប្រសិន បើសម្ព័ន្ធសាសនាមានកិរិតខ្លាំង នោះសេវាកម្ម ឬកិច្ចប្រជុំសាសនាអាចជាមធ្យោបាយមួយក្នុងការចូលទៅដល់ ប្រជាជន ហើយមេដឹកនាំសាសនាអាចជាតំណាងយ៉ាងត្រឹមត្រូវរបស់សមាជិកសហគមន៍។ ជនជាតិ និង សាសនាក៏អាចផ្តល់នូវការយល់ដឹងអំពីការយល់ឃើញរបស់ប្រជាជន និងតំលៃនៃធនធានផងដែរ ទោះបីជាការ នេះទាមទារឱ្យមានការយល់ដឹងអំពីសាសនា និងជំនឿជនជាតិរបស់ពួកគេក៏ដោយ។

ដោយអាស្រ័យទៅលើវប្បធម៌ ភេទក៏អាចជាសូចនាករដ៏រឹងមាំមួយនៃការចូលរួមផងដែរ ដោយហេតុថាក្នុង វប្បធម៌ខ្លះ ស្ត្រីមិនចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនយោបាយ និងគ្រប់គ្រងនោះទេ។ វាអាចកាន់តែលំបាកទៅ ទៀត ក្នុងករណីទាំងនេះ ក្នុងការជំរុញពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងកិច្ចការគ្រប់គ្រង។

ការអប់រំ អក្ខរកម្ម និងសាសនា ព្រមទាំងសម្ព័ន្ធជនជាតិ មានសារៈសំខាន់ ក្នុងការយល់ដឹងអំពីផលប៉ះពាល់ នៃការគ្រប់គ្រងលើការងារចិញ្ចឹមជីវិត និងសុខុមាលភាព ក្នុងរយៈពេលមួយ។ ការកើនឡើងនៃការអប់រំ ដែល ទាក់ទិនទៅនឹងយុទ្ធសាស្ត្រគ្រប់គ្រងជាក់លាក់មួយចង្អុលបង្ហាញឱ្យឃើញអំពីផលប៉ះពាល់ជាវិជ្ជមាន។

ការធ្លាក់ចុះ យ៉ាងធ្ងន់ធ្ងរនៃភាគរយជាក់លាក់របស់ប្រជាជនក្នុងក្រុមជនជាតិមួយអាចបង្ហាញថា យុទ្ធសាស្ត្រគ្រប់ គ្រងមានផលប៉ះពាល់មិនស្មើគ្នាទៅលើក្រុមនោះ។ ការលំបាកក្នុងការបកស្រាយទាំងនេះ ការភ្ជាប់ទំនាក់ទំនង ទៅនឹងយុទ្ធសាស្ត្រគ្រប់គ្រង ក្នុងចំណោមគោលនយោបាយ និងកម្មវិធីផ្សេងទៀតទាំងអស់ ដែលអាចបណ្តាល ឱ្យមានការប្រែប្រួលទាំងនេះ។

អាយុមានប្រយោជន៍សំរាប់ការព្យាករណ៍សម្ពាធលើធនធាននាពេលអនាគត។ ប្រជាជនមានអាយុក្មេងខ្លាំង ដែលជាធម្មតានៅក្នុងប្រជាជាតិអាស៊ីជាច្រើន ចង្អុលបង្ហាញថាមានសម្ពាធកាន់តែខ្លាំងទៅលើធនធាននៅក្នុង ឆ្នាំខាងមុខៗ។

ដូចគ្នានេះដែរ ទាក់ទិនទៅនឹងគោលគំនិតស្តីពីកម្មវិធីតាមដានផ្នែកសេដ្ឋកិច្ចសង្គម ព័ត៌មានស្តីពីរបាយអាយុ ភេទ ការអប់រំជនជាតិ សាសនា និងរចនាសម្ពន្ធការងារនឹងមានប្រយោជន៍សំរាប់ការធានាបាននូវល្បាយរបស់ប្រជាជន ក្នុងតំបន់សិក្សាដែលត្រូវបានសម្ភាសន៍។ ឧទាហរណ៍ ប្រសិនបើមានប្រជាជន ៣០% កាន់សាសនាហិណ្ឌូ ៤០% មូស្លីម និង ៤០% សាសនាគ្រីស្តនោះ ក្រុមតាមដានចាំបាច់ត្រូវធានាថាកិច្ចសម្ភាសន៍ត្រូវបានអនុវត្តជាមួយនឹង ភាគរយ ប្រជាជនក្នុងចំនួនប្រមាណស្មើគ្នាមកពីក្រុមនីមួយៗ។ វាជាការសំខាន់មួយ ដែលត្រូវប្រមូលព័ត៌មាន នេះចេញពីបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ មុននឹងចាប់ផ្តើមបទសម្ភាសន៍តាមគ្រួសារ។ សូមអាន*ផ្នែកទី ៣.៦* សំរាប់ការ ពិភាក្សាស្តីពីការជ្រើសរើសអ្នកចូលរួម។

## KS12. *មុខរបរ*

### ការកំណត់និយមន័យ

មុខរបរសំដៅសកម្មភាពដែលផ្ដល់មធ្យោបាយចិញ្ចឹមជីវិត ដូចជា ប្រាក់ចំណូល ចំណីអាហារ ឬមធ្យោបាយផ្សេងទៀតក្នុងការរស់នៅ។ មុខរបរចំបងគឺជាប្រភពសំខាន់នៃមធ្យោបាយចិញ្ចឹមជីវិត រីឯមុខរបរទីពីរគឺជាប្រភពនៃមធ្យោបាយចិញ្ចឹមជីវិតដែលសំខាន់បំផុតទីពីរ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យស្ដីពីមុខរបរអាចទទួលបានតាមរយៈប្រភពបន្ទាប់បន្សំ ដូចជា ស្ថិតិជំរឿន កំណត់ត្រាផ្នែកនេសាទ និងផែនការអភិវឌ្ឍន៍សហគមន៍។ ប៉ុន្តែ វាអាចមិនបង្ហាញអំពីកិរិតនៃមុខរបរ ដែលមានប្រយោជន៍ចំពោះអ្នកគ្រប់គ្រង។ ឧទាហរណ៍ "ទេសចរណ៍" អាចត្រូវបានកត់សំគាល់ថាជាមុខរបរ ប៉ុន្តែ អ្នកគ្រប់គ្រងអាចត្រូវការដឹងអំពីភាគរយនៃប្រតិបត្តិករកីឡាកំសាន្តក្នុងទឹក និងកម្មករសណ្ឋាគារ ដាច់ៗពីគ្នា។ ដូច្នេះវាជាការសំខាន់មួយដែលត្រូវសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗ ដូចជា ប្រធានភូមិ ចៅហ្វាយក្រុង និងប្រធានសហគមន៍ផ្សេងទៀត និងតំណាងពីវិស័យផ្សេងៗ (ឧ. សមាគមនេសាទ សមាគមសណ្ឋាគារ)។ ព័ត៌មានចាំបាច់ត្រូវបញ្ចូលក្នុង*តារាងស្ដីពីមគ្គុទេសន៍កិច្ចសម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចដែលបានបង្ហាញ។

*ការប្រមូលទិន្នន័យបន្ថែម* : ក្រុមតាមដានក៏អាចត្រូវការសាកសួរអំពីមុខរបរទីបី ដែលអាចមានប្រយោជន៍ដល់ការកំណត់ភាគរយនៃសហគមន៍ដែលចូលរួមក្នុងសកម្មភាពផងដែរ ប៉ុន្តែមិនផ្អែកទៅលើវា សំរាប់ជាប្រភពបន្ទាប់បន្សំ ឬចំបងស្ដីពីមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេនោះទេ។

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលទទួលបានពីប្រភពបន្ទាប់បន្សំ និងអ្នកផ្ដល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់ភាគរយនៃប្រជាជនដែលធ្វើការងារនៅក្នុងប្រភេទនីមួយៗ និងចំនួនប្រជាជនដែលចូលរួមជាចំបងនៅក្នុងមុខរបរនីមួយៗជាមុខរបរចំបងរបស់ពួកគេ។ បញ្ជាក់អំពីព័ត៌មានទាំងនេះនៅលើ*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចក្នុងឧទាហរណ៍ខាងក្រោម។

| មុខរបរសំខាន់ៗក្នុងសហគមន៍ | ភាគរយនៃប្រជាជនធ្វើការងារដែលប្រកបមុខរបរនេះជាមុខរបរចំបង | ចំនួនប្រជាជនដែលប្រកបមុខរបរជាមុខរបរចំបង | ភាគរយប្រជាជនធ្វើការងារដែលប្រកបមុខរបរនេះជាមុខរបរទីពីរ |
|---|---|---|---|
| ១. *អ្នកនេសាទ* | *៦០%* | *៦០០* | *២០%* |
| ២. *ប្រតិបត្តិករកីឡាក្នុងទឹក* | *១០%* | *១០០* | *0%* |
| ៣. *កម្មករវារីវប្បកម្ម* | *២០%* | *២០០* | *៥%* |
| ៤. *កម្មករសណ្ឋាគារ* | *៥%* | *៥០* | *0%* |
| ៥. *កសិករ* | *៥%* | *៥០* | *១០%* |

*ការវិភាគបន្ថែម :* ស្រង់លទ្ធផលទទួលបានពីឆ្នាំមុនៗ ដើម្បីគណនាបំរែបំរួលក្នុងរយៈពេលមួយ។ ប្រៀបធៀបលទ្ធផលទាំងនេះជាមួយនឹងបំរែបំរួលនៃស្ថានភាពធនធាន *ប្រភេទនៃការប្រើប្រាស់ (KS16) ករិត និងប្រភេទនៃផលប៉ះពាល់ (KS20* និង *KS21)* និង*ការយល់ឃើញអំពីការគំរាមកំហែង (H17)* ដើម្បីពិនិត្យថាតើមានទំនាក់ទំនងនឹងគ្នាដែរឬទេ។ ប្រធានបទខ្លីមួយអាចត្រូវបានរៀបចំឡើង ដែលបរិយាយអំពីមុខរបរសំខាន់ៗ សារៈសំខាន់របស់វាដែលនាំឱ្យមានភាគរយ និងចំនួនប្រជាជនចូលរួមក្នុងមុខរបរទាំងនោះនីមួយៗ និងទំហំនៃការប្រែប្រួលរបស់វាក្នុងរយៈពេលមួយ។

ទិន្នន័យស្រដៀងគ្នានេះត្រូវបានប្រមូល ដើម្បីជាផ្នែកមួយនៃបទសម្ភាសន៍តាមគ្រួសារ។ ការប្រៀបធៀបរវាងលទ្ធផល សំរួលដល់ការពិនិត្យទៅលើភាពត្រឹមត្រូវរបស់ទិន្នន័យ។ ប្រសិនបើមានភាពខុសគ្នាធំៗរវាងលទ្ធផលទាំងនេះ នោះការអង្កេតជំរឿនពេញលេញមួយអាចចាំបាច់ត្រូវធ្វើឡើង។ កត់សំគាល់ថា ទិន្នន័យបទសម្ភាសន៍តាមគ្រួសារគឺផ្អែកទៅលើចំនួនប្រជាជនទាំងអស់ (មិនមែនគ្រាន់តែប្រជាជនដែលធ្វើការងារនោះទេ) ដែលរួមទាំងអ្នកទាំងឡាយដែលគ្មានការងារផងដែរ។ ដើម្បីប្រៀបធៀបឱ្យបានត្រឹមត្រូវ ចាំបាច់ត្រូវមានការគណនាជាថ្មីនូវភាគរយគ្រួសារ ដោយផ្អែកតែទៅលើប្រជាជនដែលកត់ត្រាថា ជាប្រជាជនដែលធ្វើការប៉ុណ្ណោះ (មានន័យថាមិនមែនប្រជាជនដែលកត់ត្រាថាជា "សិស្ស" "គ្មានការងារ" ។ល។ ជាមុខរបរ របស់ពួកគេនោះទេ)។

## សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

រចនាសម្ព័ន្ធការងារគឺជាប្រភពមួយក្នុងចំណោមប្រភពព័ត៌មានដែលមានប្រយោជន៍បំផុត ទាក់ទិនទៅនឹងការគំរាមកំហែង។ វាផ្តល់នូវការយល់ដឹងអំពីចំនួនប្រជាជនដែលចូលរួមក្នុងសកម្មភាពនៅតាមតំបន់ឆ្នេរ ដែលក្នុងនោះសកម្មភាពជាច្រើនមានការគំរាមកំហែងជាសក្តានុពលដល់ធនធាន។ បំរែបំរួលក្នុងរយៈពេលមួយ និងការប្រៀបធៀបជាមួយនឹង*ករិតនៃផលប៉ះពាល់ (KS20)* ព្រមទាំងស្ថានភាពធនធានអាចជាចំណេះដឹងពិសេសទាក់

ទិននឹងការគំរាមកំហែង។ ឧទាហរណ៍ ប្រសិនបើមានការមើលឃើញថាមានប្រជាជនកាន់តែច្រើនឡើងៗកំពុងប្តូរមុខរបរទៅមុខរបរនេសាទជាមុខរបរចំបងរបស់ពួកគេក្នុងរយៈពេលមួយនោះ នោះការនេសាទលើសកំរិតអាចជាបញ្ហាដែលកំពុងដុះដាលឡើង។ ការប្រៀបធៀបជាមួយនឹងស្ថានភាពធនធានត្រូវចង្អុលបង្ហាញអំពីការធ្លាក់ចុះនៃចំនួនត្រី និងចំនួនប្រជាជនដែលប្រកបមុខរបរនេសាទមានការកើនឡើង។ ការប្រៀបធៀបជាមួយនឹង*ប្រភេទនៃការប្រើប្រាស់ (KS16)* និង *កំរិត និងប្រភេទផលប៉ះពាល់ (KS20 និង KS21)* ក៏អាចមានប្រយោជន៍ក្នុងការពិនិត្យមើលអំពីទំហំនៃការកើនឡើងនូវសកម្មភាពទាំងនោះផងដែរ។ ការប្រៀបធៀបជាមួយនឹងការគំរាមកំហែងដែលយល់ឃើញមានប្រយោជន៍ក្នុងការពិនិត្យអំពីលក្ខណៈដែលសហគមន៍យល់ឃើញអំពីការកើនឡើងទាំងនេះ - ថាតើពួកវាត្រូវបានមើលឃើញថាជាការប៉ះពាល់ធនធានដែរឬទេ។ ប្រសិនបើចំនួនអ្នកនេសាទកំពុងកើនឡើង ប៉ុន្តែស្ថានភាពធនធាននៅល្អ គ្មានគ្រោះថ្នាក់ ហើយសហគមន៍មិនគិតថាការនេសាទមានផលប៉ះពាល់ជាមធ្យម ឬកំរិតខ្ពស់នោះ ការនេសាទអាចមិនមែនជាការគំរាមកំហែងនោះទេ។

រចនាសម្ព័ន្ធការងារក៏មានប្រយោជន៍សំរាប់ការកំណត់អំពីសារៈសំខាន់នៃធនធានសមុទ្រផងដែរ។ កាលណាភាគរយនៃប្រជាជនដែលប្រើប្រាស់ធនធានមានចំនួនកាន់តែច្រើនឡើង នោះភាពពឹងផ្អែកទៅលើធនធានកាន់តែមានខ្លាំង ដូច្នេះធនធានគឺកាន់តែមានសារៈសំខាន់។ កើនឡើងនៃចំនួន និង/ឬភាគរយនៃប្រជាជនដែលធ្វើការក្នុងសកម្មភាពទាក់ទិននឹងតំបន់ឆ្នេរ ក្នុងរយៈពេលមួយ ចង្អុលបង្ហាញថាសារៈសំខាន់ក៏កើនឡើងផងដែរ។ របាយប្រជាជនក្នុងមុខរបរផ្សេងៗ ក៏ចង្អុលបង្ហាញអំពីកំរិតស្ថិរភាពសេដ្ឋកិច្ចសហគមន៍ ដែលជាចំណុចសំខាន់ក្នុងការការយល់ដឹងអំពីសារៈសំខាន់របស់ធនធានផងដែរ។ ប្រសិនបើប្រជាជនភាគច្រើនពឹងផ្អែកទៅលើការនេសាទ នោះសហគមន៍នឹងរងការប៉ះពាល់ធ្ងន់ធ្ងរពីដួលរលំក្នុងវិស័យនេសាទ។

ជាទីបញ្ចប់ រចនាសម្ព័ន្ធមុខរបរក៏មានសារៈសំខាន់សំរាប់ការកំណត់ឥទ្ធិពលនៃយុទ្ធសាស្ត្រគ្រប់គ្រងមធ្យោបាយចិញ្ចឹមជីវិតក្នុងសហគមន៍ផងដែរ។ ឧទាហរណ៍ អ្នកគ្រប់គ្រងអាចមើលឃើញថាតើការប្តូរមុខរបរកើតមានបន្ទាប់ពីមានការបណ្តុះបណ្តាលអំពីមុខរបរចិញ្ចឹមជីវិតផ្សេង ឬពួកគេអាចមើលឃើញថាតើការបង្កើតតំបន់មិននេសាទកើតមានទន្ទឹម គ្នា នឹងការប្តូរមុខរបរនេសាទ ទៅជាមុខរបរផ្សេងទៀតឬយ៉ាងណា។

## ហេដ្ឋារចនាសម្ព័ន្ធសហគមន៍

### KS13. *ហេដ្ឋារចនាសម្ព័ន្ធសហគមន៍*

#### ការកំណត់និយមន័យ

ហេដ្ឋារចនាសម្ព័ន្ធសហគមន៍គឺជារង្វាស់ជាទូទៅនៃការអភិវឌ្ឍន៍ និងទ្រព្យសម្បត្តិរបស់សហគមន៍មូលដ្ឋាន។ វាគឺជា ការបរិយាយអំពីកំរិតនៃសេវាកម្មក្នុងសហគមន៍ (ឧ. មន្ទីរពេទ្យ សាលារៀន) និងហេដ្ឋារចនាសម្ព័ន្ធ (ឧ.

ផ្លូវថ្នល់ សេវាសាធារណៈ) ដែលអាចបញ្ចូលនូវព័ត៌មានដែលមានសារៈសំខាន់ចំពោះការកំណត់អំពីប្រភពនៃផលប៉ះពាល់ ដែលបង្កើតឡើងដោយមនុស្ស ទៅលើធនធានតាមតំបន់ឆ្នេរ (ឧ. ប្រព្រឹត្តិកម្មទឹកស្អុយ)។

## វិធីសាស្ត្រប្រមូលទិន្នន័យ

ព័ត៌មាននេះត្រូវបានប្រមូលតាមរយៈការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា ប្រធានភូមិ ចៅហ្វាយក្រុង ឬ វិស្វករក្រុង ការពិនិត្យទិន្នន័យបន្ទាប់បន្សំដែលទទួលបានពីកំណត់ត្រារបស់ក្រុង ជាពិសេស ពីការិយាល័យអភិវឌ្ឍន៍ សហគមន៍ និងតាមរយៈការដើរក្នុងសហគមន៍ ដើម្បីសង្កេត និងកត់ត្រាហេដ្ឋារចនាសម្ព័ន្ធសហគមន៍ទាំងនោះ។

វាជាការសំខាន់មួយដែលត្រូវកំណត់ថាតើចំណុចខាងក្រោមមាននៅក្នុងតំបន់សិក្សាដែរឬទេ :

សាលារៀន វេជ្ជបណ្ឌិតក្នុងមូលដ្ឋាន គិលានុប្បដ្ឋាយិការក្នុងមូលដ្ឋាន មន្ទីរពេទ្យ គ្លីនិកវេជ្ជសាស្ត្រ អគ្គិសនី ទូរស័ព្ទ សេវាអ៊ីនធើណិត វិទ្យុ ទូរទស្សន៍ សារព័ត៌មាន រោងចក្រប្រព្រឹត្តិកម្មទឹកស្អុយ រោងចក្រទឹកកក លទ្ធភាព ប្រើប្រាស់ផ្លូវថ្នល់រឹង ការផ្គត់ផ្គង់ទឹកទៅតាមផ្ទះ សេវាធនាគារ ផ្ទះសំណាក់/សណ្ឋាគារ/ភោជនាល័យ ភោជនីយដ្ឋាន។

ក្នុងករណីខ្លះបញ្ជីខាងលើនេះចាំបាច់ត្រូវកែសំរួល ដើម្បីឆ្លុះបញ្ចាំងឱ្យបានកាន់តែត្រឹមត្រូវអំពីសូចនាករស្តីពីការអភិវឌ្ឍន៍សហគមន៍ នៅក្នុងតំបន់សិក្សា។ វាជាការសំខាន់មួយ ដែលត្រូវបញ្ចូលប្រភេទផ្សេងៗនៃហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់។ ឧទាហរណ៍ ប្រសិនបើទូរទស្សន៍គឺមានជាទូទៅរួចមកហើយនៅក្នុងតំបន់ ប៉ុន្តែថាសទទួលសញ្ញាពីផ្កាយរណបគឺទើបតែចាប់ផ្តើមមាននោះ វាអាចជាការសមរម្យជាងដែលត្រូវបញ្ចូលថាសទទួលសញ្ញាពីផ្កាយរណបទៅក្នុងបញ្ជី។ ការសាងសង់ក្នុងទំហំត្រឹមត្រូវមួយចាំបាច់ត្រូវតែបញ្ចូល ដើម្បីធ្វើការប្រៀបធៀបប្រកបដោយអត្ថន័យរវាងសហគមន៍នានា និងក្នុងរយៈពេលមួយ ដូចជានៅមុន និងក្រោយការបង្កើតតំបន់សមុទ្រដែលត្រូវការពារ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ចងក្រងព័ត៌មានដែលទទួលបានពីការសង្កេត ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំទៅក្នុងបញ្ជីមួយស្តីពីហេដ្ឋារចនាសម្ព័ន្ធ ដែលមាននៅក្នុងតំបន់សិក្សា ព្រមទាំងបញ្ជាក់វានៅលើ *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ*។

*ការវិភាគបន្ថែម :* ប្រៀបធៀបបញ្ជីទាំងនេះក្នុងរយៈពេលមួយ។ ប្រធានបទខ្លីៗមួយ ផ្អែកទៅតាមបញ្ជីនេះ អាចត្រូវបានរៀបចំ ដើម្បីបរិយាយអំពីហេដ្ឋារចនាសម្ព័ន្ធដែលមាននៅក្នុងតំបន់សិក្សា និងអំពីទំហំនៃការប្រែប្រួលរបស់វាក្នុងរយៈពេលមួយ។

### សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ហេដ្ឋារចនាសម្ព័ន្ធសហគមន៍គឺមានប្រយោជន៍សំរាប់ការកំណត់អំពីទ្រព្យសម្បត្តិដែលមាននៅក្នុងតំបន់សិក្សា ដូចដែលបានវាស់វែងតាមរយៈកំរិតនៃការអភិវឌ្ឍន៍សហគមន៍ និងផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍ក្នុងតំបន់សិក្សា។ តាមរយៈការពិនិត្យតាមដានវត្តមាននៃចំណុចដែលបានកត់ត្រាក្នុងបញ្ជី អ្នកគ្រប់គ្រងអាចមើលឃើញថាតើទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់សហគមន៍កំពុងកើនឡើង ធ្លាក់ចុះ ឬនៅដដែល។ ការលំបាកនោះ គឺការភ្ជាប់ការប្រែប្រួលទាំងនេះទៅនឹងកម្មវិធីផ្តួចផ្តើមគ្រប់គ្រងតំបន់ឆ្នេរ។ ក្នុងករណីខ្លះការប្រែប្រួលទាំងនេះមានការជាប់ទាក់ទងយ៉ាងជិតស្និត ឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងបានផ្តល់នូវលទ្ធភាពប្រើប្រាស់ទឹក ឬប្រព្រឹត្តិកម្ម ទឹកស្អុយជូនដល់សហគមន៍។ នៅក្នុងតំបន់ផ្សេងទៀត អ្នកគ្រប់គ្រងតំបន់ឆ្នេរពុំគ្មានការទទួលខុសត្រូវលើហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ទេ។

ព័ត៌មានស្តីពីវត្តមាននៃសេវាធនាគារ ទីកកកសំរាប់អ្នកនេសាទ និងផ្លូវថ្នល់រឹងអាចមានប្រយោជន៍សំរាប់ការកំណត់អំពីសមត្ថភាពរបស់អ្នកនេសាទក្នុងការកសាងអាជីវកម្មរបស់ពួកគេ។ ស្របពេលនោះដែរ ព័ត៌មានស្តីពីប្រព្រឹត្តិកម្មទឹកស្អុយ ផ្តល់នូវការយល់ដឹងថាតើប្រព័ន្ធបង្ហូរកាកសំណល់អាចកំពុងប៉ះពាល់ដល់គុណភាពទឹកតំបន់ឆ្នេរឬយ៉ាងណា។ ព័ត៌មានស្តីពីផ្ទះសំណាក់/សណ្ឋាគារ/ភោជនាល័យ និងភោជនីយដ្ឋានមានប្រយោជន៍សំរាប់ការកំណត់អំពីកំរិតទូទៅនៃវិស័យទេសចរណ៍នៅក្នុងតំបន់។

ជាទីបញ្ចប់ ព័ត៌មានស្តីពីវត្តមាននៃសេវាទូរស័ព្ទ អ៊ីនធើណិត វិទ្យុ ទូរទស្សន៍ និងសារព័ត៌មានគឺមានប្រយោជន៍សំរាប់ការរៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយដល់មូលដ្ឋាន នៅក្នុងសហគមន៍។ យុទ្ធនាការលើកកំពស់ការយល់ដឹងអាចត្រូវបានកែសំរួលទៅតាមប្រព័ន្ធផ្សព្វផ្សាយទូទៅបំផុត។

## សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ

### *KS14. សកម្មភាព*

### ការកំណត់និយមន័យ

សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រគឺជាអត្តសញ្ញាណនៃការប្រើប្រាស់ធនធានតាមតំបន់ឆ្នេរ និងសមុទ្រនៅក្នុងតំបន់សិក្សា។ ទាំងនេះអាចរាប់បញ្ចូលទាំងសកម្មភាព ប្រើប្រាស់ ឬប៉ះពាល់ ដោយផ្ទាល់ ឬដោយប្រយោល លើធនធានតាមតំបន់ឆ្នេរ និងសមុទ្រ។ សកម្មភាពទាំងនេះអាចមានឧទាហរណ៍ៈ ការនេសាទ ទេសចរណ៍ វារីវប្បកម្ម ការដឹកជញ្ជូនតាមសមុទ្រ កសិកម្ម រ៉ែផ្កាថ្ម រ៉ែខ្សាច់ ការបូម ការអភិវឌ្ឍន៍ប្រេង-ឧស្ម័ន មូលដ្ឋានយោធា ការឆ្ការព្រៃកោងកាង ការឆ្ការព្រៃ ឧស្សាហកម្ម និងការអភិរក្ស។

| សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ |
|---|
| *នេសាទ* |
| |
| *ទេសចរណ៍* |
| |
| *វារីវប្បកម្ម* |

### វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យស្តីពីសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ ត្រូវទទួលបានតាមរយៈការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗក្នុងមូលដ្ឋាន ដូចជា ចៅហ្វាយក្រុង អាជីវករ អ្នកនេសាទ និង មគ្គុទេសន៍ទេសចរ ដើម្បីកំណត់អំពីសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ នៅក្នុងតំបន់។ ការសង្កេតក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីកំណត់សកម្មភាពប្រើប្រាស់នៅក្នុងតំបន់។ បញ្ជី មួយត្រូវបានចងក្រងឡើង ស្តីពីសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ ព្រមទាំងត្រូវបាន បញ្ជាក់ជូននៅក្នុង *មគ្គុទេសក៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់* ដូចដែលបានបង្ហាញ។

ដោយហេតុថាសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រខ្លះអាចប្រែប្រួលតាមរដូវកាល អនុវត្តនៅម៉ោងមិនធម្មតា ឬធ្វើឡើងឆ្ងាយពីដីគោក វាជាការសំខាន់មួយដែលត្រូវប្រើប្រាស់វិធីសាស្ត្រចំរុះ ដោយរាប់បញ្ចូលទាំងការសង្កេតនៅម៉ោងផ្សេងៗ និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗផ្សេងៗគ្នា ដើម្បីធានាថា ប្រភេទសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រជាច្រើនត្រូវបានកំណត់អត្តសញ្ញាណ។

*ការប្រមូលទិន្នន័យបន្ថែម :* សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រអាចត្រូវបានកំណត់នៅលើផែនទីតំបន់សិក្សា។ ឧទាហរណ៍ តំបន់សណ្ឋាគារអាចត្រូវបានកំណត់ដោយដាក់ពណ៌មួយ ហើយតំបន់មុជកំសាន្តក្រោមទឹកដោយពណ៌ផ្សេងទៀត។ ទិន្នន័យអាចត្រូវបានដាក់លើផែនទីក្នុងលក្ខណៈទូទៅ ឬលក្ខណៈជាក់លាក់ខ្លាំង។

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ ផ្សេងៗ និងការសង្កេត ទៅក្នុងតារាង នៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចមានបង្ហាញ។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីៗអាចត្រូវបានរៀបចំឡើងដើម្បីបរិយាយអំពីសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រសំខាន់ៗនៅក្នុងតំបន់សិក្សា។

### សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

អត្តសញ្ញាណនៃសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រគឺមានសារៈសំខាន់សំរាប់អ្នកគ្រប់គ្រង ក្នុងការទទួលបានការយល់ដឹងអំពីការប្រើប្រាស់ផ្សេងៗនូវធនធានតាមតំបន់ឆ្នេរ និងសមុទ្រ ព្រមទាំងទំនាស់ជាដែលអាចកើតមាននៅក្នុងតំបន់។ ឧទាហរណ៍ កំពង់ផែសំខាន់ៗ នៅក្នុងតំបន់ដែលមានចលនានាវាគគ្រឹកគគ្រេង និងមានការបញ្ចេញជាសក្តានុពលនូវកាកសំណល់អាចមានទំនាស់ជាសក្តានុពលជាមួយនឹងនឹងវិស័យទេសចរណ៍។

## KS15. *ទំនិញ និងសេវាកម្ម*

### ការកំណត់និយមន័យ

ទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រគឺជាផលិតផលជាក់លាក់ដែលផលិតចេញពីសកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ ដែលបានកំណត់។ ទាំងនេះរួមមានទាំងទំនិញចំរាញ់ ដូចជា បង្កង ឈើកោងកាង

ផលិតផលផ្កាថ្ម និងខ្សាច់ និងសេវាកម្ម មិនមែនចំរាញ់ ដូចជាការមុជកំសាន្តក្រោមទឹក ការមុជដោយពាក់អុកស៊ីហ្សែន ទេសចរបាតសមុទ្រតាមផ្លូវកញ្ចក់ ទេសចរព្រៃកោងកាង និងការនេសាទកំសាន្ត។

## វិធីសាស្ត្រប្រមូលទិន្នន័យ

| **សកម្មភាពតំបន់ ឆ្នេរ និងសមុទ្រ** | **ទំនិញ និងសេវាកម្ម តំបន់ឆ្នេរ និងសមុទ្រ** |
|---|---|
| *នេសាទ* | *បង្កង* |
| | *ត្រីតុកកែ* |
| *ទេសចរណ៍* | *សណ្ឋាគារ* |
| | *ការមុជកំសាន្តក្រោមទឹក* |
| *វារីវប្បកម្ម* | *ខ្យង* |

ទិន្នន័យស្តីពីទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រត្រូវទទួលបានតាមរយៈការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ចេញពីសកម្មភាពទាក់ទិន (ឧ. អ្នកនេសាទរយៈពេលយូរមកហើយ ប្រធានសមាគមសណ្ឋាគារ ប្រតិបត្តិករទូកមុជកំសាន្តក្រោមទឹករយៈពេលយូរមកហើយ អ្នកដឹកនាំក្រុមទេសចរ) ក៏ដូចជាអ្នកផ្តល់ព័ត៌មានសំខាន់ៗដែលមានចំណេះដឹងអំពីសកម្មភាពទាំងនោះ (ឧ. មន្ត្រីរដ្ឋាភិបាល)។ វាក៏ជាការសំខាន់មួយដែរ ដែលត្រូវសង្កេតសកម្មភាពនៅតាមតំបន់ឆ្នេរ និងភស្តុតាងជារូបសាស្ត្ររបស់វា ដើម្បីទទួលបានព័ត៌មានបន្ថែម និងដើម្បីជាការផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបានពីការសម្ភាសន៍។

សំរាប់សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រនីមួយៗ អ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបាន សុំឱ្យកំណត់អត្តសញ្ញាណនៃទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រដែលបានផលិត។ ឧទាហរណ៍ សំរាប់វិស័យទេសចរណ៍ ទំនិញ និងសេវាកម្មទាំងនេះអាច រាប់បញ្ចូលទាំងសណ្ឋាគារ និងការមុជកំសាន្តក្រោមទឹកផងដែរ។ បញ្ជីមួយស្តីពីទំនិញ និងសេវាកម្ម ត្រូវបានចងក្រងឡើងសំរាប់សកម្មភាពនីមួយៗ និងបានបញ្ជាក់ជូននៅក្នុង *មគ្គុទេសក៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ / ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ* ដូចដែលបានបង្ហាញ។ ដោយហេតុថាទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រខ្លះអាចប្រែប្រួលតាមរដូវកាល អនុវត្តនៅម៉ោងមិនធម្មតា ឬធ្វើឡើងនៅឆ្ងាយពីដីគោក វាជាការសំខាន់មួយ ដែលត្រូវប្រើប្រាស់វិធីសាស្ត្រចំរុះ ដោយរាប់បញ្ចូលទាំងការសង្កេតនៅម៉ោងផ្សេងៗ និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗផ្សេងៗគ្នា ដើម្បីធានាថាប្រភេទទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និង សមុទ្រជាច្រើនត្រូវបានកំណត់អត្តសញ្ញាណ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗផ្សេងៗ និងការសង្កេត ទៅក្នុងតារាងនៅក្នុង*សន្លឹកវិភាគការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់/ ប្រភពបន្ទាប់បន្សំ* ដូចមានបង្ហាញ។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីមួយ ផ្អែកទៅតាមតារាងខាងលើអាចត្រូវបានរៀបចំឡើង ដោយបរិយាយអំពីទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រដែលបានផលិតនៅក្នុងតំបន់សិក្សា។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ព័ត៌មានស្តីពីទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រមានប្រយោជន៍សំរាប់ការកំណត់ផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍ក្នុងតំបន់សិក្សា ជាពិសេស ទីផ្សារ និងផលិតកម្ម។ ជាលទ្ធផលនៃវិធានការគ្រប់គ្រង អាចមានការផ្លាស់ប្តូរនូវទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ ដែលបានផលិតនៅក្នុងតំបន់ដែលមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានទៅលើអ្នកប្រើប្រាស់ធនធាន។ ឧទាហរណ៍ ប្រសិនបើតំបន់សមុទ្រក្រោមការការពារមានការលើកកំពស់យ៉ាងសកម្មនូវវិស័យទេសចរណ៍នៅក្នុងតំបន់ នោះនឹងមានការរំពឹងទុកថាតំលៃនៃការមុជកំសាន្តក្រោមទឹកនឹងកើនឡើង ហើយការកំណត់គោលដៅទីផ្សារនឹងមានការពង្រីក។

## KS16. *ប្រភេទនៃការប្រើប្រាស់*

### ការកំណត់និយមន័យ

ប្រភេទនៃការប្រើប្រាស់សំដៅដល់វិធី ឬការអភិវឌ្ឍន៍ជាក់លាក់ដែលកំពុងត្រូវបានប្រើប្រាស់ (ដូចជា លបសំណាញ់ ផ្ទះសំណាក់ ការមុជទឹកកំសាន្តនៅបាតសមុទ្រ) សំរាប់ទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចទទួលបានទិន្នន័យស្តីពីប្រភេទនៃការប្រើប្រាស់បាន តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលតំណាងឱ្យក្រុមអ្នកពាក់ព័ន្ធផ្សេងៗ (ដូចជា ប្រធានសមាគមអ្នកនេសាទ អ្នកគ្រប់គ្រងប្រតិបត្តិការរ៉ែខ្សាច់យូរបំផុត ជាដើម)។ លើសពីនេះទៀតនោះ ការពិនិត្យប្រៀបធៀបព័ត៌មាននេះតាមរយៈការដើរអង្កេតមើលនៅពាសពេញសហគមន៍ទាំងមូល ជាពិសេសកន្លែងដែលមានសកម្មភាពផ្សេងៗកកើតឡើង ក៏មានសារៈសំខាន់ ផងដែរ។

| សកម្មភាពតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្ម តំបន់ឆ្នេរ និងសមុទ្រ | ប្រភេទនៃការប្រើប្រាស់ (សំខាន់ៗ) |
|---|---|---|
| *នេសាទ* | *បង្កង* | *លប* |
| | *ត្រីតុកកែ* | *ខ្សែសន្ទូច* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *ផ្ទះសំណាក់ (១-៧បន្ទប់)* |
| | *មុជទឹកកំសាន្ត បាតសមុទ្រ* | *ឧបករណ៍ដកដង្ហើម* |
| *វារីវប្បកម្ម* | *ខ្យង* | ខ្សែសន្ទូច |

បញ្ហាសំខាន់ដែលត្រូវដោះស្រាយ គឺជាអ្វីដែលជាប្រភេទនៃការប្រើប្រាស់កំពុងកើតមានសំរាប់ទំនិញ និងសេវាកម្មនីមួយៗ។ ជាឧទាហរណ៍ សំរាប់ទំនិញនេសាទ (ដូចជា ត្រីតុកកែ បង្កង) ចំលើយអាចរួមមានដូចជា លបសំណាញ់ ខ្សែសន្ទូច ស្ន ការម្រួល។ សំរាប់សេវាកម្មសណ្ឋាគារនៅក្នុងសកម្មភាពទេសចរណ៍វិញ ចំលើយអាចមានចាប់ពីផ្ទះសំណាក់ (១-៧បន្ទប់) ទៅដល់ភោជនាល័យ (៥-៥០បន្ទប់) រហូតទៅដល់សណ្ឋាគារ/រមណីយដ្ឋាន (ច្រើនជាង ៥០ បន្ទប់)។ សំរាប់វារីវប្បកម្មចំលើយអាចមាន ដូចជា ស្រះ ខ្សែសន្ទូច ឬទ្រុង។ សំរាប់ការដឹកជញ្ជូនតាមសមុទ្រ ចំលើយអាចមាន ដូចជា

ការអភិវឌ្ឍន៍កំពង់ផែ ការដឹកជញ្ជូនទំនិញ និងការជិះ ទូកកំសាន្ត។ ទាំងនេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ ជាឧទាហរណ៍ ប្រសិនបើមានតែសណ្ឋាគារធំៗនោះ ក្រុមតាមដានអាចសំរេចចិត្តធ្វើការចាត់ថ្នាក់ចំលើយសំរាប់សណ្ឋាគារដោយផ្អែកលើហេតុផលថា តើសណ្ឋាគារទាំងនោះមានលក្ខណៈ ពេញលេញទាំងស្រុងដែរ ឬយ៉ាងណានោះ។ សូមកត់ត្រាបញ្ចូលព័តិមានជាលទ្ធផលទាំងនោះចូលទៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័តិមានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការប្រមូលទិន្នន័យបន្ថែម :* សំរាប់ប្រភេទនៃការប្រើប្រាស់ទាំងនេះ ក្រុមតាមដានអាចនឹងចង់សាកសួរអំពីកំរិតនៃការប្រើប្រាស់លើមាត្រដ្ឋានមួយដែលមានកំរិតពីមួយដល់ដប់ ដោយកំរិតមួយបង្ហាញអំពីការប្រើប្រាស់មានកំរិតទាប ហើយកំរិតដប់បង្ហាញអំពីការប្រើប្រាស់មានកំរិតអតិបរិមា។ គេគួរធ្វើការប្រៀបធៀបការចាត់កំរិតទាំងនេះ ពីពេលមួយទៅពេលមួយដើម្បីកំណត់ថា តើកំរិតទាំងនេះមានការកើនឡើង ថយចុះ ឬនៅដដែល។

សំរាប់ទិន្នន័យជលផលវិញ ក្រុមតាមដានអាចនឹងចង់បន្ថែមកូឡោនមួយថែមទៀត ដើម្បីធ្វើការកំណត់នូវប្រភេទរបរអាជីវកម្មនេសាទ ដោយផ្អែកតាមប្រភេទដូចខាងក្រោម :

*ទ្រង់ទ្រាយធំ*-មានបំពាក់នូវឧបករណ៍ធ្វើពីគ្រឿងចក្រ ការវិនិយោគខ្ពស់ និងដំណើរការដោយថាមពលឧបករណ៍អេឡិកត្រូនិក មានផ្អែកពលករស៊ីប្រាក់ឈ្នួល ផលិផលមានលក់នៅទូទាំងសកលលោកធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងដែនទឹកឆ្ងាយៗ។

*ឧស្សាហកម្ម*-មានបំពាក់នូវឧបករណ៍ធ្វើពីគ្រឿងចក្រ ការវិនិយោគខ្ពស់ និងដំណើរការដោយថាមពលឧបករណ៍អេឡិកត្រូនិក មានផ្អែកពលករស៊ីប្រាក់ឈ្នួល ផលិផលមានលក់នៅទូទាំងសកលលោកធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសថ្នាក់ជាតិ។

*ទ្រង់ទ្រាយតូច*-ទូកតូច ម៉ាស៊ីនតូច ឧបករណ៍ធ្វើពីគ្រឿងចក្រមួយផ្នែកណាមួយ ឬទាំងមូលដែលត្រូវបានផ្តុំដំណើរការ មានពលករធ្វើការពេញម៉ោង ឬក្រៅម៉ោង ចែវដោយដៃឬម៉ាស៊ីន មានទីផ្សារលក់ ក្នុងមូលដ្ឋាន ឬក្នុងប្រទេស ធ្វើប្រតិបត្តិការនៅក្នុងដែនទឹកឆ្នេរក្បែរច្រាំង។

*សិប្បកម្ម*-ទូកតូច ម៉ាស៊ីនតូច ឧបករណ៍ធ្វើពីគ្រឿងចក្រមួយផ្នែកណាមួយ ឬទាំងមូលដែលត្រូវបានផ្តុំដំណើរការ មានពលករធ្វើការពេញម៉ោង ឬក្រៅម៉ោង ចែវដោយដៃឬម៉ាស៊ីន មានទីផ្សារលក់ក្នុងមូលដ្ឋាន ធ្វើប្រតិបត្តិការនៅក្នុងដែនទឹកឆ្នេរក្បែរច្រាំង។

*ជាលក្ខណៈគ្រួសារ*-នេសាទតែឯង ជាគ្រួសារ ឬជាក្រុមសហគមន៍ មានពលករធ្វើការក្រៅម៉ោង ទូកតូច ឧបករណ៍នេសាទ នេសាទផ្តុំប្រតិបត្តិការដោយគ្មានគ្រឿងចក្រ គ្មានថាមពលសំរាប់ដំណើរការ នេសាទជាចំបងសំរាប់ជាម្ហូបអាហារក្នុងគ្រួសារ ធ្វើប្រតិបត្តិការនៅក្នុងដែនទឹកក្បែរឆ្នេរ។

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងការអង្កេតទាំងឡាយ ដើម្បីចងក្រងជាបញ្ជីមួយស្តីពីប្រភេទនៃការប្រើប្រាស់ដែលកំពុងកើតមាននៅក្នុងតំបន់សិក្សា។ ចូរកត់ត្រានូវព័ត៌មាននេះបញ្ចូលទៅក្នុង*សន្លឹកវិភាគទិន្នន័យបានមកពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* ធ្វើការប្រៀបធៀបលទ្ធផលទាំងនោះជាបន្តបន្ទាប់ ដើម្បីកំណត់នូវការផ្លាស់ប្តូរនៃប្រភេទនៃការប្រើប្រាស់។ ហើយប្រៀបធៀបការផ្លាស់ប្តូរនៃប្រភេទនៃការប្រើប្រាស់ជាមួយនឹងការផ្លាស់ប្តូរនៃលក្ខណៈរបស់ធនធាន និង*កំរិត* និង*ប្រភេទនៃផលប៉ះពាល់ (KS20* និង *KS21)* ដើម្បីពិនិត្យមើលថាតើប្រភេទនៃការប្រើប្រាស់ ទាំងនោះមានជាប់ពាក់ព័ន្ធទៅនឹងលក្ខណៈ និងផលប៉ះពាល់ដែរ ឬយ៉ាងណា។

### សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

ព័ត៌មានស្តីអំពីប្រភេទនៃការប្រើប្រាស់មានសារប្រយោជន៍យ៉ាងពិសេស សំរាប់ធ្វើការកំណត់នូវការគំរាមកំហែមនានា ចំពោះធនធានតំបន់ឆ្នេរ និងសមុទ្រ ដូចជា ការនេសាទដោយប្រើគ្រាប់បែក ឬ ការរុករានព្រៃកោងកាងជាដើម។ តាមរយៈការធ្វើការតាមដាននូវព័ត៌មានប្រភេទនេះជាបន្តបន្ទាប់នោះ អ្នកគ្រប់គ្រងក៏អាចពិនិត្យឃើញនូវអ្វីដែលជាផលប៉ះពាល់ដែលការគ្រប់គ្រងបង្កទៅលើប្រភេទនៃការប្រើប្រាស់ទាំងនេះផងដែរ។ ឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរបានផ្តួចផ្តើមបង្កើតយុទ្ធនាការដាំព្រៃកោងកាងឡើងវិញ ប៉ុន្តែការកាប់រុករានព្រៃកោងកាងនៅតែបន្តជាប្រភេទនៃការប្រើប្រាស់មួយនៅឡើយនោះ វាបង្ហាញឱ្យឃើញថា យុទ្ធនាការនេះមិនបានបង្ការបាននូវការកាប់រុករានព្រៃកោងកាងដែលបានបន្តមាននោះទេ។ ព័ត៌មាននេះក៏អាចជួយដល់ការកំណត់នូវប្រសិទ្ធភាពនៃកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរនោះដែរ។

ការបានដឹងថាមានប្រភេទនៃការប្រើប្រាស់អ្វីខ្លះកំពុងកើតមាននៅក្នុងតំបន់សិក្សានោះ ក៏មានសារៈសំខាន់ក្នុងការទាក់ទាញការចូលរួមពីអ្នកពាក់ព័ន្ធ និងការបង្កើតកម្មវិធីលើកកំពស់ការយល់ដឹងនៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរផងដែរ។ អ្នកគ្រប់គ្រងចាំបាច់ដឹងអំពីរបៀបដែលប្រជាជនទាញយកផលប្រយោជន៍ពីធនធានទាំងនោះ ដើម្បីអាចធ្វើការជាមួយពួកគេ និងផ្សព្វផ្សាយដល់ពួកគេអំពីការគំរាមកំហែងនានាចំពោះធនធានទាំងនោះ។

## *KS17. តំលៃទំនិញ និងសេវាកម្ម*

### ការកំណត់និយមន័យ

តំលៃនៃទំនិញ និងសេវាកម្មឆ្នេរ និងសមុទ្រនោះ គឺជាតំលៃជាទឹកប្រាក់សំរាប់ផលិតផលនីមួយៗនៅក្នុងទីផ្សារ។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

គេអាចទទួលបានទិន្នន័យស្តីពីតំលៃទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រតាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័តិមានសំខាន់ៗនៅក្នុងមូលដ្ឋាន ដូចជា អ្នកនេសាទ អ្នកទិញ ប្រតិបត្តិករសណ្ឋាគារ និងប្រតិបត្តិករសេវា-កម្មមុជទឹកកំសាន្តក្នុងបាតសមុទ្រ។

គេអាចស្នើឱ្យអ្នកផ្តល់ព័តិមានសំខាន់ៗទាំងនេះដាក់តំលៃ (ខ្ពស់ មធ្យម ឬទាប) ទៅលើទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រ។ ជាឧទាហរណ៍ គេអាចនឹងដាក់តំលៃថាខ្ពស់ទៅលើបង្កង ប្រសិនបើបង្កងជាទំនិញមានតំរូវការខ្ពស់ និងតំលៃជាទឹកប្រាក់ខ្ពស់ទាំងនៅក្នុងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ គេអាចនឹងដាក់តំលៃមធ្យម ទៅលើការអភិវឌ្ឍន៍សណ្ឋាគារ ប្រសិនបើការអភិវឌ្ឍន៍ គេឃើញមានតែផ្ទះសំណាក់តែប៉ុន្មានកន្លែងនោះ។ គេអាចនឹងដាក់តំលៃទាបទៅលើតំបន់ដែលមានការកាប់បំផ្លាញព្រៃកោងកាង ដែលមិនបានគាំទ្រច្រើន ដល់ជីវិតសត្វបក្សី ហើយជាហេតុឱ្យវាផ្តល់នូវសក្តានុពលទាប សំរាប់អេកូទេសចរណ៍។ ក្រុមតាមដាននឹងចាំបាច់ត្រូវដាក់តំលៃទំនិញ និងសេវា (ខ្ពស់ មធ្យម និងទាប) ឱ្យបានច្បាស់លាស់សំរាប់តំបន់សិក្សានីមួយៗ។ ចូរកត់ត្រាព័តិមាននេះទៅក្នុងតារាង *ណែនាំស្តីពីការធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកផ្តល់ព័តិមានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

| សកម្មភាពតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្មតំបន់ឆ្នេរ និងសមុទ្រ | តំលៃទំនិញ និងសេវាកម្ម |
|---|---|---|
| *នេសាទ* | *បង្កង* | *ខ្ពស់* |
| | *ត្រីតុកកែ* | *ខ្ពស់* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *មធ្យម* |
| | *មុជទឹកកំសាន្តបាតសមុទ្រ* | *ទាប* |
| *វារីវប្បកម្ម* | *ខ្យង* | *មធ្យម* |

**វិធីសាស្ត្រវិភាគទិន្នន័យ**

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័តិមានសំខាន់ៗបញ្ចូលទៅក្នុងតារាងនៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័តិមានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* សេចក្តីបរិយាយខ្លីមួយអាចត្រូវបានរៀបចំឡើងដោយពណ៌នាអំពីតំលៃនៃទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រ។

**សារប្រយោជន៍នៃព័តិមានសំរាប់អ្នកគ្រប់គ្រង**

តំលៃនៃទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រមានសារប្រយោជន៍ដើម្បីធ្វើការកំណត់នូវផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍នៅក្នុងតំបន់សិក្សា រួមមានដូចជា របរចិញ្ចឹមជីវិត ទីផ្សារ ផលិតកម្ម និង

សន្តិសុខស្បៀង។ ជាឧទាហរណ៍ ប្រសិនបើអាជ្ញាធរគ្រប់គ្រងធ្វើការចាប់ផ្តើមជំរុញការលក់ផលិតផលពីវារីវប្បកម្ម ដូច្នេះគេរំពឹងថា តំលៃនៃផលិតផលទាំងនេះក៏នឹងកើនឡើងដែរ ខណៈដែលតំរូវការបានកើនឡើងនោះ។

តំលៃទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រក៏មានសារប្រយោជន៍ផងដែរក្នុងការបង្ហាញនូវសារៈសំខាន់នៃការគ្រប់គ្រងតំបន់សិក្សាដើម្បីការប្រើប្រាស់ប្រកបដោយចិរភាព។ ជាឧទាហរណ៍ ប្រសិនបើសេវាកម្មមុជទឹកកំសាន្តក្នុងបាតសមុទ្របាននាំឱ្យមានការកើនឡើងនៃចំនួនភ្ញៀវទេសចរបរទេសយ៉ាងច្រើន ដែលនាំមកជាមួយនូវតំលៃខ្ពស់ ដោយសារតែតំរូវការបន្ទប់ស្នាក់នៅ ភោជនីយដ្ឋានសំរាប់ទទួលអាហារ និងប្រតិបត្តិករផ្តល់សេវាកម្មមុជទឹកកំសាន្តក្នុងបាតសមុទ្រសំរាប់ភ្ញៀវទេសចរទាំងនោះ ដូច្នេះអ្នកគ្រប់គ្រងឆ្នេរមានភាពហេតុផលត្រឹមត្រូវក្នុងការដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រង ដើម្បីធានាឱ្យបាននូវចិរភាពនៃថ្មប៉ប្រះទឹក និងជលផលនៅក្នុងតំបន់សិក្សានោះ។ ផ្ទុយមកវិញ ប្រសិនបើថ្មប៉ប្រះទឹកទាំងនោះបានរងការខូចខាតដោយសារតែការបំផ្ទុះគ្រាប់បែក និងមានតំលៃទាប សំរាប់ការមុជទឹកកំសាន្តបាតសមុទ្រនោះ អ្នកគ្រប់គ្រងប្រហែលជាមានការលំបាកក្នុងការបង្ហាញហេតុផលថា ថ្មប៉ប្រះទឹកមានសារៈសំខាន់សំរាប់ការមុជទឹកកំសាន្តក្នុងបាតសមុទ្រ។

តំលៃទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រក៏មានសារប្រយោជន៍ផងដែរសំរាប់ការកំណត់ថា តើមានធនធានប្រភេទណាមួយដែលស្ថិតនៅក្រោមសម្ពាធប្រមូលផលខ្ពស់ជាងគេ ហើយដែលជាហេតុធ្វើឱ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់យ៉ាងពិសេសទៅលើធនធានប្រភេទនេះ។ តំលៃគឺជាវិធីវាស់វែងនូវសារប្រយោជន៍នៃផលិតផល។ ដោយសារតែតំលៃជះឥទ្ធិពលទៅលើឥរិយាបថរបស់មនុស្ស នោះសម្ពាធនៃការប្រមូលផលមាន ទំនោរខ្លាំងជាងគេទៅលើផលិតផលណាដែលមានតំលៃខ្ពស់ជាងគេដែរ។ ជាឧទាហរណ៍ ត្រីប្រភេទមានតំលៃកាន់តែខ្ពស់នឹងតំរូវឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំង និងការខិតខំនេសាទត្រីប្រភេទនេះក៏មានទំហំធំជាងប្រភេទត្រីមានតំលៃទាបជាងផងដែរ ដូច្នេះត្រីប្រភេទនេះអាចទាមទារនូវការចាប់អារម្មណ៍យ៉ាងពិសេសពីអ្នកគ្រប់គ្រងឆ្នេរទៅតាមនោះដែរ។

តំលៃទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រក៏មានសារប្រយោជន៍ផងដែរដើម្បីយល់ដឹងអំពីកំរិតនៃចំណូលតាមគ្រួសារ និងជីវភាពរស់នៅតាមគ្រួសារ។ ជាឧទាហរណ៍ ប្រសិនបើតំលៃផលិតផលផ្លាស់ប្តូរពី "ខ្ពស់" ទៅ "ទាប" នោះគេក៏រំពឹងទុកនូវការធ្លាក់ចុះនៃចំណូល និងជីវភាពរស់នៅទៅតាមនោះដែរ។

## *KS18. គោលដៅទីផ្សារទំនិញ និងសេវាកម្ម*

### ការកំណត់និយមន័យ

ទំនោរទីផ្សារទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រគឺជាការកំណត់នូវទីផ្សារណាដែលផលិតផលនីមួយៗត្រូវបានដាក់លក់ជាចំបង។

| សកម្មភាពតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្ម តំបន់ឆ្នេរ និងសមុទ្រ | ទំនោរទីផ្សារ ទំនិញ និង សេវាកម្ម (សំខាន់) |
|---|---|---|
| *នេសាទ* | *បង្កង* | *អន្តរជាតិ* |
| | *ត្រីតុកកែ* | *ក្នុងតំបន់* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *អន្តរជាតិ* |
| | *មុជទឹកកំសាន្ត បាតសមុទ្រ* | *អន្តរជាតិ* |
| *វារីវប្បកម្ម* | *ខ្យង* | *ក្នុងមូលដ្ឋាន* |

## វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចទទួលបានទិន្នន័យស្ដីពីទំនោរទីផ្សារទំនិញ និង សេវាកម្មតំបន់ឆ្នេរនិងសមុទ្រតាមរយៈការធ្វើបទសម្ភាសន៍ ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗនៅក្នុងមូលដ្ឋាន ដូចជា អ្នកនេសាទ អ្នកទិញ ប្រតិបត្តិករសណ្ឋាគារ និង ប្រតិបត្តិករសេវាកម្មមុជទឹកកំសាន្តក្នុងបាតសមុទ្រជាដើម។ គេអាចសាកសួរអ្នកផ្ដល់ព័ត៌មានសំខាន់ទាំងនេះ ដើម្បីទទួលបានព័ត៌មានស្ដីអំពីទីផ្សារសំខាន់សំរាប់ទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រនីមួយៗ។

គេក៏អាចសាកសួរអ្នកផ្ដល់ព័ត៌មានសំខាន់ដើម្បីធ្វើការកំណត់នូវទីផ្សារសំខាន់ណាដែលទំនិញ និងសេវាកម្មប្រភេទនីមួយៗ ត្រូវដាក់លក់ (ទីផ្សារក្នុងមូលដ្ឋាន ក្នុងតំបន់ ក្នុងប្រទេស និងអន្តរជាតិ)។ សូមកត់ត្រាបញ្ចូលព័ត៌មានជាលទ្ធផលទាំងនេះចូលទៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការប្រមូលទិន្នន័យបន្ថែម :* តាមជំរើសផ្សេងមួយទៀត គេក៏អាចស្នើឱ្យអ្នកផ្ដល់ព័ត៌មានសំខាន់ធ្វើការបញ្ជាក់នូវបណ្ដាទីផ្សារទាំងអស់ដែលទំនិញ និងសេវាកម្មនីមួយៗត្រូវបានលក់ និងចាត់ចំណាត់ថ្នាក់សារៈសំខាន់នៃទីផ្សារនីមួយៗទាំងនោះ។ ធ្វើដូច្នេះផ្ដល់នូវសារប្រយោជន៍ក្នុងការស្វែងយល់អំពីទីផ្សារទាំងអស់។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្ដល់ព័ត៌មានសំខាន់ៗបញ្ចូលទៅក្នុងតារាងនៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* សេចក្ដីបរិយាយខ្លីមួយដែលផ្អែកទៅលើតារាងខាងលើអាចត្រូវបានរៀបចំឡើងដោយពណ៌នានូវទីផ្សារសំរាប់ទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រនីមួយៗ។ ដ្យាក្រាមមួយអាចនឹងត្រូវបានរៀបចំឡើងផងដែរ ដើម្បីបង្ហាញអំពីលំហូរនៃទំនិញ និងសេវាកម្មនីមួយៗពីប្រភពរបស់វាទៅកាន់ទីផ្សារ។

## សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

ទំនោរទីផ្សារទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រមានសារប្រយោជន៍ដើម្បីធ្វើការកំណត់នូវផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍នៅក្នុងតំបន់សិក្សា រួមមានដូចជា របរចិញ្ចឹមជីវិត ទីផ្សារ ផលិតកម្ម និង

សន្តិសុខស្បៀង។ ជាឧទាហរណ៍ ដោយហេតុថា មុខរបរ និងចំណូលរបស់ប្រជាជននៅក្នុងតំបន់សិក្សាមានជាប់ពាក់ព័ន្ធគ្នាជាមួយទីផ្សារនោះ ទំនោរទីផ្សារត្រីមានសារៈសំខាន់ក្នុងការកំណត់នូវទីកន្លែងដែលទំនិញ និងសេវាកម្មផលិតនៅក្នុងតំបន់នោះត្រូវបានលក់។ កត្តានេះអនុញ្ញាតឱ្យមានការវិភាគនូវបំលាស់ប្តូរជាបន្តបន្ទាប់នៃបណ្តាញទីផ្សារសំរាប់ទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រសំខាន់ៗ។ វាបង្ហាញឱ្យឃើញនូវទំនាក់ទំនងនៃផលិតករ និងពាណិជ្ជករក្នុងមូលដ្ឋានជាមួយនឹងទីផ្សារផ្សេងៗ ដូចជាទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិដែលអាចប៉ះពាល់ដល់ ការអនុវត្តនៃការប្រមូលផលជាដើម។

ទំនោរទីផ្សារក៏អាចផ្តល់សារប្រយោជន៍ជាសូចនាករមួយបង្ហាញអំពីទំហំសម្ពាធដែលអាចដាក់ទៅលើធនធានផងដែរ ។ ឧទាហរណ៍ អ្នកនេសាទអាចដាក់ការខិតខំប្រឹងប្រែងខ្ពស់របស់ខ្លួនទៅលើការនេសាទត្រីដែលមានតំលៃខ្ពស់សំរាប់ទីផ្សារអន្តរជាតិ។ វាក៏អាចបង្ហាញឱ្យឃើញជាបន្តបន្ទាប់នូវការផ្លាស់ប្តូរនៃទីផ្សារសំរាប់ទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រផងដែរ។ គេអាចធ្វើការវាយតំលៃអំពីផលប៉ះពាល់នៃវិធានការគ្រប់គ្រងបានតាមរយៈការផ្លាស់ប្តូរនៃទីផ្សារ។ ជាឧទាហរណ៍ បណ្តាវិធានការគ្រប់គ្រងទាំងឡាយអាចនាំឱ្យត្រីនៅក្នុងតំបន់នោះមានតំលៃខ្ពស់ជាងមុន ដែលអាចនាំទៅលក់នៅក្នុងទីផ្សារក្នុងតំបន់ និងទីផ្សារក្នុងប្រទេសបាន។

## *KS19. លំនាំនៃការប្រើប្រាស់*

### ការកំណត់និយមន័យ

លំនាំនៃការប្រើប្រាស់សំដៅដល់ទីតាំងសកម្មភាពតាមតំបន់ឆ្នេរ និងសមុទ្រ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

ដំបូង គេអាចប្រមូលទិន្នន័យស្តីពីលំនាំនៃការប្រើប្រាស់បានពីប្រភពបន្ទាប់បន្សំ ដូចជា ពីការិយាល័យភូមិ និងក្រុង ជាទីដែលអាចមានផែនទីបង្ហាញអំពីទីតាំងសកម្មភាពផ្សេងៗនៅក្នុងតំបន់សិក្សា (ដូចជា ផែនទីតំបន់ដែលបញ្ជាក់អំពីតំបន់កសិកម្ម ការសិក្សាផ្នែកជលផលដែលបញ្ជាក់អំពីតំបន់នេសាទ)។ បន្ទាប់មក បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបានធ្វើឡើងជាមួយអ្នកតំណាងឱ្យសកម្មភាពនីមួយៗ (ដូចជា ប្រធានសមាគមសណ្ឋាគារជាដើម)។ នៅទីបញ្ចប់ ការអង្កេតត្រូវបានប្រើប្រាស់ដើម្បីធ្វើការកំណត់ និងផ្ទៀងផ្ទាត់នូវលំនាំនៃការប្រើប្រាស់ផ្សេងៗ។

ការប្រមូលព័ត៌មានអំពីទីតាំងសកម្មភាពនីមួយៗ ត្រូវធ្វើឡើងដោយផ្អែកតាមទំនិញ ឬសេវាកម្មទាំងនោះ ហើយកត់ត្រាព័ត៌មានទាំងនោះបញ្ចូលទៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

| សកម្មភាពតំបន់ឆ្នេរនិងសមុទ្រ | ទំនិញ និង សេវាកម្មតំបន់ឆ្នេរ និងសមុទ្រ | ប្រភេទនៃការប្រើប្រាស់ (សំខាន់ៗ) | លំនាំនៃការប្រើប្រាស់ |
|---|---|---|---|
| *នេសាទ* | *បង្កង* | *លប* | *ឆកសមុទ្រ* |
| | *ត្រីតុកកែ* | *ខ្សែសន្ទូច* | *ថ្មប៉ប្រះទឹក* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *ផ្ទះសំណាក់ (១-៧បន្ទប់)* | *ឆ្នេរសមុទ្រ* |
| | *មុជទឹកកំសាន្ត បាតសមុទ្រ* | *ឧបករណ៍ដកដង្ហើម* | *ថ្មប៉ប្រះទឹក* |
| *វារីវប្បកម្ម* | *ខ្យង* | *ខ្សែសន្ទូច* | *ឆកសមុទ្រ* |

*ការប្រមូលទិន្នន័យបន្ថែម :* ក្រុមតាមដានអាចកត់ត្រានូវបណ្តាទីតាំងនៃសកម្មភាពផ្សេងៗនៅលើផែនទីគោលដែលផ្តល់ព័ត៌មានជាច្រើនអំពីទីតាំងជាជាងការដែលកត់ត្រាត្រឹមតែ "ឆកសមុទ្រ" ឬ "ថ្មប៉ប្រះទឹក" យ៉ាងខ្លី។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីប្រភពបន្ទាប់បន្សំ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗដើម្បីកំណត់នូវទីតាំងនៃសកម្ម-ភាពទាំងនោះ ដែលទិន្នន័យទាំងនេះចាំបាច់ត្រូវកត់ត្រាបញ្ចូលលើតារាងនោះនៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ /ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគទិន្នន័យបន្ថែម :* ទិន្នន័យទាំងនេះក៏អាចដាក់បង្ហាញនៅលើផែនទីគោលដែលមានកត់សំគាល់នូវតំបន់សិក្សាផងដែរ។ តាមរយៈការប្រៀបធៀបនូវបណ្តាទីតាំងនៃសកម្មភាពផ្សេងៗគ្នាទាំងនោះ ក្រុមតាមដានអាចកំណត់បាននូវតំបន់ដែលត្រួតគ្នា ហើយដែលអាចកើតមានជំលោះ។ សូមធ្វើការប្រៀបធៀបទីតាំងទាំងនោះជាបន្តបន្ទាប់ ដើម្បីពិនិត្យមើលនូវរបៀបដែលទំរង់ទាំងនោះមានការផ្លាស់ប្តូរ។ សេចក្តីបរិយាយសង្ខេបមួយអាចត្រូវបានរៀបចំឡើងដោយពណ៌នានូវសកម្មភាពទាំងនោះ ទីតាំងសកម្មភាពទាំងនោះ និងរបៀបដែលសកម្មភាពទាំងនោះផ្លាស់ប្តូរ ពីពេលមួយទៅពេលមួយផងដែរ។

## សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

ស្រដៀងគ្នាទៅនឹង *ប្រភេទបរិបំរាស់ (KS16)* ផងដែរ ព័ត៌មានស្តីពីលំនាំនៃការប្រើប្រាស់ទាំងនេះមានសារ-ប្រយោជន៍ក្នុងការកំណត់នូវកត្តាគំរាមកំហែងនានាចំពោះបណ្តាធនធានតំបន់ឆ្នេរ និងសមុទ្រ។ អ្នកគ្រប់គ្រង

អាចកំណត់បានកាន់តែប្រសើរនូវផលប៉ះពាល់ទាំងនេះ តាមរយៈការយល់ដឹងអំពីទីតាំងនៃសកម្មភាពទាំងនោះ។ ជាឧទាហរណ៍ ប្រសិនបើការអភិវឌ្ឍន៍សណ្ឋាគារកំពុងកើតមាននៅក្បែរតំបន់ថ្មប៉ប្រះទឹកនោះ វាអាចបង្កផលប៉ះពាល់ពីការហូរហៀរកាកសំណល់ និងការបង្ហូរទឹកល្វ។ ទំហំនៃតំបន់នោះក៏ជាសូចនាករមួយបង្ហាញអំពីកំរិតនៃផលប៉ះពាល់ផងដែរ។ ការនេះផ្តល់ផលប្រយោជន៍យ៉ាងពិសេស ដោយហេតុថា ព័ត៌មានពី*ប្រភេទបំរើបំរាស់* ផ្តល់ឱ្យយើងយល់ដឹងអំពីសកម្មភាពដែលកំពុងកើតមាន ប៉ុន្តែមិនច្រើនពេកនោះទេ។

តាមរយៈការតាមដានព័ត៌មាននេះជាបន្តបន្ទាប់ អ្នកគ្រប់គ្រងក៏អាចពិនិត្យឃើញផលប៉ះពាល់ដែលការគ្រប់គ្រងបង្កទៅលើសកម្មភាពទាំងនេះ។ ជាឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងឆ្នេរបានចាប់ផ្តើមធ្វើយុទ្ធនាការដាំព្រៃកោងកាងឡើងវិញ តែការកាប់បំផ្លាញព្រៃកោងកាងនៅតែបន្តស្ថិតក្នុងបញ្ជីជាសកម្មភាពមួយនៅឡើយនោះ អ្នកគ្រប់គ្រងអាចពិនិត្យមើលលើទំហំនៃតំបន់ដែលរងការកាប់បំផ្លាញនោះ ហើយសង្កេតមើលថា តើទំហំនោះមានការកើនឡើង ឬថយចុះ ឬនៅដដែលពីឆ្នាំមុនៗ។ ប្រសិនបើវាថយចុះនោះ កម្មវិធីនេះប្រហែលជាមានឥទ្ធិពលជាវិជ្ជមានមួយចំនួនហើយ។ ព័ត៌មាននេះក៏ជួយដល់ការកំណត់នូវប្រសិទ្ធភាពនៃបណ្តាកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរទាំងឡាយផងដែរ។

ជាទីបញ្ចប់ តាមរយៈការគូសវាសផែនទីលំនាំនៃការប្រើប្រាស់នោះ បណ្តាអ្នកគ្រប់គ្រងអាចយល់អំពីបញ្ហាបានកាន់តែប្រសើរ ជាពិសេសអំពីជំលោះលើលទ្ធភាពក្នុងការទាញផលពីធនធាន និងការប្រើប្រាស់ត្រួតគ្នា នៅក្នុងចំណោមបណ្តាក្រុមអ្នកពាក់ព័ន្ធនានា។ ការនេះអាចជួយកំណត់បានថា តើវិធានការគ្រប់គ្រងទាំងអស់ ដូចជាវិធានការ កំណត់តំបន់សំរាប់សកម្មភាព មានភាពសមស្របសំរាប់តំបន់មួយដែរ ឬយ៉ាងណា។

## *KS20 & KS21. កំរិត និងប្រភេទនៃផលប៉ះពាល់*

### ការកំណត់និយមន័យ

កំរិត និងប្រភេទនៃផលប៉ះពាល់គឺជាវិធានការដើម្បីស្វែងយល់អំពីទស្សនៈយល់ឃើញរបស់សាធារណជនទូទៅ និងប្រភេទផលប៉ះពាល់នៃសកម្មភាពតាមតំបន់ឆ្នេរ និងសមុទ្រទៅលើធនធានតំបន់ឆ្នេរ និងសមុទ្រ។ នេះមិនមែនជាការវាយតំលៃជាក់លាក់មួយអំពីកំរិត និងប្រភេទនៃផលប៉ះពាល់នោះទេ ប៉ុន្តែគ្រាន់តែជាការចងក្រងជាឯកសារមួយអំពីអ្វីដែលប្រជាជនគិតប៉ុណ្ណោះ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចប្រមូលទិន្នន័យប្រភេទនេះ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជាមន្ត្រីភូមិ សមាជិកយុវអង្វែងនៅក្នុងសហគមន៍ និងអ្នកដទៃទៀតដែលតំណាងឱ្យទស្សនៈទូទៅរបស់សហគមន៍។

អ្នកផ្តល់ព័ត៌មានសំខាន់ៗទាំងនេះត្រូវបានស្នើឱ្យធ្វើការកំណត់នូវកំរិតផលប៉ះពាល់នៃសកម្មភាពតាមតំបន់ឆ្នេរ និងសមុទ្រនីមួយៗទៅតាមទំនិញ និងសេវាកម្មសកម្មភាពទាំងនោះ ដោយប្រើប្រាស់នូវមាត្រដ្ឋានកំរិតខ្ពស់/មធ្យម/ទាប/គ្មាន។ ខណៈដែលកំរិតទាំងនោះនឹងត្រូវបានសំរបសំរួលទៅតាមតំបន់សិក្សានីមួយៗនោះ កំរិតខ្ពស់អាចមានន័យថា ជាផលប៉ះពាល់ទៅលើធនធានក្នុងកំរិតធ្ងន់ធ្ងរ និងមិនអាចស្តារឡើងវិញបាន ដូចជាការកាប់ព្រៃកោងកោង ហើយចាក់បំពេញដីនៅតំបន់នោះ កំរិតមធ្យមអាចមានន័យថា ជាផលប៉ះពាល់ទៅលើធនធានក្នុងកំរិតមធ្យម ដូចជាការកាប់ព្រៃកោងកាង កំរិតទាបអាចមានន័យថា ជាផលប៉ះពាល់ទៅលើធនធានក្នុងកំរិតតិចតួច ដូចជាផ្ទៃព្រៃកោងកាងមួយភាគតូចត្រូវបានទទួលការយាយីរំខាន និងកំរិតគ្មានអាចមានន័យថាគ្មានផលប៉ះពាល់អ្វីទាំងអស់។ បន្ទាប់មក ប្រភេទនៃផលប៉ះពាល់សំខាន់ៗ ត្រូវបានកត់ចំណាំខ្លីៗ។ឧទាហរណ៍ ប្រសិនបើការអភិវឌ្ឍន៍សណ្ឋាគារកំពុងបង្កឱ្យមានការបំពុលនោះ "ការបំពុល" នឹងត្រូវបានកត់សំគាល់។ សូមកត់ត្រាបញ្ចូលព័ត៌មាន ជាលទ្ធផលទាំងនោះចូលទៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការប្រមូលទិន្នន័យបន្ថែម :* ប្រភេទនៃផលប៉ះពាល់អាចត្រូវបានពណ៌នាពិស្តារជាងនេះ ដើម្បីកំណត់នូវផលប៉ះពាល់ផ្ទាល់ និងមិនផ្ទាល់។ ឧទាហរណ៍ ការហូរហៀរលូរបង្ហូរទឹកគឺជាផលប៉ះពាល់ដោយផ្ទាល់មួយទៅលើគុណភាពទឹក និងការធ្វើកសិកម្មក្នុងខ្សែទឹកខាងលើអាចបង្កឱ្យមានជាដីល្បប់នៅក្នុងអំឡុងរដូវវស្សារ។

| សកម្មភាពតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្មតំបន់ឆ្នេរ និងសមុទ្រ | ប្រភេទនៃការប្រើប្រាស់ (សំខាន់ៗ) | កំរិតនៃផលប៉ះពាល់ | ប្រភេទនៃផលប៉ះពាល់ (សំខាន់ៗ) |
|---|---|---|---|---|
| *នេសាទ* | *បង្កង* | *លប* | *ទ* | *នេសាទហួសកំរិត* |
| | *ត្រីតុកកែ* | *ខ្សែរសន្ទូច* | *ទ* | *នេសាទហួសកំរិត* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *ផ្ទះសំណាក់ (១-៧បន្ទប់)* | *ខ* | *ការបំពុល* |
| | *មុជទឹកកំសាន្ត បាតសមុទ្រ* | *ឧបករណ៍ដកដង្ហើម* | *ខ* | *ការខូចខាតយុថ្កា* |
| *វារីវប្បកម្ម* | *ខ្យង* | *ខ្សែរសន្ទូច* | *ម* | *បន្ទុកជីវជាតិ* |

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ធ្វើសំយោគទិន្នន័យនេះ ដើម្បីកំណត់ពីកំរិតទូទៅនៃផលប៉ះពាល់ និងប្រភេទនៃផលប៉ះពាល់ រួចបញ្ចូលវាទៅក្នុងតារាងនៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម* : លទ្ធផលទាំងនេះត្រូវបានយកទៅធ្វើការប្រៀបធៀបជាមួយនឹងលទ្ធផលពីឆ្នាំមុនៗដើម្បីកំណត់នូវការផ្លាស់ប្តូរនៃប្រភេទ និងកំរិតនៃផលប៉ះពាល់។ ការ ផ្លាស់ប្តូរទាំងនេះត្រូវបានយកទៅប្រៀបធៀបជាមួយនឹងលក្ខណៈរបស់ធនធានដើម្បីកំណត់ថា តើមានភាពជាប់ពាក់ព័ន្ធគ្នាដែរឬយ៉ាងណា។ ទិន្នន័យស្រដៀងគ្នានេះត្រូវប្រមូលជាផ្នែកមួយនៃបទសម្ភាសន៍តាមគ្រួសារដោយសាកសួរប្រជាជនអំពីអ្វីដែលពួកគេគិតថាគឺជាការគំរាមកំហែងធំៗចំនួនប្រាំចំពោះធនធានឆ្នេរ។ ការប្រៀបធៀបរវាងលទ្ធផលទាំងឡាយអនុញ្ញាតឱ្យយើងអាចត្រួតពិនិត្យមើលនូវភាពប្រាកដប្រជានៃទិន្នន័យនេះ។ បណ្តាសកម្មភាពដែលកំណត់ឡើងដោយបុគ្គលទាំងឡាយ គួរត្រូវបានកត់សំគាល់ថា "ខ្ពស់" នៅក្នុងតារាងដែលបំពេញដោយអ្នកផ្តល់ព័ត៌មានសំខាន់ៗ។ ប្រសិនបើមានភាពខុសគ្នាច្រើនរវាងលទ្ធផលទាំងនោះ គេគប្បីធ្វើការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗដើម្បីធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់។ ការធ្វើស្ទង់មតិប្រជាជនពេញលេញមួយអាចនឹងចាំបាច់ត្រូវធ្វើឡើងដើម្បីកំណត់ឱ្យបានច្បាស់នូវទស្សនៈយល់ដឹងរបស់ពួកគេ។

## សារៈសំខាន់នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

ស្រដៀងគ្នាទៅនឹង*ប្រភេទបរិបរាស់ (KS16)* និង *លំនាំនៃការប្រើប្រាស់ (KS19)* ផងដែរ ព័ត៌មានស្តីពីកំរិត និងប្រភេទនៃផលប៉ះពាល់មានសារប្រយោជន៍សំរាប់ធ្វើការកំណត់នូវការគំរាមកំហែងចំពោះធនធានឆ្នេរ។ សមាជិកសហគមន៍ ជាពិសេសប្រជាជនដែលប្រើប្រាស់ធនធានដោយផ្ទាល់ជាធម្មតាមានចំណេះដឹងច្រើនជាងគេអំពីអ្វីដែលកំពុងបង្កផលប៉ះពាល់ជាទៀងទាត់ដល់ធនធានដែលពួកគេប្រើប្រាស់។ ព័ត៌មាននេះអាចមាន

សារៈសំខាន់សំរាប់ធ្វើការកំណត់នូវបណ្តុសកម្មភាពដែលចាំបាច់សំរាប់ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ ជាឧទាហរណ៍ សមាជិកសហគមន៍អាចនឹងកត់សំគាល់ថា ការអភិវឌ្ឍន៍ផ្នែកប្រេង និងឧស្ម័ន គឺជាកត្តាបង្កផលប៉ះពាល់ខ្ពស់ ដោយសារតែពួកគេធ្លាប់បានឃើញការកំពប់សារធាតុទាំងនេះក្នុងបរិមាណច្រើនរយៈពេលប៉ុន្មានដង។ ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រដែលធ្វើឡើងក្នុងរយៈពេលតែម្តងក្នុងមួយឆ្នាំនោះអាចនឹងខកខានមិនបានបញ្ចូលនូវផលប៉ះពាល់នេះ។

តាមរយៈការតាមដានព័ត៌មាននេះជាបន្តបន្ទាប់នោះ អ្នកគ្រប់គ្រងក៏អាចពិនិត្យឃើញនូវផលប៉ះពាល់ដែលការគ្រប់គ្រងបានបង្កទៅលើសកម្មភាពទាំងនេះ ហើយដូច្នេះពួកគេក៏អាចពិនិត្យដឹងថា តើការគ្រប់គ្រងនោះមានប្រសិទ្ធភាពបានត្រឹមកំរិតណាផងដែរ។ ឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងឆ្នេរបានផ្តួចផ្តើមបង្កើតកម្មវិធីមួយ ដើម្បីកាត់បន្ថយនូវការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងសារធាតុគីមីដទៃទៀតនៅក្នុងតំបន់កសិកម្មបញ្ច្រាស់ទឹក ប៉ុន្តែការប្រើប្រាស់សារធាតុទាំងនេះនៅតែបន្តស្ថិតនៅជាប្រភេទនៃផលប៉ះពាល់មួយដដែលនោះមានន័យថា កម្មវិធីគ្រប់គ្រងឆ្នេរនោះមិនមានប្រសិទ្ធភាពនោះទេ។

ជាទីបញ្ចប់ ព័ត៌មាននេះពិតជាមានសារៈសំខាន់សំរាប់ការបង្កើតកម្មវិធីលើកកំពស់ការយល់ដឹង និងការស្វះស្វែងឱ្យមានការចូលរួមពីក្រុមអ្នកពាក់ព័ន្ធ។ ប្រសិនបើសមាជិកសហគមន៍មិនគិតថាមានផលប៉ះពាល់ទៅលើធនធានតំបន់ឆ្នេរទេ នោះវានឹងមានការពិបាកក្នុងការទាក់ទាញឱ្យពួកគេចូលរួមនៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ។ ប្រសិនបើសមាជិកសហគមន៍គិតថា មានតែសកម្មភាពមួយ ឬពីរប៉ុណ្ណោះដែលកំពុងបង្កផលប៉ះពាល់ទៅលើធនធាន ប៉ុន្តែ ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្របានបង្ហាញថា មានផលប៉ះពាល់ជាច្រើនផ្សេងទៀត នោះគេអាចចាំបាច់បង្កើតកម្មវិធីយល់ដឹងមួយ ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេអំពីបណ្តុសកម្មភាពទាំងអស់ដែលកំពុងបង្កផលប៉ះពាល់ទៅលើធនធាន។

## *KS22. កំរិតការប្រើប្រាស់របស់អ្នកពីខាងក្រៅ*

### ការកំណត់និយមន័យ

កំរិតនៃការប្រើប្រាស់របស់អ្នកពីខាងក្រៅសំដៅដល់ចំនួនអ្នកខាងក្រៅ ដែលប្រើប្រាស់ធនធានឆ្នេរដោយប្រៀបធៀបទៅនឹងចំនួនអ្នកប្រើប្រាស់ក្នុងស្រុកពីតំបន់សិក្សា។ ជាឧទាហរណ៍ ប្រសិនបើមានអ្នកនេសាទបរទេសចំនួន ១000 នាក់ ហើយអ្នកនេសាទក្នុងស្រុកតែ ១០ នាក់ នោះកំរិតនៃការប្រើប្រាស់ដោយអ្នកពីខាងក្រៅមានកំរិតខ្ពស់។ អ្នកពីខាងក្រៅគឺជាប្រជាជនដែលមិនរស់នៅក្នុងតំបន់សិក្សា។ ពួកគេអាចធ្វើដំណើរមកពីភូមិក្បែរខាង ឬ ពីប្រទេសផ្សេង។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

គេអាចទទួលបានព័ត៌មាននេះតាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា មេភូមិ ឬ មន្ត្រីក្រុង ព្រមទាំងអ្នកតំណាងមកពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ។

អ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបានសាកសួរអំពីកំរិតនៃការប្រើប្រាស់ដោយអ្នកពីខាងក្រៅនាពេលបច្ចុប្បន្នសំរាប់សកម្មភាពតាមតំបន់ឆ្នេរ និងសមុទ្រនីមួយៗ ដោយប្រើប្រាស់មាត្រដ្ឋានកំរិត ខ្ពស់ មធ្យម និងទាប។ មាត្រដ្ឋាននេះនឹងត្រូវកំណត់ទៅតាមតំបន់សិក្សានីមួយៗ ប៉ុន្តែទោះជាយ៉ាងណា កំរិតខ្ពស់មានន័យសំដៅដល់ចំនួននៃការប្រើប្រាស់ច្រើនដោយអ្នកពីខាងក្រៅ ឧទាហរណ៍ ភាគច្រើននៃការនេសាទនៅក្នុងតំបន់សិក្សានោះត្រូវបានធ្វើឡើងដោយអ្នកពីខាងក្រៅ កំរិតមធ្យមមានន័យសំដៅដល់កំរិតនៃការប្រើប្រាស់ជាមធ្យមដោយអ្នកពីខាងក្រៅ ឧទាហរណ៍ មានវត្តមានភ្ញៀវទេសចរមួយចំនួន និងកំរិតទាបអាចមានន័យសំដៅដល់កំរិតនៃការប្រើប្រាស់ទាបដោយអ្នកពីខាងក្រៅ ឧទាហរណ៍ ក្នុងចំណោមផ្ទះសំណាក់ចំនួនម្ភៃនៅក្នុងតំបន់សិក្សាមានតែផ្ទះសំណាក់តែមួយប៉ុណ្ណោះជាកម្មសិទ្ធិរបស់ជនបរទេស។ ចំលើយត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការប្រមូលទិន្នន័យបន្ថែម :* អ្នកផ្តល់ព័ត៌មានសំខាន់ៗអាចត្រូវបានស្នើឱ្យធ្វើការកំណត់នូវប្រភពដើម ជាទីដែលអ្នកពីខាងក្រៅទាំងនោះធ្វើដំណើរមកកាន់តំបន់សិក្សានេះ។

| សកម្មភាពតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្ម តំបន់ឆ្នេរ និងសមុទ្រ | ប្រភេទនៃការប្រើប្រាស់ (សំខាន់ៗ) | កំរិតនៃការប្រើប្រាស់របស់អ្នកពីខាងក្រៅ |
|---|---|---|---|
| *នេសាទ* | *បង្កង* | *លប* | *ទ* |
| | *ត្រីតុកកែ* | *ខ្សែសន្ទូច* | *ទ* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *ផ្ទះសំណាក់ (១-៧បន្ទប់)* | *ខ* |
| | *មុជទឹកកំសាន្តនៅបាតសមុទ្រ* | *ឧបករណ៍មុជទឹក* | *ខ* |
| *វារីវប្បកម្ម* | *ខ្យង* | ខ្សែសន្ទូច | *ម* |

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័ត៌ -មានសំខាន់ៗ ដើម្បីកំណត់ពីកំរិតនៃការប្រើប្រាស់ដោយអ្នកពីខាងក្រៅសំរាប់សកម្មភាពនីមួយៗ រួចបញ្ចូលវាទៅក្នុងតារាងនៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៏ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* ចូរធ្វើការប្រៀបធៀបកំរិតទាំងនេះជាបន្តបន្ទាប់ ។ប្រធានខ្លីមួយអាចត្រូវបានរៀបចំឡើងដោយធ្វើការសង្ខេបទំហំការប្រើប្រាស់របស់ប្រជាជនចំណូលស្រុក និងរបៀបដែលទំហំនោះបានផ្លាស់ប្តូរពីពេលមួយមួយ។

## សារប្រយោជន៏នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

ព័ត៌មានស្តីពីកំរិតនៃការប្រើប្រាស់ដោយអ្នកពីខាងក្រៅផ្តល់ជាសារប្រយោជន៏សំរាប់ធ្វើការទាក់ទាញការចូលរួមពីអ្នកពាក់ព័ន្ធ និងការបង្កើតនូវកម្មវិធីលើកកំពស់ការយល់ដឹងផ្សេងៗ។ ជាញឹកញាប់ អ្នកមិនមានទីលំនៅនៅក្នុងតំបន់សិក្សាត្រូវបានគេមើលរំលង ដោយសារតែគេមិនកត់សំគាល់ឃើញពួកគេបានដោយភ្លាមៗ។ ការដែលបានដឹងអំពីចំនួនប្រជាជនដែលធ្វើដំណើរមកពីតំបន់ដទៃ អាចជួយឱ្យអ្នកគ្រប់គ្រងអាចកំណត់បាននូវសារៈសំខាន់នៃការកសាងទំនាក់ទំនងជាមួយប្រជាជនមកពីខាងក្រៅសហគមន៏។ ប្រសិនបើអ្នកគ្រប់គ្រងបានដឹងអំពីទីកន្លែងដែលអ្នកពីខាងក្រៅទាំងនោះធ្វើដំណើរមកពីនោះ លោក/លោកស្រីអាចធ្វើការកំណត់គោលដៅតំបន់ទាំងនោះបាន។ ក្នុងករណីដែលមានអ្នកធ្វើដំណើរមកពីបរទេស (ដូចជា ទូកនេសាទបរទេស) អ្នកគ្រប់គ្រងអាចនឹងសំរេចចិត្តធ្វើការតាមរយៈការិយាល័យគយ និងអន្តោប្រវេសន៏។ នៅករណីដោយឡែកផ្សេងទៀត គេក៏អាចធ្វើការពង្រីកកម្មវិធីអប់រំ និងចុះ ផ្ទាល់ទៅកាន់សហគមន៏ក្បែរខាងផ្សេងទៀតទាំងនោះផងដែរ។ ការប្រើប្រាស់ដោយអ្នកពីខាងក្រៅក៏ផ្តល់នូវសារៈសំខាន់ផងដែរក្នុងការស្វែងយល់អំពីបញ្ហាគ្រប់គ្រងតំបន់ឆ្នេរ។ ជាឧទាហរណ៏ ចំនួនបរទេសកើនឡើងអាចក្លាយជាប្រភពមួយនៃជំលោះនៅក្នុងសហគមន៏មួយផងដែរ។

ព័ត៌មាននេះក៏អាចផ្តល់ជាសារប្រយោជន៍ផងដែរសំរាប់ធ្វើការកំណត់នូវតំលៃ និងសារៈសំខាន់របស់ធនធានទាំងនោះ។ ប្រសិនបើប្រជាជនពីខាងក្រៅតំបន់សិក្សាកំពុងប្រើប្រាស់ធនធានទាំងនោះ នោះវាមានន័យថា ធនធានទាំងនោះមានសារៈសំខាន់ចំពោះតំបន់ដែលមានទំហំធំជាងសហគមន៍នោះផ្ទាល់។ នេះអាចផ្តល់សារៈសំខាន់ដើម្បីជាការជូនដំណឹងដល់អ្នកនយោបាយ និងសាធារណជនអំពីតំរូវការធនធានបន្ថែមសំរាប់ការគ្រប់គ្រងតំបន់ឆ្នេរ។

## *KS23. ការប្រើប្រាស់តាមគ្រួសារ*

### ការកំណត់និយមន័យ

ការប្រើប្រាស់តាមគ្រួសារនូវទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រគឺជាវិធានការមួយសំរាប់ធ្វើការវាស់ស្ទង់ថាតើ ប្រជាជនតាមគ្រួសារនីមួយៗនៅក្នុងតំបន់សិក្សានោះទាញផលពីទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រសំរាប់ការប្រើប្រាស់ ការលំហែ និងការលក់ដូរតាមរបៀបណា។

### វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចទទួលបានទិន្នន័យស្តីពីការប្រើប្រាស់តាមគ្រួសារនូវទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្របានតាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា មន្ត្រីក្នុងសហគមន៍ និងអាជីវករជាដើម។ គេសាកសួរ អ្នកផ្តល់ព័ត៌មានសំខាន់ៗដើម្បីធ្វើការកំណត់ និងចាត់ថ្នាក់ នូវការប្រើប្រាស់តាមគ្រួសារជាទូទៅនូវទំនិញ ឬសេវាកម្មនីមួយៗ។ អ្នកផ្តល់ព័ត៌មានសំខាន់ក៏ត្រូវបានសាកសួរផងដែរ ប្រសិនបើពួកគេទាញយកផលពីធនធានទាំងនោះ សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ការលំហែ ឬលក់ដូរផ្ទាល់ខ្លួនផងដែរនោះ។ "ការប្រើប្រាស់ផ្ទាល់ខ្លួន" មានន័យថាការប្រើប្រាស់នៅក្នុងផ្ទះ ដូចជា ត្រីសំរាប់ធ្វើជាអាហារជាដើម។ "ការលំហែ" មានន័យសំរាប់ការកំសាន្ត និង "លក់ដូរ"

| សកម្មភាពតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្មតំបន់ឆ្នេរ និងសមុទ្រ | ការប្រើប្រាស់របស់គ្រួសារ (សំខាន់ៗ) |
|---|---|---|
| *នេសាទ* | *បង្កង* | *លក់ដូរ* |
| | *ត្រីតុកកែ* | *ផ្ទាល់ខ្លួន* |
| *ទេសចរណ៍* | *សណ្ឋាគារ* | *លក់ដូរ* |
| | *មុជទឹកកំសាន្តបាតសមុទ្រ* | *លក់ដូរ* |
| *វារីវប្បកម្ម* | *ខ្យង* | *លក់ដូរ* |

មានន័យថា ជាការលក់ដើម្បីទទួលបានថវិកា ឬដើម្បីដោះដូរនឹងទំនិញដទៃទៀត។ ចំលើយត្រូវបានកត់ត្រាទុកនៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

**វិធីសាស្រ្តវិភាគទិន្នន័យ**

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័ត៌មានសំខាន់ៗបញ្ចូលទៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ /ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* ទិន្នន័យស្រដៀងគ្នាត្រូវបានប្រមូលជាផ្នែក មួយនៃបទសម្ភាសន៍តាមគ្រួសារ។ ការប្រៀបធៀបលទ្ធផលដែលទទួលបានទាំងនោះ អាចឱ្យយើងត្រួតពិនិត្យឃើញនូវភាពត្រឹម ត្រូវនៃទិន្នន័យទាំងនោះ។ ប្រសិនបើលទ្ធផលមានភាពខុសៗគ្នានោះ ដើម្បីជាប្រយោជន៍ គេគួរធ្វើការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីស្វែងរកមូលហេតុនៃភាពលំអៀងនោះ។ បើមិនដូច្នោះទេ គេគួរតែធ្វើស្ទង់មតិជាលក្ខណៈពេញលេញ (ធ្វើសម្ភាសន៍គ្រប់ផ្ទះទាំងអស់ មិនមែនតែមួយក្រុមអ្នកចូលរួមណាមួយទេ) ដើម្បីយល់ដឹងឱ្យបានច្បាស់អំពីទិន្នន័យប្រជាសាស្រ្តនៅក្នុងតំបន់សិក្សានោះ។

**សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង**

ព័ត៌មានអំពីការប្រើប្រាស់តាមគ្រួសារនូវទំនិញ និងសេវាកម្មតំបន់ឆ្នេរ និងសមុទ្រផ្តល់ឱ្យយើងយល់ដឹងអំពីការពឹងផ្អែករបស់ប្រជាជនតាមគ្រួសារទៅលើធនធានទាំងនោះដើម្បីធ្វើជាម្ហូបអាហារ និងបង្កើតប្រាក់ចំណូល។ ដូច្នេះ ជាការសំខាន់ដែលគួរយល់ដឹងអំពីបញ្ហាសន្តិសុខស្បៀងរបស់គ្រួសារទាំងនោះ។ ព័ត៌មាននេះអាចផ្តល់ជាផលប្រយោជន៍សំរាប់ការស្វែងយល់ថា តើវិធានការគ្រប់គ្រងអាចបង្កផលប៉ះពាល់ទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់អ្នកប្រើប្រាស់ធនធាន និងសន្តិសុខស្បៀងរបស់គ្រួសារទាំងនោះដោយរបៀបណាខ្លះ។ ជាឧទាហរណ៍ ប្រសិនបើគ្រួសារទាំងនោះពឹងផ្អែកជាចំលងទៅលើផលនេសាទរបស់ពួកគេនោះ នោះការដាក់វិធានការរិតត្បិតលើការនេសាទត្រូវបានរំពឹងថា អាចនឹងបង្កផលប៉ះពាល់ទៅលើលទ្ធភាពក្នុងការស្វែងរកចំណីអាហារ ហើយដូច្នេះវាធ្វើ ឱ្យប៉ះពាល់ដល់សន្តិសុខស្បៀងរបស់គ្រួសារទាំងនោះ។

## *KS24. អ្នកពាក់ព័ន្ធ*

**ការកំណត់និយមន័យ**

អ្នកពាក់ព័ន្ធគឺជាបណ្តាបុគ្គល ក្រុម ឬអង្គការទាំងឡាយរបស់ប្រជាជនដែលមានចំណាប់អារម្មណ៍ ជាប់ពាក់ព័ន្ធ ឬរង ផលប៉ះពាល់ (ទាំងវិជ្ជមាន និងអវិជ្ជមាន) ពីការគ្រប់គ្រងធនធានតំបន់ឆ្នេរ។ អ្នកពាក់ព័ន្ធទាំងនេះអាច ឬមិនអាចជាអ្នកដែលរស់នៅជាក់ស្តែងនៅក្នុង ឬជាប់នឹងតំបន់នោះដោយផ្ទាល់ ប៉ុន្តែគឺជាអ្នកដែលមានចំណាប់

អារម្មណ៍ ឬមានឥទ្ធិពលទៅលើការគ្រប់គ្រងធនធានតំបន់ឆ្នេរ។ សូមអានសៀវភៅ *GCRMN Manual ជំពូកទី១ : សកម្មភាពត្រៀមការកំណត់និយមន័យអ្នកជាប់ពាក់ព័ន្ធនឹងថ្មប៉ប្រះទឹក* សំរាប់ការយល់ដឹងបន្ថែម។

## វិធីសាស្ត្រប្រមូលទិន្នន័យ

ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (ដូចជា មន្ត្រីរដ្ឋាភិបាល មន្ត្រីជាប់ឆ្នោត អ្នកនេសាទ មេដឹកនាំអាជីវកម្ម) គឺ ដើម្បីកំណត់នូវអត្តសញ្ញាណក្រុមអ្នកពាក់ព័ន្ធសំខាន់ៗចំនួនបីសំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ (ដូចជា សកម្មភាព នេសាទ វារីវប្បកម្ម និងទេសចរណ៍)។ សកម្មភាពតាមតំបន់ឆ្នេរទាំងនេះត្រូវបានកំណត់ថាជាផ្នែកមួយនៃសូចនាករនេះ*សកម្មភាព (KS14)* និងត្រូវបានកត់សំគាល់នៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

| សកម្មភាពតាមតំបន់ឆ្នេរ* | ក្រុមអ្នកពាក់ព័ន្ធទី ១ | ក្រុមអ្នកពាក់ព័ន្ធទី ២ | ក្រុមអ្នកពាក់ព័ន្ធទី ៣ |
|---|---|---|---|
| *នេសាទ* | *អ្នកនេសាទនៅកន្លែងចំណតភាគខាងកើត* | *អ្នកនេសាទនៅកន្លែងចំណតភាគខាងលិច* | *អ្នកនេសាទនៅកន្លែងចំណតភាគខាងជើង* |
| *វារីវប្បកម្ម* | *ម្ចាស់ អ្នកគ្រប់គ្រង និងបុគ្គលិកវារីវប្បកម្ម* | | |
| *ទេសចរណ៍* | *ម្ចាស់ អ្នកគ្រប់គ្រង និងបុគ្គលិកសណ្ឋាគារ* | *ក្រុមហ៊ុនសេវាកម្មកីឡាលើទឹក* | *ភ្ញៀវទេសចរ* |
| ** បង្កើតតារាងទៅតាមសកម្មភាពដែលត្រូវបានកំណត់បញ្ចូលក្នុងបណ្តាសកម្មភាព (KS14)* | | | |

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័ត៌មានសំខាន់ៗបញ្ចូលទៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* សេចក្តីបរិយាយខ្លីមួយអាចត្រូវបានរៀបចំឡើងដើម្បីកំណត់នូវអត្តសញ្ញាណក្រុមអ្នកពាក់ព័ន្ធដែលមានចំណែកពាក់ព័ន្ធនៅក្នុងសកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។

## សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

បណ្តាអ្នកគ្រប់គ្រងធនធានតំបន់ឆ្នេរកាន់តែយល់ច្បាស់ថា ការចូលរួមយ៉ាងសកម្មនៃអ្នកពាក់ព័ន្ធធនធានតំបន់ឆ្នេរនៅក្នុងការរៀបចំផែនការ និងការគ្រប់គ្រង អាចបង្កើនភាពជោគជ័យនៃការគ្រប់គ្រងធនធានឆ្នេរ។ ប្រសិនបើ

ប្រជាជននៅក្នុងមូលដ្ឋានមានចំណែកពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានឆ្នេរ និងមានអារម្មណ៍ជាម្ចាស់របស់វានោះ ពួកគេក៏កាន់តែមានទំនោរចិត្តគាំទ្រដល់ការគ្រប់គ្រងធនធានតំបន់ឆ្នេរផងដែរ។ ការយល់ដឹងរបស់អ្នកពាក់ព័ន្ធនឹងអនុញ្ញាតឱ្យអ្នកគ្រប់គ្រងអាចធ្វើការកំណត់បានកាន់តែប្រសើរនូវបុគ្គលដែលអាចនឹងរងផលប៉ះពាល់ពីវិធានការគ្រប់គ្រង និងធ្វើការដោះស្រាយផលប៉ះពាល់ទាំងនេះជាមួយអ្នកពាក់ព័ន្ធទាំងនោះ។

គេធ្វើការកំណត់រកអ្នកពាក់ព័ន្ធក៏ដើម្បីបញ្ជាក់ថា តើអ្នកណាខ្លះគួរតែជាអ្នកត្រូវផ្តោតអារម្មណ៍នៅក្នុងការតាមដាននេះ។

## អភិបាលកិច្ច

### *KS25. ស្ថាប័នគ្រប់គ្រង*

#### ការកំណត់និយមន័យ

ស្ថាប័នគ្រប់គ្រងគឺជាស្ថាប័នមួយដែលដឹកនាំដំណើរការគ្រប់គ្រងធនធានតំបន់ឆ្នេរ និងធានាថា មានដំណើរការប្រកបដោយតំលាភាពមួយសំរាប់ធ្វើការរៀបចំផែនការ បង្កើត និងអនុវត្តន៍នូវគោលការណ៍ និងបទបញ្ញត្តិទាំងឡាយ។ ស្ថាប័នគ្រប់គ្រងអាចជា ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការក្នុងសហគមន៍ ហើយអាចធ្វើប្រតិបត្តិការនៅកំរិតមូលដ្ឋាន ខេត្ត/រដ្ឋ ជាតិ ឬអន្តរជាតិ។ នៅក្នុងតំបន់សិក្សាមួយក៏អាចមានស្ថាប័នគ្រប់គ្រងច្រើនធ្វើការសំរាប់សកម្មភាពតាមតំបន់ឆ្នេរផ្សេងៗ ដូចជា សកម្មភាពគ្រប់គ្រងតំបន់ឆ្នេរ ការអភិវឌ្ឍន៍ជលផល វារីវប្បកម្ម ព្រៃកោងកាង ទេសចរណ៍ ការដឹកជញ្ជូនតាមសមុទ្រ និងការអភិវឌ្ឍន៍លំនៅស្ថានជាដើម។

#### វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចទទួលព័ត៌មានអំពីស្ថាប័នគ្រប់គ្រងតាមរយៈការអានផែនការគ្រប់គ្រងសំរាប់សកម្មភាពផ្សេងៗ។ គេក៏អាចទទួលបានព័ត៌មាននេះ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលមានចំណេះដឹងអំពីការគ្រប់គ្រងធនធានតំបន់ឆ្នេរ ឬសកម្មភាពតាមតំបន់ឆ្នេរ (ដូចជា តំណាងទីភ្នាក់ងាររដ្ឋាភិបាល មន្ត្រីជាប់ឆ្នោត តំណាងអង្គការក្រៅរដ្ឋាភិបាលនានា ជាដើម)។ ជាការសំខាន់ដែលត្រូវធ្វើការបញ្ជាក់អំពីវត្តមាន និងឈ្មោះរបស់ស្ថាប័នគ្រប់គ្រងនីមួយៗសំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ តាមរយៈការកំណត់អត្តសញ្ញាណ និងសម្ភាសន៍អ្នកដែលទទួលខុសត្រូវលើប្រតិបត្តិការរបស់ស្ថាប័នគ្រប់គ្រងទាំងនោះ។ ព័ត៌មានទាក់ទិនថា តើស្ថាប័នគ្រប់គ្រងមួយមានវត្តមាន ឬគ្មាន ព្រមទាំងឈ្មោះស្ថាប័នគ្រប់គ្រងនោះត្រូវកត់ត្រាបញ្ចូលទៅក្នុងតារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានពីផែនការគ្រប់គ្រង អ្នកផ្តល់ព័ត៌មានសំខាន់ៗ និងអ្នកទទួលខុសត្រូវទាំងនោះ បញ្ចូល ទៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

| សកម្មភាព តំបន់ឆ្នេរ 8 | ស្ថាប័នគ្រប់គ្រង (មាន/គ្មាន) 7 ឈ្មោះ |
|---|---|
| *នេសាទ* | *ម* |
| *ទេសចរណ៍* | *ម* |
| *វារីវប្បកម្ម* | *គ* |
| ** បង្កើតតារាងទៅតាមសកម្មភាពដែលត្រូវបានកំណត់បញ្ចូលក្នុងបណ្តាសកម្មភាព ១ត្ស១៤ប* | |

*ការវិភាគបន្ថែម :* សេចក្តីបរិយាយខ្លីមួយអាចត្រូវបានរៀបចំឡើងដោយកត់សំគាល់នូវឈ្មោះរបស់ស្ថាប័នគ្រប់គ្រងទាំងនោះសំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។

### សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកគ្រប់គ្រង

ព័ត៌មានស្តីពីស្ថាប័នគ្រប់គ្រងផ្តល់នូវសារប្រយោជន៍ក្នុងការកំណត់នូវផលប៉ះពាល់ជារួមពីការគ្រប់គ្រងទៅលើសហគមន៍ ជាពិសេសទៅលើផ្នែកអភិបាលកិច្ច។ ការកំណត់បាននូវអាជ្ញាធរធ្វើសេចក្តីសំរេចចិត្តដែលមានអាណត្តិប្រើប្រាស់ស្របច្បាប់សំរាប់សកម្មភាពតាមតំបន់ឆ្នេរ នឹងជួយឱ្យអ្នកគ្រប់គ្រងយល់បានកាន់តែប្រសើរអំពីសកម្មភាពគ្រប់គ្រងនានា ដែលកើតមាននៅក្នុងតំបន់នោះ ធ្វើការសំរបសំរួលបានល្អជាមួយស្ថាប័នគ្រប់គ្រងផ្សេងទៀតធ្វើការកាន់តែមានតំលាភាពនៅក្នុងដំណើរការគ្រប់គ្រង និងកាន់តែមានប្រសិទ្ធភាពក្នុងន័យគ្រប់គ្រង។

ការកំណត់អត្តសញ្ញាណ បាននូវស្ថាប័នគ្រប់គ្រងទាំងនោះក៏ផ្តល់ឱ្យអ្នកគ្រប់គ្រងនូវកង្វល់អំពីផលប៉ះពាល់ពីវិធានការគ្រប់គ្រង និងអាជ្ញាធរ ដែលត្រូវពិគ្រោះយោបល់ផងដែរ។

## *KS26. ផែនការគ្រប់គ្រង*

### ការកំណត់និយមន័យ

ផែនការគ្រប់គ្រងកំណត់នូវទិសដៅជាយុទ្ធសាស្ត្រសំរាប់កម្មវិធីគ្រប់គ្រងធនធានឆ្នេរ។ ផែនការគ្រប់គ្រងគឺជាឯកសារមួយដែលបញ្ជាក់អំពីគោលដៅ និងកម្មវត្ថុនៃកម្មវិធីគ្រប់គ្រងជារួម រចនាសម្ព័ន្ធស្ថាប័ននៃប្រព័ន្ធគ្រប់គ្រង និងវិធានការគ្រប់គ្រងនានា។

### វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចទទួលបានព័ត៌មានស្តីពីផែនការគ្រប់គ្រង តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗមកពី

| សកម្មភាពតំបន់ឆ្នេរ ៖ | ផែនការគ្រប់គ្រង (មាន/គ្មាន) |
|---|---|
| *នេសាទ* | *ម* |
| *ទេសចរណ៍* | *ម* |
| *វារីវប្បកម្ម* | *គ* |
| *៖ បង្កើតតារាងទៅតាមសកម្មភាពដែលត្រូវបានកំណត់បញ្ចូលក្នុងបណ្ដាសកម្មភាព ១ដល់១៨ប* | |

ទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន ទីភ្នាក់ងារថ្នាក់ជាតិ និងថ្នាក់តំបន់ពាក់ព័ន្ធ ដែលមានអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រងធនធានឆ្នេរ។ នៅក្នុងតំបន់សិក្សា អាចមានផែនការគ្រប់គ្រងជាច្រើន ដោយអាស្រ័យលើសកម្មភាពតាមតំបន់ឆ្នេរផ្សេងៗ រួមមានដូចជា ផែនការគ្រប់គ្រងតំបន់ឆ្នេរជារួម ផែនការគ្រប់គ្រងជលផល ផែនការអភិវឌ្ឍន៍ឆ្នេរ ផែនការអភិវឌ្ឍន៍ព្រៃកោងកាង និង/ឬ ផែនការអភិវឌ្ឍន៍ទេសចរណ៍ជាដើម។ វាអាចផ្តល់នូវសារប្រយោជន៍ ប្រសិនធ្វើការស្នើសុំបាននូវច្បាប់ថតចំលងនៃផែនការគ្រប់គ្រងដែលពាក់ព័ន្ធទាំងនោះដើម្បីជួយដល់ការកំណត់នូវបណ្តាសកម្មភាពដែលត្រូវដោះស្រាយ។

សំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ ត្រូវធ្វើកំណត់ថា តើ (មាន ឬគ្មាន) វត្តមាននៃផែនការគ្រប់ដែរឬយ៉ាងណា ហើយ ចូរកត់សំគាល់វាទៅក្នុងតារាង*ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំ ហើយកត់ត្រាបញ្ចូលទៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីមួយអាចនឹងរៀបចំឡើងដោយពណ៌នាអំពីផែនការគ្រប់គ្រងសំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។ វាក៏អាចផ្តល់ជាសារប្រយោជន៍ផងដែរ ដែលត្រូវធ្វើការប្រៀបធៀបនូវការផ្លាស់ប្តូរនៃផែនការគ្រប់គ្រង ដែលកើតមាននាពេលកន្លងមកជាមួយនឹងការផ្លាស់នៃលំនាំនៃការប្រើប្រាស់ និងលក្ខណៈធនធាដើម្បីកំណត់ថា តើមានភាពជាប់ពាក់ព័ន្ធគ្នាដែរ ឬយ៉ាងណា។

## សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកប្រើប្រាស់

ការដែលបានដឹងថា តើមានផែនការគ្រប់គ្រងសំរាប់បណ្តាសកម្មភាពផ្សេងៗ ឬក៏គ្មាននោះ ផ្តល់សារប្រយោជន៍ក្នុងការកំណត់នូវផលប៉ះពាល់ជារួមពីការគ្រប់គ្រងទៅលើតំបន់សិក្សា ជាពិសេសទៅលើអភិបាលកិច្ច។ វត្តមាននិងការអនុវត្តន៍ផែនការគ្រប់គ្រងប្រាប់ឱ្យអ្នកគ្រប់គ្រងបានដឹងថា ការគ្រប់គ្រងធនធារឆ្នេរបានដំណើរការទៅស្របតាមគោលដៅ និងកម្មវត្ថុឆ្ពោះទៅកាន់ការសំរេចបាននូវលទ្ធផលជាក់លាក់ (ដូចជា ការងារអភិរក្ស

និងការពារ) និងដឹងថា មានយុទ្ធសាស្ត្រជាមូលដ្ឋានមួយដើម្បីសំរេចបាននូវគោលដៅ និងកម្មវត្ថុទាំងនេះ ព្រមទាំង ដឹងដែរថា ផែនការទាំងមូលមានអាណត្តិស្របច្បាប់សំរាប់ធ្វើការអនុវត្តន៍។

ការវិភាគដែលធ្វើការប្រៀបធៀបនូវវត្តមាននៃផែនការគ្រប់គ្រង និងកត្តាអភិបាលកិច្ចដទៃទៀត (ដូចជា សិទ្ធិប្រើប្រាស់ និងគោលការណ៏ផ្លូវការ) ជាមួយនឹងលំនាំនៃការប្រើប្រាស់ធនធាន និងលក្ខណៈធនធានផ្តល់សារ-ប្រយោជន៏ក្នុងការកំណត់ថា តើវិធានការអភិបាលកិច្ចទាំងនេះកំពុងជះឥទ្ធិពលទៅលើលក្ខខណ្ឌ និងស្ថានភាពនៃធនធានទាំងនោះដែរ ឬយ៉ាងណា។

### *KS27. ច្បាប់អនុវត្តន៏*

#### ការកំណត់និយមន័យ

ច្បាប់អនុវត្តន៏គឺជាច្បាប់ផ្លូវការជាធរមានពីរដ្ឋាភិបាល ដែលផ្តល់ឱ្យការគ្រប់គ្រងធនធានឆ្នេរនូវមូលដ្ឋានច្បាប់ដ៏ល្អមួយដើម្បីអាចឱ្យផែនការគ្រប់គ្រងរចនាសម្ព័ន្ធគ្រប់គ្រង គោលការណ៏ និងបទបញ្ញត្តិ ព្រមទាំងនីតិវិធីអនុវត្តទាំងឡាយត្រូវបានទទួលស្គាល់ ពន្យល់ គោរព និងអនុវត្ត។ ជាឧទាហរណ៏ ច្បាប់ ឬក្រមជលផលជាតិត្រូវបានចាត់ទុកថាជាច្បាប់អនុវត្តន៏មួយ ដោយហេតុថា វាបង្ហាញឱ្យដឹងថា តើនឹងត្រូវប្រើប្រាស់ និងគ្រប់គ្រងជលផលនៅក្នុងប្រទេសដោយមធ្យោបាយបែបណា។

#### វិធីសាស្ត្រប្រមូលទិន្នន័យ

គេអាចទទួលបានព័តិតមានស្តីពីផែនការគ្រប់គ្រង តាមរយៈការធ្វើបទសម្ភាសន៏ជាមួយអ្នកផ្តល់ព័តិមានសំខាន់ៗមកពីទីភ្នាក់ងាររដ្ឋាភិបាលក្នុងមូលដ្ឋានទីភ្នាក់ថ្នាក់ជាតិ និងថ្នាក់តំបន់ពាក់ព័ន្ធ ដែលមានអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រងធនធានឆ្នេរ។ នៅក្នុងអំឡុងពេលសម្ភាសន៏ វាអាចផ្តល់ជាសារប្រយោជន៏ដែលអាចស្នើសុំបាននូវច្បាប់ថតចំលងនៃឯកសារបោះពុម្ពផ្សាយនៃច្បាប់អនុវត្តន៏ដែលជាប់ពាក់ព័ន្ធ ដើម្បីជួយក្នុងការកំណត់នូវច្បាប់អនុវត្តន៏ណាដែលបានចូលជាធរមាន។

ច្បាប់អនុវត្តន៏អាចមាននៅកំរិតមូលដ្ឋាន ខេត្ត/រដ្ឋ ជាតិ និងអន្តរជាតិ។ ទំរង់ និងវិសាលភាពនៃច្បាប់អនុវត្តន៏សំរាប់ការគ្រប់គ្រងធនធានឆ្នេរនឹងមានលក្ខណៈខុសគ្នាខ្លាំងទៅតាមប្រទេសនីមួយៗ។ ការរៀបចំច្បាប់ទាំងនោះអាចនឹងពឹងផ្អែកលើធាតុជាច្រើន ដូចជា ទំរង់រដ្ឋាភិបាល ហិរញ្ញវត្ថុដែលមាន រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈកំរិតមជ្ឈការ/វិមជ្ឈការថ្នាក់រដ្ឋាភិបាល រដ្ឋ ដែនសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ និងការធ្វើការសេចក្តីសំរេចចិត្តនិងប្រភេទសកម្មភាព និងធនធានតាមតំបន់ឆ្នេរ។

បទសម្ភាសន៍ និងការត្រួតពិនិត្យឯកសារធ្វើឡើងដើម្បីកំណត់វត្តមាន (មាន ឬគ្មាន) នៃច្បាប់អនុវត្តន៍ដើម្បីគាំទ្រដល់ផែនការគ្រប់គ្រងសំរាប់សកម្មភាពនីមួយៗ។ ព័ត៌មាននេះត្រូវកត់ត្រាចូលក្នុងតារាង*ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំបញ្ចូលទៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

| **សកម្មភាពតាមតំបន់ឆ្នេរ** *(បង្កើតតារាងទៅតាមសកម្មភាពដែលត្រូវបានកំណត់បញ្ចូលក្នុងបណ្តាសកម្មភាព [KS14])* | **ច្បាប់អនុវត្តន៍** (មាន/គ្មាន) |
|---|---|
| *នេសាទ* | *ម* |
| *ទេសចរណ៍* | *គ* |
| *វារីវប្បកម្ម* | *គ* |

*ការវិភាគបន្ថែម :* ប្រធានបទខ្លីមួយអាចនឹងរៀបចំឡើងដោយពណ៌នាអំពីច្បាប់អនុវត្តន៍សំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។ ចូរធ្វើធ្វើការប្រៀបធៀបនូវការផ្លាស់ប្តូរនៃវត្តមាននៃច្បាប់អនុវត្តន៍ដែលមាននាពេលកន្លងមកជាមួយ នឹងការផ្លាស់នៃលំនាំនៃការប្រើប្រាស់ និងលក្ខណៈធនធានដើម្បីកំណត់ថាតើមានភាពជាប់ពាក់ព័ន្ធគ្នាដែរ ឬយ៉ាងណា។

## សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកប្រើប្រាស់

ច្បាប់អនុវត្តន៍មានសារប្រយោជន៍សំរាប់ការកំណត់នូវផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍នៅក្នុង តំបន់សិក្សា ជាពិសេសទៅលើអភិបាលកិច្ច។ ការយល់ដឹងអំពីច្បាប់អនុវត្តន៍មានសារមានសារប្រយោជន៍ដើម្បីធានាបានថា ផែនការ និងយុទ្ធសាស្ត្រគ្រប់គ្រងត្រូវបានគាំទ្រដោយច្បាប់គ្រប់គ្រងដើម្បីឱ្យការអនុវត្តន៍ផែនការ និងយុទ្ធសាស្ត្រទាំងនោះទទួលបានភាពជោគជ័យ។ ការយល់ដឹងអំពីច្បាប់អនុវត្តន៍នឹងធានាថាវិធានការគ្រប់គ្រងដែលត្រូវបានដាក់ឡើងនោះត្រូវបានចែងគាំទ្រនៅក្នុងច្បាប់នេះ។ កង្វល់អំពីផលប៉ះពាល់ពីវិធានការគ្រប់គ្រងអាចជាប់ទាក់ទិនទៅនឹងផែនការគ្រប់គ្រង និងច្បាប់អនុវត្តន៍វិញផងដែរ។

ការវិភាគដែលធ្វើការប្រៀបធៀបនូវវត្តមាននៃផែនការគ្រប់គ្រង និងកត្តាអភិបាលកិច្ចដទៃទៀត (ដូចជា សិទ្ធិប្រើប្រាស់ និងគោលការណ៍ផ្លូវការ) ជាមួយនឹងលំនាំនៃការប្រើប្រាស់ធនធាន និងលក្ខណៈធនធានផ្តល់សារ-ប្រយោជន៍ក្នុងការកំណត់ថា តើវិធានការអភិបាលកិច្ចទាំងនេះកំពុងជះឥទ្ធិពលទៅលើលក្ខខណ្ឌ និងស្ថានភាពនៃធនធានទាំងនោះដែរ ឬយ៉ាងណា។

## KS28. *ការបែងចែកធនធាន*

### ការកំណត់និយមន័យ

ការបែងចែកធនធានសំដៅទៅដល់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលអនុវត្តសកម្មភាពនៃផែនការគ្រប់គ្រងនោះ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

| សកម្មភាព តំបន់ឆ្នេរ * | ចំនួនបុគ្គលិក | ថវិកា |
|---|---|---|
| *ទេសាទ* | *៥* | *១.000* |
| *ទេសចរណ៍* | *២៥* | *២៥.000* |
| *វារីវប្បកម្ម* | *0* | *0* |
| ** បង្កើតតារាងទៅតាមសកម្មភាពដែលត្រូវបានកំណត់បញ្ចូលក្នុងបណ្តាសកម្មភាព (KS14)* | | |

គេអាចប្រមូលព័ត៌មានស្តីពីការបែងចែកធនធានបានតាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកគ្រប់គ្រង ឬ នាយកស្ថាប័នគ្រប់គ្រងនីមួយៗនៅក្នុងតំបន់សិក្សា។ អ្នកគ្រប់គ្រង ឬនាយកត្រូវបានស្នើឱ្យសុំនូវរចនាសម្ព័ន្ធ ស្ថាប័នដែលគួរតែមានបង្ហាញនូវការបែងចែកបុគ្គលិតទៅតាមកម្មវិធី ឬសកម្មភាពរបស់ស្ថាប័ន។ គេគួរកំណត់ ឱ្យបាននូវចំនួនបុគ្គលិក (ពេញម៉ោង ក្រៅម៉ោង ស្ម័គ្រចិត្ត) ដែលត្រូវបានចាត់តាំងឱ្យបំពេញកម្មវិធី ឬសកម្មភាពនីមួយៗ។ ក្នុងករណីគ្មានរចនាសម្ព័ន្ធស្ថាប័នទេនោះ គេគួរពិភាក្សាជាមួយអ្នកគ្រប់គ្រង ឬនាយកស្ថាប័ននោះ ដើម្បីបង្កើតជារចនាសម្ព័ន្ធស្ថាប័ន ដោយដំបូងត្រូវកំណត់នូវកម្មវិធី ឬសកម្មភាពនីមួយៗរបស់ស្ថាប័នគ្រប់គ្រង ហើយបន្ទាប់មកត្រូវកំណត់នូវសមាជិកជាបុគ្គលិកធ្វើការ។ គេក៏ត្រូវសាកសួរអ្នកគ្រប់គ្រង ឬនាយកស្ថាប័នអំពីថវិកាសរុបសំរាប់ស្ថាប័នគ្រប់គ្រង និងសំរាប់ការអនុវត្តន៍ផែនការគ្រប់ គ្រងផងដែរ។ ចំលើយត្រូវបានកត់ត្រាទុកនៅក្នុងតារាង*ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

ការប្រមូលទិន្នន័យបន្ថែម : គេក៏អាចប្រមូលព័ត៌មាន បន្ថែមតាមការបែងចែក ថវិកាលើមុខព្រួញចំណាយជាបុគ្គលសំរាប់សកម្មភាពគ្រប់គ្រងផ្សេងៗ។ ព័ត៌មានក៏អាចទទួលបានផងដែរទាក់ទិននឹងការបែងចែកលើផ្នែកបច្ចេកទេស និងគ្រឿងបរិក្ខាសំរាប់សកម្មភាពគ្រប់គ្រងនីមួយៗ។

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំ និងកត់ត្រាបញ្ចូលទៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ /ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីមួយអាចនឹងរៀបចំឡើងទាក់ទិនទៅនឹងការបែងចែកបុគ្គលិកនាពេលបច្ចុប្បន្ន និង ថវិកាសំរាប់ការគ្រប់គ្រងឆ្នេរ ។

**សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកប្រើប្រាស់**

ការយល់ដឹងអំពីការបែងចែកធនធានមានសារប្រយោជន៍សំរាប់ការកំណត់នូវផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍នៅក្នុងតំបន់សិក្សា ជាពិសេសទៅលើអភិបាលកិច្ច។ ជាឧទាហរណ៍ ការយល់ដឹងអំពីការបែងចែកបុគ្គលិកដើម្បីអនុវត្តកម្មវិធី ឬសកម្មភាពនីមួយៗមានសារប្រយោជន៍សំរាប់ធ្វើការស្វែងយល់អំពីសារប្រយោជន៍នៃសកម្មភាពផ្សេងៗ និងក៏សំរាប់ធ្វើការប៉ាន់ស្មានពីចំនួន និងភាពញឹកញាប់នៃសកម្មភាពមួយចំនួនដូចជា ការល្បាតលើការអនុវត្តន៍ជាដើម ។

## *KS29. សិទ្ធិប្រើប្រាស់ និង គោលការណ៍ផ្លូវការ*

**ការកំណត់និយមន័យ**

សិទ្ធិប្រើប្រាស់ផ្លូវការគឺសំដៅទៅដល់សិទ្ធិប្រើប្រាស់ដែលទាក់ទិនទៅនឹងសកម្មភាពតាមតំបន់ឆ្នេរនានា។ សិទ្ធិប្រើប្រាស់ផ្លូវការត្រូវបានចាត់ទុកថា ជាការប្រើប្រាស់សិទ្ធិយ៉ាងត្រឹមត្រូវ ដែលត្រូវបានតាក់តែងទៅជាច្បាប់។ ជាឧទាហរណ៍ ការរៀបចំសិទ្ធប្រើប្រាស់ផ្លូវការមួយ គឺជាសិទ្ធិដែលត្រូវបានផ្តល់ជូនឱ្យអ្នកនេសាទមួយរូបអាចចូលទៅកាន់តំបន់មួយដើម្បីធ្វើការនេសាទ ។

គោលការណ៍ផ្លូវការត្រូវបានតាក់តែងទៅជាច្បាប់ និងកំណត់យ៉ាងជាក់លាក់នូវសកម្មភាពអ្វីខ្លះដែលអ្នកពាក់ព័ន្ធ និងទីភ្នាក់ងាររដ្ឋាភិបាលតំរូវឱ្យមានអនុញ្ញាត និងហាមឃាត់ ទាក់ទិនទៅនឹងការប្រើប្រាស់ធនធានឆ្នេរ។ គោលការណ៍បង្កើតនូវនីតិវិធីដែលសិទ្ធិប្រើប្រាស់ត្រូវអនុវត្ត។ ឧទាហរណ៍ ប្រសិនបើអ្នកនេសាទទាំងនោះទទួលបានសិទ្ធិប្រើប្រាស់សិទ្ធិប្រើប្រាស់ផ្លូវការដើម្បីចូលទៅនេសាទនៅក្នុងតំបន់មួយនោះ គោលការណ៍ផ្លូវការណ៏វិញគឺថា ពួកគេអាចប្រើប្រាស់បានតែឧបករណ៍នេសាទដោយដៃប៉ុណ្ណោះដើម្បីធ្វើការនេសាទនៅក្នុងតំបន់នោះ ។

ចំពោះសូចនាករនេះ ការយកចិត្តទុកដាក់គឺផ្តោតទៅលើគោលការណ៍ និងបទបញ្ញត្តិប្រតិបត្តិជាផ្លូវការទាំងឡាយដែលប៉ះពាល់ដោយផ្ទាល់ទៅលើសេចក្តីសំរេចចិត្តប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់ធនធាន ទាក់ទិនទៅនឹងពេលវេលា ទីកន្លែង និងវិធីក្នុងការប្រើប្រាស់ធនធានឆ្នេរ។ គោលការណ៍ និងបទបញ្ញត្តិទាំងនេះមានលក្ខណៈជាក់លាក់ចំពោះសកម្មភាពតាមតំបន់ឆ្នេរមួយ ហើយនឹងត្រូវបានបង្កើតឡើងដោយទីភ្នាក់ងារមួយដែលមានការទទួលខុសត្រូវស្របច្បាប់លើការគ្រប់គ្រងសកម្មភាពតាមតំបន់ឆ្នេរមួយនោះ ។

## វិធីសាស្ត្រប្រមូលទិន្នន័យ

| សកម្មភាព តំបន់ឆ្នេរ * | ការរៀបចំសិទ្ធិប្រើប្រាស់ផ្លូវការ ( មាន/គ្មាន) | គោលការណ៍ និងបទបញ្ញត្តិពាក់ព័ន្ធ ( មាន/គ្មាន) |
|---|---|---|
| *នេសាទ* | *ម* | *ម* |
| *ទេសចរណ៍* | *គ* | *គ* |
| *វារីវប្បកម្ម* | *ម* | *ម* |
| ** បង្កើតតារាងទៅតាមសកម្មភាពដែលត្រូវបានកំណត់បញ្ចូលក្នុងបណ្តាសកម្មភាព (KS14)* | | |

បញ្ញត្តិផ្លូវការទាក់ទិននឹងសិទ្ធិប្រើប្រាស់អាចកំណត់បានពីព័ត៌មានបន្ទាប់បន្សំ ដូចជា បញ្ញត្តិ សំណេរនៅកំរិតមូលដ្ឋាន កំរិតតំបន់ និងកំរិតជាតិ។ បញ្ញត្តិនេះត្រូវបានតាក់តែងឡើង និងបោះពុម្ពស្របច្បាប់ដោយរដ្ឋាភិបាល។ បញ្ញត្តិទាំងនេះ រួមមានដូចជា ក្រម ឬច្បាប់ស្តីពីជលផលជាតិ បណ្តាច្បាប់បរិស្ថានដែលទាក់ទិនទៅនឹងការកាប់ព្រៃកោងកាង បណ្តាច្បាប់ដែលទាក់ទិនទៅនឹងការប្រើប្រាស់ផ្កាថ្ម និងប្រមូលផលពីផ្កាថ្ម និងបណ្តាច្បាប់ដែលទាក់ទិនទៅនឹង ការអភិវឌ្ឍន៍លំនៅស្ថាននៅតំបន់ឆ្នេរជាដើម។ ព័ត៌មានបន្ថែមអាចទទួលបានពីបទសម្ភាសន៍អ្នកផ្តល់ព័ត៌មាន សំខាន់ៗ ដូចជាពីមន្ត្រីរដ្ឋាភិបាលនៅក្នុងទីភ្នាក់ងារពាក់ព័ន្ធ ដែលមានការទទួលខុសត្រូវលើការគ្រប់គ្រងសកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។

គោលការណ៍ និងបទបញ្ញត្តិផ្លូវការអាចកំណត់បានពីព័ត៌មានបន្ទាប់បន្សំ ដូចជា បញ្ញត្តិសំណេរនៅកំរិតមូលដ្ឋាន កំរិតតំបន់ និងកំរិតជាតិ។ បញ្ញត្តិនេះត្រូវបានតាក់តែង និងបោះពុម្ពស្របច្បាប់ដោយទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ។ ព័ត៌មានបន្ថែមអាចទទួលបានពីបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ដូចជា ពីមន្ត្រីរដ្ឋាភិបាលនៅក្នុងទីភ្នាក់ងារ ពាក់ព័ន្ធដែលមានការទទួលខុសត្រូវលើការគ្រប់គ្រងសកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។

បញ្ញត្តិផ្លូវការទាក់ទិននឹងសិទ្ធិប្រើប្រាស់ និងគោលការណ៍ផ្លូវការសំរាប់សកម្មភាពតាមតំបន់ឆ្នេរគួរទទួលបាននៅកំរិតរដ្ឋបាលមូលដ្ឋាន កំរិតតំបន់ និងកំរិតជាតិ។ ចំពោះសកម្មភាពតាមតំបន់ឆ្នេរនីមួយៗ សូមកំណត់ ( មាន ឬគ្មាន) ថាតើមានការរៀបចំ សិទ្ធិប្រើប្រាស់ផ្លូវការ និងគោលការណ៍ផ្លូវការនៅកំរិតសហគមន៍ដែរឬយ៉ាងណា។ ព័ត៌មាននេះបានកត់សំគាល់នៅក្នុង តារាង *ណែនាំអំពីការធ្វើបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យបានមកពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំ និងកត់ត្រាបញ្ចូលទៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ /ប្រភពបន្ទាប់បន្សំ* ដូចបានបង្ហាញ។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីមួយអាចនឹងរៀបចំឡើងដោយពណ៌នាអំពីការរៀបចំសិទ្ធិប្រើប្រាស់ និងគោលការណ៍ផ្លូវការសំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។ ចូរធ្វើធ្វើការប្រៀបធៀបនូវការផ្លាស់ប្តូរនៃវត្តមានរបស់ផែនការគ្រប់គ្រង ដែលមាននាពេលកន្លងមកជាមួយនឹងការផ្លាស់ប្តូរនៃលំនាំនៃការប្រើប្រាស់ និងលក្ខណៈធនធាន ដើម្បីកំណត់ថា តើមានភាពជាប់ពាក់ព័ន្ធគ្នាដែរ ឬក៏អត់។

## សារប្រយោជន៍នៃព័ត៌មានសំរាប់អ្នកប្រើប្រាស់

សិទ្ធិប្រើប្រាស់ផ្លូវការមានសារប្រយោជន៍សំរាប់ការកំណត់នូវផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍នៅក្នុងតំបន់សិក្សា ជាពិសេសទៅលើអភិបាលកិច្ច។ សិទ្ធិប្រើប្រាស់ផ្លូវការទៅលើធនធានឆ្នេរមានរាប់ចាប់ពីភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រងយ៉ាងពេញលេញទៅលើការប្រើប្រាស់ និងការបែងចែកធនធានឆ្នេររបស់ក្រុមមួយចំនួន ដូចជា អង្គការនេសាទ រហូតដល់គ្មានកម្មសិទ្ធិប្រើប្រាស់ស្របច្បាប់អ្វីទាំងអស់។ ជាការសំខាន់ដែលអ្នកគ្រប់គ្រងយល់ដឹងអំពីព័ត៌មាននេះ ដើម្បីឱ្យការរៀបចំផ្នែកគ្រប់គ្រងអាចបង្កើតឡើង និងអនុវត្តបានប្រកបដោយសមភាព និងប្រសិទ្ធភាព ហើយយល់អំពីផលប៉ះពាល់ និងដំណោះស្រាយ។ គេចាំបាច់ត្រូវយល់អំពីវត្តមានលក្ខណៈ និងភាពរឹងមាំនៃសិទ្ធិប្រើប្រាស់ផ្លូវការដែលអ្នកពាក់ព័ន្ធនៅក្នុងមូលដ្ឋាន រាប់ទាំងអាជ្ញាធរគ្រប់គ្រងផង មានទៅលើធនធានសមុទ្រនៅក្នុងតំបន់នោះ ដើម្បីឱ្យរចនាសម្ព័ន្ធគ្រប់គ្រងទាំងនោះអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

គោលការណ៍ផ្លូវការក៏មានសារប្រយោជន៍ផងដែរ សំរាប់ការកំណត់នូវផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍នៅក្នុងតំបន់សិក្សា ជាពិសេសទៅលើអភិបាលកិច្ច។ កត្តានេះក៏មានសារប្រយោជន៍សំរាប់ធ្វើការកំណត់នូវកំរិតគ្រប់គ្រងដែលមានស្រាប់ទៅលើសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ឆ្នេរ និងទំហំដែលប្រជាជនអាចនឹងទទួលយកនូវគោលការណ៍បន្ថែមដែលគ្រប់គ្រងការប្រើប្រាស់សកម្មភាពតាមតំបន់ឆ្នេរ និងរងផលប៉ះពាល់ពីគោលការណ៍ផ្លូវការទាំងនោះ។ អ្នកប្រើប្រាស់ធនធានអាចនឹងបំពានលើគោលការណ៍ ប្រសិនបើពួកគាត់មិនបានយល់ច្បាស់ ឬប្រសិនបើគោលការណ៍ទាំងនោះមិនមានភាពសមហេតុផលទេនោះ។

ការវិភាគដែលធ្វើការប្រៀបធៀបនូវវត្តមាននៃការរៀបចំសិទ្ធិប្រើប្រាស់ និងគោលការណ៍ផ្លូវការជាមួយនឹងលំនាំនៃការប្រើប្រាស់ធនធាន និងលក្ខណៈធនធានផ្តល់សារប្រយោជន៍ក្នុងការកំណត់ថា តើវិធានការអភិបាលកិច្ចទាំងនេះកំពុងជះឥទ្ធិពលទៅលើលក្ខខណ្ឌ និងស្ថានភាពនៃធនធានទាំងនោះដែរឬយ៉ាងណា។

## KS30. *សិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការ ប្រពៃណី និងទំនៀមទំលាប់*

### ការកំណត់និយមន័យ

ក្នុងសហគមន៍តំបន់ឆ្នេរជាច្រើន មានប្រព័ន្ធគ្រប់គ្រងធនធានតំបន់ឆ្នេរទេ។ ប្រព័ន្ធគ្រប់គ្រងមិនផ្លូវការ ដែលត្រូវបង្កើត និងអនុវត្តដោយសហគមន៍អ្នកប្រើប្រាស់ធនធាន ជារឿយៗត្រូវបានអនុវត្តរួមជាមួយនឹងប្រព័ន្ធគ្រប់គ្រងផ្លូវការរបស់រដ្ឋាភិបាល។ ប្រព័ន្ធមិនផ្លូវការទាំងនេះអាចមានលក្ខណៈសាំញ៉ាំ ឬសាមញ្ញ ត្រូវបានគោរពយ៉ាងងាយស្រួល ឬត្រូវបានការពារយ៉ាងយកចិត្តទុកដាក់។

ប្រពៃណី និងទំនៀមទំលាប់ សំរាប់ការប្រើប្រាស់ និងការគ្រប់គ្រងធនធានតំបន់ឆ្នេរ គឺជាការអនុវត្តន៍ដែលបន្សល់ទុកតពីជំនាន់មួយទៅជំនាន់មួយ ដែលជាការឆ្លុះបញ្ចាំងអំពីលក្ខណៈជនជាតិ អំបូរ ត្រកូល ឋានៈឬ ភេទរបស់សហគមន៍។ ពួកវាអាចមាន ឧទាហរណ៍ អត្តសញ្ញាណរបស់មន្រ្តីជលផលជាន់ខ្ពស់ដែលដឹកនាំសកម្មភាពនេសាទ ពាក្យបួងសួងមុនពេលនេសាទ យន្តការគ្រប់គ្រងវិវាទ ឬរបៀបធ្វើសេចក្តីសំរេច។

សិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការសំដៅលើការអនុវត្តន៍មិនផ្លូវការមិនមែនជាលាយលក្ខណ៍អក្សរ (តាមទំលៀមទំលាប់ និងប្រពៃណី) ដែលអនុញ្ញាតឱ្យប្រជាជនប្រើប្រាស់សិទ្ធិ និងកំណត់ជាក់លាក់ថាតើសកម្មភាពមួយណា ចាំបាច់ត្រូវបានអនុញ្ញាត និងត្រូវបានហាមឃាត់ ដោយអ្នកប្រើប្រាស់ធនធាន ទាក់ទិនទៅនឹងសកម្មភាពតាមតំបន់ឆ្នេរ។ សិទ្ធិប្រើប្រាស់មិនផ្លូវការ ជារឿយៗ សំដៅលើសិទ្ធិប្រើប្រាស់ជាក់ស្តែង (ការអនុវត្តន៍តាមទំលៀមទំលាប់ និងប្រពៃណី)។

### វិធីសាស្រ្តប្រមូលទិន្នន័យ

ព័តិមានស្តីពីសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការសំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ (តាមដែលស័ក្តិសម) អាចទទួលបានតាមរយៈការបញ្ចូលនូវបទសម្ភាសន៍អ្នកផ្តល់ព័តិមានសំខាន់ៗជាមួយនឹងការសង្កេត។ ប្រជាជនដែលទាក់ទិនបំផុតសំរាប់ជាអ្នកផ្តល់ព័តិមានសំខាន់ៗ រួមមានមន្រ្តីជលផលជាន់ខ្ពស់ សមាជិកជាន់ខ្ពស់របស់សហគមន៍ និងមន្រ្តីរដ្ឋាភិបាល។ អ្នកផ្តល់ព័តិមានសំខាន់ៗត្រូវបានស្នើសុំឱ្យអធិប្បាយសង្ខេបអំពីទំនៀមទំលាប់/ប្រពៃណី សិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានា សំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ ដូចបានកត់សំគាល់ក្នុង*តារាងស្តីពីមគ្គុទេសន៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័តិមានសំខាន់ៗ* ខាងក្រោម។ ការសង្កេតក៏ជាការសំខាន់មួយផងដែរ ពីព្រោះព័តិមានដែលទទួលបានតាមរយៈបទសម្ភាសន៍អាចឆ្លុះបញ្ចាំងតែអំពីឥរិយាបថល្អ គ្មានលក្ខណៈពិតប្រាកដប៉ុណ្ណោះ។ អ្នកប្រើប្រាស់ធនធានអាចត្រូវបានសង្កេតនៅពេលដែលពួកគេអនុវត្តការសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានា ដើម្បីកំណត់ថាតើវាកំពុងត្រូវបានអនុវត្ត ដូចដែលបានអធិប្បាយជូនដែរឬទេ។

| សកម្មភាពតំបន់ឆ្នេរ* | ទំនៀមទំលាប់ និងប្រពៃណី | ការរៀបចំសិទ្ធិប្រើប្រាស់មិនផ្លូវការ | វិធានមិនផ្លូវការ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| **រៀបចំបញ្ជីអនុលោមទៅតាមសកម្មភាពដែលបានកំណត់ក្នុងសកម្មភាព (KS14)* | | | |

នៅពេលប្រមូលព័ត៌មានស្តីពីអភិបាលកិច្ចមិនផ្លូវការ វាគួរត្រូវបានកត់សំគាល់ថា វាអាចត្រូវការពេលវេលាបន្ថែម ដើម្បីយល់អំពីការរៀបចំទាំងនេះឱ្យបានពេញលេញ។ នេះអាចទាក់ទិនទៅនឹងការចំណាយពេលបន្ថែមជាមួយ នឹងសមាជិកសហគមន៍ ដើម្បីសិក្សាលំអិតឱ្យបានជាក់លាក់អំពីប្រព័ន្ធទាំងនេះ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗទៅក្នុង*សន្លឹកវិភាគទិន្នន័យបានមកពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ*។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីៗមួយអាចនឹងត្រូវរៀបចំឡើង ដើម្បីអធិប្បាយអំពីសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានា និងទំនៀមទំលាប់ និងប្រពៃណី ដែលទាក់ទិនទៅនឹងការប្រើប្រាស់ និងការគ្រប់គ្រងធនធានតំបន់ឆ្នេរ សំរាប់សកម្មភាពតាមតំបន់ឆ្នេរនីមួយៗ។

## សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ប្រពៃណី និងទំនៀមទំលាប់សំរាប់ការប្រើប្រាស់ និងការគ្រប់គ្រងតំបន់ឆ្នេរ និងសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានាគឺមានប្រយោជន៍សំរាប់ការកំណត់អំពីផលប៉ះពាល់ជារួមនៃការគ្រប់គ្រងទៅលើសហគមន៍ និងសំរាប់ការយល់ដឹងអំពីសារៈសំខាន់ផ្នែកវប្បធម៌នៃធនធាន និងការប្រើប្រាស់របស់វា។

ការយល់ដឹងអំពីសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានាគឺមានសារៈសំខាន់ ដោយហេតុថាអ្នកប្រើប្រាស់ធនធានអាចគិតថាសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានាគឺកាន់តែមានលក្ខណៈស្របច្បាប់សំរាប់ពួកគេជាងការប្រើប្រាស់សិទ្ធិ និងវិធានផ្លូវការ ហើយដូច្នេះហើយ មិនគោរពច្បាប់ និងការហាមឃាត់ស្របច្បាប់។

ការយល់ដឹងអំពីសិទ្ធិប្រើប្រាស់ និងគោលការណ៍មិនផ្លូវការនានានឹងសំរួលដល់អ្នកគ្រប់គ្រង ក្នុងការរៀបចំកម្មវិធីគ្រប់គ្រង ដែលមានលក្ខណៈគោរពចំពោះប្រពៃណី និងទំនៀមទំលាប់ និងមានមូលដ្ឋានលើការរៀបចំទាំងនេះក្នុងខណៈពេលដែលដោយរាប់បញ្ចូលវិធានការស្របច្បាប់។ នេះអាចកាន់តែងាយទទួលយកសំរាប់អ្នកប្រើប្រាស់ធនធាន និងនាំទៅរកការគោរពតាមក្នុងកំរិតមួយកាន់តែខ្ពស់។ តាមរយៈការយល់ដឹងអំពីប្រពៃណី និងទំនៀមទំលាប់ទាំងនេះ អ្នកគ្រប់គ្រងអាចស្គាល់ និងបញ្ចូលវាក្នុងកម្មវិធីគ្រប់គ្រង ដើម្បីកាត់បន្ថយឱ្យនៅសល់តិចតួចបំផុតនូវ ឬកុំឱ្យមានផលប៉ះពាល់ទៅលើការអនុវត្តនីផ្នែកសង្គម និងវប្បធម៌ក្នុងសហគមន៍។

## KS31. *ការចូលរួមរបស់អ្នកពាក់ព័ន្ធ*

### ការកំណត់និយមន័យ

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺជាការវាស់វែងនូវចំនួននៃការបញ្ចូលរបស់អ្នកពាក់ព័ន្ធ ក្នុងការធ្វើសេចក្តីសំរេចលើការគ្រប់គ្រងតំបន់ឆ្នេរ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

ការចូលរួមរបស់អ្នកពាក់ព័ន្ធអាចទទួលបាន តាមរយៈ*ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ* ជាមួយនឹង មន្ត្រីសហគមន៍ ប្រធានសហគមន៍ និងអង្គការអ្នកចូលរួម ព្រមទាំងបុគ្គលិកគ្រប់គ្រងតំបន់ឆ្នេរ។ ដូចបានកត់សំគាល់ក្នុង*តារាងស្តីពីមគ្គុទេសន៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ* ដែលបានបង្ហាញអ្នកផ្តល់ព័ត៌មានសំខាន់ៗត្រូវបានសាកសួរ ថាតើអ្នកពាក់ព័ន្ធបានចូលរួមក្នុងការសេចក្តីសំរេចលើការគ្រប់គ្រងតំបន់ឆ្នេរដែរ ឬទេ (បាទ,ចាស ឬទេ)។

*ការប្រមូលទិន្នន័យបន្ថែម :* ការចូលរួមរបស់អ្នកចូលរួមក៏អាចទទួលបាន តាមរយៈការសង្កេតកិច្ចប្រជុំស្តីពីការគ្រប់គ្រងតំបន់ឆ្នេរផងដែរ ដើម្បីពិនិត្យថាតើអ្នកពាក់ព័ន្ធបានចូលរួមក្នុងកិច្ចប្រជុំ និងសំដែងឱ្យឃើញអំពីយោបល់របស់ពួកគេ ព្រមទាំងកំណត់ថាតើយោបល់របស់ពួកគេត្រូវបានពិចារណាដោយស្ថាប័នគ្រប់គ្រងដែរឬទេ។

| **អ្នកពាក់ព័ន្ធ*** | **ការចូលរួមរបស់អ្នកពាក់ព័ន្ធ (បាទ,ចាស/ទេ)** |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |

**រៀបចំបញ្ជីអនុលោមទៅតាមអ្នកចូលរួមដែលបានកំណត់ក្នុងអ្នកពាក់ព័ន្ធ(KS24)*

**វិធីសាស្ត្រវិភាគទិន្នន័យ**

ធ្វើសំយោគទិន្នន័យដែលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងពីការសង្កេតទៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ ប្រភពបន្ទាប់បន្សំ ។*

*ការវិភាគបន្ថែម :* ប្រធានបទមួយអាចត្រូវរៀបចំ ដើម្បីពិពណ៌នាអំពីកំរិត និងប្រភេទនៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសំរេចលើការគ្រប់គ្រងតំបន់ឆ្នេរ ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

សកម្មការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសំរេចលើការគ្រប់គ្រងតំបន់ឆ្នេរអាចលើកកំពស់ជោគជ័យនៃសកម្មភាពគ្រប់គ្រងតំបន់ឆ្នេរ ។ ប្រសិនបើអ្នកពាក់ព័ន្ធកាន់តែចូលរួមក្នុងការធ្វើសេចក្តីសំរេចលើការគ្រប់គ្រងតំបន់ឆ្នេរ និងគិតថាមានភាពម្ចាស់ការលើដំណើរការនោះ ពួកគេកាន់តែពេញចិត្តក្នុងការគាំទ្រសកម្មភាពគ្រប់គ្រងតំបន់ឆ្នេរ ។ អ្នកពាក់ព័ន្ធគឺមានសារៈសំខាន់ណាស់ ពីព្រោះពួកគេអាចគាំទ្រ និងរក្សានូវការគ្រប់គ្រងតំបន់ឆ្នេរ ។

## KS32. *សហគមន៍ និងស្ថាប័នពាក់ព័ន្ធ*

**ការកំណត់និយមន័យ**

សហគមន៍ និងស្ថាប័នពាក់ព័ន្ធគឺមធ្យោបាយតំណាងអ្នកប្រើប្រាស់ធនធាន និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរ និងសំរាប់ជះឥទ្ធិពលទៅដល់ទិសដៅនៃការធ្វើសេចក្តីសំរេច និងការគ្រប់គ្រង ។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ព័ត៌មានស្តីពីសហគមន៍ និងស្ថាប័នពាក់ព័ន្ធត្រូវបានទទួលពីប្រភពបន្ទាប់បន្សំ និងពីបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ។ អ្នកផ្តល់ព័ត៌មានសំខាន់ៗអាចមានមន្ត្រីមកពីការិយាល័យទីភ្នាក់ងារគ្រប់គ្រងធនធានតំបន់ឆ្នេរ មន្ត្រីរដ្ឋាភិបាលទាក់ទិនផ្សេងទៀត ប្រធានសហគមន៍ សមាជិកសមាគមផ្សេងទៀតក្នុងសហគមន៍ មន្ត្រីជលផលជាន់ខ្ពស់ តំណាងរបស់អង្គការសាសនា និងតំណាងរបស់អង្គការក្រៅរដ្ឋាភិបាល ។

ដូចបានកត់សំគាល់ក្នុង *តារាងស្តីពីមគ្គុទេសន៍កិច្ចសម្ភាសន៍ប្រភពបន្ទាប់បន្សំ/ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ* សំរាប់អង្គការនីមួយៗ ព័ត៌មានត្រូវបានប្រមូលស្តីពីថាតើអង្គការត្រូវបានអនុញ្ញាតជាផ្លូវការ ឬមិនផ្លូវការ និងស្តីពីមុខងារសំខាន់ៗរបស់អង្គការ ។ អ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានសួរថាតើអង្គការមានឥទ្ធិពលអ្វីទៅលើបញ្ហាក្នុងការគ្រប់គ្រងតំបន់ឆ្នេរ បញ្ហាសហគមន៍ ទាំងបញ្ហាគ្រប់គ្រងតំបន់ឆ្នេរ និងសហគមន៍ ឬគ្មានឥទ្ធិពលទេ ។

| អង្គការរបស់សហគមន៍ | ផ្លូវការ ឬមិនផ្លូវការ | មុខងារសំខាន់ៗ | ឥទ្ធិពល (លើការគ្រប់គ្រងតំបន់ឆ្នេរ បញ្ហាសហគមន៍ទាំងពីរ ឬគ្មាន) |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**វិធីសាស្ត្រវិភាគទិន្នន័យ**

ធ្វើសំយោគទិន្នន័យដែលទទួលបានពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងប្រភពបន្ទាប់បន្សំទៅក្នុងតារាងក្នុង*សន្លឹកវិភាគទិន្នន័យបានមកពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ ប្រភពបន្ទាប់បន្សំ* ។

*ការវិភាគបន្ថែម :* ប្រធានបទខ្លីៗមួយអាចត្រូវបានរៀបចំឡើង ដើម្បីកំណត់អំពីចំនួនសហគមន៍ និងអង្គការក្រុមអ្នកចូលរួមថាតើពួកគេមានលក្ខណៈជាផ្លូវការ ឬមិនផ្លូវការ និងមុខងារ/ការទទួលខុសត្រូវដែរឬទេ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ការយល់ដឹងអំពីសហគមន៍ និងស្ថាប័នពាក់ព័ន្ធអាចជួយដល់អ្នកគ្រប់គ្រងក្នុងការកែលំអការចូលរួម និងតំណាងរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រង និងការធ្វើសេចក្តីសំរេច។ លទ្ធផលចាំបាច់ត្រូវមានការបកស្រាយប្រៀបធៀបទៅនឹងប្រវត្តិនៃកិរិតសកម្មភាពរបស់សហគមន៍ ឬសមូហភាពនៅក្នុងប្រទេស ឬតំបន់។ ការយល់ដឹងអំពីអង្គការនឹងសំរួលដល់អ្នកគ្រប់គ្រងក្នុងការកំណត់នូវក្រុមផ្សេងៗគ្នា ដែលអាចត្រូវប៉ះពាល់ដោយវិធានការគ្រប់គ្រង និងដោះស្រាយនូវផលប៉ះពាល់ទាំងនេះជាមួយនឹងអង្គការ។

# សូចនាករបទសម្ភាសន៍តាមគ្រួសារ

## ប្រជាសាស្ត្រស្តីពីគ្រួសារ

### *H1-8. អាយុ ភេទ ជនជាតិ ការអប់រំ សាសនា ភាសា មុខរបរ ទំហំគ្រួសារ*

**ការកំណត់និយមន័យ**

ដូចដែលបានបង្ហាញក្នុង*សូចនាករអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ ប្រភពបន្ទាប់បន្សំ* អាយុ ភេទ ជនជាតិ ការអប់រំ សាសនា ភាសា មុខរបរ និងទំហំគ្រួសារគឺជាសូចនាករប្រជាសាស្ត្រជាមូលដ្ឋាន។ អាយុត្រូវបានវាស់វែងដោយភាគរយនៃសមាជិកសហគមន៍ក្នុងប្រភេទអាយុខុសៗគ្នា។ ភេទត្រូវបានវាស់វែងដោយភាគរយនៃប្រជាជនដែលជាបុរស និងភាគរយដែលជាស្ត្រី។ អប់រំត្រូវបានវាស់វែងដោយចំនួនឆ្នាំនៃ ការសិក្សាជាផ្លូវការដែលបញ្ចប់ដោយសមាជិកសហគមន៍ដែលមានអាយុលើសពី ១៦ ឆ្នាំ។ ជនជាតិ និងសាសនាត្រូវបានវាស់វែងដោយភាគរយនៃសមាជិកសហគមន៍នោះមានជនជាតិ និងសម្ព័ន្ធសាសនាផ្សេងៗគ្នា។ ភាសាត្រូវបានវាស់វែងដោយភាគរយនៃសមាជិកសហគមន៍ដែលនិយាយភាសាផ្សេងៗគ្នា ជាភាសាចំបងរបស់ពួកគេ។ មុខរបរចំបងត្រូវបានវាស់វែងដោយចំនួនប្រជាជនដែលគិតថាមុខរបរនីមួយៗជាមុខរបរចំបងរបស់ពួកគេ។ មុខរបរទីពីរត្រូវបានវាស់វែងដោយចំនួនប្រជាជនដែលគិតថាមុខរបរនីមួយៗជាមុខរបរទីពីររបស់ពួកគេ។ ទំហំគ្រួសារគឺជាចំនួនមនុស្សជាមធ្យមនៅក្នុងផ្ទះមួយក្នុងសហគមន៍។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ព័ត៌មានស្តីពីសូចនាករប្រជាសាស្ត្រទាំងនេះត្រូវបានប្រមូល តាមរយៈការសាកសួរអំពីសមាជិកទាំងអស់ក្នុងគ្រួសារ។ តាមរបៀបនេះ ក្រុមការងារប្រមូលព័ត៌មានស្តីពីប្រភេទនៃលក្ខណៈប្រជាសាស្ត្ររបស់សមាជិកក្នុងគ្រួសារ។

ក្រុមការងារសុំឱ្យអ្នកចូលរួមបំពេញតារាងខាងក្រោម ដូចបានកត់សំគាល់ក្នុង *មគ្គុទេសក៍កិច្ចសម្ភាសន៍តាមគ្រួសារ (ឧបសម្ព័ន្ធ "គ")។* សមាជិកគ្រួសារនីមួយៗត្រូវបានកត់សំគាល់ក្នុងកូឡោនទីមួយ ហើយព័ត៌មានត្រូវបានដាក់នៅខាងស្តាំ ៖

| សមាជិកគ្រួសារ* | អាយុ | ភេទ | ការអប់រំដែលទទួល (សួរតែបុគ្គលអាយុ >១៦ ឆ្នាំ ប៉ុណ្ណោះ) | សាសនា | ជនជាតិ | ភាសា | មុខរបរចំបង | មុខរបរទីពីរ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **កំណត់អ្នកដែលរស់នៅទាំងអស់ ក្នុងផ្ទះទៅតាមឈ្មោះ ឬ តួនាទី (ឧ. ជីដូន)* | | | | | | | | |

**វិធីសាស្ត្រវិភាគទិន្នន័យ**

***ការវិភាគមុខរបរ***

សំរាប់ការវិភាគមុខរបរ ដំបូងកំណត់អំពីមុខរបរទាំងអស់ ដែលបានកត់សំគាល់ ក្នុងពេលសម្ភាសន៍ និងចុះវាក្នុងតារាងក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ (ឧបសម្ព័ន្ធ "ង")* (សូមអានឧទាហរណ៍)។ ដើម្បីងាយស្រួល ដាក់ជាក្រុមនូវមុខរបរទាំងអស់ដែលមានចំនួនមនុស្ស ៥% នៃប្រជាជនទាំងអស់ក្រោម "ផ្សេងៗ"។

បន្ទាប់មកគណនាចំនួនប្រជាជនទាំងអស់ដែលទទួលបានពីតារាងស្តីពីគ្រួសារទាំងអស់ ដែលបានចុះថាមុខរបរនេះជា មុខរបរចំបងរបស់ពួកគេ។ បន្ទាប់មក គណនាភាគរយនៃប្រជាជនដែលបំរើការនៅក្នុងមុខរបរនីមួយៗជាមុខរបរចំបងរបស់ពួកគេ ដោយចែកចំនួនប្រជាជនដែលបានកត់សំគាល់សំរាប់មុខរបរនីមួយៗទៅនឹងចំនួនប្រជាជនសរុបក្នុងគ្រួសារទាំងអស់ ដូចបានកត់សំគាល់ក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ* និងបានបង្ហាញក្នុងតារាង។

ធ្វើការគណនាដូចគ្នាសំរាប់មុខរបរទីពីរ ដោយដំបូងគណនាចំនួនប្រជាជនសរុបដែលទទួលបានពីគ្រួសារទាំង អស់ដែលបានកត់សំគាល់មុខរបរនីមួយៗជាមុខរបរទីពីររបស់ពួកគេ។ បន្ទាប់មក គណនាភាគរយនៃប្រជាជនពីគ្រួសារ ដែលបានកត់សំគាល់មុខរបរនីមួយៗជាមុខរបរទីពីររបស់ពួកគេ ដោយចែកចំនួនប្រជាជន ដែលបានកត់សំគាល់សំរាប់មុខរបរនីមួយៗ ទៅនឹងចំនួនប្រជាជនសរុបក្នុងគ្រួសារទាំងអស់ដែលបានសម្ភាសន៍ ដូចដែលបានបង្ហាញក្នុងតារាង។ សូមកត់សំគាល់ផង ដែរថា ភាគរយសរុបនៃសមាជិកគ្រួសារដែលមុខរបរទីពីរគឺតិចជាង ១០០%។ នេះគឺពីព្រោះ មិនមែនសមាជិកគ្រួសារ ទាំងអស់មានមុខរបរទីពីរនោះទេ។ ក្នុងឧទាហរណ៍ខាងក្រោម មាន ៨០% មានមុខរបរទីពីរ ២០%គ្មាន។

ជាទីបញ្ចប់ បូកភាគរយពីមុខរបរចំបង និងទីពីរ សំរាប់មុខរបរនីមួយៗ ដើម្បីកំណត់អំពីភាគរយសរុបរបស់សមាជិកសហគមន៍ ដែលផ្អែកទៅលើមុខរបរនីមួយៗ ដូចដែលបានបង្ហាញក្នុងតារាង។ កត់សំគាល់ថាផលបូកសរុបគឺច្រើនជាង ១០០%។ នេះ គឺពីព្រោះភាគរយសរុបរួមបញ្ចូលទាំងមុខរបរចំបង និងទីពីររបស់សមាជិកគ្រួសារ។ ដូច្នេះហើយ ពួកគេត្រូវបានគិតពីរដង ប្រសិនបើពួកគេមានមុខរបរទីពីរ។

| មុខរបរ | ចំបង | | ទីពីរ | | ភាគរយសរុបនៃសមាជិកសហគមន៍ដែលអាស្រ័យលើមុខរបរនេះ (ចំបង និងទីពីរ) |
|---|---|---|---|---|---|
| | ចំនួននៃសមាជិកគ្រួសារដែលបានចុះក្នុងមុខរបរចំបង | ភាគរយសមាជិកគ្រួសារដែលចុះក្នុង មុខរបរចំបង | ចំនួនដែលចុះក្នុងមុខរបរទីពីរ | ភាគរយសមាជិកគ្រួសារដែលបានចុះមុខរបរនីមួយៗជាមុខរបរទីពីរ | |
| *ការនេសាទ* | *៦៥* | *៣២.៥%* | *៥០* | *២៥%* | *៥៧.៥%* |
| *ការអភិវឌ្ឍន៍សណ្ឋាគារ* | *៥០* | *២៥%* | *២០* | *១០%* | *៣៥%* |
| *វារីវប្បកម្ម* | *៣០* | *១៥%* | *៦០* | *៣០%* | *៤.៥%* |
| *ផ្សេងៗ* (*ការរុករករ៉ែថ្មា*) | *៥* | *២.៥%* | *៣០* | *១៥%* | *១៧.៥%* |
| *គ្មានមុខរបរ*** | *៥០* | *២៥%* | *០* | *០%* | *២៥%* |
| *សរុប* | *២០០* | *១០០%* | *១៦០* | *៨០%* | *១៨០%* |

* *កត់ត្រារួមគ្នានូវមុខរបរទាំងអស់ដែលបាកត់សំគាល់សំរាប < ៥% នៃសមាជិកគ្រួសារ*

** *ឧទាហរណ៍ គ្មានការងារ សិស្ស ចូលនិវត្តន៍*

*ការវិភាគបន្ថែម :* ប្រៀបធៀបលទ្ធផលទាំងនេះជាមួយនឹងទិន្នន័យដែលទទួលបានពី *មុខរបរអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ ប្រភពបន្ទាប់បន្សំ (KS12)* ដែលសាកសួរអំពីភាគរយនៃប្រជាជនដែលមានមុខរបរនេះជា មុខរបរចំបង និងមុខរបរទីពីរ។ ប្រសិនបើមានភាពខុសគ្នាសំខាន់ៗ នោះសូមប្រឹក្សាយោបល់ជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់អំពីមូលហេតុ។ ប្រសិនបើភាពខុសគ្នាមិនអាចត្រូវបានពន្យល់នោះទេ វាអាចចាំបាច់ត្រូវសម្ភាសន៍តាមគ្រួសារទាំងអស់ ដើម្បីកំណត់ឱ្យបានត្រឹមត្រូវអំពីរចនាសម្ព័ន្ធការងារ។ សូមកត់សំគាល់ថា ទិន្នន័យអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំគឺផ្អែក ទៅតាមប្រជាជន*ធ្វើការងារ* ដូច្នេះហើយសូមកុំបញ្ចូលអ្នកដែលជាសិស្ស ចូលនិវត្តន៍ ឬបើមិនដូច្នេះទេ មិនអាចដំណើរការទៅបានទេ។ ដើម្បីប្រៀបធៀប

ឱ្យបានត្រឹមត្រូវ ភាគរយគ្រួសារនឹងត្រូវបានគណនាជាថ្មី ផ្អែកតែទៅលើប្រជាជនដែលបានចុះថាធ្វើការ (មានន័យថា មិនដោយរាប់បញ្ចូលនូវប្រជាជនដែលបានកត់សំគាល់ថាជា "សិស្ស" "គ្មាន ការងារ"។ល។ ជាមុខរបររបស់ពួកគេ) នោះទេ។

ប្រៀបធៀបការប្រែប្រួលនៃចំនួនប្រជាជនក្នុងមុខរបរនីមួយៗក្នុងពេលមួយ ជាមួយនឹងទិន្នន័យស្ដីពីប្រែប្រួលនៃ *ប្រភេទប្រើប្រាស់ (KS16) កំរិតនៃផលប៉ះពាល់ (KS20)* និងលក្ខខណ្ឌធនធាន ក្នុងពេលមួយ ដើម្បីកំណត់នូវទំនាក់ទំនងនានា។

ដូចគ្នានេះដែរ គណនាការប្រែប្រួលនៃរចនាសម្ពន្ធការងារក្នុងពេលមួយ។ យកភាគរយ និងចំនួនក្នុងឆ្នាំបច្ចុប្បន្ន រួចដកនឹងឆ្នាំមុនដើម្បីពិនិត្យថាតើ មានការកើនឡើង ការធ្លាក់ចុះ ឬគ្មានការកែប្រែ។

*ការវិភាគប្រជាសាស្ត្រ :* សំរាប់មុខរបរចំបងនីមួយៗ គណនាភាគរយនៃប្រជាជន ក្នុងប្រភេទអាយុនីមួយៗ ប្រភេទការ អប់រំ ប្រភេទជនជាតិ ប្រភេទសាសនា និងប្រភេទភេទ រួចកត់សំគាល់ភាគរយទាំងនេះ ក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ* (សូមអានឧទាហរណ៍ខាងក្រោមសំរាប់តារាងស្ដីពីអាយុ និង ការអប់រំ)។

| ការឆ្លើយតបជាភាគរយ | | | | | | | |
|---|---|---|---|---|---|---|---|
| **មុខរបរចំបង** | ០-១៥ ឆ្នាំ | ១៦-២៥ ឆ្នាំ | ២៦-៤៥ ឆ្នាំ | ជាង ៤៥ ឆ្នាំ | សិក្សា <៦ ឆ្នាំ | សិក្សា <៦-៩ ឆ្នាំ | សិក្សា >៩ ឆ្នាំ |
| *នេសាទ* | *៦%* | *២៩%* | *៣៩%* | *៣៥%* | *១០%* | *៦០%* | *៣០%* |
| *ការអភិវឌ្ឍន៍សណ្ឋាគារ* | *០%* | *៤៥%* | *៣០%* | *២៥%* | *៥%* | *៣០%* | *៦៥%* |

*ការវិភាគបន្ថែម :* ប្រៀបធៀបទិន្នន័យប្រជាសាស្ត្រទាំងនេះ សំរាប់មុខរបរទាំងអស់រួមគ្នាជាមួយនឹងទិន្នន័យ *សម្ភាសន៍អ្នកផ្ដល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ អាយុ ភេទ ការអប់រំ អក្ខរកម្ម ជនជាតិ សាសនា និងភាសា (KS5-11)*។ ប្រសិនបើមានភាពខុសគ្នាសំខាន់ៗ នោះសូមប្រឹក្សាយោបល់ជាមួយនឹងអ្នកផ្ដល់ព័ត៌មានសំខាន់ៗដើម្បីកំណត់អំពីមូលហេតុ។ ប្រសិនបើភាពខុសគ្នាមិនអាចត្រូវបានពន្យល់ទេនោះ វាអាចចាំបាច់ត្រូវសម្ភាសន៍តាមគ្រួសារទាំងអស់ ដើម្បីកំណត់ឱ្យបានត្រឹមត្រូវអំពីប្រជាសាស្ត្រសហគមន៍។ លើសពីនេះទៅទៀត ប្រធានបទខ្លីមួយអាចត្រូវបានរៀបចំឡើង ដើម្បីអធិប្បាយអំពីលក្ខណៈនៃក្រុមមុខរបរនីមួយៗ។

*ទំហំគ្រួសារ :* គណនាទំហំគ្រួសារជាមធ្យម ដោយបូកចំនួនមនុស្សក្នុងគ្រួសារនីមួយៗ រួចចែកនឹងចំនួនគ្រួសារ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ក្នុងការប្រៀបធៀបទៅនឹងទិន្នន័យប្រជាសាស្ត្រ ដែលទទួលបានពីទិន្នន័យអ្នកផ្តល់ព័ត៌មានសំខាន់ៗ/ប្រភពបន្ទាប់បន្សំ ដែលទទួលបានពីបទសម្ភាសន៍តាមគ្រួសារត្រូវបានវិភាគជាក់លាក់ចំពោះមុខរបរនីមួយៗ។ ការនេះអាចធ្វើឱ្យអ្នកគ្រប់គ្រងទទួលបានការយល់ដឹងអំពីប្រភេទនៃបុគ្គលដែលបំរើការនៅក្នុងមុខរបរខុសៗគ្នា ដែលអាចជួយគាត់/នាងក្នុងការកែសំរួលកម្មវិធីគ្រប់គ្រង។ ឧទាហរណ៍ ប្រសិនបើអ្នកគ្រប់គ្រងដឹងថាម្ចាស់វារីវប្បកម្មភាគច្រើនគឺមិនចេះអក្សរ និងម្ចាស់សណ្ឋាគារភាគច្រើនមានការអប់រំខ្ពស់ នោះគាត់/នាងអាចរៀបចំកម្មវិធីអប់រំផ្អែកទៅតាមបែបមនោគតិរូបភាពសំរាប់ម្ចាស់វារីវប្បកម្ម និងកម្មវិធីអប់រំផ្អែកទៅតាមការយោងជាលក្ខណៈវិទ្យាសាស្ត្រសំរាប់ម្ចាស់សណ្ឋាគារ។

## *H9. ចំណូលគ្រួសារ*

### ការកំណត់និយមន័យ

ចំណូលគ្រួសារសំដៅប្រភពចំណូលសំខាន់ៗសំរាប់គ្រួសារ។ ព័ត៌មាននេះត្រូវបានប្រមូលបន្ថែមលើរចនាសម្ព័ន្ធការងារ ដើម្បីកំណត់អំពីប្រភពចំណូលនានា ដែលមិនទាក់ទិនទៅនឹងមុខរបរ ដូចជាប្រាក់ផ្ញើពីក្រៅប្រទេសជាដើម។

### វិធីសាស្ត្រប្រមូលទិន្នន័យ

ដូចបានកត់សំគាល់ក្នុង *មគ្គុទេសក៍បទសម្ភាសន៍តាមគ្រួសារ* ទិន្នន័យស្តីពីចំណូលគ្រួសារត្រូវបានទទួលតាមរយៈការសាកសួរអ្នកចូលរួមនីមួយៗ :

តើប្រភពចំណូលសំខាន់បំផុតរបស់គ្រួសារអ្នកគឺជាអ្វី?_______________

តើប្រភពចំណូលសំខាន់បំផុតទីពីររបស់គ្រួសារអ្នកគឺជាអ្វី?__________

សូមកត់សំគាល់ថាការប្រមូលទិន្នន័យនេះអាចងាយប៉ះពាល់ចំពោះបុគ្គលមួយចំនួន ដោយគិតថាវាជាបញ្ហាផ្ទាល់ខ្លួន។ ក្រុមការងារត្រូវពិចារណាយ៉ាងយកចិត្តទុកដាក់អំពីតំបន់សិក្សារបស់ពួកគេ និងសមាជិកសហគមន៍ដើម្បីកំណត់ថាតើវាសមរម្យដែរឬទេក្នុងការសួរ*សំណួរនេះ។*

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលទទួលបានពីបទសម្ភាសន៍តាមគ្រួសារទាំងអស់។ សំរាប់មុខរបរនីមួយៗ គណនាភាគរយនៃអ្នកចូលរួមដែលបានកត់សំគាល់ថា វាគឺជាប្រភពចំណូលចំបងរបស់គ្រួសារពួកគេ និងភាគរយនៃអ្នកចូលរួមដែលបានកត់សំគាល់ថា វាគឺជាប្រភពចំណូលសំខាន់បំផុតទីពីររបស់គ្រួសារអ្នក និងកត់សំគាល់អំពីភាគរយទាំងនេះក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ។*

*ការវិភាគបន្ថែម :* ប្រៀបធៀបលទ្ធផលទាំងនេះជាមួយនឹងទិន្នន័យស្តីពី*មុខរបរ* (*KS12* និង *H7*) ដើម្បីផ្ទៀងផ្ទាត់ថា មុខរបរដូចគ្នាមានសារៈសំខាន់។ កត់សំគាល់ថា វាអាចមានភាពខុសគ្នាដោយសារប្រភេទចំណូលដែលមិនមែនជាមុខរបរ (ឧ. ប្រាក់ផ្ញើជូន)។ តាមដានលទ្ធផលទាំងនេះក្នុងពេលមួយ ដើម្បីកំណត់អំពីការកែប្រែនៃសារៈសំខាន់មុខរបរផ្សេងៗ។

### សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ព័ត៌មានស្តីពីប្រភពចំណូលចំបង និងទីពីរមានប្រយោជន៍សំរាប់ការកំណត់អំពីសារៈសំខាន់នៃធនធានចំពោះសហគមន៍។ ឧទាហរណ៍ ប្រសិនបើ ជាង ៨០% នៃសហគមន៍គិតថាការនេសាទគឺជាប្រភពចំណូលចំបង ឬទីពីរនោះ នេះការបង្ហាញថាសហគមន៍មានការពឹងផ្អែកខ្ពស់ទៅលើការនេសាទ និងជាផលវិបាកគឺទៅលើធនធានសមុទ្រ។

## សកម្មភាពនៅតាមតំបន់ឆ្នេរ និង សមុទ្រ

### *H10. សកម្មភាពគ្រួសារ*

### ការកំណត់និយមន័យ

សកម្មភាពគ្រួសារនៅតាមតំបន់ឆ្នេរ និងសមុទ្រ គឺជាដំណើរការកំណត់អំពីការប្រើប្រាស់របស់គ្រួសារនូវធនធាននៅតាមតំបន់ឆ្នេរ និងសមុទ្រនៅក្នុងតំបន់សិក្សា។

| សកម្មភាពនៅតាម តំបន់ឆ្នេរ និងសមុទ្រ |
|---|
| ១. ការនេសាទ |
| ២. ទេសចរណ៍ |

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ស្នើឱ្យអ្នកចូលរួមធ្វើការកំណត់ការប្រើប្រាស់របស់សមាជិកគ្រួសារទាំងអស់ទៅលើធនធាននៅតាមតំបន់ឆ្នេរ និងសមុទ្រ។ ព័ត៌មាននេះត្រូវបានបញ្ជាក់ជូននៅក្នុងតារាង *គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញស្រាប់។

**វិធីសាស្ត្រវិភាគទិន្នន័យ**

ទិន្នន័យពីការអង្កេតគ្រួសារទាំងអស់ត្រូវរៀបចំទៅតាមលំដាប់លំដោយ ទៅតាមសកម្មភាពសំខាន់បំផុតចំពោះគ្រួសារទាំងឡាយ។ សកម្មភាពដែលចាត់ទុកថាសំខាន់ជាងគេបំផុតចំពោះគ្រួសារគួរសរសេរមុនគេ បន្ទាប់មកសកម្មភាពដែលចាត់ទុកថាសំខាន់បំផុតទី២ ។ល។ ព័ត៌មាននេះ ត្រូវបានបញ្ជាក់ជូននៅក្នុង *សន្លឹកវិភាគ*

*ទិន្នន័យបានពី បទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញ។

*ការវិភាគបន្ថែម:* ប្រធានបទមួយអាចនឹងត្រូវរៀបចំឡើង ដោយធ្វើការពិពណ៌នាអំពីសកម្មភាពផ្សេងៗរបស់គ្រួសារក្នុង សហគមន៍នៅតាមតំបន់ឆ្នេរ និងសមុទ្រ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ការកំណត់ពីសកម្មភាពរបស់គ្រួសារនៅតាមតំបន់ឆ្នេរ និងសមុទ្រ មានសារៈសំខាន់ចំពោះអ្នកគ្រប់គ្រង ដើម្បីស្វែងយល់អំពីការប្រើប្រាស់ផ្សេងៗនូវធនធាននៅតាមតំបន់ឆ្នេរ និងសមុទ្រនៅក្នុងមូលដ្ឋាន និងការពឹងផ្អែករបស់គ្រួសារចំពោះសកម្មភាពជាក់ស្តែងទាំងឡាយ។

### H11. *ទំនិញ និងសេវាកម្មរបស់គ្រួសារ*

**ការកំណត់និយមន័យ**

ទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ គឺជាផលិតផលជាក់លាក់ទាំងឡាយណាដែលផលិតចេញពីសកម្មភាពគ្រួសារនៅតាមតំបន់ឆ្នេរ និងសមុទ្រ។ ផលិតផលទាំងនេះត្រូវបានផលិតឡើងពីប្រភពធនធាននានាដូចជា ត្រី ឈើព្រៃ កោងកាង ផលិតផលធ្វើអំពីផ្កាថ្ម និងខ្សាច់ ហើយនិងសេវាកម្មមិនទាញយកប្រយោជន៍ពីធម្មជាតិផ្សេងៗ ដូចជា ទេសចរណ៍/សកម្មភាពសំរាកវិស្សមកាល និងវារីវប្បកម្ម។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ស្នើឱ្យអ្នកចូលរួមធ្វើការកំណត់ទៅលើទំនិញ និងសេវាកម្មទាំងអស់ដែលកើតចេញពីសកម្មភាពរបស់គ្រួសារនីមួយៗ នៅតាមតំបន់ឆ្នេរ និងសមុទ្រ។ ព័ត៌មាននេះត្រូវបានបញ្ជាក់ជូននៅក្នុងតារាង *គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍ តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញស្រាប់។

## វិធីសាស្ត្រវិភាគទិន្នន័យ

| សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ |
|---|---|
| ១. ការនេសាទ | ត្រីតុកកែ |
| | មឹក |
| | បង្គា |
| ២. ទេសចរណ៍ | ការអភិវឌ្ឍន៍សណ្ឋាគារ |
| | ការមុជទឹកនៅបាតសមុទ្រ |
| | ការនេសាទជាលក្ខណៈកំសាន្ត |

ទិន្នន័យពីការអង្កេតគ្រួសារទាំងអស់ ត្រូវរៀបចំទៅតាមលំដាប់លំដោយនៃសារៈសំខាន់ចំពោះគ្រួសារ នៃប្រភេទទំនិញ និងសេវានៅតាមតំបន់ឆ្នេរ និងសមុទ្រ ដែលកើតចេញពីសកម្មភាពនីមួយៗ។ ទំនិញ និងសេវាកម្មដែលចាត់ទុកថា សំខាន់ជាងគេបំផុតចំពោះគ្រួសារ គួរសរសេរមុនគេ បន្ទាប់មកទំនិញ និងសេវាដែលចាត់ទុកថាសំខាន់បំផុតទី២ ។ល។ ព័ត៌មាននេះត្រូវបានបញ្ជាក់ជូននៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញ។

*ការវិភាគបន្ថែម* : ប្រធានបទមួយអាចនឹងត្រូវរៀបចំឡើង ដោយធ្វើការពិពណ៌នាអំពីទំនិញ និងសេវាកម្មរបស់គ្រួសារក្នុងសហគមន៍នៅតាមតំបន់ឆ្នេរ និងសមុទ្រ ។

## សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ព័ត៌មានស្តីអំពីទំនិញ និងសេវាកម្មរបស់គ្រួសារនៅតាមតំបន់ឆ្នេរ និងសមុទ្រ មានសារៈសំខាន់ក្នុងការកំណត់ផលប៉ះពាល់នៃការគ្រប់គ្រងទៅលើគ្រួសារទាំងអស់ ជាពិសេសផ្នែកទីផ្សារ និងផលិតផល នៅក្នុងតំបន់សិក្សា។ ជាលទ្ធផល ការអនុវត្តន៍វិធានការគ្រប់គ្រង អាចនឹងមានការផ្លាស់ប្តូរនៃការផលិតទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ នៅក្នុងតំបន់សិក្សា ដោយវាមានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានទៅលើគ្រួសារ។ ជាឧទាហរណ៍ ប្រសិនបើតំបន់សមុទ្រដែលមានការការពារលើកកំពស់វិស័យទេសចរណ៍បានយ៉ាងសកម្មនៅក្នុងតំបន់ នោះសង្ឃឹមថាតំលៃនៃការហែលទឹកកំសាន្ត មានការកើនឡើង ហើយសមាជិកគ្រួសារទាំងឡាយនឹងងាកមករកការធ្វើអាជីវកម្មលើការហែលទឹកវិញ។

### H12. *ប្រភេទនៃការប្រើប្រាស់របស់គ្រួសារ*

## ការកំណត់និយមន័យ

ប្រភេទនៃការប្រើប្រាស់របស់គ្រួសារ កំណត់ទៅលើវិធីសាស្ត្រ ឬការអភិវឌ្ឍន៍ជាក់លាក់ដែលកំពុងតែប្រើប្រាស់ (ឧ. ការដាក់លប សំណាញ់ ផ្ទះសំណាក់ ឧបករណ៍មុជទឹកនៅបាតសមុទ្រ) សំរាប់ទំនិញ និងសេវាកម្មនីមួយៗនៅតាមតំបន់ឆ្នេរ និងសមុទ្រ (សូមមើលប្រភេទនៃការប្រើប្រាស់ *(KS16)* សំរាប់ព័ត៌មានបន្ថែម) ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

ស្នើឱ្យអ្នកចូលរួមធ្វើការកំណត់ទៅលើវិធីសាស្ត្រ ឬការអភិវឌ្ឍន៍ជាក់លាក់ដែលកំពុងតែប្រើប្រាស់សំរាប់ទំនិញ និងសេវាកម្មនីមួយៗនៅតាមតំបន់ឆ្នេរ និងសមុទ្រ។ ព័ត៌មាននេះ ត្រូវបានបញ្ជាក់ជូននៅក្នុងតារាង *គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញស្រាប់។

| សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ប្រភេទនៃការប្រើប្រាស់របស់គ្រួសារ |
|---|---|---|
| ១. ការនេសាទ | ត្រីតុកកែ | លប ខ្សែសន្ទូច ថ្នាំបំពុល ស៊ីយ៉ានីត |
| | មឹក | អួន |
| | បង្គា | អួន |
| ២. ទេសចរណ៍ | ការអភិវឌ្ឍន៍សណ្ឋាគារ | រួមបញ្ចូលផ្ទះសំណាក់ទាំងអស់ |
| | ការមុជទឹកនៅបាតសមុទ្រ | ឧបករណ៍មុជទឹកនៅបាតសមុទ្រ |
| | ការនេសាទជាលក្ខណៈកំសាន្ត | ទូកដែលមានចំណុះ ២៥នាក់ |

### វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យពីការអង្កេតគ្រួសារទាំងអស់ត្រូវរៀបចំទៅតាមលំដាប់លំដោយ ដោយផ្អែកទៅតាមភាព សំខាន់បំផុតចំពោះគ្រួសារទាំងឡាយ នៃទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រដែលកើតចេញពីសកម្មភាពនីមួយៗ។ ទំនិញ និងសេវាកម្មដែលចាត់ទុកថាសំខាន់ជាងគេបំផុតចំពោះគ្រួសារគួរតែសរសេរមុនគេ បន្ទាប់មកទំនិញ និងសេវាកម្មដែលចាត់ទុកថាសំខាន់បំផុតទី២ ។ល។ ព័ត៌មាននេះត្រូវបានបញ្ជាក់ជូននៅក្នុង*សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញ។

*ការវិភាគបន្ថែម*: ប្រធានបទមួយ អាចនឹងត្រូវរៀបចំឡើង ដោយធ្វើការពិពណ៌នាអំពីទំនិញ និងសេវាកម្មរបស់គ្រួសារក្នុងសហគមន៍ នៅតាមតំបន់ឆ្នេរ និងសមុទ្រ។

### សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ព័ត៌មានស្តីអំពីប្រភេទនៃការប្រើប្រាស់ មានសារៈសំខាន់ជាពិសេសសំរាប់ធ្វើការកំណត់ទៅលើការគំរាមកំហែងនានាចំពោះធនធាននៅតាមតំបន់ឆ្នេរ និងសមុទ្រ មានដូចជា ការនេសាទត្រីដោយគ្រាប់បែក ឬការកាប់បំផ្លាញព្រៃកោងកាង។ តាមរយៈការគ្រប់គ្រងព័ត៌មាននេះនាពេលកន្លងមក អ្នកគ្រប់គ្រងអាចយល់ដឹងអំពីការគ្រប់គ្រងផលប៉ះពាល់ជាក់លាក់ ដែលកើតមានចំពោះការប្រើប្រាស់ទាំងនេះផងដែរ។ ឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរ បានបង្កើតឱ្យមានយុទ្ធនាការដាំព្រៃកោងកាងឡើងវិញ ប៉ុន្តែព្រៃកោងកាងនៅតែទទួលរងនូវ

ការកាប់បំផ្លាញជាបន្តបន្ទាប់ ដើម្បីបំពេញទៅតាមតំរូវការនៃការប្រើប្រាស់ ដែលនេះឆ្លុះបញ្ចាំងឱ្យឃើញថា យុទ្ធនាការនេះមិនបានបន្តការពារចំពោះការកាប់បំផ្លាញព្រៃកោងកាងទៀតទេ។ ព័ត៌មាននេះក៏បានជួយកំណត់ទៅលើប្រសិទ្ធភាពនៃកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរផងដែរ។

ការយល់ដឹងអំពីប្រភេទនៃការប្រើប្រាស់ណាខ្លះដែលកើតមាននៅក្នុងតំបន់សិក្សា ក៏មានសារៈសំខាន់ផងដែរ ក្នុងការរៀបចំបង្កើតកម្មវិធីលើកកំពស់ការយល់ដឹង និងជំរុញការចូលរួមពីភាគីដែលពាក់ពន្ធ័ផ្សេងៗ នៅក្នុងដំណើរការគ្រប់គ្រងតំបន់ឆ្នេរ។ អ្នកគ្រប់គ្រងចាំបាច់ត្រូវយល់ដឹងអំពីទំនាក់ទំនងរវាងមនុស្ស និងធនធាននានា ដើម្បីធ្វើការទំនាក់ទងជាមួយពួកគេ ទាក់ទងទៅនឹងការគំរាមកំហែងទៅលើធនធានទាំងនេះ។

### *H13. ការកំណត់គោលដៅទីផ្សាររបស់គ្រួសារ*

#### ការកំណត់និយមន័យ

ការកំណត់គោលដៅទីផ្សាររបស់គ្រួសារ គឺជាការកំណត់ទីផ្សារ សំរាប់ផលិតផលនៅតាមតំបន់ឆ្នេរ និងសមុទ្រនីមួយៗដែលគ្រួសារផលិតជាចំបងសំរាប់លក់ទៅកាន់ទីផ្សារ។ ព័ត៌មានស្តីអំពីគ្រួសារអាចត្រូវបានប្រើប្រាស់សំរាប់កំណត់គោលដៅទីផ្សាររបស់សហគមន៍ទាំងមូល។

#### វិធីសាស្ត្រប្រមូលទិន្នន័យ

សំរាប់ទំនិញ និងសេវាកម្មនីមួយៗនៅតាមតំបន់ឆ្នេរ និងសមុទ្រ ស្នើឱ្យអ្នកចូលរួមធ្វើការកត់សំគាល់អំពីទីផ្សារជាចំបងដែលគេលក់ផលិតផលទាំងនេះ (អន្តរជាតិ ជាតិ ក្នុងតំបន់ ឬក្នុងស្រុក)។ អ្នកចូលរួមត្រូវបានកំណត់នៅក្នុងតារាង *គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញស្រាប់។

| សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ប្រភេទនៃការប្រើប្រាស់របស់គ្រួសារ | ការកំណត់គោលដៅទីផ្សាររបស់គ្រួសារ |
|---|---|---|---|
| ១. ការនេសាទ | ត្រីតុកកែ | លប ខ្សែសន្ទូច ថ្នាំបំពុលស៊ីយ៉ានីត | ក្នុងតំបន់ |
| | មឹក | អួន ខ្សែសន្ទូច | ក្នុងស្រុក |
| | បង្គា | អួន | ក្នុងតំបន់ |
| ២. ទេសចរណ៍ | ការអភិវឌ្ឍន៏សណ្ឋាគារ | រួមបញ្ចូលផ្ទះសំណាក់ទាំងអស់ | អន្តរជាតិ |
| | ការមុជទឹកនៅបាតសមុទ្រ | ឧបករណ៏មុជទឹកនៅបាត សមុទ្រ | ជាតិ |
| | ការនេសាទជាលក្ខណៈកំសាន្ត | ទូកដែលមានចំណុះ ២៥នាក់ | ក្នុងស្រុក |

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលបានមកពីការអង្កេតគ្រួសារទាំងអស់។ ចុះមុខទំនិញ និងសេវាកម្ម និងគិតជាភាគរយនៃអ្នកចូលរួមទាំងឡាយណាដែលគត់សំគាល់ថា ទំនិញ និងសេវាកម្មនីមួយៗបានលក់នៅតាមទីផ្សារអន្តរជាតិ ជាតិ ក្នុងតំបន់ ឬ ក្នុងស្រុក។ ព័ត៌មាននេះត្រូវបានបញ្ចោក់ជូននៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៏តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញ។

| ទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ | %ដែលសំគាល់ជាទីផ្សារអន្តរជាតិ | %ដែលសំគាល់ជាទីផ្សារជាតិ | %ដែលសំគាល់ជាទីផ្សារក្នុងតំបន់ | %ដែលសំគាល់ជាទីផ្សារក្នុងស្រុក |
|---|---|---|---|---|
| ត្រីតុកកែ | 0% | 30% | 40% | 30% |
| មឹក | 0% | 15% | 35% | 50% |
| បង្គា | 20% | 20% | 35% | 35% |
| ការអភិវឌ្ឍន៏សណ្ឋាគារ | 60% | 35% | 3% | 3% |
| ការហែលទឹកនៅបាតសមុទ្រ | 50% | 40% | 8% | 2% |

| ការនេសាទជាលក្ខណៈកំសាន្ត | 10% | 10% | 30% | 50% |
|---|---|---|---|---|

*ការវិភាគបន្ថែមៈ* ប្រធានបទមួយ អាចនឹងត្រូវរៀបចំឡើង ដោយធ្វើការពិពណ៌នាអំពីទីផ្សារផ្សេងៗ សំរាប់លក់ទំនិញ និងសេវាកម្មទាំងនេះ ។

### សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ការកំណត់គោលដៅទីផ្សារ មានសារៈសំខាន់ណាស់សំរាប់កំណត់ទៅលើផលប៉ះពាល់ទាំងមូលទៅលើការគ្រប់គ្រងនៅតាមសហគមន៍ ជាពិសេសផ្នែកទីផ្សារ ផលិតកម្ម និងសន្តិសុខស្បៀង ។ ឧទាហរណ៍ ការវិនិយោគនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគមន៍ មានដូចជាការស្ថាបនាផ្លូវតភ្ជាប់ទៅកាន់ទីក្រុងធំៗ អាចនឹងបង្កើតបានជាបណ្តាញគមនាគមន៍ ដ៏សំខាន់ឆ្ពោះទៅកាន់ទីផ្សារជាតិ ក្នុងតំបន់ និងអន្តរជាតិ ។

ដោយសារតែជីវភាពរស់នៅ និងប្រាក់ចំណូលរបស់ប្រជាជននៅតាមសហគមន៍ពឹងផ្អែកទៅលើទីផ្សារ ហេតុនេះហើយការកំណត់យកទីផ្សារត្រីមានសារៈសំខាន់ណាស់ ដោយសារវាអាចឱ្យគេដឹងពីកន្លែងសំរាប់ដាក់លក់ធនធានសមុទ្រដែលផលិតបាននៅក្នុងតំបន់នេះ ។ តាមរយៈសូចនាករនេះ យើងអាចធ្វើការវិភាគទៅលើការប្រែប្រួលទីផ្សារផលិតផលសមុទ្រសំខាន់ៗ នាពេលកន្លងមក ។ វាបង្ហាញអំពីទំនាក់ទំនងរវាងផលិតករក្នុងស្រុកជាមួយនឹងអាជីវករនៅតាមទីផ្សារផ្សេងៗ ឧ. ទំនាក់ទំនងជាមួយនឹងទីផ្សារអន្តរជាតិទាំងឡាយដែលអាចនឹងមានឥទ្ធិពលនៅលើការប្រមូលទិន្នផល ។

ការកំណត់គោលដៅទីផ្សារក៏អាចមានសារៈសំខាន់ ក្នុងការបង្ហាញអំពីការិតនៃការដាក់គំនាបដែលអាចនឹងមានចំពោះធនធានផងដែរ ។ ឧ. អ្នកនេសាទអាចនឹងខំប្រឹងប្រែងនេសាទត្រីដែលមានតំលៃថ្លៃសំរាប់លក់នៅទីផ្សារអន្តរជាតិ ។ វាក៏អាចបង្ហាញឱ្យឃើញអំពីការប្រែប្រួលទីផ្សារផលិតផលសមុទ្រនាពេលកន្លងមកផងដែរ ។ ផលប៉ះពាល់នៃវិធានការគ្រប់គ្រងអាចត្រូវបានវាយតំលៃតាមរយៈការប្រែប្រួលទីផ្សារ ។ ឧ. វិធានការគ្រប់គ្រងអាចជួយរក្សាឱ្យមានត្រីដែលមានតំលៃ ថ្លៃនៅក្នុងតំបន់ដែលអាចលក់នៅតាមទីផ្សារក្នុងតំបន់ និងទីផ្សារជាតិ ។

## H14. *ការប្រើប្រាស់របស់គ្រួសារ*

### ការកំណត់និយមន័យ

ការប្រើប្រាស់របស់គ្រួសារ នូវទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ គឺជាការវាស់វែងមួយទៅលើរបៀបនៃការប្រើប្រាស់របស់គ្រួសារ នូវទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ នៅក្នុងតំបន់សិក្សាក្នុងលក្ខណៈជាការប្រើប្រាស់ផ្ទាល់ខ្លួន ការសំរាកលំហែ និងការលក់។ សូចនាករនេះទាក់ទងជាសំខាន់ទៅនឹងសកម្មភាព ទាញយក ប្រយោជន៍ពីធម្មជាតិ (ឧ. ការនេសាទ វារីវប្បកម្ម) ។

### វិធីសាស្ត្រប្រមូលទិន្នន័យ

អ្នកចូលរួមនីមួយៗ ត្រូវបានស្នើឱ្យធ្វើការកំណត់ទៅលើការប្រើប្រាស់ជាចំបងរបស់គ្រួសារ នូវទំនិញ និងសេវាកម្មនីមួយៗ មានដូចជាការប្រើប្រាស់ផ្ទាល់ខ្លួន ការសំរាកលំហែ ឬការលក់ដែលមាននៅក្នុងតារាង *គោលការណ៍ណែនាំស្តីអំពីការធ្វើបទសម្ភាសន៍តាមគ្រួសារ* ដូចដែលបានធ្វើការពន្យល់បង្ហាញស្រាប់។

| សកម្មភាពនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ទំនិញ និង សេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ | ការប្រើប្រាស់របស់គ្រួសារ |
|---|---|---|
| ១. ការនេសាទ | ត្រីតុកកែ | ការប្រើប្រាស់ផ្ទាល់ខ្លួន |
| | មឹក | លក់ |
| | បង្គា | លក់ |
| ២. ទេសចរណ៍ | ការអភិវឌ្ឍន៍សណ្ឋាគារ | លក់ |
| | ការមុជទឹកនៅបាតសមុទ្រ | លក់ |
| | ការនេសាទជាលក្ខណៈកំសាន្ត | លក់ |

### វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលទទួលបានមកពីការអង្កេតគ្រួសារទាំងអស់។ ស្រដៀងទៅនឹងសូចនាករនៃការកំណត់គោលដៅទីផ្សាររបស់គ្រួសារផងដែរ សូមចុះមុខទំនិញ និងសេវាកម្ម និងគិតជាចំនួន និងភាគរយនៃអ្នកចូលរួមទាំងឡាយណាដែលគត់សំគាល់ថា ទំនិញ និងសេវាកម្មនីមួយៗ បានប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួន ការសំរាកលំហែ និងការលក់។ ព័ត៌មាននេះត្រូវបានបញ្ជាក់ជូននៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ* ។

*ការវិភាគបន្ថែម:* ប្រធានបទមួយអាចនឹងត្រូវរៀបចំឡើង ដោយធ្វើការពិពណ៌នាអំពីការប្រើប្រាស់ផ្សេងៗរបស់គ្រួសារ នូវទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ នៅតាមសហគមន៍នីមួយៗ។

### សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ព័ត៌មានស្តីអំពីការប្រើប្រាស់របស់គ្រួសារ នូវទំនិញ និងសេវាកម្មនៅតាមតំបន់ឆ្នេរ និងសមុទ្រ បង្ហាញឱ្យឃើញច្បាស់អំពីការពឹងផ្អែករបស់គ្រួសារទៅលើធនធាននៅតាមតំបន់ឆ្នេរ និងសមុទ្រក្នុងការស្វែងរកស្បៀង និងប្រាក់ចំណូល។ ហេតុនេះ វាមានសារៈសំខាន់ណាស់ ដែលត្រូវយល់ដឹងអំពីបញ្ហាសន្តិសុខស្បៀងនៅក្នុងគ្រួសារ។ ព័ត៌មានទាំងនេះក៏មានសារៈសំខាន់ផងដែរ ដើម្បីស្វែងយល់អំពីការអនុវត្តវិធានការគ្រប់គ្រង ដែលអាចមានផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់អ្នកប្រើប្រាស់ធនធាន និងសន្តិសុខស្បៀងរបស់គ្រួសារ។ ឧ. ប្រសិនបើគ្រួសារប្រើប្រាស់ផលនេសាទជាចំបងនោះ ការដាក់កំហិតទៅលើការនេសាទ អាចនឹងប៉ះពាល់ទៅលើស្បៀងអាហារដែលមាន ហើយអាចប៉ះពាល់ទៅលើសន្តិសុខស្បៀងរបស់គ្រួសារ។

## ឧបសម្ព័ន្ធ និងការយល់ឃើញ

### *H15. តំលៃមិនមែនទីផ្សារ និងសំរាប់ការប្រើប្រាស់*

**ការកំណត់និយមន័យ**

តំលៃមិនមែនទីផ្សារ និងសំរាប់ការប្រើប្រាស់របស់ធនធានតំបន់ឆ្នេរ គឺជាការវាស់វែងទៅលើការយល់ឃើញរបស់មនុស្ស ចំពោះតំលៃរបស់ធនធានតំបន់ឆ្នេរដែលមិនមែនសំរាប់លក់នៅតាមទីផ្សារ (មិនមែនទីផ្សារ) និងតំលៃធនធានសំរាប់ក្រុមមនុស្សមួយចំនួននៅក្នុងសង្គម ដែលមិនបានប្រើប្រាស់ធនធានទាំងនេះ (មិនប្រើប្រាស់)។ តំលៃមិនមែនទីផ្សារ គឺជាតំលៃធនធាន (ឧ. ត្រី) និងសេវាកម្មនានា (ឧ. ការមុជទឹកនៅបាតសមុទ្រ) ដែលមិនបានលក់ដូរនៅលើ ទីផ្សារនានាទេ។ សេវាកម្មទាំងនេះរួមបញ្ចូលទាំងការប្រើប្រាស់ដោយផ្ទាល់ ដូចជាអ្នកដែលបានធ្វើដំណើរទៅហែលទឹកកំសាន្តតាមមធ្យោបាយផ្ទាល់ខ្លួន និងការប្រើប្រាស់ដោយប្រយោល ដូចជាមុខងារជំនួយផ្នែកជីវសាស្ត្រ ក្នុងលក្ខណៈ សារធាតុចិញ្ចឹម ការការពារជំរកត្រី និងឆ្នេរសមុទ្រពីព្យុះ។ តំលៃមិនមែនសំរាប់ការប្រើប្រាស់មិនទាក់ទងជាមួយនឹង ការប្រើប្រាស់ណាមួយទេ ហើយរួមបញ្ចូលនូវតំលៃតាមទស្សនៈយល់ឃើញ (ថា ធនធាននេះនឹងមាន ពេលដែលយើងសំរេចប្រើវានៅពេលណាមួយនាពេលអនាគត) តំលៃជាកេរ្តិ៍តំណែល (តំលៃនៃការយល់ដឹងថា ធនធានទាំងនេះនឹងមាន សំរាប់អ្នកជំនាន់ក្រោយៗទៀត) តំលៃស្ថិតស្ថេរ (តំលៃនៃការយល់ដឹងថា ធនធានទាំងនេះកើតមាននៅក្នុងលក្ខខណ្ឌជាក់លាក់ណាមួយ)។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

គោលគំនិតនៃតំលៃមិនមែនទីផ្សារ និងសំរាប់ការប្រើប្រាស់ ភាគច្រើនមានលក្ខណៈជាអរូបីយ៍ និងជាទ្រឹស្តី។ ជាការល្អ សេដ្ឋវិទូគួររៀបចំការវាយតំលៃទៅលើសូចនាករទាំងនេះ ដោយសារតែទ្រឹស្តីសេដ្ឋកិច្ចដែលបានប្រើប្រាស់នេះមានលក្ខណៈស្មុគ្រស្មាញ។ ដោយយល់ឃើញថា ភាគច្រើនមិនទាន់មានសេដ្ឋវិទូនៅតាមតំបន់សិក្សាផ្នែកសង្គមកិច្ច ស្នើឱ្យមានវិធីសាស្ត្រមួយស្តីអំពីការវាស់វែងទៅលើការយល់ដឹងរបស់ប្រជាជនដោយផ្អែកទៅលើកំរិតមាត្រដ្ឋាន។

វិធីសាស្ត្រនេះប្រើប្រាស់ប្រភេទសំណួរទាំងឡាយណា ដែលផ្តោតទៅលើការយល់ដឹងរបស់ប្រជាជនស្តីអំពីតំលៃមិនមែនសំរាប់លក់នៅតាមទីផ្សារដោយប្រយោល (ឧ. មុខងារជំនួយផ្នែកជីវសាស្ត្រ) ហើយនិងតំលៃមិនមែនសំរាប់ប្រើប្រាស់ ដែលទាក់ទងទៅនឹងតំលៃជាកេរ្តិ៍តំណែល និងស្ថិតស្ថេររបស់ធនធាន។ តំលៃទាំងនេះអាចរួមបញ្ចូលទាំងសេចក្តីពិពណ៌នាស្តីអំពីសោភណ្ឌភាព ការថែរក្សាសមុទ្រសំរាប់កូនចៅរបស់ពួកគេ "ការលេងកំសាន្តនៅលើផ្ទៃទឹកសមុទ្រ" ព្រមទាំង ទំនិញ និងសេវាកម្មមិនទាញយកប្រយោជន៍ពីធម្មជាតិដទៃទៀតដែលផ្តល់ដោយបរិស្ថានឆ្នេរសមុទ្រដ៏ស្រស់ស្អាត។

ប្រយោគដូចបានលើកមកបង្ហាញជូនខាងក្រោមនេះត្រូវរៀបចំឡើងទាក់ទងទៅនឹងធនធាន និងសកម្មភាពនៅតាមតំបន់នីមួយៗ។ អ្នកចូលរួមនីមួយៗ ត្រូវបានស្នើឱ្យធ្វើការបង្ហាញអំពីកំរិតនៃការយល់ស្របរបស់ពួកគេជាមួយនឹងប្រយោគនីមួយៗទាំងនេះ។ អ្នកចូលរួមត្រូវបានសួរថា តើពួកគេៈ យល់ស្របទាំងស្រុង (៥), យល់ស្រប (៤), មិនដឹង (៣), មិនយល់ស្រប (២) មិនយល់ស្របទាំងស្រុង(១) ជាមួយនឹងប្រយោគនីមួយៗដែរឬទេ។

__________ក) ផ្កាថ្មប៉ប្រះទឹកមានសារៈសំខាន់ក្នុងការការពារដីពីព្យុះរលក។ (តំលៃប្រយោលមិនមែនសំរាប់ទីផ្សារ)

__________ ខ) ការនេសាទនឹងមានភាពប្រសើរឡើងសំរាប់រយៈពេលយូរអង្វែង ប្រសិនបើយើងសំអាតផ្កាថ្មចេញ។ (តំលៃប្រយោលមិនមែនសំរាប់ទីផ្សារ)

__________ គ) ប្រសិនបើគ្មានការការពារព្រៃកោងកាងទេ យើងនឹងមិនមានត្រីសំរាប់នេសាទទេ។ (តំលៃប្រយោលមិនមែន សំរាប់ទីផ្សារ)

__________ ឃ) ផ្កាថ្មប៉ប្រះទឹកមានសារៈសំខាន់ ប្រសិនបើនេសាទត្រី ឬហែលទឹកលេងតែប៉ុណ្ណោះ។ (តំលៃប្រយោលមិនមែនសំរាប់ទីផ្សារ)

__________ ង) ខ្ញុំចង់ឱ្យអ្នកជំនាន់ក្រោយ ចេះស្រលាញ់ព្រៃកោងកាង និងផ្កាថ្មប៉ប្រះទឹក។ (តំលៃជាកេ្តរ៍តំណែល)

__________ ច) គួរតែដាក់កំហិតទៅលើការនេសាទត្រីនៅក្នុងតំបន់ទាំងនេះ ប្រសិនបើមិនធ្លាប់មានអ្នកណានេសាទនៅតំបន់ នោះ គឺគ្រាន់តែដើម្បីឱ្យត្រី និងផ្កាថ្ម បានលូតលាស់។ (តំលៃស្ថិតស្ថេរ)

__________ ឆ) យើងគួរតែដាក់កំហិតទៅលើការអភិវឌ្ឍន៍នៅតាមតំបន់ឆ្នេរ ដើម្បីឱ្យអ្នកជំនាន់ក្រោយមានបរិស្ថានបែបធម្មជាតិ។ (តំលៃជាកេ្តរ៍តំណែល)

__________ ជ) រុក្ខជាតិដែលដុះនៅបាតសមុទ្រ គ្មានតំលៃចំពោះមនុស្សទេ។ (តំលៃស្ថិតស្ថេរ)

កំណត់ចំណាំ : ប្រយោគទាំងនេះត្រូវរៀបចំឡើងឱ្យមានការយល់ស្របខ្លះ ដែលជាការយល់ឃើញដ៏ត្រឹមត្រូវ ឬជាវិជ្ជមាន និងការយល់ស្របខ្លះទៀតដែលមានទស្សនៈផ្ទុយគ្នា។ ការធ្វើបែបនេះ គឺដើម្បីត្រួតពិនិត្យទៅលើចំលើយដែលអ្នកចូលរួម បានយល់ស្រប និងមិនយល់ស្របជាមួយនឹងសំណួរទាំងអស់។ ប្រយោគនីមួយៗត្រូវបានរៀបចំឡើងដោយព្រាវៗ សំរាប់ការសួរសំណួរដែលមានលក្ខណៈផ្ទុយគ្នាបែបនេះ។

*ការប្រមូលព័ត៌មានបន្ថែម:* សំណួរបើក ដូចជា : ប្រសិនបើផ្កាថ្មប៉ប្រះទឹកបាត់បង់ តើវានឹងបង្កបញ្ហាបែបណាខ្លះចំពោះអ្នក? ប្រសិនបើរបរនេសាទត្រីបាត់បង់ តើវានឹងបង្កបញ្ហាបែបណាខ្លះ ចំពោះអ្នក? ប្រសិនបើតំបន់មុខឆ្នេរត្រូវបានអភិវឌ្ឍទាំងស្រុង តើវានឹងបង្កបញ្ហាបែបណាខ្លះចំពោះអ្នក? អាចសួរសំណួរ ដើម្បីស្វែងយល់បន្ថែមទៀតអំពីសារៈសំខាន់របស់ធនធាន និងការប្រើប្រាស់ធនធានទាំងនោះ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ធ្វើសំយោគទិន្នន័យដែលបានមកពីការធ្វើបទសម្ភាសន៍ទាមគ្រួសារទាំងអស់។ សំរាប់សំណួរនីមួយៗ ចូរគិតជាភាគរយនៃចំលើយដែលបានផ្តល់សំរាប់កំរិតនៃការយល់ស្របនីមួយៗ និងកត់សំគាល់ជាភាគរយនៅក្នុង *សន្លឹកវិភាគបទសម្ភាសន៍តាមគ្រួសារ* ។ ដើម្បីធ្វើការកំណត់ថា តើអ្នកចូលរួម ចាត់ទុកធនធានទាំងនេះជា តំលៃមិនមែនទីផ្សារ ឬ មិនមែនសំរាប់ការប្រើប្រាស់ ចូរធ្វើការពិចារណាទៅលើកំរិតនៃការយល់ស្របរបស់ពួកគេជាមួយនឹងប្រយោគទាំងនេះ។ ប្រយោគ (ក) (គ) (ង) (ច) និង (ឆ) គឺជាប្រយោគវិជ្ជមាន។ ប្រសិនបើអ្នកចូលរួមយល់ស្របជាមួយនឹងប្រយោគទាំងនេះ នោះមានន័យថាពួកគេឱ្យតំលៃទៅលើធនធាន។ ប្រយោគ (ខ) (ឃ) និង (ជ) គឺជាប្រយោគអវិជ្ជមាន។ ប្រសិនបើអ្នកចូលរួម យល់ស្របជាមួយនឹងប្រយោគទាំងនេះនោះ មានន័យថា ពួកគេមិនឱ្យតំលៃទៅលើធនធានទេ។

*ការវិភាគទិន្នន័យបន្ថែម:* កំរិតនៃការយល់ស្រប (ឧ. ការយល់ស្របទាំងស្រុង និងការយល់ស្រប) អាចដាក់បញ្ចូលគ្នា ដើម្បីងាយស្រួលធ្វើការបកស្រាយ។ ឧ. ប្រសិនបើ ២៣%នៃអ្នកចូលរួមបានយល់ស្របទាំងស្រុងជាមួយ នឹង ប្រយោគ (ក) ហើយ ៣៤%នៃអ្នកចូលរួមបានយល់ស្របជាមួយនឹងប្រយោគ (ក) នោះតួលេខនេះអាចបញ្ចូលគ្នាជា " ជាង ៥០%នៃអ្នកចូលរួម បានយល់ស្របថា ផ្កាថ្មប៉ប្រះទឹកមានសារៈសំខាន់ក្នុងការការពារដីពីព្យុះរលក"។ ការធ្វើបែបនេះមានភាពងាយស្រួលយល់ ជាងការសរសេរនូវរាល់ភាគរយសំរាប់ប្រភេទនីមួយៗ។

វាអាចនឹងមានប្រយោជន៍សំរាប់ការរៀបចំជាការពន្យល់បែបពិពណ៌នាខ្លីៗ ទាក់ទងទៅនឹងកំរិតដែលមនុស្សឱ្យតំលៃទៅលើធនធានទាំងនេះ។ ចូរធ្វើការប្រៀបធៀបលទ្ធផលនាពេលកន្លងមក ដើម្បីធ្វើការបង្ហាញថាតើការយល់ដឹងរបស់ប្រជាជន មានការផ្លាស់ប្តូរ ដែរឬយ៉ាងណា។

## សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង

ព័ត៌មានស្តីអំពីតំលៃមិនមែនសំរាប់ការប្រើប្រាស់ និងមិនមែនសំរាប់ទីផ្សារ មានសារៈសំខាន់ចំពោះការយល់ដឹងអំពីការដែលមនុស្សឱ្យតំលៃទៅលើធនធានតំបន់ឆ្នេរ។ ការឱ្យតំលៃតែងផ្តោតទាំងស្រុងទៅលើតំលៃនានាដែល

ទាក់ទងទៅនឹងទីផ្សារ ដូចជាក៏រិតនៃការប្រើប្រាស់ ប្រាក់ចំណូល និងប្រាក់ចំណេញដុល។ តាមរយៈការយល់ដឹងអំពីតំលៃមិនមែនសំរាប់ការប្រើប្រាស់ និងមិនមែនសំរាប់ទីផ្សារ អ្នកគ្រប់គ្រងទទួលបាននូវរូបភាពទាំងស្រុងនៃតំលៃទាំងអស់របស់ធនធាន។ វាមានប្រយោជន៏ក្នុងការបង្ហាញអំពីសារៈសំខាន់របស់ធនធាន និងការការពារនូវធនធានទាំងនោះ ចំពោះអ្នកបង្កើតគោលនយោបាយ និងសាធារណៈជនទូទៅ ដោយបានវាស់ស្ទង់ទៅលើការគាំទ្ររបស់សាធារណៈជនចំពោះការគ្រប់គ្រង និងបានបង្ហាញថា ធនធានសមុទ្រមានតំលៃជាងផលិតផលដែលអាចទិញ និងលក់នៅតាមទីផ្សារ។

ការយល់ដឹងទាំងនេះ ក៏មានសារៈសំខាន់ផងដែរចំពោះការបង្កើតកម្មវិធីលើកកំពស់ការយល់ដឹង ដោយសារតែអ្នកគ្រប់គ្រងអាចយល់ដឹងអំពីក៏រិតដែលប្រជាជនគិតគូរចំពោះធនធានទាំងឡាយ ដែលជាទំនិញ និងសេវាកម្មដែលពួកគេមិនអាចទិញ និងលក់បាន។ ការត្រួតពិនិត្យព័ត៌មានទាំងនេះនាពេលកន្លងមក អាចមានប្រយោជន៏ដើម្បីបង្ហាញអំពីផលប៉ះពាល់របស់កម្មវិធីគ្រប់គ្រង ដែលអាចមានចំពោះឥរិយាបថ និងការយល់ដឹងរបស់មនុស្ស។

### H16. *ការយល់ឃើញអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន*

**ការកំណត់និយមន័យ**

ការយល់ឃើញអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន ធ្វើការវាស់វែងទៅលើអ្វីដែលមនុស្សយល់ឃើញអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធានតំបន់ឆ្នេរ។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ទិន្នន័យស្តីអំពីការយល់ឃើញអំពីលក្ខខណ្ឌនៃស្ថានភាពធនធាន អាចទទួលបានតាមរយៈការសួរសំណួរទៅកាន់អ្នកចូលរួមនីមួយៗ:

តើអ្នកយល់បែបណាដែរចំពោះលក្ខខណ្ឌនៃស្ថានភាពបច្ចុប្បន្នរបស់ធនធាននីមួយៗ ដូចខាងក្រោមនេះ ដោយប្រើប្រាស់ក៏រិតមាត្រដ្ឋាន ល្អណាស់ (៥) ល្អ (៤) ធម្មតា (៣) អាក្រក់ (២) អាក្រក់ណាស់ (១) (ចូរធ្វើ បញ្ជីធនធានថ្មីដែលបង្ហាញពីធនធានក្នុងតំបន់) : ព្រៃកោងកាង _________ ផ្កាថ្មប៉ប្រះទឹក _________ ទឹកស្អាត (ទន្លេ) _________ ព្រៃតំបន់ខ្ពង់រាប _________

**វិធីសាស្ត្រវិភាគទិន្នន័យ**

ចូរធ្វើការសំយោគទិន្នន័យដែលបានមកពីការធ្វើបទសម្ភាសន៏តាមគ្រួសារទាំងអស់។ សំរាប់ធនធាននីមួយៗ ចូរគិតជាភាគរយនៃចំនួនអ្នកចូលរួម សំរាប់ក៏រិតនៃមាត្រដ្ឋាននីមួយៗ នឹងធ្វើការកត់សំគាល់នៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៏តាមគ្រួសារ* ។

| ធនធាន * | ភាគរយនៃចំលើយរបស់អ្នកចូលរួមដែលយល់ឃើញអំពីលក្ខខណ្ឌនៃធនធានដូចខាងក្រោម : | | | | |
|---|---|---|---|---|---|
| | ល្អណាស់ (៥) | ល្អ (៤) | មិនល្អ មិនអាក្រក់ (៣) | អាក្រក់ (២) | អាក្រក់ណាស់ (១) |
| ព្រៃកោងកាង | 3% | 10% | 30% | 34% | 23% |
| ផ្កាថ្មប៉ប្រះទឹក | 5% | 12% | 34% | 30% | 23% |
| ទឹកស្អាត | 2% | 15% | 62% | 15% | 6% |
| ព្រៃតំបន់ខ្ពង់រាប | 40% | 30% | 20% | 8% | 2% |
| * បញ្ជីធនធានថ្មីដែលបង្ហាញពីធនធានក្នុងតំបន់ | | | | | |

*ការវិភាគទិន្នន័យបន្ថែម:* ប្រភេទមួយចំនួនអាចដាក់បញ្ចូលគ្នាបាន ដើម្បីងាយស្រួលធ្វើការបកស្រាយ។ ឧ. ប្រសិនបើ ២៣%នៃអ្នកចូលរួម បាននិយាយថាព្រៃកោងកាងស្ថិតនៅក្នុងលក្ខណៈអាក្រក់ខ្លាំងណាស់ ហើយ ៣៤% និយាយថាវា ស្ថិតនៅក្នុងលក្ខណៈអាក្រក់ នោះតួលេខនេះអាចបញ្ចូលគ្នាទៅជា "ជាង៥០%នៃអ្នកចូលរួម បានកត់សំគាល់ឃើញថា ព្រៃកោងកាងស្ថិតនៅក្នុងលក្ខណៈអាក្រក់ ឬ អាក្រក់ខ្លាំងណាស់។ ការធ្វើបែបនេះ គឺមានភាពងាយស្រួលយល់ជាងការសរសេរនូវរាល់ភាគរយសំរាប់ប្រភេទនីមួយៗ។ បន្ថែមពីនេះទៀត ការពន្យល់បែបពិពណ៌នាខ្លីៗ អាចនឹងរៀបចំឡើង ដោយធ្វើការរៀបរាប់អំពីរបៀបដែលប្រជាជនយល់ដឹងអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធានទាំងនេះ។ ចូរធ្វើការត្រួតពិនិត្យលទ្ធផលនាពេលកន្លងមក ដើម្បីបង្ហាញថា ការយល់ដឹងរបស់ប្រជាជនចំពោះលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន មានការផ្លាស់ប្តូរ។ ចូរធ្វើការប្រៀបធៀបលទ្ធផលទាំងនេះជាមួយនឹងការសិក្សាបែបវិទ្យាសាស្ត្រអំពីលក្ខខណ្ឌស្ថានភាពរបស់ធនធាន ដើម្បីធ្វើការកំណត់ទៅលើភាពត្រឹមត្រូវនៃការយល់ដឹងរបស់ប្រជាជនចំពោះលក្ខខណ្ឌនៃស្ថានភាពរបស់ធនធានទាំងនេះ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ព័ត៌មានស្តីពីការយល់ឃើញរបស់ប្រជាជនចំពោះលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន មានសារប្រយោជន៍ក្នុងការកំណត់អំពីការគំរាមកំហែងចំពោះធនធានតំបន់ឆ្នេរ។ ការយល់ឃើញថា ធនធានណាខ្លះដែលស្ថិតនៅក្នុងស្ថានភាពអាក្រក់ អាចឱ្យអ្នកគ្រប់គ្រងធ្វើការកំណត់បានប្រសើរជាងមុននូវការគំរាមកំហែងជាចំបងចំពោះធនធាន ដោយសារតែ ការគំរាមកំហែងភាគច្រើនទាក់ទងទៅនឹងធនធានសំខាន់ៗ។ ឧ. ប្រសិនបើព្រៃកោងកាងរុក្ខជាតិសមុទ្រ និងផ្កាថ្មប៉ប្រះ ទឹក ស្ថិតនៅក្នុងស្ថានភាពអាក្រក់ខ្លាំងជាងព្រៃតំបន់ខ្ពង់រាប និងទឹកស្អាត នោះសកម្មភាពនៅតាមសមុទ្រ ដែលមានដូចជា ការនេសាទ និងការជិះទូក អាចនឹងទទួលការគំរាមកំហែងខ្លាំងជាងសកម្មភាពនៅលើដីគោក។

ព័ត៌មាននេះក៏មានសារៈសំខាន់ផងដែរ សំរាប់ការរៀបចំកម្មវិធីលើកកំពស់ការយល់ដឹង និងជំរុញការចូលរួមរបស់ភាគីដែលពាក់ព័ន្ធ។ ប្រសិនបើសមាជិកនៅក្នុងសហគមន៍មិនបានយកចិត្តទុកដាក់ទៅលើធនធានដែលប្រឈមទៅនឹងគ្រោះថ្នាក់នោះទេ នោះវានឹងបង្កការលំបាកក្នុងការដាក់បញ្ចូលពួកគេទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ។ ប្រសិនបើសមាជិកក្នុងសហគមន៍យកចិត្តទុកដាក់ទៅលើធនធាន ដែលកំពុងស្ថិតនៅក្នុងស្ថានភាពល្អ ប៉ុន្តែការស្រាវជ្រាវបែបវិទ្យាសាស្រ្តបង្ហាញថា ពួកគេកំពុងបំផ្លាញវា នោះចាំបាច់ត្រូវបង្កើតកម្មវិធីលើកកំពស់ការយល់ដឹង ដើម្បីបង្កើន ការយល់ដឹងអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធានទាំងនេះ។

តាមរយៈការគ្រប់គ្រងព័ត៌មានទាំងនេះនាពេលកន្លងមក អ្នកគ្រប់គ្រងអាចយល់ដឹងអំពីការគ្រប់គ្រងផលប៉ះពាល់ដែលកើតមានចំពោះឥរិយាបថ និងការយល់ដឹងរបស់ប្រជាជន។ ជាឧទាហរណ៏ ប្រសិនបើកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរបាន បង្កើតឡើងនូវយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីស្ថានភាពអាក្រក់នៃប្រព័ន្ធអេកូ-ឡូស៊ីនៅតាមតំបន់ឆ្នេរ ប៉ុន្តែអ្នកចូលរួមនៅតែបន្តរាយការណ៏មកថា វាស្ថិតនៅក្នុងស្ថានភាពល្អប្រសើរ នោះសន្មតថាកម្មវិធីនេះមិនមានប្រសិទ្ធភាពទេ។

ការយល់ដឹងរបស់ប្រជាជនអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន ក៏មានសារៈសំខាន់ផងដែរ សំរាប់ការងារស្រាវជ្រាវផ្នែកជីវរូបសាស្រ្ត ហើយនិងសំរាប់គ្រប់គ្រងកម្មវិធី។ ជាធម្មតា សមាជិកសហគមន៍ ជាពិសេសប្រជាជនដែលប្រើប្រាស់ធនធានដោយផ្ទាល់ ច្រើនមានការយល់ដឹងអំពីលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន។ ព័ត៌មាននេះអាចជួយណែនាំអំពីរបៀបវារៈវិទ្យាសាស្រ្ត ជាពិសេស នៅក្នុងតំបន់ដែលខ្វះខាតទិន្នន័យ វិទ្យាសាស្រ្ត។

## H17. *ការយល់ឃើញអំពីគំរាមកំហែង*

### ការកំណត់និយមន័យ

ការយល់ឃើញអំពីការគំរាមកំហែង ធ្វើការវាស់វែងទៅលើអ្វីដែលប្រជាជនយល់ថា ជាការគំរាមកំហែងជាចំបងចំពោះធនធានតំបន់ឆ្នេរ។

### វិធីសាស្រ្តប្រមូលទិន្នន័យ

ទិន្នន័យស្តីអំពីការគំរាមកំហែងដែលកើតមាន ទទួលបានតាមរយៈការសួរសំណួរទៅកាន់អ្នកចូលរួមនីមួយៗ: តើការគំរាមកំហែងជាចំបងទាំង៥ ចំពោះស្ថានភាពធនធានតំបន់ឆ្នេរ មានអ្វីខ្លះ?

១. ________________ ២. ________________ ៣. ________________ ៤. ________________ ៥. ________________

## វិធីសាស្ត្រវិភាគទិន្នន័យ

ចូរធ្វើសំយោគទៅលើទិន្នន័យដែលបានមកពីការធ្វើបទសម្ភាសន៍តាមគ្រួសារទាំងអស់។ ចូរធ្វើការកត់ត្រានូវរាល់ការគំរាមកំហែងចំបង១។ គិតជាភាគរយនៃចំនួនអ្នកចូលរួមទាំងឡាយណាដែលបានកត់ត្រាការគំរាមកំហែងនីមួយ១ ដូចដែលបានពន្យល់នៅក្នុងបញ្ជីនេះ និងធ្វើការកត់ត្រានៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ* ដូចខាងក្រោមនេះ :

| **ការគំរាមកំហែងដែលកំណត់ដឹង** | **ភាគរយនៃការគំរាមកំហែងនេះ** |
|---|---|
| កាកសំណល់ទឹកកខ្វក់ | ៥៣% |
| ការនេសាទលើសកំណត់ | ៣០% |
| ការខូចយុថ្កា | ២៦% |

** ចូរធ្វើការកត់ចំណាំថា ចំលើយបូកសរុបមិនស្មើនឹង១០០%ទេ ដោយសារតែអ្នកចូលរួមអាចនឹងកត់ត្រាការគំរាមកំហែងរហូតដល់ទៅ ៥ ករណី។*

*ការវិភាគទិន្នន័យបន្ថែម:* ចូរដាក់បញ្ចូលការគំរាមកំហែងទាំងនេះឱ្យបានត្រឹមត្រូវ។ ឧ. ប្រសិនបើអ្នកចូលរួមនិយាយថា "ខូចយុថ្កា" ហើយអ្នកដទៃទៀតនិយាយថា "ដំណើរកំសាន្តតាមទូក" នោះចំលើយ "ខូចយុថ្កា" អាចនឹងរួមបញ្ចូលទៅក្នុង "ដំណើរកំសាន្តតាមទូក" ដោយសារតែវានៅក្នុងក្រុមជាមួយគ្នា។ ចូរធ្វើការត្រួតពិនិត្យលទ្ធផលទាំងនេះនាពេលកន្លងមក ដើម្បីធ្វើការកំណត់ទៅលើការគំរាមកំហែងដែលកើតមានមានការផ្លាស់ប្តូរបែបណាខ្លះ។

ចូរធ្វើការប្រៀបធៀបលទ្ធផលទាំងនេះជាមួយនឹងទិន្នន័យដែលបានមកពី *អ្នកផ្តល់ព័ត៌មានសំខាន់១/ទិន្នន័យពីប្រភពព័ត៌មានបន្ទាប់បន្សំ* នៅក្នុងចំណុច *កំរិតនៃផលប៉ះពាល់ (KS20)*។ ការគំរាមកំហែងដែលបានកត់ត្រាខាងលើ គួរតែកត់ត្រានៅក្នុងកំរិតលទ្ធផលនៃផលប៉ះពាល់ ថា "ខ្ពស់" ។ ប្រសិនបើវាមានភាពខុសគ្នាខ្លាំងចូរធ្វើការពិភាក្សាជាមួយអ្នក ផ្តល់ព័តមានសំខាន់១ ដើម្បីធ្វើការកត់សំគាល់អំពីមូលហេតុ។ ប្រសិនបើមិនអាចពន្យល់អំពីភាពខុសគ្នានេះទេ នោះវាអាចនឹងចាំបាច់ត្រូវធ្វើបទសម្ភាសន៍តាមគ្រួសារទាំងអស់ ដើម្បីធ្វើការកំណត់ទៅលើការគំរាមកំហែងដែលកើតមានឱ្យបានត្រឹមត្រូវ។ ប្រធានបទខ្លី១អាចនឹងរៀបចំឡើងដោយធ្វើការពិពណ៌នាអំពីចំណុចណាខ្លះដែលប្រជាជនយល់ថា ជាការគំរាមកំហែងជាចំបង ដែលដកស្រង់ចេញពីទិន្នន័យទាំងពីរនេះ។

ចូរធ្វើការប្រៀបធៀបលទ្ធផលទាំងនេះ ជាមួយនឹងការសិក្សាបែបវិទ្យាសាស្ត្រស្តីអំពីការគំរាមកំហែងនានាចំពោះលក្ខខណ្ឌនៃស្ថានភាពរបស់ធនធាន ដើម្បីធ្វើការកំណត់អំពីភាពត្រឹមត្រូវនៃការយល់ដឹងរបស់ប្រជាជនចំពោះការគំរាមកំហែងទាំងនេះ។

**សារប្រយោជន៍នៃព័ត៌មានចំពោះអ្នកគ្រប់គ្រង**

ព័តមានស្តីអំពីការគំរាមកំហែងដែលកើតមាន មានសារៈសំខាន់សំរាប់ធ្វើការកំណត់ទៅលើការគំរាមកំហែងនានាចំពោះធនធានតំបន់ឆ្នេរ។ ជាធម្មតា សមាជិកសហគមន៍ ជាពិសេសប្រជាជនដែលប្រើប្រាស់ធនធានដោយផ្ទាល់ច្រើនមាន ការយល់ដឹងអំពីការគំរាមកំហែងចំពោះធនធាន។ ព័ត៌មាននេះអាចជួយណែនាំអំពីរបៀបវារៈវិទ្យាសាស្ត្រ ជាពិសេស នៅក្នុងតំបន់ដែលខ្វះខាតទិន្នន័យវិទ្យាសាស្ត្រ ដោយធ្វើការកំណត់ទៅលើសកម្មភាពជាអាទិភាពណាខ្លះដែលត្រូវយកចិត្ត ទុកដាក់។

តាមរយៈការត្រួតពិនិត្យព័ត៌មាននាពេលកន្លងមក អ្នកគ្រប់គ្រងអាចយល់ដឹងអំពីការគ្រប់គ្រងផលប៉ះពាល់ដែលកើតមានចំពោះសកម្មភាពនៅតាមតំបន់ឆ្នេរ។ ឧទាហរណ៍ ប្រសិនបើកម្មវិធីគ្រប់គ្រងហាមឃាត់ការនេសាទ ប៉ុន្តែប្រជាជននៅតែចាត់ទុក ការនេសាទជាការគំរាមកំហែងមួយ នោះសន្មតថាកម្មវិធីនេះមិនមានប្រសិទ្ធភាពទេ។ ការសិក្សាបែបវិទ្យា សាស្ត្របន្ថែមទៀត គួរអាចជួយកំណត់ថា តើកម្មវិធីនេះមានភាពត្រឹមត្រូវដែរឬទេ។

សរុបសេចក្តីមក ព័ត៌មាននេះមានសារៈសំខាន់ណាស់សំរាប់បង្កើតលើកកំពស់ការយល់ដឹង និងជំរុញការចូលរួមរបស់ភាគីដែលពាក់ព័ន្ធ។ ប្រសិនបើសមាជិកសហគមន៍មិនបានចាត់ទុកអ្វីទាំងនោះមានផលប៉ះពាល់ទៅលើធនធានតំបន់ឆ្នេរទេ នោះវានឹងមានការលំបាកក្នុងការបញ្ចូលពួកគេទៅក្នុងកម្មវិធីគ្រប់គ្រង។ ប្រសិនបើសមាជិកសហគមន៍ចាត់ទុកសកម្មភាពតែ ១ ឬ ២ ប៉ុណ្ណោះដែលមានផលប៉ះពាល់ទៅលើធនធាន ប៉ុន្តែការស្រាវជ្រាវបែបវិទ្យាសាស្ត្របានបង្ហាញថាមានផលប៉ះពាល់មួយចំនួនផ្សេងទៀត នោះកម្មវិធីលើកកំពស់ការយល់ដឹងអាចនឹងចាំបាច់បង្កើតឡើង ដើម្បីបង្កើនការយល់ដឹងអំពីវិសាលភាពនៃសកម្មភាពទាំងនោះដែលមានផលប៉ះពាល់ចំពោះធនធាន។

## H18. *ការយល់ដឹងអំពីច្បាប់ និងបទបញ្ញត្តិ*

**ការកំណត់និយមន័យ**

ការយល់ដឹងអំពីច្បាប់ និងបទបញ្ញត្តិធ្វើការវាស់វែងទៅលើចំណេះដឹងរបស់ប្រជាជនទៅលើច្បាប់ និងបទបញ្ញត្តិស្តីពីធនធានតំបន់ឆ្នេរដែលបង្កើតឡើង។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ទិន្នន័យស្តីអំពីការយល់ដឹងអំពីច្បាប់ និងបទបញ្ញត្តិ ទទួលបានតាមរយៈការសួរសំណួរទៅកាន់អ្នកចូលរួមៈ

តើមានច្បាប់ និងបទបញ្ញត្តិដែលទាក់ទងទៅនឹង (មាន/មិនមាន) (ចូរបង្កើតបញ្ជីសកម្មភាពដែលឆ្លុះបញ្ចាំងអំពី *សកម្មភាព* (KS14)៖ ការនេសាទ __________ ការប្រើប្រាស់ព្រៃកោងកាង __________

វារីវប្បកម្ម ____________ ការអភិវឌ្ឍន៍សណ្ឋាគារ ____________ ការអភិវឌ្ឍន៍លំនៅដ្ឋាន____________ កីឡាលេងនៅលើទឹក ____________ ការដឹកជញ្ជូនតាមសមុទ្រ ____________

ដើម្បីធ្វើការកំណត់អំពីកំរិតនៃការយល់ដឹងនេះ ក្រុមការងារខ្លួនឯងត្រូវមានការយល់ដឹងអំពីច្បាប់ និងបញ្ញត្តិដែលកើតមាន។ វាអាចកំណត់បានតាមរយៈការសួរទៅកាន់អ្នកគ្រប់គ្រង។ ចូរគូសរង្វង់ទៅលើធនធានទាំងឡាយណាដែលមានច្បាប់ និងបទបញ្ញត្តិសំរាប់ធ្វើការប្រៀបធៀបចំលើយ។

## វិធីសាស្ត្រវិភាគទិន្នន័យ

ចូរធ្វើសំយោគទិន្នន័យដែលបានមកពីការធ្វើបទសម្ភាសទាមគ្រួសារទាំងអស់។ គិតជាភាគរយនៃអ្នកចូលរួមដែលបានឆ្លើយថា មានច្បាប់ និងបទបញ្ញត្តិសំរាប់សកម្មភាពនីមួយៗ និងធ្វើការកត់ត្រាតួរលេខនេះនៅក្នុង *សន្លឹកវិភាគទិន្នន័យបានពីបទសម្ភាសន៍តាមគ្រួសារ*។

*ការវិភាគទិន្នន័យបន្ថែម:* ចូរធ្វើការប្រៀបធៀបភាគរយនេះ ជាមួយនឹងចំលើយដែលពួកគេបានគូសរង្វង់។ សកម្មភាពដែលបានគូសរង្វង់ (មានច្បាប់ និងបទបញ្ញត្តិ) គួរតែមានការយល់ដឹងខ្ពស់ ដោយប្រៀបធៀបជាមួយនឹងសកម្មភាពដទៃទៀត។ សកម្មភាពទាំងឡាយណាដែលមានការយល់ដឹងខ្ពស់ ក៏ប៉ុន្តែវាមិនទាន់មានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ បង្ហាញពីការយល់ខុសជាសាធារណៈ។ សកម្មភាពដែលបានគូសរង្វង់ និងមានការយល់ដឹងតិចតួចបង្ហាញថា សាធារណៈជនមិនបានដឹងថា មានច្បាប់ និងបទបញ្ញត្តិចំពោះសកម្មភាពទាំងនេះ។ ប្រធានបទខ្លីមួយអាចនឹងរៀបចំឡើង ដោយធ្វើការពិភាក្សាអំពីច្បាប់ និងបទបញ្ញត្តិដែលមានការគោរពច្បាប់ និងការអនុវត្តច្បាប់ ដោយដកស្រង់ចេញពី លទ្ធផលនៃសូចនាករពីរខាងក្រោមនេះ។

## សារប្រយោជន៍នៃព័តិមានចំពោះអ្នកគ្រប់គ្រង

ព័តិមាននេះ មានសារៈសំខាន់ចំពោះការបង្កើតកម្មវិធីលើកកំពស់ការយល់ដឹង និងជំរុញការចូលរួមរបស់ភាគីដែលពាក់ព័ន្ធ។ ប្រសិនបើសមាជិកសហគមន៍ មិនបានដឹងថាមានច្បាប់ និងបទបញ្ញត្តិទាំងនេះទេ វានឹងបង្កផលលំបាកក្នុងការដាក់បញ្ចូលពួកគេទៅក្នុងកម្មវិធីគ្រប់គ្រងតំបន់ឆ្នេរ។ ការយល់ដឹងអំពីកំរិតនៃការយល់ដឹងរបស់ប្រជាជនទៅលើច្បាប់ និងបទបញ្ញត្តិមានប្រយោជន៍ក្នុងការបង្កើតកម្មវិធីលើកកំពស់ការយល់ដឹង។ ការអប់រំគឺជាមូលដ្ឋានគ្រឹះនៃការគោរពច្បាប់។ ហេតុនេះហើយ វាមានសារៈសំខាន់សំរាប់អ្នកគ្រប់គ្រងក្នុងការកំណត់ទៅលើច្បាប់ និងបទបញ្ញត្តិណាខ្លះដែលសហគមន៍មិនធ្លាប់បានដឹង ដើម្បីឱ្យកម្មវិធីលើកកំពស់ការយល់ដឹងនេះអាចកំណត់គោលដៅសំរាប់ច្បាប់ និងបទបញ្ញត្តិទាំងនេះ។ ដូច្នេះហើយ ការត្រួតពិនិត្យការយល់ដឹងរបស់សហគមន៍អំពីច្បាប់ និងបទបញ្ញត្តិទាំងនេះ មានសារៈសំខាន់ក្នុងការកំណត់អំពីផលប៉ះពាល់នៃការគ្រប់គ្រងតំបន់ឆ្នេរទៅលើឥរិយាបថ និងការយល់ដឹងរបស់ប្រជាជន។

### *H19. ការគោរពច្បាប់*

**ការកំណត់និយមន័យ**

ការគោរពច្បាប់ ធ្វើការវាស់វែងទៅលើកំរិតនៃការយល់ដឹងរបស់ប្រជាជនអំពីការគោរពបទបញ្ញត្តិ។

**វិធីសាស្ត្រប្រមូលទិន្នន័យ**

ទិន្នន័យស្តីអំពីការគោរពច្បាប់ទទួលបានតាមរយៈការសួរសំណួរទៅកាន់អ្នកចូលរួមៈ

ដោយផ្អែកលើកំរិតមាត្រដ្ឋានពី១ ទៅដល់៥ (១=មិនគោរពតាម ៥ = គោរពតាមទាំងស្រុង) តើប្រជាជនគោរពតាមច្បាប់ និងបទបញ្ញត្តិនៃការគ្រប់គ្រងតំបន់ឆ្នេរ ក្នុងកំរិតណា? ________________

*ការវិភាគទិន្នន័យបន្ថែម :* អ្នកចូលរួមអាចត្រូវបានសួរថា តើសកម្មភាព និងច្បាប់មួយណាដែលប្រជាជនគោរពតាម។

**វិធីសាស្ត្រវិភាគទិន្នន័យ**

ចូរធ្វើសំយោគទិន្នន័យដែលបានមកពីការធ្វើបទសម្ភាសទាមគ្រួសារទាំងអស់។ ចូរគិតជាភាគរយនៃអ្នកចូលរួមសំរាប់កំរិតនៃការគោរពច្បាប់ដែលកើតមាន និងធ្វើការកត់ត្រានៅក្នុង *សន្លឹក វិភាគបទសម្ភាសន៍តាមគ្រួសារ។*

